បណ្ណាល័យ
គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
**Kingdom of Cambodia**

ជាតិ សាសនា ព្រះមហាក្សត្រ
**Nation Religion King**



ព្រះរាជាណាចក្រកម្ពុជា
**Kingdom of Cambodia**

អង្គការពាណិជ្ជកម្មពិភពលោក
**World Trade Organization**

# របាយការណ៍របស់ក្រុមការងារ ស្ដីពី
# ការចូលជាសមាជិក
# អង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា

# REPORT OF THE WORKING PARTY
# ON THE ACCESSION OF CAMBODIA

# អង្គការពាណិជ្ជកម្មពិភពលោក

**ហាមផ្សព្វផ្សាយ**

(០៣-៤២៨៥)

**ក្រុមការងារសំរាប់**

**ការចូលជាសមាជិករបស់កម្ពុជា**

## របាយការណ៍ក្រុមការងារស្តីពីដំណើរការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក របស់កម្ពុជា

## សេចក្តីផ្តើម

១. រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ពាក្យសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅខែតុលាឆ្នាំ១៩៩៤ ។ នៅឯកិច្ចប្រជុំនាថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ នៃគណៈកម្មាធិការរៀបចំសំរាប់កិច្ចការនៃអង្គការពាណិជ្ជកម្មពិភពលោកបានបង្កើតក្រុមការងារមួយ ដើម្បីពិនិត្យពាក្យសុំចូលជាសមាជិករបស់រដ្ឋាភិបាលកម្ពុជា ដោយយោងលើមាត្រា៧នៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្ម ពិភពលោកហៅថា "កិច្ចព្រមព្រៀងម៉ារ៉ាកេស Marrakesh)" ។ លក្ខខ័ណ្ឌនៃសេចក្តីព្រាង (Terms of Reference) និងសមាជិកភាពនៃក្រុមការងារមានចែងក្នុងឯកសារ WT/ACC/KHM/ 1/ [Rev.5] ។

២. ក្រុមការងារបានជួបប្រជុំនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ថ្ងៃទី១៤ កុម្ភៈ និង ថ្ងៃទី១៤ វិច្ឆិកា ឆ្នាំ២០០២ ថ្ងៃទី១៦ មេសា និង ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ នៅក្រោម អធិបតីភាពរបស់លោក **អា. ម៉ែឡូនី** ជនជាតិអ៊ីតាលី ដែលជាប្រធានក្រុមការងារ ។

## ឯកសារដែលបានផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា

៣. ដើម្បីធ្វើជាមូលដ្ឋានសំរាប់ការពិភាក្សា ក្រុមការងារបានទទួលអនុស្សារណៈស្តីអំពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា (ឯកសារ WT/ACC/KHM/2) សំណួរចោទសួរ ដោយសមាជិកក្រុមការងារទៅលើ

អនុស្សារណៈស្តីអំពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជារួមជាមួយនឹងចំលើយ និង ពត៌មានផ្សេងៗ ដែលផ្តល់ដោយអាជ្ញាធរកម្ពុជា (WT/ACC/ KHM/3; WT/ACC/KHM/6; WT/ ACC/KHM/7 និងការ កែប្រែលើកទី១ និងទី២; WT/ACC/ KHM/8; WT/ACC/ KHM/9; WT/ACC/KHM/10 និងការ កែប្រែលើកទី១ និងទី២; WT/ACC/KHM/12; WT/ACC/KHM /13 និងការកែប្រែ លើកទី១ ; WT/ACC/KHM/14 និងការកែប្រែ លើកទី១ ; WT/ ACC/KHM/15 និងការកែប្រែលើកទី១; WT/ACC/ KHM/16 និងការកែប្រែលើកទី១; WT/ACC/ KHM/17 និងការកែប្រែ លើកទី១; WT/ACC/KHM/18; WT/ACC/KHM/20;...), ព្រមទាំងបញ្ជីបញ្ញត្តិច្បាប់និងឯកសារដទៃទៀត ដែលមានចុះក្នុងឧបសម្ព័ន្ធទី១។

## សេចក្តីថ្លែងហេតុ

៤. តំណាងប្រតិភូកម្ពុជាបានថ្លែងថា កម្ពុជាបានចាប់ដំណើរការកែទំរង់សេដ្ឋកិច្ច និងនយោបាយជាមូលដ្ឋាន ចាប់តាំងពីការអនុម័តច្បាប់រដ្ឋធម្មនុញ្ញថ្មីក្នុងឆ្នាំ១៩៩៣ ដែលបានស្តារឡើងវិញនូវរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញនៅកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយកម្ពុជានៅតែត្រូវបានគេសំគាល់ថាជាប្រទេស ដែលមានជំលោះប្រដាប់អាវុធអស់ជាងពីរទសវត្សរ៍ ដែលបណ្តាលអោយបាត់បង់ធនធានមនុស្សយ៉ាងធ្ងន់ធ្ងរ និងទទួលរងនូវអស្ថេរភាពសេដ្ឋកិច្ច និងនយោបាយ។ កង្វះខាតនៃកម្លាំងពលកម្មជំនាញនៅតែជាឧបសគ្គចំបងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា។

៥. រដ្ឋាភិបាលកម្ពុជាបានបង្កើតនូវ "យុទ្ធសាស្ត្រត្រីកោណ" មួយដើម្បីស្តារសន្តិភាព, ធានានិរន្តរ៍ភាពនៃការអភិវឌ្ឍន៍ និង ធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍ពិភពលោក។ កំណែទម្រង់ត្រូវបានអនុវត្តលើវិស័យជាច្រើនក្នុងពេលតែមួយដូចជា: វិស័យរដ្ឋបាល ច្បាប់និងតុលាការ ការកែទំរង់ហិរញ្ញវត្ថុ សេដ្ឋកិច្ច និងការគ្រប់គ្រងពាណិជ្ជកម្ម ព្រមទាំងលើវិស័យយោធា។ កម្ពុជាបានចូលរួមក្នុងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ASEAN) នៅខែមេសា ឆ្នាំ១៩៩៩។

៦. ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក គឺជា អាទិភាពដ៏ខ្ពស់បំផុតរបស់រដ្ឋាភិបាលកម្ពុជា។ ការធ្វើសមាហរណកម្ម ទៅក្នុងសេដ្ឋកិច្ចពិភពលោកគឺជាឧបករណ៍ដ៏មានឥទ្ធិពលមួយ ដើម្បីកាត់បន្ថយភាពក្រីក្រ និងជាកម្លាំងចលករដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ក្នុងការកែទំរង់ប្រព័ន្ធពាណិជ្ជកម្មរបស់ខ្លួន រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ជាពិសេសការតំរង់ទិសនៃគោលនយោបាយ និង ការអនុវត្តន៍របស់ខ្លួនអោយស្របទៅនឹងច្បាប់របស់អង្គការ ពាណិជ្ជកម្មពិភពលោកជាពិសេសគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលការអនុគ្រោះ(MFN) និងប្រព្រឹត្តិកម្មជាតិ។ នាមវលីនៃពន្ធគយ ដែល ផ្អែកលើប្រព័ន្ធស្របគ្នា (HS) ឆ្នាំ១៩៩៦ បានរៀបចំយ៉ាងត្រឹមត្រូវ ច្បាប់មួយចំនួនធំបានព្រាងនិងបានអនុម័ត ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវទៅនឹងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក ។

៧. ទោះបីជាយ៉ាងណាក៏ដោយការអនុវត្តន៍លក្ខខ័ណ្ឌ និង លក្ខណៈតំរូវរបស់អង្គការពាណិជ្ជកម្មពិភពលោក គឺជាដំណើរការដ៏លំបាកនិងយូរអង្វែងមួយ ។ ក្នុងទស្សនៈអំពីភាពលំបាកនានា ដែលកម្ពុជាកំពុងតែប្រឈមមុខ និង ឋានៈរបស់ប្រទេសកម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់តិចតួច តំណាងប្រតិភូកម្ពុជាបានអំពាវនាវដល់ សមាជិកទាំងអស់របស់ក្រុមការងារអោយផ្តល់នូវលទ្ធភាព នៃការផ្លាស់ប្តូរតាមកាលៈទេសៈក្នុងការចរចា ដើម្បីបង្កើតឡើងនូវកិច្ចសន្យាធ្វើ និងកាតព្វកិច្ចរបស់កម្ពុជានៅក្រោមអង្គការពាណិជ្ជកម្មពិភពលោកព្រមទាំង ផ្តល់នូវការលើកលែងជាពិសេស ដូចដែលបានចែងជាមុននិងបន្តការយកចិត្តទុកដាក់ជាពិសេសទៅក្នុងបញ្ញត្តិ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ចំពោះប្រទេសដែលមានការអភិវឌ្ឍន៏ តិចតួច (LDCs) ។

៨. សមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក បានស្វាគមន៏ការដាក់ពាក្យស្នើសុំចូលជាសមាជិក របស់កម្ពុជាក្នុងអង្គការនេះ ។ សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោក ត្រូវពិចារណាជាសំខាន់ទៅលើ ការអភិវឌ្ឍន៏របស់កម្ពុជា និងសមាហរណកម្មទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក ។ ដោយការកោតសរសើរកិច្ច ខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីធ្វើអោយស្របតាមច្បាប់ និងគោលការណ៏របស់អង្គការពាណិជ្ជកម្មពិភពលោក សមាជិកទាំងអស់បានកត់សំគាល់ឃើញថា កម្ពុជាត្រូវតែបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនតទៅទៀត ដើម្បីធ្វើ អោយច្បាប់ទំលាប់ និងការអនុវត្តន៏របស់ខ្លួនបានស្របទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ សមាជិកទាំងអស់បានសន្យាធ្វើការក្នុងន័យស្ថាបនាជាមួយកម្ពុជា ដើម្បីសំរេចអោយបានកិច្ចការនេះ ហើយ សមាជិកមួយចំនួននឹងផ្តល់ជំនួយបច្ចេកទេសដើម្បីសំរួលដល់ការចូលជាសមាជិករបស់កម្ពុជា ។ សមាជិកទាំងអស់ ចង់ឃើញកម្ពុជាបានចូលជាសមាជិកអង្គការនេះអោយបានឆាប់ក្រោមលក្ខខ័ណ្ឌសមស្រប ។ សមាជិកខ្លះបានលើក យកស្ថានភាពប្រទេសអភិវឌ្ឍន៏តិចតួចរបស់កម្ពុជាមកពិចារណាហើយប្រើប្រាស់កត្តានេះជាកត្តាពាក់ព័ន្ធមួយជា គោលការណ៏ដើម្បីបង្កើតជាលក្ខខ័ណ្ឌនៃការចរចារចូលជាសមាជិរបស់កម្ពុជា ។

៩. ក្រុមការងារបានពិនិត្យមើលគោលនយោបាយសេដ្ឋកិច្ច និង របបពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា ព្រមទាំងលក្ខខ័ណ្ឌនានា ដែលអាចបង្កើតអោយមានពង្រាងនៃពិធីសារអំពីការចូលអង្គការពាណិជ្ជកម្ម ពិភពលោក ។ ទស្សនៈដែលសំដែងឡើងដោយសមាជិកទាំងអស់របស់ក្រុមការងារលើចំណុចផ្សេងៗ នៃរបប ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា ព្រមទាំងស្តីអំពីលក្ខខ័ណ្ឌនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោករបស់កម្ពុជា ត្រូវបានសង្ខេប ដូចខាងក្រោមចាប់តាំងពីកថាខ័ណ្ឌ ទី១០ ដល់កថាខ័ណ្ឌទី ២២៣ ។

## គោលនយោបាយសេដ្ឋកិច្ច

### គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ

១០. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៏ថា មូលដ្ឋានគ្រឹះនៃគោលនយោបាយរូបិយវត្ថុរបស់កម្ពុជា គឺកំណើនសេដ្ឋកិច្ចដែលមានអតិផរណាទាប ។ គោលនយោបាយរូបិយវត្ថុតឹងរឹងមួយត្រូវបានបង្កើតអោយមាន

តាំងពីឆ្នាំ ១៩៩៣ ក្នុងគោលបំណងសំរេចអោយបាននូវគោលដៅនេះ។ ជាលទ្ធផល អតិផរណាប្រចាំឆ្នាំបានធ្លាក់ចុះពីកំរិតបីខ្ទង់ នៅឆ្នាំ១៩៩៣ មកត្រឹមប្រហែលមួយខ្ទង់នាពេលបច្ចុប្បន្ន។

១១. ប្រព័ន្ធធនាគារកម្ពុជាត្រូវបានផ្លាស់ប្តូរគួរអោយកត់សំគាល់ តាំងពីឆ្នាំ១៩៨៩ នៅពេលដែលប្រព័ន្ធធនាគារប្រភេទផ្តាច់មុខត្រូវបានជំនួសដោយប្រព័ន្ធធនាគារពីរថ្នាក់ (Two Tier) មួយដែលរួមមានធនាគារកណ្តាល និងធនាគារពាណិជ្ជកម្ម។ ធនាគារកណ្តាល ធនាគារជាតិនៃកម្ពុជា (NBC) ទទួលខុសត្រូវក្នុងការបង្កើត និងប្រតិបត្តិគោលនយោបាយរូបិយវត្ថុរបស់កម្ពុជា ។ ឧបករណ៍ចាំបាច់សំរាប់ប្រើប្រាស់ដើម្បីគ្រប់គ្រងលទ្ធភាពសងបំណុលបានគឺប្រាក់តំកល់ បំរុងទុកដែលចាំបាច់ត្រូវមាន ព្រមទាំងការកំរិតលើការបញ្ចេញប្រាក់ របស់ធនាគារ។ ការដាក់អោយប្រើប្រាស់នូវប័ណ្ណរតនាគារ (Treasury bills) ដែលជាឧបករណ៍គោលនយោបាយបន្ថែមគឺ ត្រូវស្ថិតនៅក្នុងការពិចារណា ហើយក្នុងឆ្នាំ២០០៣ស្ថានការណ៍ពីរនៃប័ណ្ណរតនាគារត្រូវបាន បង្កើតអោយមាន។

១២. គោលនយោបាយសារពើពន្ធត្រូវបានចាត់ទុកជាស្នូល នៃយុទ្ធសាស្ត្រកែទំរង់របស់កម្ពុជា។ ការឧបត្ថម្ភទុនក្នុងស្រុកបានលុបចោល តាំងពីឆ្នាំ១៩៩៥ ហើយការយកចិត្តទុកដាក់ត្រូវបានផ្តោតទៅលើការពង្រីកមូលដ្ឋានពន្ធ និងបានបង្កើនការប្រមូលពន្ធ។ ប្រព័ន្ធពន្ធដាត្រូវបានកែទំរង់ក្នុងខែមករា ឆ្នាំ១៩៩៧ ដោយមានការអនុម័តច្បាប់ពន្ធដា។ ច្បាប់នេះបានណែនាំអោយប្រើពន្ធលើផលរបរ (Turnover Tax) លើការលក់ផលិតផលនាំចូលដំបូង (ដែលកាលពីមុនបានលើកលែង)។ អាករបន្ថែមត្រូវបានកំណត់អោយយកលើរថយន្ត ការធ្វើដំណើរអន្តរជាតិតាមផ្លូវអាកាស និងសេវាទូរគមនាគមន៍អន្តរជាតិ ព្រមទាំងការយកពន្ធលើប្រាក់ចំណូលការប្រាក់ និងផលចំណេញ. ពង្រឹងការអនុវត្តន៍កំរិតពន្ធ អប្បបរិមា កំណត់ពន្ធ ៣០ភាគរយលើផលចំណេញលើការរុករកប្រេងកាត ឧស្ម័ន និងធនធានធម្មជាតិ។ កំណត់យកពន្ធលើប្រាក់ចំណូល របស់មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល. បង្កើតប្រព័ន្ធពន្ធកាត់ទុក (Withholding tax) ក៏ដូចជាការឧបត្ថម្ភកធនពន្ធលើ ផលរបរ និងពន្ធលើការប្រើប្រាស់ខ្លះទៀតដោយការយកអាករលើ តំលៃបន្ថែម (VAT) ។ អនុបាត្រនៃចំណូលពន្ធធៀបនឹងផលិតផលសរុបក្នុងស្រុកសរុប (GDP) នៅតែមានកំរិតទាបនៅឡើយ ហើយបានសង្កត់ធ្ងន់តែទៅលើប្រភពពីរបីតែប៉ុណ្ណោះ។ ក្នុងឆ្នាំ២០០០ ចំណូលពន្ធដែលប្រមូលបានគឺប្រមាណ ៧៣ភាគរយនៃចំណូលសរុបរបស់រដ្ឋាភិបាល ជាពិសេសបានមកពីពន្ធគយ (៤៨ភាគរយ) ពន្ធអាករ (១២ភាគរយ) និងអាករលើតំលៃបន្ថែម (៤០ភាគរយ)។

១៣. កម្ពុជាបានបង្កើតឡើងនូវរបបពន្ធ ២ប្រភេទពោលគឺ "របបពិត" និង "របបប៉ាន់ស្មាន"។ "របបពន្ធពិត" អនុវត្តលើអ្នកបង់ពន្ធ មធ្យមនិងធំដូចជាអង្គភាពច្បាប់ និងអង្គភាពអាជីវកម្មនានា ដែលមានចំណូលលើផលរបរប្រចាំឆ្នាំលើសពី ៥០០លានរៀល (ចំពោះទំនិញ ប្រហែល ១៣០ពាន់ដុល្លា ) ឬ ២៥០លានរៀល (ចំពោះសេវា ៦៥ពាន់ដុល្លា) ឬ ១២៥ លានរៀល (៣២ ពាន់ដុល្លា )ក្នុងករណីផ្តល់ក្រោមកិច្ចសន្យារបស់រដ្ឋាភិបាល ។ អ្នកជាប់ពន្ធខ្នាតមធ្យម និងធំ ត្រូវជាប់កាតព្វកិច្ចបង់អាករលើតំលៃបន្ថែមនៅពេលដែលអ្នកជាប់ពន្ធដទៃទៀតត្រូវជាប់ពន្ធលើចំណូលដុលប្រមាណ ២ភាគរយ នៅក្រោម "របបពន្ធប៉ាន់ស្មាន"។ តំណាងប្រតិភូកម្ពុជាបានបន្ថែមថា

ការបង្កើតអោយមាននូវរបបពន្ធធម្មតាមួយ ដែលស្រដៀងគ្នាទៅនឹងពន្ធបែបរបបពិតប៉ុន្តែដាក់បញ្ចូលនូវអ្នកបង់ពន្ធតូចតាច ហើយផ្អែកលើការវាយតំលៃដោយខ្លួនឯងអាចនឹងត្រូវប្រកាសអោយប្រើនៅពេលខាងមុខ។

## រូបិយប័ណ្ណបរទេស និងការបង់ប្រាក់

១៤. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា គោលបំណងនៃការកំណត់គោលនយោបាយលើអត្រាប្តូរប្រាក់របស់កម្ពុជាគឺធ្វើ អោយមានលំនឹងដល់អត្រាប្តូរប្រាក់លើទីផ្សារ។ តំលៃនៃរូបិយប័ណ្ណ ជាតិប្រាក់រៀល-ត្រូវកំណត់ដោយទីផ្សារចាប់តាំងពីឆ្នាំ១៩៩៣។ ធនាគារជាតិបានធ្វើអន្តរាគមន៏ ជារឿយៗនៅក្នុងទីផ្សាររូបិយប័ណ្ណប្រាក់បំរុងជារូបិយប័ណ្ណអន្តរជាតិ និងធ្វើអោយមានលំនឹងលើអត្រាប្តូរប្រាក់។

១៥. ប្រព័ន្ធប្តូររូបិយប័ណ្ណបរទេសនាពេលបច្ចុប្បន្ននៅកម្ពុជា គឺពឹងផ្អែកលើច្បាប់ច្បាប់រូបិយប័ណ្ណបទេសឆ្នាំ១៩៩៧ ។ តាមរយៈច្បាប់នេះរាល់ប្រតិបត្តិការប្តូរប្រាក់បរទេសទាំងអស់ រួមទាំងការទិញ និង ការលក់រូបិយប័ណ្ណបរទេស ការផ្ទេរ និងការទូទាត់ និង លំហូរមូលធនអន្តរជាតិគ្រប់ប្រភេទត្រូវបានអនុញ្ញាតិ ដោយពុំមានការដាក់កំហិត ដែលជាហេតុធ្វើអោយទង្វើទាំងនេះត្រូវជះឥទ្ធិពលតាមរយៈអន្តរការីដែលមានសិទ្ធិ (ដែលនឹងរួមបញ្ចូលទាំងសាខារបស់ធនាគារបរទេសផង)។ រាល់ប្រតិបត្តិការរូបិយប័ណ្ណបរទេស ដែលមានតំលៃស្មើ ឬច្រើនជាង ១០,០០០ដុល្លា គឺតំរូវអោយមានការប្រកាស។ កម្ពុជាមិនតំរូវអោយមានការបង់ប្រាក់លើការធានារ៉ាប់រងរូបិយប័ណ្ណបរទេស ដែលបានមកពីការនាំចូល ឬនាំចេញឡើយ។

១៦. កម្ពុជាបានដាក់ចេញនូវគណនីចរន្តសំរាប់ការប្តូររូបិយវត្ថុរបស់ខ្លួនដូចដែលបានចែងក្នុងមាត្រា ៨ ផ្នែកទី២, ៣ និង៤ នៃបណ្តាមាត្រាក្នុងកិច្ចព្រមព្រៀងរបស់ IMF ព្រមទាំងត្រូវផ្តល់ ជាសមាជិកនៅក្រោមមាត្រា ៨ នាថ្ងៃទី ១ ខែមករា ឆ្នាំ២០០២។

## ការគ្រប់គ្រងការធ្វើវិនិយោគទុន

១៧. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ច្បាប់វិនិយោគទុន ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤ និងអនុក្រឹត្យចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៧ និងថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ បានគ្រប់គ្រងការធ្វើវិនិយោគគ្រប់ប្រភេទនៅកម្ពុជាទាំងការវិនិយោគទុនពីក្នុងប្រទេស និងការវិនិយោគទុនពីបរទេស។ មាត្រាទី៨នៃច្បាប់នេះបានផ្តល់ដល់ប្រព្រឹត្តិកម្មជាតិជាទូទៅ ចំពោះអ្នកវិនិយោគបរទេសលើកលែងតែកម្មសិទ្ធដីធ្លី ។ មន្ត្រីតំណាងប្រតិភូកម្ពុជាបានបន្ថែមទៀតថា ជាធម្មតាកម្ពុជាមិនហាមឃាត់ ឬដាក់កំហិតដល់វិនិយោគទុនបរទេសទេ លើកលែងតែលើហេតុផលនៃសន្តិសុខជាតិ និងសុវត្ថិភាពសង្គម ឬក៏ ហេតុផលដែលចាត់ទុកជាពេលវេលាចាំបាច់សំរាប់សេដ្ឋកិច្ច។ បណ្តាវិស័យដែលស្ថិតក្រោមការដាក់កំហិតលើការវិនិយោគ មានបញ្ជាក់ក្នុង

ឧបសម្ព័ន្ធ១ នៃឯកសារ WT/ACC/KHM/6។ ក្នុងករណីខ្លះដូចជាការ វិនិយោគលើម៉ាស៊ីនកិនស្រូវវិនិយោគទុនបរទេសតំរូវអោយមានការចូលរួមទុនពីវិនិយោគិនក្នុងស្រុក នឹងត្រូវកំណត់តាមរយៈការចរចារវាងអ្នកវិនិយោគ ។ ការវិនិយោគទុនបរទេសលើវិស័យបសុសត្វ និងព្រៃឈើតំរូវអោយមានដៃគូក្នុងស្រុកដែរ។ លក្ខណៈវិនិច្ឆ័យលើការដាក់ កំហិតទាំងនេះ មានចែងក្នុងអនុក្រឹត្យលេខ៨៨ ចុះថ្ងៃ ទី ២៩ ខែធ្នូ ឆ្នាំ១៩៩៧។

១៨. មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា បានរក្សាទុកភាពជាម្ចាស់នៃដីធ្លីសំរាប់ពលរដ្ឋកម្ពុជា ឬ នីតិបុគ្គលដែលមានចំណែកអប្បបរមា ៥១ភាគរយ ជាកម្មសិទ្ធិរបស់កម្ពុជា។ ស្របតាមច្បាប់វិនិយោគទុន ឆ្នាំ១៩៩៤ វិនិយោគិនបរទេសត្រូវអនុញ្ញាតិអោយជួល ឬប្រើប្រាស់ដីធ្លីសំរាប់រយៈពេលដល់ទៅ៧០ឆ្នាំ។ សំណើសុំ ពន្យារពេលពី ៧០ឆ្នាំ ទៅ ៩៩ឆ្នាំ ត្រូវបានពិចារណា។ នៅក្នុងឆ្នាំ២០០១ ច្បាប់ដីធ្លីបានកំណត់ប្រភេទដីធ្លីជាពីរប្រភេទគឺ ដីសម្បទាន និងដីជួល។ ដីសម្បទានអាចជួលបានក្នុងរយៈពេលអតិបរមា ៩៩ឆ្នាំ សំរាប់គំរោងកសិឧស្សាហកម្ម។ ដីជួលត្រូវកំណត់ជាប្រភេទអចលនទ្រព្យដោយរាប់បញ្ចូលទាំងអាគារ និង ដី ដែលអាចជួលបានសំរាប់រយៈពេលវែង ឬខ្លី។ រយៈពេលនៃការជួលអាចគ្មាន ឬមានរយៈពេលជាក់លាក់។ ការជួលក្នុងរយៈពេលជាក់លាក់រួមមានការជួលរយៈពេលខ្លីដោយមានកិច្ចសន្យាអាចបន្តបាន ឬ ការជួលរយៈពេលវែងសំរាប់រយៈពេល ១៥ឆ្នាំឡើងទៅ។

១៩. នីតិបញ្ញត្តិរបស់កម្ពុជាបានធានាដល់ការសងក្នុងករណី ដែលមានការដកហូតតាមច្បាប់។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញបានចែងថា ទ្រព្យសម្បត្តិស្របច្បាប់ឯកជនត្រូវបានការពារដោយច្បាប់ ហើយសិទ្ធិរឹបអូសយកទ្រព្យសម្បត្តិអាចប្រព្រឹត្តទៅបានតែក្នុងផលប្រយោជន៍ សាធារណៈដូចដែលបានចែងក្នុងច្បាប់ជាការសងជំងឺចិត្តជាមុនដោយស្មើភាពនិងយុត្តិធម៌។ មាត្រា៩ នៃច្បាប់ស្តីពីវិនិយោគទុនបានផ្តល់ការធានា ជាទូទៅដល់ជាតូបនីយកម្ម។ដើម្បីបង្កើនជំនឿទុកចិត្តដល់វិនិយោគិនបន្ថែមទៀត កម្ពុជាបានសំរេចលើសន្ធិសញ្ញាស្តីពីវិនិយោគទុនទ្វេភាគី ដើម្បីផ្តល់ការការពារស្របច្បាប់ចំពោះវិនិយោគិនក្នុងស្រុកនិង បរទេស។ កម្ពុជាបានចុះលើកិច្ចព្រមព្រៀងធានារ៉ាប់រងលើវិនិយោគទ្វេ ភាគី ជាមួយប្រទេសចំនួន ១២ (ចិន គ្រូអាត បារាំង អាល្លឺម៉ង់ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សាធារណរដ្ឋកូរ៉េ សឹង្ហបុរី ស្វីស ថៃឡង់ដ៍ និងវៀតណាម) ដែលបានចុះហត្ថលេខា និងធ្វើសច្ចានុម័តព្រមព្រៀងមួយជាមួយនឹងសាជីវកម្មវិនិយោគឯកជនក្រៅប្រទេស (OPIC) នៃសហរដ្ឋ អាមេរិក និងបានផ្តល់សច្ចានុម័តលើភ្នាក់ងារ ធានារ៉ាប់រង វិនិយោគពហុភាគី (MIGA) នៃធនាគារពិភពលោក។

២០. កម្ពុជាបានផ្តល់ការលើកទឹកចិត្ត ដើម្បីទាក់ទាញវិនិយោគទុន ដោយអនុលោមតាមមាត្រា ១៤ នៃច្បាប់វិនិយោគទុន ។ ការលើកទឹកចិត្ត ទាំងនេះត្រូវផ្តល់ដល់បណ្តាក្រុមហ៊ុនកម្ពុជា និង បរទេសដោយពុំមានការរើសអើង គឺអាស្រ័យលើការដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍ នៃកម្ពុជា (CDC) ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពិនិត្យនិងសំរេចលើ ពាក្យសុំក្នុងរវាង ៤៥ថ្ងៃ។ ការលើកទឹកចិត្តរួមមាន (១) ពន្ធសាជីវកម្ម

(Corporate Tax) នៅអត្រា ៩ភាគរយ លើកលែងតែការរុករកធនធានធម្មជាតិ ឈើ ប្រេងកាត រ៉ែ មាស និងត្បូង ថ្ម មានតំលៃ (៣០ភាគរយ); (២) ការលើកលែងមិនយកពន្ធ (Tax Holidays) លើពន្ធសាជីកម្ម (Corporate Tax) រយៈពេល៨ឆ្នាំ និងបន្តរយៈពេល៥ឆ្នាំក្នុងការរកស៊ីខាតបង់ ព្រមទាំងលើកលែងពន្ធលើពន្ធសាជីកម្មទាំងអស់ចំពោះប្រាក់ចំណេញ ដែលត្រូវវិនិយោគឡើងវិញក្នុងប្រទេសកម្ពុជា (រយៈពេលរួចពន្ធត្រូវផ្តល់លើលក្ខខ័ណ្ឌ សេដ្ឋកិច្ចសង្គម និង ភូមិសាស្ត្រ ដែលបានចុះក្នុងឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យលេខ៨៨ ចុះខែធ្នូ ឆ្នាំ១៩៩៧); (៣) ពុំមានពន្ធ កាត់ទុកលើភាគលាភ (Dividends) ឡើយ; និង (៤) ពុំមានការដាក់កំហិតលើការផ្ទេរប្រាក់ចំណេញដែលត្រូវផ្ញើចេញទៅបរទេស (Repatriation of Profits) ច្រើនជាងឡើយ។ លើសពីនេះទៀត ចំពោះគំរោងវិនិយោគទុនដែលទំនិញនាំចេញ៨០ភាគរយ ឬច្រើនជាងនៃផលិតកម្មត្រូវបានទទួលប្រយោជន៍ពីការលើកលែងពន្ធនាំចូលពេញលេញចំពោះសំភារៈសំណង់ មធ្យោបាយផលិតកម្ម ឧបករណ៍ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់។ ការលើកលែងពន្ធនាំចូល គឺត្រូវអនុវត្តចំពោះបណ្តាគំរោងដែលតាំងនៅក្នុង តំបន់លើកលែងពិសេស (SPZ) ឧស្សាហកម្មទេសចរណ៍ ឧស្សាហកម្ម ទាំងឡាយដែលប្រើប្រាស់កំលាំងពលកម្មច្រើន (ដូចជាឧស្សាហកម្មកាត់ដេរ, ដេរស្បែកជើង និងធ្វើប្រដាប់ប្រដាក្មេងលេង) កសិឧស្សាហកម្ម និងឧស្សាហកម្ម ទាំងឡាយផលិតម្ហូបអាហារ (ដូចជា ម្ហូបកំប៉ុង) ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធ និងការបង្កើតថាមពល (ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ កំពង់ផែសមុទ្រ ថាមពលអគ្គីសនី ។ល។) ការលើកទឹកចិត្តត្រូវដកហូតវិញ អាស្រ័យលើមាត្រា៧.២ នៃអនុក្រឹត្យ លេខ៨៨ ហើយរដ្ឋាភិបាលកម្ពុជាកំពុងតែកែសំរួលលើការលើកលែងខ្លះៗ ដែលបានផ្តល់អោយនៅក្រោមច្បាប់វិនិយោគទុន។ សភាបាន អនុម័តលើច្បាប់ស្តីពីការធ្វើវិសោធនកម្មច្បាប់ វិនិយោគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៣។ ច្បាប់ថ្មីនេះបានកែប្រែលើការលើកទឹកចិត្តមួយចំនួន ប៉ុន្តែរក្សាទុកនូវប្រការចែងដំបូងនានា ក្នុងលក្ខណៈជាអន្តរកាលដោយអនុញ្ញាតិអោយ បន្តនូវសិទ្ធិជាប្រយោជន៍ ដែលបានទទួលរួចហើយលើប្រាក់ចំណេញក្នុងរយៈពេល ៥ឆ្នាំទៅមុខទៀត។ តំណាង កម្ពុជាមានទស្សនៈថា ការហាមឃាត់ចំពោះការឧបត្ថម្ភទុនសំរាប់ការនាំចេញដែលមានចែងក្នុងកថាខ័ណ្ឌ ១ (ក) នៃមាត្រា៣ នៃកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភទុន និងការដាក់វិធានការតបតនឹង មិនត្រូវបានអនុវត្តនៅកម្ពុជាទេ ដោយផ្អែកលើប្រយោជន៍ដែលមានចែងក្នុងប្រការ ២៧.១ នៃកិច្ចព្រមព្រៀងនេះ។ សំរាប់ការពិភាក្សាបន្ត សូមពិនិត្យផ្នែក "ការឧបត្ថម្ភទុនសំរាប់ការនាំចេញ"។

## <u>សហគ្រាសរដ្ឋ និងឯកជនភាវូបនីយកម្ម</u>

២១. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា គំនិតផ្តួចផ្តើមពីវិស័យឯកជនត្រូវបានលើកទឹកចិត្តនៅក្នុងផ្នែកកសិកម្មតាំងពីឆ្នាំ ១៩៨៧ នៅពេលដែលសហគ្រាសរដ្ឋត្រូវបានផ្តល់ស្វ័យតភាពជាបន្តបន្ទាប់ ដែលពីមុនត្រូវបានគ្រប់គ្រងតាមរបៀបសេដ្ឋកិច្ចផែនការ។ កម្មសិទ្ធិឯកជនឥឡូវនេះគឺជាសិទ្ធិធម្មនុញ្ញមួយ ដែលចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។

២២. ឯកជនភាវូបនីយកម្មត្រូវចាប់ធ្វើក្នុងកំឡុងដំណាក់កាលដំបូង ពីឆ្នាំ១៩៩១ ដល់ពាក់កណ្តាល ឆ្នាំ១៩៩៣ និង ដំណាក់កាលទីពីរ ដែលចាប់ផ្តើមពីខែមេសា ឆ្នាំ១៩៩៥។ ក្នុងដំណាក់កាលដំបូងការទាក់ទាញវិនិយោគិនបរទេស និងការធានាអោយមានការងារធ្វើ គឺត្រូវចាត់ទុកជាអាទិភាពទីមួយ។ បណ្តាក្រសួង និងស្ថាប័នរដ្ឋត្រូវបានអនុញ្ញាតិអោយមានសិទ្ធិលក់ និងជួលសហគ្រាសរដ្ឋ ដែលខ្លួនទទួលខុសត្រូវដោយពុំចាំបាច់អោយមានការឯកភាពពីថ្នាក់លើ ដែលមិនពាក់ព័ន្ធឡើយ។

២៣. ដំណាក់កាលទី២ នៃដំណើរការឯកជនភាវូបនីយកម្មបានចាប់ផ្តើមដោយមានបទបញ្ញត្តិថ្មីៗ ដែលបង្ខំអោយរឹតបន្តឹងនិងធ្វើមជ្ឈការត្រួតពិនិត្យលើការធ្វើឯកជនភាវូបនីយកម្ម។ នៅក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដើម្បីសន្និដ្ឋានលើសារពើភ័ណ្ឌបណ្តាសហគ្រាសដែលនៅសល់ បង្កើតចេញនូវយុទ្ធសាស្រ្តឯកជនភាវូបនីយកម្ម និងត្រួតពិនិត្យដំណើរការឯកជនភាវូបនីយកម្ម។ ឯកជនភាវូបនីយកម្ម ដែលមានសារៈសំខាន់ជាងគេបង្អស់បានចាប់ផ្តើមធ្វើបន្ទាប់ពីឆ្នាំ ១៩៩៥។ តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា សហគ្រិនក្នុងស្រុក និង បរទេសត្រូវបានផ្តល់សិទ្ធិស្មើគ្នានៅក្នុងដំណើរការឯកជនភាវូបនីយកម្ម លើកលែងតែចំពោះការដាក់កំហិតទូទៅលើកម្មសិទ្ធិដីធ្លីរបស់បរទេស។

២៤. រហូតមកដល់ខែមេសាឆ្នាំ ២000 មាន១៧៧ សហគ្រាសត្រូវបានធ្វើឯកជនភាវូបនីយកម្ម ពោលគឺនៅក្នុងវិស័យផលិតកម្ម កសិកម្ម និងពាណិជ្ជកម្ម ដែលក្នុងនោះ ១៥២ សហគ្រាសត្រូវបានជួលទៅអោយសហគ្រិនឯកជន ៥សហគ្រាសជាសហគ្រាសចំរុះទុន និង២0សហគ្រាសទៀត ត្រូវបានលក់ទាំងស្រុង។ មាន១១សហគ្រាសត្រូវបានផ្ទេរអោយទៅជាសហគ្រាសសាធារណៈ ហើយ១៦ទៀតនៅមិនទាន់បញ្ចប់ដំណើរឯកជនភាវូបនីយកម្មនៅឡើយ។ របាយការណ៍ពិស្តារមួយផ្តល់ជូននៅក្នុងតារាង ១ (ក) ចំណែកឯសហគ្រាសរដ្ឋ គិតត្រឹមខែមិនា ឆ្នាំ២000 មានចែងក្នុងតារាង ១(ខ)។ លោកបានបន្ថែមទៀតថា ១៣សហគ្រាស ដែលជាសហគ្រាសគន្លឹះក្នុងវិស័យសេវាកម្មសាធារណៈចំពោះសេដ្ឋកិច្ចជាតិ នឹងត្រូវរក្សាទុកជាសហគ្រាសរដ្ឋរហូតដល់ការបញ្ចប់នៃកម្មវិធីឯកជនភាវូបនីយកម្ម។ ក្រុមហ៊ុនចំការកៅស៊ូ ៧ នឹងនៅជាសហគ្រាសរដ្ឋរហូតដល់ ឆ្នាំ២00៦។ បញ្ជីនៃក្រុមហ៊ុនទាំងអស់ដែលត្រូវរក្សាទុកជាក្រុមហ៊ុនរដ្ឋរួមមានអយស្ម័យាន ទឹកស្អាត ថាមពល អគ្គីសនី ព្រមទាំងការងារសាធារណៈការ និងដឹកជញ្ជូនសាធារណៈ ក៏ដូចជាក្រុមហ៊ុនកសិកម្មដែលមានចែងនៅ ក្នុងតារាង ១(គ)។

២៥. តំណាងប្រតិភូកម្ពុជាបានបង្ហាញថា រដ្ឋាភិបាលរបស់ខ្លួននឹង ធ្វើអោយមានតំលាភាពលើកម្មវិធីឯកជនភាវូបនីយកម្ម ដែលកំពុងបន្តរបស់ខ្លួន ហើយនឹងបន្តជូនដំណឹងដល់សមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ចំពោះការរីកចំរើន នៃកំណែទំរង់លើរបបពាណិជ្ជកម្ម និងសេដ្ឋកិច្ចរបស់ខ្លួន។ លោកបានបញ្ជាក់ថារដ្ឋាភិបាលរបស់លោក នឹងផ្តល់របាយការណ៍ តាមពេលជូនសមាជិកអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការអភិវឌ្ឍន៏ក្នុងកម្មវិធីឯកជនភាវូបនីយកម្មរហូត ដល់ពេលណាដែលកម្មវិធីឯកជនភាវូបនីយកម្មនេះនៅតែមានដើម្បីអោយស្របជាមួយនឹងអ្វីដែលបានផ្តល់ជូនក្រុមការងាររួចមកហើយ។ លោកបានមានប្រសាសន៏ថា

រដ្ឋាភិបាលរបស់លោកនឹងផ្តល់របាយការណ៍តាមពេលជាក់លាក់ស្តីពីបញ្ហាដទៃទៀត ដែលទាក់ទងនឹងកំណែទំរង់សេដ្ឋកិច្ចរបស់ខ្លួន ក៏ដូចជាអ្វីដែលទាក់ទងនឹងកាតព្វកិច្ចរបស់ខ្លួននៅក្រោមច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក ។ ក្រុមការងារបាន កត់ត្រានូវការសន្យាទាំងអស់នេះ ។

## គោលនយោបាយកំណត់ថ្លៃ

២៦. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ការកំណត់ថ្លៃ ត្រូវបានលុបចោលក្នុងឆ្នាំ១៩៨៩ ។ តំលៃរបស់ទំនិញ និងសេវាត្រូវកំណត់ដោយទីផ្សារលើកលែងតែថាមពលអគ្គិសនី និងទឹកស្អាត ។ តំលៃលើការប្រើប្រាស់ថាមពលអគ្គិសនីត្រូវបានកំណត់ដោយក្រសួងឧស្សាហកម្មរ៉ែ និងថាមពលតាមអនុក្រឹត្យលេខ ៣៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ឯបទបញ្ញត្តិនៃការកំណត់ ថ្លៃទឹកស្អាតត្រូវចេញដោយសាលាក្រុង និងសាលាខេត្ត ។ ចំពោះការប្រើប្រាស់ការកំណត់ថ្លៃនាពេលអនាគត វានៅតែជាបញ្ហាមួយដែលរដ្ឋាភិបាលកម្ពុជាត្រូវបញ្ជាក់ ។

២៧. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ចាប់ពីពេលដែលកម្ពុជាចូលជាសមាជិកតទៅការអនុវត្តន៍ការកំណត់ថ្លៃកម្ពុជានឹងធ្វើតាមវិធានការនានាដែលស្របគ្នានឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងគិតដល់ប្រយោជន៍នៃការនាំចេញរបស់ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនានា ដូចដែលបានចែងនៅក្នុង មាត្រា ៣.៩ នៃច្បាប់ GATT ឆ្នាំ១៩៩៤ ព្រមទាំងក្នុងមាត្រា៨ នៃកិច្ច ព្រមព្រៀងទូទៅស្តីអំពីពាណិជ្ជកម្មលើវិស័យសេវាកម្ម (GATS) ។ លោកក៏បានបញ្ជាក់ផងដែរថា កម្ពុជាបានបោះពុម្ពបញ្ជីទំនិញ និងសេវាកម្ម ដែលស្ថិតក្រោមការត្រួតពិនិត្យដោយរដ្ឋ និងការផ្លាស់ប្តូរនានា នៅក្នុងសារពត៌មានផ្លូវការរបស់ខ្លួន ហើយនឹងបន្តធ្វើដូច្នេះបន្ទាប់ពីការចូលជាសមាជិករួចហើយ ។ ក្រុមការងារបានកត់ត្រាលើការសន្យាទាំងនេះ ។

## គោលនយោបាយប្រកួតប្រជែង

២៨. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ប្រទេសកម្ពុជាមិនទាន់មានច្បាប់ប្រកួតប្រជែងទេ ប៉ុន្តែកម្ពុជាបាននឹងកំពុងស្វែងរកជំនួយឧបត្ថម្ភ ដើម្បីធ្វើពង្រាងបទបញ្ញត្តិសំរាប់អោយមានការប្រកួតប្រជែងត្រឹមត្រូវក្នុងសកម្មភាពអាជីវកម្មផ្សេងៗ ។ ឆ្លើយតបទៅនឹងសំណូរអោយផ្តល់ពតិមាន លើអ្វីដែលកម្ពុជាថ្លែងអំពីបទបញ្ញត្តិត្រង់មាត្រា៨ នៃច្បាប់ GATS ដែលទាក់ទងទៅនឹងភាពផ្តាច់មុខ និងអ្នកផ្គត់ផ្គង់សេវាកម្មមានសិទ្ធិផ្តាច់មុខ ។ តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ជាទូទៅរដ្ឋាភិបាលរបស់លោកបានបន្តគោលនយោបាយសេរីភាវូបនីយកម្មជាជំហានៗលើសេវាកម្មផ្តាច់ដែលមានពីមុន ដើម្បីអោយមានការចូលរួមពីវិស័យឯកជន រួមទាំងការប្រកួតប្រជែងពីបរទេស ។

## ក្របខ័ណ្ឌសំរាប់ការបង្កើត និងការអនុវត្តន៍គោលនយោបាយ

២៩. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាគឺជាប្រទេសរាជានិយមអាស្រ័យធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញត្រូវបានប្រកាសអោយប្រើនៅក្នុងខែកញ្ញា ឆ្នាំ១៩៩៣។ ព្រះមហាក្សត្រគឺជាប្រមុខរដ្ឋអស់មួយជីវិត។ ព្រះមហាក្សត្រតែងតាំងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីក៏ដូចជាអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ។ ព្រះមហាក្សត្រ បានចុះព្រះហស្ថលេខាលើក្រឹត្យស្តីពីការតែងតាំងការផ្លាស់ប្តូរ ឬការបញ្ឈប់មន្ត្រីស៊ីវិល ឬយោធាជាន់ខ្ពស់និងចៅក្រម ប្រកាសសង្គ្រាម ហើយអាចប្រកាសពីភាពអាសន្នរបស់ប្រទេស។ លើសពីនេះទៀត ព្រះមហាក្សត្រចុះព្រះហស្ថលេខា និងតាមរយៈនេះផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ដែលបានស្នើឡើងដោយសភាជាតិ។

៣០. អំណាចនិតិបញ្ញត្តិ ត្រូវបានអនុវត្តដោយសភាជាតិដែលរួមមានសមាជិក ១២២រូប ជ្រើសតាំងដោយការបោះឆ្នោតផ្ទាល់ និងទូទៅសំរាប់រយៈពេល៥ឆ្នាំ និងព្រឹទ្ធសភាដែលបានបង្កើតឡើងដោយមានសមាជិកចំនួន ៦១រូប។ សភាជាតិគឺជា អង្គការតែមួយគត់ដែលមានអំណាចក្នុងការអនុម័តច្បាប់។ មុខងារផ្សេង១ទៀតរបស់សភារួមមានការសំរេចលើថវិការជាតិ សំរេចលើកម្មវិធីនិងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងសំរេចលើសំណើរបស់រដ្ឋាភិបាលក្នុងការណែនាំអោយកាត់បន្ថយ ឬលុបចោលពន្ធប្រចាំឆ្នាំ។ ច្បាប់ និង បញ្ញត្តិនានាជាធម្មតារៀបចំឡើងជាដំបូងដោយក្រសួងនានា។ ពង្រាងច្បាប់ និងបញ្ញត្តិនានា ដែលបានឯកភាពដោយគណៈរដ្ឋមន្ត្រីត្រូវដាក់ជូនសភា ដើម្បីត្រួតពិនិត្យឡើងវិញនិងអនុម័ត។ ព្រឹទ្ធសភាត្រួតពិនិត្យច្បាប់ ដែលបានអនុម័តដោយ សភាជាតិ ហើយអាចផ្តល់អនុសាសន៍ជូនសភាលើច្បាប់ ឬបទបញ្ញត្តិ ដែលបានស្នើឡើង។ ច្បាប់ និងបញ្ញត្តិនានាត្រូវប្រកាសអោយប្រើដោយមានព្រះហស្ថលេខារបស់ព្រះមហាក្សត្រ និងមានសុពលភាពក្នុងរាជធានីភ្នំពេញក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីបានឡាយព្រះហស្ថលេខា និងក្នុងទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃ។ ច្បាប់ដែលរំលោភលើគោលការណ៍រដ្ឋធម្មនុញ្ញអាចត្រូវចាត់ទុកជាមោឃៈដោយក្រុមប្រឹក្សាធម្មនុញ្ញ ដែលរួមមានសមាជិកចំនួន ៩រូប សំរាប់អណត្តិ៩ឆ្នាំ ដែលបង្កើតឡើងដោយព្រះមហាក្សត្រសភាជាតិ និងក្រុមប្រឹក្សានៃអង្គចៅក្រម។ ប្រធានរដ្ឋសភាជាតិ គឺជាសមាជិកមួយរូបនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលជាអ្នកសំរេចលើការស្នងរាជសម្បត្តិ។ ប្រធានព្រឹទ្ធសភាជាប្រមុខរដ្ឋស្តីទីនៅពេលនៅក្នុងព្រះរាជអវត្តមាននៃព្រះមហាក្សត្រ (ឬប្រសិនបើពុំមានលទ្ធភាពបំពេញមុខងាររបស់ខ្លួនបាន)។

៣១. អំណាចតុលាការត្រូវបានអនុវត្តដោយតុលាការឯករាជ្យ វិនិច្ឆ័យដោយផ្អែកលើមូលដ្ឋាននៃច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ដែលមានស្រាប់និង កិច្ចព្រមព្រៀងអន្តរជាតិ ដែលបានផ្តល់សច្ចាប័នដោយព្រះរាជាណាចក្រ ។ ប្រព័ន្ធតុលាការកម្ពុជារួមមានតុលាការថ្នាក់ទាបដែលក្នុងនោះ មានតុលាការខេត្ត-ក្រុង និង តុលាការយោធា តុលាការឧទ្ធរណ៍ និង តុលាការកំពូល។ ទោះបីជាយ៉ាងណាក៏ដោយតុលាការកំពូល ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញខែកញ្ញា ឆ្នាំ១៩៩៣ មិនបានត្រូវបង្កើតឡើងទេ។ ហេតុនេះ សេចក្តីសំរេចចិត្តរបស់តុលាការឧទ្ធរណ៍ អាចត្រូវតវ៉ាឡើងទៅតុលាការកំពូល ដែលបានបង្កើតឡើងដោយអតីតរដ្ឋកម្ពុជា។ តាមរយៈ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ តុលាការ

កំពូលនឹងទទួលខុសត្រូវចំពោះការពិនិត្យដោយប្រិតប្រៀងនៃច្បាប់ និង បណ្តឹងតវ៉ានៃការសំរេចទាំងឡាយ ដែលបានកាត់សេចក្តីដោយតុលាការឧទ្ធរណ៍។

៣២. ប្រព័ន្ធតុលាការបច្ចុប្បន្នរបស់កម្ពុជា គ្មានតុលាការឯកទេស ដូចជាតុលាការរដ្ឋបាល ឬតុលាការពាណិជ្ជកម្មទេ។ បច្ចុប្បន្ននេះ សេចក្តីសំរេចរដ្ឋបាលនានា អាចប្តឹងតវ៉ាទៅអជ្ញាធរថ្នាក់ខ្ពស់នៃក្រសួងស្ថាប័នពាក់ព័ន្ធ ដូចជាទៅរដ្ឋមន្ត្រីជាដើម។ វិធានបែបនេះផ្ទុយទៅវិញអាចប្តឹងឧទ្ធរណ៍ ទៅតុលាការ ឬទៅនាយករដ្ឋមន្ត្រី។ កម្ពុជាបានទទួលស្គាល់ពីតំរូវការដើម្បីបង្កើតដំណើរការ ខាងឧទ្ធរណ៍មួយរួមទាំងខាងរដ្ឋបាល និងខាងសាលាក្តីឯករាជ្យ ដើម្បីបំពេញតំរូវការនៃមាត្រា១០ របស់ GATT ឆ្នាំ១៩៩៤ និងតំរូវការដទៃទៀត ដូចជាកិច្ចសន្យានៅក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដូចជាការកំណត់តំលៃពន្ធគយ និងនីតិវិធីដទៃទៀត សំណងពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចូល និងកូតា។ ទាក់ទងទៅនឹងបញ្ហានេះ, ជំពូក III នៃពង្រាងច្បាប់ស្តីពីអង្គការតុលាការបានបញ្ជាក់អំពីសិទ្ធិសុំតវ៉ាចំពោះសេចក្តីសំរេចខាងរដ្ឋបាលនៅចំពោះមុខក្រុមប្រឹក្សារដ្ឋបាលនៃតុលាការឧទ្ធរណ៍ ។ បន្ទាប់មកសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋបាលនេះអាចត្រូវបានតវ៉ាចំពោះមុខតុលាការកំពូល។ ពង្រាងច្បាប់ស្តីពីអង្គការតុលាការត្រូវបានពិនិត្យដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅខែមិថុនា ឆ្នាំ២០០៣ ហើយបន្ទាប់មកនឹងបញ្ជូនទៅរដ្ឋសភា។

៣៣. ចំពោះវិវាទពាណិជ្ជកម្មក្រសួងយុត្តិធម៌ និងក្រសួងពាណិជ្ជកម្មបានរៀបចំពង្រាងច្បាប់មួយ ដែលបង្កើតអោយមានសាលាក្តីពាណិជ្ជកម្ម។ នៅក្នុងដំណាក់កាលបណ្តោះអាសន្នរាល់រឿងក្តីពាណិជ្ជកម្មត្រូវប្តឹងជាដំបូងទៅតុលាការខេត្ត ក្រុង ។ ដំណោះស្រាយវិវាទពាណិជ្ជកម្មតាមការស្ម័គ្រចិត្តបានធ្វើឡើងតាមរយៈសមត្ថកិច្ចរបស់សភាពាណិជ្ជកម្ម ដែលត្រូវអនុញ្ញាតិអោយដើរតួជាអាជ្ញាកណ្តាល នៅក្រោមមាត្រា៩ នៃច្បាប់សភាពាណិជ្ជកម្មឆ្នាំ១៩៩៥។ កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញា ទីក្រុងញូយ៉កស្តីពីការអនុវត្តន៍នៃការវិនិច្ឆ័យរបស់អាជ្ញាកណ្តាលអន្តរជាតិនាថ្ងៃទី ៥ ខែមករា ឆ្នាំ១៩៦០។ ក្រសួងពាណិជ្ជកម្មបានរៀបចំច្បាប់ស្តីអំពីអាជ្ញាកណ្តាលពាណិជ្ជកម្ម ដើម្បីអនុវត្តសន្ធិសញ្ញាក្រុងញូយ៉ក។

៣៤. សមាជិកគណៈប្រតិភូ១រូបបានកត់សំគាល់ថា រឿងក្តីពាណិជ្ជកម្មទាំងអស់ត្រូវបានគេកាត់ក្តីនៅក្នុងតុលាការធម្មតា, ដោយរង់ចាំការបង្កើតអោយមានប្រព័ន្ធតុលាការពាណិជ្ជកម្មមួយ។ ទស្សនៈរបស់លោកបានបង្ហាញថា ប្រព័ន្ធតុលាការបច្ចុប្បន្នមិនបានផ្តល់ការការពារតាមច្បាប់គ្រប់គ្រាន់ដល់ការធ្វើអាជីវកម្មទេ។ សមាជិករូបនេះបានចាត់ទុកថា ការបង្កើតប្រព័ន្ធតុលាការពាណិជ្ជកម្មមួយដោយមានបុគ្គលិក និងចៅក្រមដែលមានការបណ្តុះបណ្តាលត្រឹមត្រូវគឺជាការចាំបាច់ ដើម្បីបង្កើតអោយមានបរិយាកាសនៃតំលាភាពនិងអាចព្យាករណ៍បាន ដូច្នេះប្រព័ន្ធតុលាការពាណិជ្ជកម្ម ឬប្រព័ន្ធតុលាការដែលមានតួនាទី ដូចគ្នានេះចាំបាច់ត្រូវបង្កើតអោយមាននៅពេលដែលកម្ពុជាត្រូវប្រកាសអោយចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ សមាជិករូបនេះក៏បានកត់សំគាល់ផងដែរថា កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាក្រុងញូយ៉ក ស្តីពីការអនុវត្តន៍សាលក្រម

អាជ្ញាកណ្តាលអន្តរជាតិ. ហើយបានសួរថាអ្វីទៅជាសកម្មភាពនីតិបញ្ញត្តិដែលក្រសួងពាណិជ្ជកម្មបានទទួលយកដើម្បីអនុវត្តសន្ធិសញ្ញានេះ ។

៣៥. តំណាងប្រតិភូកម្ពុជាបានជំរាបថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុម័តច្បាប់ ដើម្បីផ្តល់សច្ចាប័នសន្ធិសញ្ញាទីក្រុងញូយ៉កស្តីអំពីការអនុវត្តន៍សេចក្តីសំរេចរបស់អាជ្ញាកណ្តាលអន្តរជាតិនៅឆ្នាំ២០០២។ លោកបានបន្ថែមដូចមានបញ្ជាក់ជូនក្នុងឯកសារ WT/ACC/KHM/10/ Rev. 2 ក្រសួងពាណិជ្ជកម្មកំពុង ធ្វើសេចក្តីព្រាងច្បាប់ស្តីអំពីការបង្កើតតុលាការពាណិជ្ជកម្មដើម្បីអនុវត្តសន្ធិសញ្ញា។ សេចក្តីព្រាងច្បាប់ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅ ខែមិនា ឆ្នាំ២០០៣ និងកំពុងត្រូវបានពិចារណាដោយសភាជាតិ។ គាត់បានរំពឹងថា ដំណើរការនៃការអនុម័តនិងការប្រកាសឱ្យប្រើច្បាប់ត្រូវបញ្ចប់សព្វគ្រប់នៅ ខែ មិថុនា ឆ្នាំ ២០០៤ គាត់បានកត់សំគាល់ថាកម្ពុជាបានទទួលជំនួយបច្ចេកទេសខ្លះៗក្នុងវិស័យនេះ ហើយកម្ពុជាកំពុងតែស្វែងរកជំនួយបច្ចេកទេសដែលគួរអោយទុកចិត្តផ្សេងៗថែមទៀត។ គាត់បានបន្ថែមទៀតថា ប្រព័ន្ធតុលាការពាណិជ្ជកម្មដែលមានចៅក្រមដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដែលជាការចាំបាច់ក្នុងការបង្កើតអោយមានបរិយាកាស ដែលមានតំលាភាពនិងអាចទស្សទាយបាន ឬក៏ប្រព័ន្ធដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះត្រូវតែបង្កើតអោយមាននៅចុងឆ្នាំ ២០០៤។

៣៦. តំណាងប្រតិភូកម្ពុជាបញ្ជាក់ថា ប្រព័ន្ធតុលាការឧទ្ធរណ៍ ទាក់ទងទៅនឹងសេក្តីសំរេចរដ្ឋបាលលើវិស័យនានាដែលស្ថិតក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកត្រូវតែជាស្ថាប័នកាត់ក្តីឯករាជ្យ ដែលមានចែងនៅក្នុងមាត្រាទី១០ នៃកិច្ចព្រមព្រៀង GATT និងកិច្ចព្រមព្រៀងនានានៃអង្គការពាណិជ្ជកម្មពិភពលោកហើយកំពុងត្រូវស្ថិតនៅក្នុងការរៀបចំបង្កើតតាមរយៈសេចក្តីព្រាងច្បាប់ស្តីអំពីអង្គការតុលាការ ហើយអង្គការនេះនឹងត្រូវដំណើរការនៅខែធ្នូ ឆ្នាំ ២០០៤។ ដូចគ្នានេះដែរប្រព័ន្ធតុលាការនឹងត្រូវបង្កើតឱ្យមាននៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៥ ។ ក្រុមការងារកត់សំគាល់នូវកិច្ចសន្យានេះ។

៣៧. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា គណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល គឺជាសាខាប្រតិបត្តិរបស់ព្រះរាជាណាចក្រកម្ពុជា។ គណៈរដ្ឋមន្ត្រីទទួលខុសត្រូវចំពោះសភាជាតិហើយត្រូវបានដឹកនាំដោយ នាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីទទួលខុសត្រូវលើការអនុវត្តន៍ការធ្វើសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីត្រូវរៀបចំអនុកិត្យ ដើម្បីថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខា ហើយចេញអនុក្រឹត្យក្រោមអំណាចផ្ទាល់ខ្លួនដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី។ រដ្ឋមន្ត្រី និមួយៗចេញប្រកាសរបស់ក្រសួង សេចក្តីសំរេចនិងសារាចរ។ នៅពេលដែលបានចុះហត្ថលេខារួចរាល់សេចក្តីសំរេចទាំងអស់ត្រូវបោះពុម្ពផ្សាយនៅក្នុងសារពត៌មានផ្លូវការរបស់រដ្ឋ។

៣៨. គោលនយោបាយដែលទាក់ទងនឹងពាណិជ្ជកម្មក្រៅប្រទេសត្រូវបង្កើត និងអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ធនាគារជាតិនៃកម្ពុជា ក្រសួងផែនការ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ការពិនិត្យតាមព្រំដែនលើការធ្វើពាណិជ្ជកម្មអន្តរជាតិ គឺជាសមត្ថកិច្ចរបស់ទីចាត់ការគយ និងរដ្ឋាករ ដែលមានភារៈប្រមូលពន្ធ និងរៀបចំតារាងពន្ធគយ។ ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីគ្រប់សកម្មភាពពាណិជ្ជកម្មបរទេសទាំងអស់។ ក្រសួងពាណិជ្ជកម្មក៏រួមចំណែកក្នុងការត្រួតពិនិត្យទំនិញតាមព្រំដែន បង្ក្រាបការក្លែងបន្លំ បង្កើតនិងអនុវត្តបទដ្ឋានបច្ចេកទេស និងក្នុងការអភិវឌ្ឍន៍គោលនយោបាយដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអនុវត្តបញ្ញត្តិវិនិយោគទុន និងរាល់បញ្ហាដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍បច្ចេកវិទ្យា និង ឧស្សាហកម្ម ការរុករកធនធានធម្មជាតិ និងផលិតកម្ម និងការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹកសំរាប់បរិភោគ ដែលជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ លោកបានបញ្ជាក់ថា អាជ្ញាធរខេត្ត-ក្រុងពុំមានយុត្តាធិការលើគោលនយោបាយដែលជះឥទ្ធិពលលើពាណិជ្ជកម្មក្រៅប្រទេស ដូចជានៅក្នុងការឧបត្ថម្ភទុន ការធ្វើវិនិយោគទុនការប្រមូលពន្ធ បន្ទុកលើទំនិញនាំចូលដែលមិនអនុវត្តចំពោះទំនិញក្នុងស្រុក ឬការដាក់កំហិតជាបរិមាណលើការនាំចូល ឬនាំចេញ។ កម្ពុជាបានបញ្ជាក់ថា អាជ្ញាធរមូលដ្ឋាន នឹងមិនមាន អំណាចដូចគ្នានេះនៅក្នុងតំបន់កែច្នៃនាំចេញនៅក្នុងក្របខ័ណ្ឌ យុត្តាធិការរបស់ពួកគេឡើយ។

៣៩. ក្រសួងពាណិជ្ជកម្មបានដើរតួជាចំណុចប្រសព្វ (Focal point) លើសកម្មភាពដែលទាក់ទងនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ការិយាល័យអង្គការពាណិជ្ជកម្មពិភពលោករបស់ក្រសួងមានមន្ត្រីជំនាញចំនួន ១០រូប រួមទាំងគណៈកម្មាធិការសំរបសំរួលអន្តរក្រសួងស្តីពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក៏ត្រូវបានបង្កើតឡើងក្នុង ខែកញ្ញា ឆ្នាំ១៩៩៧។ តួនាទីរបស់គណៈកម្មាធិការ ដែលរួមមានសមាជិកថ្នាក់នយោបាយ ១៩រូប និង៣រូប ជាមន្ត្រីជំនាញមកពីក្រសួង និង ភ្នាក់ងារដែលពាក់ព័ន្ធទាំង២៣នេះគឺ (១) សំរួលបញ្ហានយោបាយ ដែលពាក់ព័ន្ធទៅនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (២) ណែនាំដល់ការអនុវត្ត កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកអោយបានល្អិតល្អន់ (៣) រៀបចំឯកសារចាំបាច់ (៤) កំណត់ពីវិស័យអាទិភាពរបស់រដ្ឋាភិបាលដែលទាក់ទងទៅនឹងគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស (៥) ធានាឱ្យមានការសំរបសំរួលជាមួយក្រសួងផ្សេងៗ (៦) រាយការណ៍ជូននាយករដ្ឋមន្ត្រី អំពីបញ្ហាដែលទាក់ទងនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ នៅខែសីហា ឆ្នាំ២០០១ រដ្ឋាភិបាលកម្ពុជាបានចាត់តាំងក្រុមការងារមួយដែលរួមមានឧត្តមមន្ត្រីរដ្ឋាភិបាលជាង១១០រូប ដើម្បីជួយជ្រោមជ្រែងនៅក្នុងបញ្ហាដែលទាក់ទងទៅនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជានេះ។

៤០. អនុសញ្ញាអន្តរជាតិ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចបច្ចេកទេស វប្បធម៌ និងការពារជាតិត្រូវចរចារថ្នាក់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានការឯកភាពពីសភាជាតិ ការផ្តល់សច្ចាប័ន និងប្រកាសអោយប្រើដោយព្រះមហាក្សត្រ។ ទាក់ទងទៅនឹងដំណើរការផ្តល់សច្ចាប័ន

លើពិធីសារនៃការចូលជាសមាជិករបស់កម្ពុជា កញ្ចប់ឯកសារមួយដែលក្នុងនោះរួមមានពិធីសារ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងឯកសារច្បាប់ទាំងអស់ត្រូវដាក់ជូនសភាជាតិ និងព្រឹទ្ធសភាដោយរាជរដ្ឋាភិបាលដើម្បីធ្វើការអនុម័ត។ បន្ទាប់មកកញ្ចប់នេះ នឹងត្រូវដាក់ថ្វាយព្រះមហាក្សត្រដើម្បីប្រកាសអោយប្រើរួចទើបបោះផ្សាយនៅក្នុងសារពត៌មានផ្លូវការ។ លោកបានបញ្ជាក់ថា ប្រការចែងទាំងឡាយរបស់កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក នឹងលុបលើនិតិបញ្ញត្តិជាតិលើកលែងតែរដ្ឋធម្មនុញ្ញរបស់កម្ពុជាក្នុងករណីដែលមាន វិវាទរវាងច្បាប់ក្នុងស្រុក និង កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ។

៤១. តំណាងប្រតិភូកម្ពុជាបានបន្ថែមទៀតថា ការធ្វើអោយស្របទៅនឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកបានតំរូវអោយមានការរៀបចំលើបទបញ្ញត្តិសំខាន់ៗជាច្រើននៅកម្ពុជា។ លោកបានផ្តល់កម្មវិធីសំរាប់ការអនុម័តច្បាប់ ដើម្បីធ្វើអោយស្របទៅនឹងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលមានចែងក្នុងឯកសារ WT/ACC/KHM/10 ដែលត្រូវបន្តការរៀបចំឡើងវិញ និង កែប្រែលើមូលដ្ឋានជាក់លាក់មួយ (សូមមើលក្នុងកំណែប្រែទី១ នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០២ លើកទី២ នៅថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៣ និងលើកទី៣ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣។) ដោយហេតុនេះ ប្រទេសជាសមាជិកមួយបារម្ភ អំពីពេលវេលាសំរាប់ការអនុម័តក្រមនីតិវិធីស៊ីវិល ដែលធានាដល់ប្រសិទ្ធិភាពនៃការប្រតិបត្តិច្បាប់ដទៃទៀត។ តំណាងប្រតិភូកម្ពុជាបានឆ្លើយតបថា ពង្រាងក្រមនីតិវិធីស៊ីវិលនឹងត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីនាពេលអនាគតដ៏ខ្លីខាងមុខនេះ។ កម្មវិធីដើម្បីអនុម័តច្បាប់សំរាប់ភាពស្របគ្នាទៅនឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្ម ពិភពលោកចុងក្រោយមានចែងនៅក្នុងឧបសម្ព័ន្ធ ១ ។

## គោលនយោបាយដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មទំនិញ

**<u>សិទ្ធិធ្វើពាណិជ្ជកម្ម ( សិទ្ធិធ្វើពាណិជ្ជកម្មនាំចូល និងពាណិជ្ជកម្មនាំចេញ</u>)**

៤២. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មចុះថ្ងៃ ទី០៣ ខែឧសភា ឆ្នាំ១៩៩៥ ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ តំរូវអោយសហគ្រាសពាណិជ្ជកម្មដែលកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជា ទាំងអស់ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ "សារាចរណែនាំស្តីពីការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងសេចក្តីប្រកាសស្តីពីការចុះបញ្ជីពាណិជ្ជកម្ម" ដែលឯកសារទាំងពីរនេះចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩៧ មានចែងនៅក្នុងឯកសារ WT/ACC/ KHM/2, ឧបសម្ព័ន្ធ ៧ (ខ) ។

៤៣. សហគ្រាសពាណិជ្ជកម្មអាចចុះបញ្ជីក្នុងទំរង់ជាក្រុមហ៊ុនឯកកម្មសិទ្ធិ ក្រុមហ៊ុនរួមទុនទូទៅ ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត ក្រុមហ៊ុនទទួលខុសត្រូវដែលមានសមាជិកភាគហ៊ុនតែម្នាក់ ក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកំរិត ស្ថាប័នសាធារណៈ សហគ្រាសរដ្ឋ ឬក្រុមហ៊ុន

សហាកម្មសិទ្ធិ ។ រូបវ័ន្តបុគ្គលមិនអាចធ្វើសកម្មភាពនាំចូលទំនិញ ដូចដែលច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្មបានអនុញ្ញាតិចំពោះនិតិបុគ្គល និង អង្គភាពចុះបញ្ជីតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយបុគ្គលម្នាក់អាចចុះបញ្ជី ឧទាហរណ៍ជាក្រុមហ៊ុនឯកកម្មសិទ្ធិ ដែលមានការទទួលខុសត្រូវមានកំរិត។

៤៤. ការហាមឃាត់ក្រុមហ៊ុន ដែលមានភាគហ៊ុនតិចជាង ៥១ ភាគរយ ជាកម្មសិទ្ធរបស់កម្ពុជាក្នុងការធ្វើសកម្មភាពនាំចូល/នាំចេញទំនិញក្នុងគោលបំណងតែមួយ នៃទំនិញលក់បន្តដោយគ្មានការកែច្នៃត្រូវបានលុបចោលស្របតាមប្រកាសរបស់ក្រសួងពាណិជ្ជកម្មចុះថ្ងៃ ទី២៥ ខែមករា ឆ្នាំ២០០០។ លោកបានបញ្ជាក់ថាគ្រប់ក្រុមហ៊ុនទាំងអស់ (ទាំងក្រុមហ៊ុនបរទេស និងក្នុងស្រុក) ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងពាណិជ្ជកម្មអាចធ្វើសកម្មភាពនាំចូលនិងនាំចេញទំនិញគ្រប់ប្រភេទ លើកលែងតែសំភារៈយោធា និងថ្នាំញៀន។ ការធ្វើពាណិជ្ជកម្មលើផលិតផលព្រៃឈើ អាចអនុញ្ញាតិចំពោះអ្នកទទួលអជ្ញាប័ណ្ណពាណិជ្ជកម្មសម្បទាន (ក្នុងស្រុក និងបរទេស) យោងតាមមាត្រា ៤ ជំពូក២ នៃអនុក្រឹត្យ លេខ ០៥ ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០០។ ក្រុមហ៊ុនមួយអាចធ្វើវិសោធនកម្មលើការចុះបញ្ជីរបស់ខ្លួន ដើម្បីបញ្ចូលសកម្មភាពនាំចូល និងនាំចេញដោយបំពេញពាក្យសុំមួយដើម្បីធ្វើវិសោធនកម្មលក្ខន្តិកៈក្រុមហ៊ុន ។ ការចុះបញ្ជីដែលបានធ្វើវិសោធនកម្មរួចនឹងតំកល់ទុកនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួង។

៤៥. ការចុះបញ្ជីពាណិជ្ជកម្មតំរូវអោយមានបុគ្គលិកក្រុមហ៊ុនមួយរូបបង្ហាញខ្លួន ហើយដាក់ឯកសារទាំងឡាយដែលត្រូវការរួមទាំងពាក្យសុំចុះបញ្ជីដែលបានបំពេញសព្វគ្រប់មួយច្បាប់ លក្ខន្តិកៈ និងមាត្រាផ្សេងៗរបស់ក្រុមហ៊ុន សេចក្តីប្រកាសរួម កម្មសិទ្ធិអចលនទ្រព្យ ឬសន្យាជួល ព្រមទាំងឯកសារថតចំលងបញ្ជាក់ពី អត្តសញ្ញាណប័ណ្ណ និង រូបថតរបស់ប្រធានក្រុមហ៊ុន និងម្ចាស់ភាគហ៊ុនមួយចំនួនជូនក្រសួងពាណិជ្ជកម្ម។ ពាក្យសុំ ដែលគ្មានឯកសារគ្រប់គ្រាន់ត្រូវបដិសេធចោល។ និតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មត្រូវការពេលវេលា២សប្តាហ៍។ តំលៃដែលត្រូវបង់ចំពោះការចុះបញ្ជីពាណិជ្ជកម្មគឺ ២៦០.០០០រៀល (ប្រហែល ៧០ដុល្លាអាមេរិក) សំរាប់ក្រុមហ៊ុនជាតិ និងក្រុមហ៊ុនបរទេស ។ លើសពីនេះទៀត បណ្តាក្រុមហ៊ុនដែលកំពុងវិនិយោគនៅក្នុងប្រទេសកម្ពុជា ហើយដាក់ពាក្យសុំការឯកភាពលើគំរោងវិនិយោគដើម្បីបានទទួលការលើកទឹកចិត្តតំរូវអោយបង់ថ្លៃចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍នៃកម្ពុជា (CDC) ដោយអនុលោមតាមច្បាប់វិនិយោគទុន ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤។ ថ្លៃចុះបញ្ជីនេះមានចំនួន ៦០០ដុល្លា អាមេរិកលើគំរោងអភិវឌ្ឍន៍ ដែលមានទុន១លានដុល្លាអាមេរិក និង តំលៃ១.២០០ដុល្លាអាមេរិកលើគំរោងវិនិយោគដែលមានទឹកប្រាក់លើសពី ១លានដុល្លាអាមេរិក។

៤៦. ប្រទេសជាសមាជិកខ្លះបារម្ភថា ការតំរូវអោយផ្តល់រូបថតនាយក និងម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនទទួលខុសត្រូវមានកំរិតនឹងធ្វើអោយស្មុគ្រស្មាញដល់ក្រុមហ៊ុនធំៗ ដែលមានម្ចាស់ភាគហ៊ុនច្រើននាក់ដូចជា

ក្រុមហ៊ុនបរទេស ដែលមានបំណងចង់បង្កើតការរកស៊ីក្នុងប្រទេសកម្ពុជា ។ ជាការឆ្លើយតបតំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា តំរូវការដូចគ្នានេះក៏បានអនុវត្តទៅលើក្រុមហ៊ុនក្នុងស្រុក និងបរទេសដែលរកស៊ីនៅក្នុងប្រទេសកម្ពុជា។ អាស្រ័យលើបទបញ្ញត្តិរបស់កម្ពុជា ក្រុមហ៊ុនទទួលខុសត្រូវមានកំរិតមិនត្រូវអនុញ្ញាតិអោយមានម្ចាស់ហ៊ុនជាងឯកត្តបុគ្គលលើសពី ៣០រូបឡើយ។ ក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកំរិតតំរូវអោយបញ្ជូនតែរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាលប៉ុណ្ណោះ។ តំរូវការរូបថតនេះ គឺក្នុងគោលបំណងរក្សាសុវត្ថិភាព ដែលជាគោលការណ៍គឺដើម្បីជៀសវាងការឆបោក ។ តំណាងប្រតិភូកម្ពុជាមិនជឿថា តំរូវការនេះបង្កើតជាឧបសគ្គដល់ការចុះបញ្ជីក្រុមហ៊ុន នៅក្នុងប្រទេសកម្ពុជាទេ។

៤៧. គួរកត់សំគាល់ថា ការនាំចូលឱសថអនុញ្ញាតិអោយធ្វើបានតែចំពោះ ឱសថការី ហើយការនាំចូលនៃវត្ថុធាតុដើមសំរាប់កសិកម្មអាចអនុញ្ញាតិអោយបានតែចំពោះអ្នកឯកទេសកសិកម្ម (សូមមើលផ្នែកការដាក់កំហិតលើបរិមាណនាំចូលរួមទាំងការហាមឃាត់ កូតា និងប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ខាងក្រោម)។ ប្រទេសជាសមាជិកមួយបានសួរថា តើកម្ពុជាបានចែកដាច់គ្នារវាងសិទ្ធិនៃការនាំចូល និងសិទ្ធិចែកចាយផលិតផលនេះនៅក្នុងស្រុកឬទេ។ ប្រទេសជាសមាជិកនេះបានគិតថា ការទទួលស្គាល់នូវសិទ្ធិនាំចូលពោលគឺដើម្បីអោយក្លាយជាអ្នកនាំចូលពិតប្រាកដ ដែលករណីបានបង្ហាញពីភាពខុសគ្នារវាងអ្នកនាំចូល និងអ្នកចែកចាយទំនិញ ។ ប្រទេសនេះបានស្វាគមន៍កម្ពុជាក្នុងការធ្វើអោយមានភាពងាយស្រួលចំពោះតំរូវការនៃការនាំចូល។ ប្រទេសនេះយល់ឃើញថាលក្ខណៈតំរូវតឹងតែងមួយ គួរតែសំរាប់អ្នកចែកចាយនៅក្នុងទីផ្សារកម្ពុជា។

៤៨. តំណាងប្រតិភូកម្ពុជាបានគូសបញ្ជាក់ថា ក្នុងចំណោមវត្ថុធាតុដើមកសិកម្មនាំចូលមានតែថ្នាំព្យាបាលសត្វប៉ុណ្ណោះ ដែលត្រូវបំរុងសំរាប់អ្នកបច្ចេកទេសកសិកម្ម។ លោកបានបន្ថែមទៀតថា ក្នុងការអនុវត្តន៍អ្នកនាំចូលវត្ថុធាតុដើមកសិកម្ម និងឱសថក៏ជាអ្នកចែកចាយទំនិញទាំងនេះនៅក្នុងទូទាំងប្រទេសផងដែរ ។ វាជាការលំបាកក្នុងការញែកអោយដាច់ពីគ្នារវាងមុខងារនៃការនាំចូល និងការចែកចាយទំនិញណាស់នៅក្នុងប្រទេសមួយដូចជាកម្ពុជា។

៤៩. ផ្អែកលើពតិមានខាងលើប្រទេសជាសមាជិកនេះសន្និដ្ឋានថា កម្ពុជាបានដាក់កំរិតតឹងតែងលើការនាំចូលផលិតផលឱសថ និងឱសថសំរាប់ព្យាបាលសត្វ ដែលមិនបានអនុវត្តចំពោះការផលិតផលិតផល ដូចគ្នានេះនៅក្នុងស្រុកទេ។ ដូច្នេះកម្ពុជាត្រូវបានស្នើសុំអោយធ្វើវិសោធនកម្មលើបញ្ញត្តិច្បាប់របស់ខ្លួន ដើម្បីបង្ហាញអោយឃើញច្បាស់ នូវភាពខុសគ្នារវាងសិទ្ធិនៃការធ្វើការនាំចូលនិងសិទ្ធិនៃការចែកចាយទំនិញ ។ ការតំរូវអោយមានការចុះបញ្ជីនិងលក្ខណៈបច្ចេកទេសដទៃទៀត ដែលកំពុងអនុវត្តចំពោះអ្នកនាំចូលត្រូវតែអនុវត្តដូចគ្នាចំពោះអ្នកចែកចាយ ។ កម្ពុជាត្រូវធានាថា លក្ខណៈតំរូវបែបនេះត្រូវអនុវត្តក្នុងលក្ខណៈស្មើភាព និងដូចគ្នារវាងផលិតផលនាំចូល និងផលិតផលផលិតក្នុងស្រុក។

៥០. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា វាមិនមែនជាចេតនារបស់រដ្ឋាភិបាលទេ ដែលលក្ខណៈតំរូវបច្ចុប្បន្ន សំរាប់ការនាំចូលផលិតផលឱសថ ឬឱសថព្យាបាលសត្វបង្កើតអោយមានចំពោះការនាំចូលនោះ។ ចំពោះបញ្ហានេះ លោកបានបញ្ជាក់បន្តថា កម្ពុជានឹងធ្វើវិសោធនកម្មនិតិបញ្ញត្តិរបស់ខ្លួន ដូចជាច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងប្រកាសលេខ ៨២ ចុះថ្ងៃ ៣១ ខែមិនា ឆ្នាំ១៩៩៩ ស្តីពី "និតិវិធី សំរាប់ការនាំចេញ និងការនាំចូលផលិតផលឱសថ" មិនអោយហួសថ្ងៃ ទី០១ ខែមិថុនា ឆ្នាំ២០០៥។ ដូច្នេះគឺវានឹងមិនបន្ថយសិទ្ធិនាំចូលនិងនាំចេញទេ ហើយក្រុមហ៊ុនដែលបានចុះបញ្ជីនិមួយៗអាចនៅតែជាអ្នកនាំចូល ឬអ្នកនាំចេញពេញលក្ខណៈដដែល។ លោកបានបញ្ជាក់ថា ចាប់ពីថ្ងៃនោះទៅកម្ពុជានឹងធានាថា ច្បាប់ និងបទបញ្ជាទាំងអស់របស់ខ្លួន ដែលទាក់ទងទៅនឹងសិទ្ធិធ្វើពាណិជ្ជកម្មខាងទំនិញ និងបន្ទុក ឬ ការបូតពន្ធទាំងអស់លើសិទ្ធិនេះ នឹងត្រូវអនុលោមតាមទាំងស្រុងជាមួយកាតព្វកិច្ចអង្គការពាណិជ្ជកម្មពិភពលោក ដែលរួមមានមាត្រា ៨:១(ក)/ មាត្រា ៩:១ និង មាត្រាទី ២ និង ទី៤ នៃច្បាប់ GATT ឆ្នាំ១៩៩៤ ហើយច្បាប់ និងបទបញ្ញត្តិទាំងនោះត្រូវអនុវត្តដោយស្របតាមកាតព្វកិច្ចទាំងនេះ។ លោកបានបញ្ជាក់ដោយឡែកទៀតថា ការណ៍នេះនឹងមិនប៉ះពាល់ដល់លក្ខណៈតំរូវដែលអ្នកចែកចាយក្នុងស្រុក និងផលិតផលនាំចូលសំរាប់ការងារផលិតកម្ម ផលិតផលនាំចូលសំរាប់ការពារសុខភាពអាយុជីវិត និងសុវត្ថិភាពមនុស្សសត្វត្រូវអនុវត្តទេ។ ក្រុមការងារបានកត់ត្រាលើការសន្យាទាំងអស់នេះ។

## ១. បញ្ញត្តិនៃការនាំចូល

**__ពន្ធគយ__**

៥១. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ទីចាត់ការគយ និងរដ្ឋាករបានដាក់ចេញនូវកម្មវិធីកំណែទំរង់ និងទំនើបភាវូបនីយកម្មពន្ធគយមួយសំដៅបង្កើតអភិបាលកិច្ចពន្ធគយដែលទំនើបមួយ ដោយរួមទាំងការប្រមូលចំណូលអោយបានពេញលេញ និងសំរួលការការពារតាមតំរូវការរបស់វិស័យឯកជននៅតាមព្រំដែនអោយបានទាន់ពេលវេលា ដើម្បីធ្វើអោយជឿទុកចិត្តចំពោះសេវាកម្មគយ។ សមាសធាតុចំបងៗ នៃកម្មវិធីកំណែទំរង់រួមមានការពង្រឹងក្របខ័ណ្ឌច្បាប់ កំណែប្រែរចនាសម្ព័ន្ធពន្ធគយ ទំនើបភាវូបនីយកម្ម និងការសំរបសំរួលនីតិវិធីគយ ការពង្រីកទំនាក់ទំនងអន្តរជាតិ ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព ប្រព័ន្ធ និង និតិវិធីស្វ័យប្រវត្តិ ការចាត់វិធានការពង្រឹងទីចាត់ការគយ និងរដ្ឋាករ ការធ្វើអោយប្រសើរឡើងនូវសេវាកម្មសាធារណៈ និងជួយសំរួលដល់ការធ្វើពាណិជ្ជកម្ម។ ការសង្ខេបពីយុទ្ធសាស្ត្រកំណែទំរង់មាននៅក្នុងឯកសារ WT/ACC/KHM/6, ឧបសម្ព័ន្ធ ៤។

៥២. ច្បាប់ស្តីពីពន្ធនាំចូល និងពន្ធនាំចេញ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៨៩ បានកែតំរូវជាបន្តបន្ទាប់ដោយសេចក្តីសំរេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ចេញនូវមូលដ្ឋានច្បាប់សំរាប់ការដាក់អាករលើពន្ធគយ។ ពន្ធគយរបស់កម្ពុជាអនុវត្តតាមប្រព័ន្ធលេខកូដចំនួនលេខ ៨ខ្ទង់។ បញ្ជីឈ្មោះទំនិញរួមមាន៦,៨២៣មុខ

នៅឆ្នាំ២០០១ ដែលបានបន្ថែមបញ្ជីទំនិញនៅឆ្នាំ១៩៩៦ ដែលអនុវត្តតាមប្រព័ន្ធលេខកូដ ដែលមានតែ៦ខ្ទង់។ អត្រាពន្ធទាំងអស់គឺកំណត់តាមតំលៃបន្ថែម (ad valorem)។ បច្ចុប្បន្នមានតែអត្រាពន្ធតាមគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលការអនុគ្រោះប៉ុណ្ណោះដែលអនុវត្តលើកលែងតែផលិតផល នៅក្នុងបញ្ជីអនុគ្រោះពន្ធគយរួម (CEPT) នៅក្នុង ASEAN ។ ដោយកម្ពុជាជាសមាជិកអាស៊ានកម្ពុជា បានសន្យាពន្យារការអនុគ្រោះពន្ធគយ ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងអាស៊ាន ស្តីពីមូលដ្ឋានបដិការ ។

៩៣. ក្នុងការកែទំរង់រចនាសម្ព័ន្ធពន្ធគយរបស់ខ្លួន កម្ពុជាបានកាត់បន្ថយចំនួនប្រភេទពន្ធគយចង ពី ១២ប្រភេទ ទៅ ៤ប្រភេទ។ បច្ចុប្បន្ន ប្រភេទពន្ធគយកំពុងអនុវត្តរួមមាន : ០ភាគរយ ៧ភាគរយ ១៥ភាគរយ និង៣៥ ភាគរយ។ អត្រាពន្ធដែលខ្ពស់បំផុត ៤០ ៥០ ៩០ និង ១២០ ភាគរយ បានត្រូវលុបចោល។ មុខទំនិញដែលជាប់ពន្ធលើអត្រាអតិបរមា ៣៥ភាគរយមានក្នុងឯកសារ WT/ACC/KHM/6 ឧបសម្ព័ន្ធ ៣។ អត្រាពន្ធគយមធ្យមមាន ប្រហែល ១៦.៤ភាគរយ នៅឆ្នាំ២០០១។ គោលដៅនៃការកែទំរង់ គឺធ្វើយ៉ាងណាអោយអត្រានេះថយដល់កំរិតទាបជាង១៥ភាគរយ នៅឆ្នាំ២០០៣ និង២០០៤។ នៅពេលដែលកម្ពុជា កំពុងកាត់បន្ថយពន្ធនាំចូលរបស់ខ្លួន អាករផ្សេងៗទៀតត្រូវបានបង្កើនឡើងដើម្បីធានា ថាការកែទំរង់ពន្ធដារនឹងនៅតែធ្វើអោយចំណូលថវិកាជាតិមានលំនឹង។

**<u>ពន្ធគយ និងបន្ទុកផ្សេងទៀត</u>**

៩៤. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ក្រៅពីពន្ធគយធម្មតា កម្ពុជាបានលើកលែងមិនយកពន្ធ ឬ បន្ទុកផ្សេងៗលើរាល់ប្រភេទទំនិញ ដែលបានកំណត់នៅក្នុង មាត្រា ២ :១(ខ) នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ចំពោះការនាំចូល លើកលែងតែ ប្រេងសាំង និងប្រេងម៉ាស៊ូត (HS: 27100021, 27100022, 27100023, 27100024, 27100025, 27100026, 27100071, 27100072, 27100079)។ ចំពោះទំនិញទាំងពីរមុខនេះ រដ្ឋាភិបាលបានយកពន្ធបន្ថែមស្មើនឹង ០.០២ ដុល្លា ចំពោះប្រេងសាំង និង ០.០៤ដុល្លា ចំពោះប្រេងម៉ាស៊ូតក្នុងមួយលីត្រ។ តំណាងប្រតិភូកម្ពុជាបានបន្ថែមថា ពន្ធបន្ថែមប្រភេទនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងអត្រាពន្ធទូទៅ។ តំណាងប្រតិភូកម្ពុជាបានបញ្ជាក់បន្ថែមទៀតថា កម្ពុជាសន្យាកំណត់ពន្ធបន្ថែមទាំងពីរប្រភេទនេះ និងបន្ទុកដទៃទៀតអោយស្របតាមមាត្រា ២ :១(ខ) របស់ GATT ឆ្នាំ១៩៩៤ នឹងត្រូវបញ្ចុះដល់ ០ភាគរយ ទៅតាមកាលកំណត់នៅក្នុងកម្មវិធីបញ្ចុះពន្ធគយលើមុខទំនិញ។

៩៥. តំណាងប្រតិភូកម្ពុជាបានថ្លែងថា ការអនុវត្តនីពន្ធបន្ថែម និង បន្ទុកដទៃទៀតក្រៅពីពន្ធគយព្រមទាំងបន្ទុកលើសេវាកម្មផ្សេងៗ នឹងធ្វើស្របតាមប្រការចែងនានារបស់អង្គការពាណិជ្ជកម្មពិភពលោកចាប់តាំងពីថ្ងៃដែលកម្ពុជាចូលជាសមាជិក។ លោកបានបញ្ជាក់បន្ថែមទៀតថា កម្ពុជាបានសន្យាកំណត់ពន្ធបន្ថែមនិងបន្ទុកផ្សេងៗ ដូចដែលបានកំណត់ក្នុងមាត្រា ២ :១(ខ) នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ក្នុងកំរិត ០ភាគរយតាមកម្មវិធីបញ្ចុះពន្ធគយ។ ក្រុមការងារបានកត់ត្រា លើការសន្យានេះ។

**អត្រាពន្ធលើទំនិញជាប់កូតា ការលើកលែងពន្ធ**

៥៦. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូលឆ្នាំ១៩៨៩ ត្រង់មាត្រា ៩.១ បានអនុញ្ញាតិអោយនាំចូលដោយរួចពន្ធចំពោះ (១) ការនាំចូលបណ្តោះអាសន្នសំរាប់ការនាំចេញទៅវិញ (២) ទំនិញឆ្លងកាត់ (៣) ទំនិញផ្ទាល់ខ្លួនរបស់ពលរដ្ឋកម្ពុជាដែលរស់នៅបរទេស (៤) ការនាំចូលដោយបេសកជនការទូតសំរាប់កិច្ចការមនុស្សធម៌ ឬគោលបំណងសាសនា ។ ល ។ និង (៥) ការធ្វើពាណិជ្ជកម្មតាមព្រំដែនស្ថិតក្រោមការកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះបីពង្រាងច្បាប់ស្តីពីពន្ធគយមិនបានបញ្ជាក់អំពីគោលការណ៍នៃការធ្វើពាណិជ្ជកម្មតាមព្រំដែនក៏ដោយ តំណាងប្រតិភូកម្ពុជាបញ្ជាក់ថា ការអនុវត្តន៍របស់កម្ពុជាគឺដូចគ្នាទៅនឹង អ្វីដែលមានចែងនៅក្នុងមាត្រា ២៤:៣ (ក) នៃ GATT ១៩៩៤។ ការលើកលែងពន្ធក៏ត្រូវពឹងផ្អែកទៅលើទំនិញនាំចូលដោយយោងទៅលើគំរោងវិនិយោគ ដែលបានឯកភាពដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្របតាមច្បាប់វិនិយោគទុន ឆ្នាំ១៩៩៤។ លើសពីនេះទៀតនាយករដ្ឋមន្ត្រីមានអំណាចគ្រប់គ្រាន់ ដើម្បីបញ្ជាលើការលើកលែងពន្ធអាស្រ័យលើហេតុផលចាំបាច់សំរាប់ជាផលប្រយោជន៍ជាតិ និងស្ថានភាពបន្ទាន់សំរាប់ប្រទេស (មាត្រា៥ នៃពង្រាងច្បាប់ស្តីពីពន្ធគយ)។ ដូច្នេះមានរថយន្ត១២០គ្រឿងនាំចូលដោយរួចពន្ធសំរាប់សមាជិកសភាក្នុងឆ្នាំ ១៩៩៤ ប៉ុន្តែពេលបច្ចុប្បន្ននេះមិនមានការលើកលែងពន្ធដូចនេះទៀតទេ។ រាល់ការលើកលែងពន្ធទាំងអស់ត្រូវអនុវត្តលើមូលដ្ឋានគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលការអនុគ្រោះ MFN ។

៥៧. ដោយកត់សំគាល់លើសេចក្តីថ្លែងការដោយតំណាងប្រតិភូកម្ពុជា ដែលថាកម្ពុជាមិនមានអត្រាពន្ធលើទំនិញជាប់កូតានាពេលបច្ចុប្បន្ននេះ ប៉ុន្តែកម្ពុជាគួរពិចារណាក្នុងការដាក់អោយប្រើអត្រាពន្ធលើទំនិញជាប់កូតាលើការនាំចូលផលិតផលកសិកម្មនាពេលអនាគត ។ សមាជិកខ្លះបានសង្កត់ធ្ងន់ថា វិធានការនេះនឹងធ្វើអោយការចរចារ បើកទីផ្សារដែលកម្ពុជាកំពុងធ្វើមានការស្មុគស្មាញ ហើយនឹងធ្វើអោយជាប់ពាក់ព័ន្ធចំពោះនិតិវិធីដែលស្មុគស្មាញក្នុងការបង្កើតលក្ខខ័ណ្ឌសមស្របសំរាប់ការចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលតំរូវអោយការមិនរើសអើង និងតំលាភាពក្នុងការបែងចែក និងគ្រប់គ្រងប្រព័ន្ធកូតា។

៥៨. តំណាងប្រតិភូកម្ពុជាបានកត់ត្រាលើយោបល់ទាំងនេះ។ ទោះបីជាកម្ពុជាគ្មានការប្រើប្រាស់អត្រាពន្ធលើទំនិញជាប់កូតាក្នុងរយៈកន្លងមកក៏ដោយកម្ពុជាសូមរក្សាសិទ្ធិរបស់ខ្លួន ដើម្បីអនុវត្តប្រព័ន្ធកូតានេះដោយផ្អែកទៅលើលទ្ធផលនៃការចរចាចូលជាសមាជិក។ កម្ពុជាបានបញ្ជាក់ថា ខ្លួននឹងគោរពតាមវិន័យរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីអត្រាពន្ធលើទំនិញជាប់កូតា។

៥៩. តំណាងប្រតិភូកម្ពុជាបានថ្លែងថា នៅថ្ងៃដែលកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក រាល់ការលើកលែងពន្ធទាំងអស់ នឹងត្រូវអនុវត្តដោយអនុលោមតាមប្រការចែងនានារបស់កិច្ចព្រមព្រៀងអង្គការ

ពាណិជ្ជកម្មពិភពលោក ដែលរួមមានមាត្រា ១ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និង កិច្ចព្រមព្រៀងស្តីពីវិធានវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម TRIMs ។ ក្រុមការងារបានកត់សំគាល់លើការសន្យានេះ ។

## ថ្លៃឈ្នួល និងបន្ទុកលើសេវាកម្ម

៦០. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ក្នុងការសុំសេចក្តីប្រកាសនាំចូល/នាំចេញមួយច្បាប់កម្ពុជាតំរូវអោយដាក់ពាក្យដោយកំណត់អោយបង់ថ្លៃ ១៥,០០០រៀល (ប្រហែល ៤ដុល្លាអាមេរិក) ។ ថ្លៃឈ្នួលនេះត្រូវកំណត់យកលើការនាំចូលពីគ្រប់ប្រទេសរួមទាំង ប្រទេសជាដៃគូអនុគ្រោះពាណិជ្ជកម្មរបស់កម្ពុជា ។ បន្ទុកដែលត្រូវបង់លើថ្លៃបោះពុម្ពលិខិតប្រកាសពន្ធ និងពេលវេលាដែលបានចំណាយដោយមន្ត្រីគយក្នុងដំណើរការនៃការរៀបចំឯកសារប្រកាសពន្ធ ។ មានមន្ត្រីគយប្រមាណ១០០នាក់ រៀបចំឯកសារប្រកាសពន្ធប្រមាណ ៦,០០០ច្បាប់រៀងរាល់ខែ ។

៦១. សមាជិកខ្លះបានស្នើអោយកម្ពុជាពិនិត្យលើកំរៃ និងដំណើរការរៀបចំឯកសារប្រកាសពន្ធ នៃសេចក្តីប្រកាសនាំចូល/នាំចេញ ដោយយោងទៅលើសេវាកម្មសាធារណៈរបស់មន្ត្រីគយ ។ ជាការឆ្លើយតបតំណាងប្រតិភូកម្ពុជាបានចាត់ទុកការយកកំរៃលើសេវាកម្មបែបនេះមិនផ្ទុយជាមួយនឹងប្រការចែងនានា របស់កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកទេ ។

៦២. តំណាងប្រតិភូកម្ពុជាបានថ្លែងថា រាល់កំរៃ និងបន្ទុកចំពោះសេវាកម្ម ដែលទាក់ទងទៅនឹងការនាំចូល និងការនាំចេញត្រូវប្រតិបត្តិដោយអនុលោមតាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសមាត្រា ៨ និង មាត្រា ១០ នៃ GATT ឆ្នាំ១៩៩៤ ។ តំណាងប្រតិភូកម្ពុជាក៏ថ្លែងបន្តទៀតថា ចាប់តាំងពីថ្ងៃចូលជាសមាជិកកម្ពុជានឹងអនុវត្ត ឬណែនាំអោយប្រើប្រាស់ការយកថ្លៃឈ្នួល និងបន្ទុកសេវាកម្មចំពោះការនាំចូលតាមភាគរយ នៃតំលៃទំនិញ (ad volrem) ទេ ។ ពតិមានដែលទាក់ទងនឹងការអនុវត្តន៏ និងការកំរិតថ្លៃឈ្នួល និងបន្ទុកចំណូលដែលប្រមូលបាន និងសារៈសំខាន់របស់វាត្រូវផ្តល់ដល់សមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់តាមការស្នើសុំ ។ ក្រុមការងារបានកត់ត្រាអំពីការសន្យានេះ ។

## ការប្រមូលពន្ធក្រៅពីពន្ធគយ

៦៣. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាបានអនុវត្តការប្រមូលពន្ធ និងអាករផ្សេងៗ ដោយអនុលោមតាមច្បាប់ស្តីពីពន្ធ និងអាករ (ច្បាប់ពន្ធដារ) ឆ្នាំ១៩៩៧ ។ អត្រាពន្ធបានកំណត់ដូចគ្នាចំពោះទំនិញផលិតក្នុងស្រុក និងទំនិញនាំចូល ។ ក្រៅពីពន្ធលើការនាំចូល ចំពោះទំនិញផលិតក្នុងស្រុកអត្រាជាប់ពន្ធគិតលើថ្លៃផលិតចេញពីរោងចក្រ ឬសហគ្រាសផលិតកម្ម (ex-factory price) ចំពោះទំនិញនាំចូលអត្រា

ជាប់ពន្ធគិតលើថ្លៃ CIF នៃទំនិញ។ ពន្ធអាករលើភេសជ្ជៈ ស្រាបៀរ ស្រា បារី និងផលិតផលថ្នាំជក់ផ្សេងទៀត ប្រេងសាំង និងប្រេងរំអិលមានអត្រា ១០ភាគរយ។ ចំពោះរថយន្ត ឡានក្រុង រថយន្តដឹកទំនិញធំៗ ម៉ូតូ និងគ្រឿងបន្លាស់ពន្ធដែលត្រូវយកគឺកំណត់ ពី១០ ទៅ ៣០ភាគរយ ដូចដែលបានបង្ហាញនៅក្នុងតារាង ២។ សព្វថ្ងៃនេះកម្ពុជាមិនមានឧស្សាហកម្មផលិតរថយន្តក្នុងស្រុកទេ។

៦៤. ប្រទេសជាសមាជិកខ្លះបានកត់សំគាល់ថា កម្ពុជាបានយកពន្ធ ៣ភាគរយបន្ថែមទៀតដែលអនុវត្តតែទៅលើផលិតផលនាំចូលរួមមាន គ្រឿងស្រវឹង និងថ្នាំជក់នៅចុងឆ្នាំ១៩៩៨។ ប្រទេសជាសមាជិកបានស្នើសុំអោយកម្ពុជា ធ្វើយ៉ាងណាអោយការយកពន្ធបន្ថែមនេះស្របតាម មាត្រា ៣ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤។ តំណាងប្រតិភូកម្ពុជា បានឆ្លើយតបថាពន្ធបន្ថែម ៣ភាគរយ ដែលកំណត់លើផលិតផលគ្រឿងស្រវឹង និងថ្នាំជក់នាំចូល ហើយបានអនុវត្តចាប់ពីខែកញ្ញា ឆ្នាំ១៩៩៩ ត្រូវបានអនុវត្តផងដែរ ចំពោះផលិតផលផលិតក្នុងស្រុក ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០២។

៦៥. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា អនុលោមតាមច្បាប់ពន្ធ និងអាករលើតំលៃបន្ថែម (VAT) ត្រូវបានប្រើប្រាស់ជំនួសពន្ធលើផលរបរ និងពន្ធលើការប្រើប្រាស់ចាប់ពីថ្ងៃ១ ខែមករា ឆ្នាំ ១៩៩៩។ អាករលើតំលៃបន្ថែមត្រូវយកតាមអត្រាទោល១០ភាគរយលើទំនិញ និងសេវាកម្ម។ ការនាំចេញរួមទាំងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាអន្តរជាតិត្រូវបានកំណត់ពន្ធសូន្យភាគរយ ។ ចំពោះផលិតផលនាំចូលអាករលើតំលៃបន្ថែម ត្រូវអនុវត្តដូចគ្នាលើការនាំចូលទំនិញពីគ្រប់ប្រភពទាំងអស់ដោយផ្អែកលើតំលៃ CIF រួមទាំងពន្ធគយ និងពន្ធអាករ ( ប្រសិនបើមាន) ។

៦៦. ប្រទេសជាសមាជិកខ្លះបានកត់សំគាល់ថា អាករលើតំលៃបន្ថែមត្រូវបានណែនាំអោយអនុវត្តជាបណ្តើរៗនៅក្នុងប្រទេសកម្ពុជា ហើយប្រទេសសមាជិកទាំងនោះបានសួរថា តើកម្ពុជាមានផែនការបែបណាដើម្បីធ្វើអោយប្រព័ន្ធនេះស្របជាមួយនឹងប្រការចែងស្តីពីប្រព្រឹត្តិកម្មជាតិរបស់អង្គការពាណិជ្ជកម្មពិភពលោក។ កម្ពុជាត្រូវបានគេជំរុញអោយលុបចោលការរើសអើងផ្សេងៗ ក្នុងការអនុវត្តន៍អាករលើតំលៃបន្ថែមចំពោះផលិតផលក្នុងស្រុក និងផលិតផលនាំចូល។

៦៧. ជាការឆ្លើយតប តំណាងប្រតិភូកម្ពុជាបានផ្តល់ការអធិប្បាយលើការដំណើរការអនុវត្តអាករលើតំលៃបន្ថែមនៅក្នុងឯកសារ WT/ACC/KHM/18 ។ ជាដំបូងប្រព័ន្ធអាករលើតំលៃបន្ថែមបានអនុវត្តតែ ចំពោះអ្នកជាប់ពន្ធធំៗ និងមធ្យមចំនួន១,០០០ប៉ុណ្ណោះផ្អែកលើផលរបរប្រចាំឆ្នាំនៅរាជធានីភ្នំពេញ។ ប្រព័ន្ធនេះត្រូវបានអនុវត្តបន្ថែមជាបន្តបន្ទាប់ទៀតលើបណ្តាក្រុមហ៊ុនជំនួញនៅក្នុងរាជធានីភ្នំពេញក៏ដូចជាអ្នកជាប់ពន្ធផ្សេងៗនៅតាមបណ្តាខេត្តចំនួន ៥ ផ្សេងទៀត។ ខេត្តចំនួន៥ទៀតត្រូវបានបន្ថែមនៅឆ្នាំ ២០០២ ហើយចំនួនអ្នកជាប់ពន្ធត្រូវបានកើនឡើងដោយឆាប់រហ័ស សព្វថ្ងៃមានប្រហែល ២,៩០០ក្រុមហ៊ុន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាន

ធ្វើការស្ទាបស្ទង់ចំពោះអ្នកជាប់ពន្ធទាំងអស់នៅគ្រប់បណ្តាខេត្តក្រុង ក្នុងឆ្នាំ២០០០ និង២០០១ ហើយការពង្រីកនាពេលថ្មីៗបំផុតនេះបណ្តាខេត្តក្រុង ទាំងអស់នៅកម្ពុជា ដែលជាការអនុវត្តន៍អាករ លើតំលៃបន្ថែមជាទូទៅនៅកម្ពុជា។ ( សូមពិនិត្យកថាខ័ណ្ឌ ១៣ នៃពតិមានអំពីក៏រិតនៃការអនុវត្តន៍អាករលើ តំលៃបន្ថែម) ។

៦៨. អ្នកជាប់ពន្ធតូចតាចមិនតំរូវអោយបង់អាករលើតំលៃបន្ថែមទេ។ ជាជំនួសពួកគេតំរូវអោយបង់ពន្ធប្រមាណ២ភាគរយលើផលរបរប្រចាំឆ្នាំ ។ ការអនុវត្តន៍តាមប្រព័ន្ធពីរបែបនេះ គឺដោយសារការគ្រប់គ្រង និងការអនុវត្តន៍ដោយពេញលេញនូវរបបអាករលើតំលៃបន្ថែម ដែលនឹងធ្វើអោយប៉ះពាល់ដល់អ្នកជាប់ពន្ធតូចតាច។ អង្គភាពដែលមិនតំរូវអោយបង់អាករលើតំលៃបន្ថែមត្រូវចុះបញ្ជីដោយស្ម័គ្រចិត្តប្រសិនបើគេចាត់ទុកថា វាមានសារៈសំខាន់ចំពោះគេ។

៦៩. ទំនិញ និងសេវាកម្មមួយចំនួនត្រូវលើកលែងមិនយកអាករ លើតំលៃបន្ថែមដូចជាសេវាកម្មប្រៃសណីយ៍សាធារណៈ មន្ទីរពេទ្យ មន្ទីរព្យាបាល សេវាកម្មវេជ្ជសាស្ត្រ និងទន្តសាស្ត្រ និងការលក់ថ្នាំពេទ្យ ព្រមទាំងឧបករណ៍សំរាប់ព្យាបាលធ្មេញការដឹកជញ្ជូនអ្នកដំណើរដោយអង្គភាពដឹកជញ្ជូនសាធារណៈរបស់រដ្ឋ សេវាកម្មធានារ៉ាប់រង និង ហិរញ្ញវត្ថុសំខាន់ៗ បណ្តាសកម្មភាពមិនគិតកំរៃដែលបំរើផលប្រយោជន៍សាធារណៈ, ការនាំចូលទំនិញសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួនដោយមានការលើកលែងពន្ធគយទំនិញដែលនាំចូលដោយអ្នកការទូត និង ស្ថានបេសកកម្មបរទេស អង្គការអន្តរជាតិនិងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងៗសំរាប់ប្រើប្រាស់ផ្លូវការ និងផលិតផលកសិកម្ម១០ប្រភេទទៀត និង "វត្ថុធាតុដើមសំរាប់វិស័យកសិកម្ម" ជីរគ្រាប់ពូជ, ថ្នាំសំរាប់ព្យាបាលសត្វ ចំណីសត្វ ពូជសត្វ ត្រាក់ទ័រតូចៗ និង គ្រឿងបន្លាស់ គ្រឿងម៉ាស៊ីនសំរាប់កសិកម្ម បន្ទាប់បន្សំទៀត ( ប្រកាស លេខ ៣០៣ MEF/TD ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០១) ។ ផលិតផលកសិកម្មនាំចូលដែលមានការលើកលែងមិនយកអាករលើតំលៃបន្ថែមត្រូវបានកត់ត្រាក្នុងតារាង ៣ ។ ទីស្តីការគណៈរដ្ឋមន្ត្រីបានអះអាងជាថ្មីម្តងទៀតថា ការយកអាករលើតំលៃបន្ថែមលើផលិតផលកសិកម្មនាំចូល និងផលិតផលក្នុងស្រុកគួរត្រូវកំណត់អត្តសញ្ញាណនៅក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីនាថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០០២។ ចាប់តាំងពីខែកក្កដា ឆ្នាំ២០០១ ការប៉ាន់ស្មានលើប្រាក់ចំណូលដែលបាត់បង់ ដែលបណ្តាលមកពីការលើកលែងមិនយកអាករលើតំលៃបន្ថែមមានចំនួន ២៣ាន់លានរៀល នៅពាក់កណ្តាលឆមាសទី២ ឆ្នាំ២០០១ និង ១.៥ពាន់លានរៀលនៅ៥ខែដំបូងនៃឆ្នាំ ២០០២។

៧០. ប្រទេសជាសមាជិកមួយបានកត់សំគាល់ថា ប្រព័ន្ធអាករលើតំលៃបន្ថែមដែលកំពុងអនុវត្តនៅកម្ពុជាបានផ្តល់រូបជាស្រេចនូវការមិនយកអាករលើតំលៃបន្ថែមលើផលិតផលក្នុងស្រុកមួយចំនួន ជាពិសេសទំនិញកសិកម្ម

ហើយការអនុវត្តន៍បែបនេះហាក់ដូចជាមិនស្របគ្នាទៅនឹងសេចក្ដីសំរេចរបស់គណៈរដ្ឋមន្ត្រី ចុះខែធ្នូ ឆ្នាំ២០០២ ស្ដីអំពីការអនុវត្តន៍ការយកអាករលើតំលៃបន្ថែមដូចគ្នាចំពោះទំនិញនាំចូល និង ទំនិញក្នុងស្រុក។

៧១. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៣ រដ្ឋាភិបាលបានអនុវត្តការយកអាករលើតំលៃបន្ថែមលើ ផលិតផលកសិកម្មដែលផលិតក្នុងស្រុកនិងនាំចូលដូចគ្នា ហើយស្របទៅនឹងមាត្រា ៣ របស់កិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤។ ចំពោះផលិតផលកសិកម្ម ដែលទទួលការលើកលែងមិនយកអាករលើតំលៃបន្ថែមមួយចំនួនត្រូវផ្ដល់ចំពោះប្រជាកសិករចាប់តាំងពីពេលដែលការយកអាករលើតំលៃបន្ថែមត្រូវបានអនុវត្តដោយអាស្រ័យលើភាពជាក់ស្ដែងនៃប្រាក់ចំណូលទាប ដែលមិនគ្រប់គ្រាន់សំរាប់ការអនុវត្តន៍ការយកអាករលើតំលៃបន្ថែមបាន ហើយមានជំរើសក្នុងការបង់ពន្ធ លើផលរបរពីការលក់ផលិតផល ។ តំណាងប្រតិភូកម្ពុជាបានបញ្ជាក់បន្ថែមទៀតថា ចាប់ពីថ្ងៃចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកតទៅកម្ពុជានឹងអនុវត្តពន្ធក្នុងស្រុករបស់ខ្លួន រួមទាំងការអនុវត្តន៍លើផលិតផលដែលបានចុះក្នុងតារាង ២ និង ៣ និង កថាខ័ណ្ឌ ៦៣-៧០អោយស្របទៅនឹងមាត្រា ៣ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងនៅក្នុងលក្ខណៈមិនមានការរើសអើងចំពោះការនាំចូលទំនិញដោយគ្មានគិតដល់ប្រទេសប្រភពដើមទំនិញ ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## ការដាក់កំហិតលើបរិមាណនាំចូល, រួមទាំងការហាមឃាត់, ការដាក់កូតា និងប្រព័ន្ធអាជ្ញាប័ណ្ណ

៧២. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ការនាំចូលថ្នាំញៀន និងថ្នាំពុល រួមទាំងថ្នាំសំលាប់សត្វល្អិតជាច្រើនប្រភេទទៀត ត្រូវហាមឃាត់។ បញ្ជីផលិតផលហាមឃាត់មិនអោយនាំចូលក្នុងប្រទេសកម្ពុជាមានចែងឡើងវិញក្នុងតារាងទី ៤។

៧៣. ពត៌មានដំបូង ស្ដីពីនីតិវិធីផ្ដល់អាជ្ញាប័ណ្ណនាំចូលបានផ្ដល់ជូននៅក្នុងឯកសារ WT/ACC/KHM/2 ឧបសម្ព័ន្ធទី ៣ និង ទី៨. ហើយឯកសារកែសំរួលត្រូវផ្ដល់ជូននៅក្នុងឯកសារ WT/ACC/KHM/17, WT/ACC/KHM/17/Rev.1 និង WT/ACC/KHM/17/Rev.2 ។ លោកបានកត់សំគាល់ថា កម្ពុជាមិនបានអនុវត្តការដាក់កំហិតបរិមាណចំពោះការនាំចូលទេ ។ ទោះជាយ៉ាងណាក៏ដោយប្រព័ន្ធអាជ្ញាប័ណ្ណមួយត្រូវបង្កើតឡើងដើម្បីការពារសុខភាពមនុស្ស ផលប្រយោជន៍អ្នកប្រើប្រាស់សន្តិសុខជាតិ និងដើម្បីការពារបរិស្ថាន។ ផលិតផលដែលត្រូវនាំចូលដោយមានអាជ្ញាប័ណ្ណនាំចូលត្រូវបានបង្ហាញនៅក្នុងតារាងទី ៥ ។ លោកបានសង្កត់ធ្ងន់ថា ប្រព័ន្ធនេះមិនមែនរៀបចំឡើងដើម្បីដាក់កំហិតបរិមាណ ឬតំលៃនាំចូលទេលើកលែងតែចំពោះថ្នាំសំលាប់

សត្វល្អិត។ លោកបានបញ្ជាក់ថា ផលិតផលដែលមិនបានបង្ហាញនៅក្នុងឯកសារ WT/ACC/KHM/17 និងនៅក្នុងឯកសារកែសំរួលលើកទី១ មិនតំរូវអោយមានអាជ្ញាប័ណ្ណនាំចូលទេ។

៧៤. ការផ្តល់អាជ្ញាប័ណ្ណមិនស្វ័យប្រវត្តិត្រូវអនុវត្តចំពោះ ការនាំចូលយន្តហោះនិងគ្រឿងបន្លាស់ នាវា និងទូក សំរាប់ការប្រើប្រាស់ក្នុងវិស័យយោធា។ រដ្ឋាភិបាលគឺជាអ្នកនាំចូលគ្រឿងយុទ្ធោបករណ៍ស្របច្បាប់តែមួយគត់នៅកម្ពុជា ។ ដោយមានការអនុញ្ញាតិពីរដ្ឋាភិបាល ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃទទួលសិទ្ធិក្នុងការនាំចូលផលិតផលទាំងអស់នេះ។ ក្រសួងការពារជាតិគ្រប់គ្រងការនាំចូល រំសេវជាតិផ្ទុះ អាវុធយុទ្ធភ័ណ្ឌ សំភារៈយោធា និងផលិតផលដទៃទៀត សំរាប់គោលបំណងយោធា ដោយអនុលោមតាមអនុក្រឹត្យលេខ៣៨ របស់រដ្ឋាភិបាល ចុះថ្ងៃទី៣0 ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យការនាំចូល ការផលិត ការចែកចាយ និងការលក់រំសេវ ជាតិផ្ទុះ និងអាវុធយុទ្ធភ័ណ្ឌគ្រប់ប្រភេទ។ ការនាំចូលផលិតផលដូចគ្នានេះសំរាប់គោលបំណងសន្តិសុខត្រូវគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ។ នេះគឺជាស្ថាប័នតែពីរគត់ដែលមានសិទ្ធិនាំចូលគ្រឿងយុទ្ធោបករណ៍។ ក្នុងការអនុវត្តន៍ជាក់ស្តែង ក្រសួងទាំងពីរនេះនឹងមិនទទួលខុសត្រូវដល់ការដេញថ្លៃផលិតផលទាំងនេះទេ ប៉ុន្តែនឹងធ្វើកិច្ចសន្យាបន្តជាមួយសហគ្រាសដែលផលិតផលិតផលទាំងនេះអោយជួយសំរួលក្នុងការទិញ និងដឹកជញ្ជូនផលិតផលទាំងនេះ។

៧៥. ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (MAFF) ចេញអាជ្ញាប័ណ្ណ (លិខិតអនុញ្ញាតិ) សំរាប់ការនាំចូលផលិតផលកសិកម្មសំខាន់បំផុតគឺថ្នាំសំលាប់សត្វល្អិត និងជីរដាំដំណាំដោយស្របទៅនឹងអនុក្រឹត្យស្តីពីស្តង់ដារ និងការគ្រប់គ្រងសំភារៈកសិកម្មចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨។ អ្នកនាំចូលគួរត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ហើយផលិតផលនាំចូលត្រូវចុះបញ្ជី និងចេញលិខិតអនុញ្ញាតិដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។ បច្ចុប្បន្នមានក្រុមហ៊ុន ចំនួន១៥ បានអនុញ្ញាតិអោយនាំចូលផលិតផលកសិកម្ម។ ការចុះបញ្ជីតំរូវអោយមានសំរាប់ផលិតផលដែលត្រូវនាំចូល។ បរិមាណនៃថ្នាំសំលាប់សត្វល្អិត ដែលនាំចូលដោយក្រុមហ៊ុននិមួយៗអាចត្រូវដាក់កំហិតដោយហេតុផលសុវត្ថិភាព ដូចជាតំរូវអោយមានឃ្លាំងស្តុកក៏ដូចជាតំរូវការប្រើប្រាស់ក្នុងស្រុក។ នាយកដ្ឋានក្សេតសាស្ត្រ នឹងបង្កើនគុណភាពដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទជាអ្នក ប៉ាន់ស្មានចំពោះសេចក្តីត្រូវការថ្នាំសំលាប់សត្វល្អិតប្រចាំឆ្នាំដោយផ្អែកលើកត្តាផ្សេងៗដូចជា ទំហំនៃដីកសិកម្មដែលបានដាំដុះ ប្រភេទធញ្ញជាតិ និងអត្រានៃការឆ្លងជំងឺ។ នាពេលអនាគត កម្ពុជានឹងពិចារណាដល់ការអនុញ្ញាតិអោយនាំចូលចំពោះទំនិញដែលបានចុះបញ្ជីរួច ដែលមាននៅក្នុងឃ្លាំង និងបញ្ចេញសំរាប់លក់ ឬប្រើប្រាស់បន្ទាប់ពីការត្រួតពិនិត្យ ឬមួយក៏អនុញ្ញាតិអោយនាំចូលថ្នាំសំលាប់សត្វល្អិតតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ជាមួយបណ្តាប្រទេសនាំចេញ ។ កម្ពុជាគ្មានសមត្ថភាពក្នុងការធ្វើវិភាគលើគ្រោះថ្នាក់បណ្តាលមកពីផលិតផល ទាំងនោះទេនា

ពេលបច្ចុប្បន្ននេះ. ហើយកម្ពុជាស្វាគមន៍ជំនួយឧបត្ថម្ភក្នុងការអភិវឌ្ឍន៍សមត្ថភាពផ្នែកនេះ។ ការនាំចូលជីរត្រូវមានអាជ្ញាប័ណ្ណ ដើម្បីកាត់បន្ថយការប៉ះពាល់បរិស្ថាននៃការខូចខាតគុណភាពជីអាស៊ីដ និងកំរិត បរិមាណអំបិល។

៧៦. ដោយត្រូវបានគេសួរបន្ថែមទៀតអំពីបែបបទនៃការនាំចូលថ្នាំសំលាប់សត្វល្អិត ជាពិសេសការរឹតត្បិតលើបរិមាណនាំចូលដោយផ្អែកលើតំរូវការប្រើប្រាស់ក្នុងស្រុក តំណាងប្រតិភូកម្ពុជាបានបន្ថែមថា លក្ខណៈអាកាសធាតុនៅកម្ពុជា ជារឿយៗបណ្តាលអោយផលិតផលជីរ ដែលនាំចូលខូចគុណភាពយ៉ាងឆាប់រហ័សហើយធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានក្នុងការចាក់កាកសំណល់ជីរខូចគុណភាពនេះចោល។ ផ្អែកលើតួលេខអំពីផ្ទៃដីដាំដុះ និងកំរិតនៃការរីករាលដាលជំងឺឆ្លងដោយសត្វល្អិតអាចអោយអាជ្ញាធរវាយតំលៃបានអំពីសេចក្តីត្រូវការថ្នាំសំលាប់សត្វល្អិតក្នុងមួយឆ្នាំៗ ។ អាជ្ញាប័ណ្ណនាំចូលត្រូវបានផ្តល់ឱ្យលើមូលដ្ឋាន អ្នកស្នើសុំមុនបានទទួលការអនុញ្ញាតិមុនរហូតដល់កំរិតដែលអនុញ្ញាតិអោយនាំចូលក្នុងឆ្នាំនីមួយៗ ។ អាជ្ញាធរមានសមត្ថកិច្ចជាអ្នកសំរេចលើការនាំចូលបន្ថែមនូវថ្នាំសំលាប់សត្វល្អិត ហើយអ្នកនាំចូលដែលបានចុះបញ្ជីត្រូវបានប្រាប់អោយដឹងអំពីការអនុញ្ញាតិអោយនាំចូលបន្ថែមនោះ ។ អ្នកនាំចូលដែលមិនបានបញ្ចេញលក់នូវផលិតផលនេះពីក្នុងឃ្លាំងរបស់ខ្លួនអាចត្រូវបានគេមិនអនុញ្ញាតិអោយធ្វើការនាំចូលជាបណ្តោះអាសន្នរហូតដល់អ្នកនាំចូលនោះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរក្សាទុកនូវថ្នាំសំលាប់សត្វល្អិតដែលនាំចូលបន្ថែម ។ កម្ពុជាគ្មានផែនការក្នុងការអនុញ្ញាតិអោយមានបណ្តឹងតវ៉ាលើការនាំចូលហួសកំរិតនោះទេ ។ ប៉ុន្តែក្នុងនាមជាប្រទេសសមាជិកអាស៊ានកម្ពុជានឹងខិតខំអនុវត្តតាមអោយបានជាអតិបរមានៃបទដ្ឋានរបស់អាស៊ានក៏ដូចជា បទដ្ឋានរបស់អង្គការស្បៀងអាហារពិភពលោក (FAO) ។ វិធានការនាំចូលបច្ចុប្បន្នត្រូវបានយកមកប្រើដោយយោងលើសមត្ថភាពនៅមានកំរិតរបស់កម្ពុជាក្នុងការគ្រប់គ្រងអោយមានសុវត្ថិភាព ក៏ដូចជាក្នុងការស្តុកថ្នាំសំលាប់សត្វល្អិត។ ហេតុនេះចំណុចនេះត្រូវបានយល់ថា អាចអនុញ្ញាតិអោយធ្វើបានដោយផ្អែកលើមាត្រា ២០ (ខ) នៃកិច្ចព្រមព្រៀង GATT - 1994 ។

៧៧. តំណាងប្រតិភូកម្ពុជាបញ្ជាក់ថា មិនហួសពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៥ កម្ពុជានឹងលុបចោលនូវការរិតត្បិតលើការនាំចូលនូវជីរដាំដំណាំ ថ្នាំសំលាប់សត្វល្អិត និងបរិក្ខារកសិកម្មផ្សេងៗទៀតដូច ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៧៥ និង៧៦ ព្រមទាំងបង្កើតនូវរបៀបក្នុងការចុះបញ្ជី និងការពិនិត្យលើបរិក្ខារកសិកម្មដែលត្រូវនាំចូលទាំងនោះអោយស្របតាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ។ តំរូវការផ្សេងៗដែលទាក់ទងនឹងសុវត្ថិភាពនៃការស្តុក និង ការចែកចាយក្នុងស្រុក នឹងត្រូវអនុវត្តចំពោះតែអ្នកចែកចាយ ឬអ្នកនាំចូលក្នុងស្រុកដែលស្តុកមុននឹងចែកចាយប៉ុណ្ណោះ ។ គាត់បានបញ្ជាក់បន្ថែមទៀតថា ក្នុងមូលបទនៃការអនុវត្តន៏កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជាស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ កម្ពុជានឹងពឹងផ្អែកលើប្រការដែលមានចែងនៃកិច្ចព្រមព្រៀងនោះ ដើម្បីធ្វើអោយមានតុល្យភាពរវាងពាណិជ្ជកម្មក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិលើវិស័យទាំងនេះ ហើយកិច្ចសន្យានៅក្នុងកថាខ័ណ្ឌ៥០

នឹងត្រូវអនុវត្តចំពោះតំរូវការសំរាប់ការចុះបញ្ជី និង លើកំរៃអាជ្ញាប័ណ្ណសំរាប់អ្នកនាំចូលវត្ថុធាតុដើមកសិកម្ម ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ ។

៧៨. កម្ពុជាបានជួបបញ្ហាឱសថក្លែងក្លាយ និងការរត់ពន្ធឱសថ ដូច្នេះហើយការអនុញ្ញាតិចំពោះការនាំចូលនៃផលិតផល និងសំភារៈ ឱសថ វីតាមីន និងអ័រម៉ូនត្រូវមានជាចាំបាច់ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងប្រកាសលេខ៨២ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៩ ស្តីពី "នីតិវិធី សំរាប់ការនាំចេញ និងនាំចូលឱសថ" ។ អ្នកនាំចូលត្រូវតែជាក្រុមហ៊ុនឱសថ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងបានអនុញ្ញាតិដោយក្រសួងសុខាភិបាល ។ នាពេលបច្ចុប្បន្ន នេះមានក្រុមហ៊ុនចំនួន ៩០ បានចុះបញ្ជីជាអ្នកនាំចូលថ្នាំ និងឧបករណ៍ពេទ្យពេញសិទ្ធិនៅនាយកដ្ឋានឱសថ និង ម្ហូបអាហារនៃក្រសួងសុខាភិបាល ។ ចំពោះផលិតផលដែលត្រូវនាំចូលក៏តំរូវអោយមានការចុះបញ្ជីផងដែរ ។ នីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណសំរាប់ការនាំចូលឱសថ និងវីតាមីនជាលើកដំបូង នឹងត្រូវចំណាយពេលជាធម្មតា ៣សប្តាហ៍ ដោយសារតែការចាំបាច់នៃការវិភាគពិសោធន៍ ។ អាជ្ញាប័ណ្ណសំរាប់ការនាំចូលជាបន្តបន្ទាប់ទៀត ត្រូវការពេល១សប្តាហ៍ដោយហេតុថាការវិភាគជាក់លាក់មិនត្រូវការធ្វើទេ ។ ពត៌មានស្តីពីនីតិវិធីដែលត្រូវធ្វើបាន បោះពុម្ពផ្សាយនៅក្នុងសារពត៌មានផ្លូវការរបស់ក្រសួងសុខាភិបាល ។

៧៩. ប្រទេសជាសមាជិកមួយបញ្ជាក់ថា ច្បាប់បច្ចុប្បន្នរបស់កម្ពុជារំលោភយ៉ាងធ្ងន់ធ្ងរលើគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលការអនុគ្រោះ (MFN) ហើយគាបសង្កត់លើសិទ្ធិនៃការធ្វើពាណិជ្ជកម្ម ។ សមាជិកនេះក៏ទទួលស្គាល់ផងដែរនូវការចាំបាច់នៃការអនុវត្តន៍បញ្ញត្តិបច្ចេកទេស ឬបទដ្ឋាននៃវត្ថុធាតុដើមសំរាប់កសិករ និងឱសថ ហើយអនុវត្តបច្ចុប្បន្ននៅកម្ពុជាហាក់ដូចជាផ្អែកលើការសន្និដ្ឋានថា កម្ពុជាគ្មានការផលិតឱសថនៅក្នុងស្រុក ។ ការសន្និដ្ឋានបែបនេះមិនត្រឹមត្រូវទេចំពោះផលិតផលឱសថ ហើយកម្ពុជាអាចផលិតផលិតផលជីវ និងថ្នាំសំលាប់សត្វល្អិតនៅពេលខាងមុខ ។ កម្ពុជាត្រូវបានគេស្នើរសុំអោយបញ្ជាក់អោយបានច្បាស់ថា គ្មានការតំរូវអោយមានការបញ្ជាក់អំពីប្រវត្តិនៃអ្នកនាំចូលទេ ដើម្បីអោយអ្នកនោះអាចបើកក្រុមហ៊ុនបាននៅកម្ពុជា ឬដើម្បីចរចារលើសិទ្ធិនាំចូល ។

៨០. ឆ្លើយតបទៅនឹងការបារម្ភអំពីការចុះបញ្ជីអ្នកនាំចូលវត្ថុធាតុដើមកសិកម្ម និងសំភារៈ និងផលិតផលឱសថ ដែលនឹងអាចរឹតបន្តឹងការនាំចូលដោយប្រយោល ឬបង្កើតជាវិធានការមិនមែនពន្ធគយ តំណាងប្រតិភូកម្ពុជាបានគូសបញ្ជាក់ថា បទបញ្ញត្តិរបស់កម្ពុជាអនុញ្ញាតិអោយរូបវន្តបុគ្គលចុះបញ្ជី ហើយការចុះបញ្ជីនឹងត្រូវបានផ្តល់អោយដោយផ្អែកលើការបំពេញលក្ខខ័ណ្ឌនានា ដែលទាក់ទងដល់សុវត្ថិភាពឃ្លាំង និងសំភារៈចាំបាច់សំរាប់ការស្តុកទំនិញ ឬអ្នកធ្វើការដែលមានជំនាញសមស្រប ។ ចំនួនតិចតួចនៃអ្នកចុះបញ្ជីនាំចូលវត្ថុធាតុដើមកសិកម្ម និងផលិតផលឱសថ និងសំភារៈពេទ្យបានឆ្លុះបញ្ចាំងពីតំរូវការតិចតួចនៃទីផ្សារក្នុងស្រុក ។ លោកបានកត់សំគាល់ថា ក្នុងចំណោមក្រុមហ៊ុនទាំង៩០ ដែលបានអនុញ្ញាតិការនាំចូលផលិតផលឱសថមានតែ ៣០ក្រុមហ៊ុនប៉ុណ្ណោះ

ដែលបានធ្វើការនាំចូលនៅឆ្នាំ២០០២។ ដូចដែលបានបញ្ជាក់ក្នុងឯកសារ WT/ACC/KHM/17/Rev.1 កម្ពុជាត្រូវការវិញ្ញាបនបត្រអំពីបទពិសោធន៍នៃការផលិតទំនិញ (Goods Manufacturing Practices) ដែលតំរូវដោយការណែនាំរបស់អង្គការសុខភាពពិភពលោក។ ប្រទេសនិមួយៗមានសិទ្ធិចេញវិញ្ញាបនបត្រប្រភេទនេះអោយដល់ក្រុមហ៊ុនផលិតឱសថ និង ឧបករណ៍ទៅតាមប្រទេសរៀងៗខ្លួន។ ប៉ុន្តែការវាយតំលៃលើលក្ខណៈសម្បត្តិត្រូវផ្អែកលើបទដ្ឋានណែនាំរបស់អង្គការសុខភាពពិភពលោកស្តីពីបទពិសោធន៍នៃការផលិតទំនិញ ។ ក្នុងករណីបន្ទាន់អាជ្ញាប័ណ្ណនាំចូលអាចត្រូវបានគេផ្តល់អោយក្នុងរយៈពេល ៣ថ្ងៃ។

៨១. អាជ្ញាប័ណ្ណនាំចូល ដែលចេញដោយក្រសួងសុខាភិបាលមានសុពលភាព ៦ខែ ហើយអាចពន្យារពេលបានទៅតាមការស្នើសុំ ។ អាជ្ញាប័ណ្ណសំរាប់វត្ថុធាតុដើមកសិកម្មមានសុពលភាពរយៈពេលមួយឆ្នាំ ហើយក៏អាចពន្យារពេលបានដែរ។ អាជ្ញាប័ណ្ណនាំចូលទាំងនេះបានចេញដោយគ្មានការគិតកំរៃទេ ប៉ុន្តែផលិតផលឱសថនិមួយៗដែលបានចុះបញ្ជីនៅក្រសួងសុខាភិបាលតំរូវអោយបង់កំរៃតែម្តងគត់ចំនួន ២០០ដុល្លាអាមេរិក (ប្រកាសរបស់ក្រសួងសុខាភិបាលលេខ២៥៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩៦)។ ចំពោះវត្ថុធាតុដើមកសិកម្មដែលបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ត្រូវបង់កំរៃចុះបញ្ជីចំនួន ៣០ដុល្លាអាមេរិក។ អាជ្ញាប័ណ្ណនាំចូលផ្សេងៗទៀតត្រូវបានផ្តល់អោយដោយតំរូវអោយបង់ថ្លៃ ១៥.០០០រៀល ហើយមានសុពលភាព ៣ខែ។ តាមសំណើរសុពលភាព នៃអាជ្ញាប័ណ្ណទាំងនេះអាចពន្យារពេលបន្ថែមរយៈពេល២ខែទៀត ។ រយៈពេល៧ថ្ងៃបន្ទាប់ពីការដាក់ពាក្យសុំដែលបានបំពេញគ្រប់គ្រាន់អាជ្ញាប័ណ្ណនាំចូលនឹងត្រូវបានផ្តល់អោយ ។ សេចក្តីសំរេចអំពីការផ្តល់អាជ្ញាប័ណ្ណអាចត្រូវប្តឹងតវ៉ាតាមរយៈ នីតិវិធីតុលាការ និងរដ្ឋបាល ដែលបានបង្កើតនៅក្នុងប្រទេសកម្ពុជា។

៨២. តំណាងប្រតិភូប្រតិភូកម្ពុជាបានបញ្ជាក់ថា ចាប់ពីពេលចូលជាសមាជិកកម្ពុជានឹងមិនដាក់អោយប្រើនូវវិធានការមិនមែនពន្ធគយ ដទៃទៀតដូចជា ការផ្តល់អាជ្ញាប័ណ្ណ ការកំរិតកូតា ការហាមឃាត់ និងការដាក់កំរិតដទៃទៀតដែលមានផលប៉ះពាល់ ដែលផ្ទុយទៅនឹងប្រការចែងនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកទេ ។ ក្នុងករណីចាំបាច់ដែលតំរូវអោយប្រើប្រាស់នូវវិធានការនានា ដើម្បីធ្វើអោយមានលំនឹងនៃជញ្ជីងទូទាត់កម្ពុជាអាចប្រើប្រាស់នូវវិធានការទាំងឡាយ ដែលអនុញ្ញាតិអោយធ្វើទៅបានតាមប្រការចែងនានានៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោករួមទាំងមាត្រា ១៨ នៃកិច្ចព្រមព្រៀង GATT និងការបកស្រាយលើប្រការចែងស្តីពីតុល្យភាព ជញ្ជីងទូទាត់នៃកិច្ចព្រមព្រៀង GATT-1994 ។ តំណាងប្រតិភូកម្ពុជាបានបញ្ជាក់បន្ថែមទៀតថា រដ្ឋាភិបាលកម្ពុជាមានសិទ្ធិព្យួរទុកការនាំចូល ឬអាជ្ញាប័ណ្ណនាំចូលដែលអាចព្យួរទុក ឬហាមឃាត់ ឬដាក់កំហិតលើបរិមាណនៃការធ្វើពាណិជ្ជកម្ម នឹងត្រូវអនុវត្តចាប់ពីថ្ងៃចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដោយធានានឹងធ្វើអោយស្របទៅនឹងសេចក្តីតំរូវរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

**ការវាយតំលៃពន្ធគយ**

៨៣. ប្រទេសជាសមាជិកខ្លះបានកត់សំគាល់ថា ប្រព័ន្ធវាយតំលៃពន្ធគយបច្ចុប្បន្នរបស់កម្ពុជាដែលផ្អែកលើច្បាប់ស្តីពីពន្ធលើទំនិញនាំចូល ឆ្នាំ១៩៨៩ មិនស្របទៅនឹងកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍មាត្រា ៧ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ទេ (កិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយ) ហើយកម្ពុជាក៏មានបំណងដោះស្រាយការខ្វះខាតនៃច្បាប់ស្តីពីពន្ធគយថ្មី និងការអនុវត្តន៍បទបញ្ញត្តិនានាដែរ ។ ហេតុនេះប្រទេសជាសមាជិកទាំងនេះបានរំលឹកកម្ពុជាអំពីប្រការចែងនានានៃកិច្ចព្រមព្រៀង ដែលជាប់ទាក់ទិននឹងរបៀបនៃការវាយតំលៃពន្ធគយ វិធីសាស្ត្រវាយតំលៃពន្ធគយដែលមិនអនុញ្ញាតិអោយប្រើ ការសំងាត់ សិទ្ធិប្តឹងតវ៉ា តំលាភាព ភាពជឿជាក់ចំពោះការបញ្ចេញទំនិញ និងការអនុម័តលើការបកស្រាយ ។ ក្នុងចំណោមបញ្ហានានា ដែលបានលើកឡើងដោយប្រទេសជាសមាជិកគឺការងារត្រួតត្រារបស់ភ្នាក់ងារគយ ភាពស្មុគ្រស្មាញនៃបែបបទរដ្ឋបាលការពន្យារការពិនិត្យឯកសារ, និងការវាយតំលៃពន្ធច្រើនជាងតំលៃជាក់ស្តែង ឬការវាយតំលៃដែលមិនសមស្របតាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ។ សមាជិកខ្លះបានឯកភាពថា ចំណុចមួយចំនួននៃកិច្ចព្រមព្រៀងអាចត្រូវអនុវត្តជាបន្តបន្ទាប់នាពេលអនាគត ប៉ុន្តែក៏បានរំពឹងថា ទំហំនៃការអនុវត្តន៍ក្នុងដំណាក់កាលអន្តរកាលគួរមានទំហំសមស្រប ។ ប្រទេសជាសមាជិកទាំងនេះយល់ឃើញថា ប្រការចែងសំខាន់ៗនៃកិច្ចព្រមព្រៀងផ្តោតសំខាន់លើបញ្ហាបើកទីផ្សារ និងធ្វើអោយមានរបបពាណិជ្ជកម្មមួយ ដែលធានាបាននូវការជឿជាក់បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ កម្ពុជាមិនគួរបន្តប្រើប្រាស់បញ្ជីតំលៃអប្បបរមានៃទំនិញអោយលើសពីអ្វីដែលមាននៅក្នុងច្បាប់បច្ចុប្បន្នរបស់ខ្លួន ហើយគួរបញ្ចប់របៀបវាយតំលៃពន្ធគយដែលផ្ទុយនឹងកិច្ចព្រមព្រៀង ។

៨៤. ជាការឆ្លើយតបតំណាងប្រតិភូប្រតិភូកម្ពុជាបានមាន ប្រសាសន៍ថា ពង្រាងច្បាប់ថ្មីស្តីពីពន្ធគយបានអនុម័តរួចហើយដោយគណៈរដ្ឋមន្ត្រី ហើយមានផែនការស្នើរអោយមានការអនុម័តពីសភាជាតិនៅខែ កក្កដា ឆ្នាំ២០០៤ ។ បទបញ្ញត្តិទាំងអស់ នឹងត្រូវបានបង្កើតឡើង នៅពេលដែលពង្រាងច្បាប់ថ្មីនេះត្រូវបានធ្វើចប់សព្វគ្រប់, រួមទាំងបទបញ្ញត្តិដើម្បីអនុវត្តមាត្រា១៧-២៤ នៃកិច្ចព្រមព្រៀង, ក៏ដូចជាកំណត់សំគាល់ដែលបកស្រាយ (Interpretative Notes) នៅឧបសម្ព័ន្ធ១ នៃកិច្ចព្រមព្រៀង ហើយនឹងបញ្ជូនទៅសមាជិកទាំងអស់ដើម្បីពិនិត្យ ។ លោកបានសង្កត់ធ្ងន់ថា កម្ពុជានឹងស្នើរសុំអោយមានដំណាក់កាលអន្តរកាលមួយ ។ ផែនការអនុវត្តសំរាប់ការអនុវត្តន៍កិច្ចព្រមព្រៀងស្តី អំពីការវាយតំលៃពន្ធគយត្រូវផ្តល់ជូននៅក្នុងឯកសារ WT/ACC /KHM/13/Rev.1 ។

៨៥. ការអនុវត្តន៍បច្ចេកទេសនៃការវាយតំលៃពន្ធគយបង្ហាញថា ការវាយតំលៃពន្ធគយដោយផ្អែកលើបញ្ជីតំលៃអប្បបរមា នៃទំនិញនាពេលបច្ចុប្បន្នរបស់កម្ពុជា ត្រូវតែលុបចោលហើយជំនួសដោយប្រការចែងស្តីពីតំលៃធ្វើពាណិជ្ជកម្មជាក់ស្តែងនៃកិច្ចព្រមព្រៀង ។ មុខទំនិញ ដែលមាននៅក្នុងបញ្ជីតំលៃអប្បបរមា នៃទំនិញមានចែងនៅក្នុងតារាងទី ៦ ។ រដ្ឋាភិបាលកម្ពុជាយល់ថា ការផ្លាស់ប្តូររបៀបវាយតំលៃពន្ធគយពីតំលៃបញ្ជីអប្បបរមាទៅ

តំលៃការធ្វើពាណិជ្ជកម្មជាក់ស្តែងនៅពេល ដែលកម្ពុជាក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនឹងបណ្តាលអោយមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ចំណូលថវិកាជាតិ ។ ដូច្នេះតំណាងប្រតិភូកម្ពុជាបានស្នើថា ការវាយតំលៃពន្ធគយដោយផ្អែកលើបញ្ជីតំលៃអប្បបរមាត្រូវដកចេញជាបណ្តើរៗក្នុងរយៈពេល៥ឆ្នាំ ហើយនៅឆ្នាំ២០០៨ ការវាយតំលៃពន្ធគយនឹងស្របទាំងស្រុងទៅនឹងកិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ ។ បញ្ហាបច្ចុប្បន្នដែលកើតមានឡើងនៅក្នុងបែបបទរដ្ឋបាលនៃការប្រមូលពន្ធ គឺការសហការពីអ្នកនាំចូលនៅមានកំរិតទាបនៅឡើយការខ្វះខាតនៃប្រព័ន្ធគណនេយ្យ ដែលគួរអោយទុកចិត្តបាននិងការខ្វះខាតការរក្សាទុកឯកសារ ហើយសមត្ថភាពនៅមានកំរិតរបស់មន្ត្រីគយក្នុងការពិនិត្យតាមដានតំលៃជាក់ស្តែងនៃការធ្វើពាណិជ្ជកម្ម។ កម្ពុជាត្រូវការពេលវេលាដើម្បីអប់រំបណ្តុះបណ្តាលអ្នកនាំចូលលើច្បាប់នៃរបៀបវាយតំលៃពន្ធគយថ្មី និងអំពីការកត់ត្រាអោយត្រឹមត្រូវ និងអំពីប្រព័ន្ធគណនេយ្យក៏ដូចជាមន្ត្រីគយផង ដែលក្នុងការរៀបចំនិតិវិធីរដ្ឋបាលផ្ទៃក្នុងដូចជាការត្រួតពិនិត្យក្រោយការបញ្ចេញទំនិញ និងការបណ្តុះបណ្តាលមន្ត្រី។ នាយកដ្ឋានគយ និងរដ្ឋាករ នឹងស្វែងរកជំនួយបច្ចេកទេសក្នុងការរៀបចំអនុវត្តផែនការ សំរាប់ដំណាក់កាលអន្តរកាល ។

៨៦. ប្រទេសជាសមាជិកខ្លះបានកត់សំគាល់ថា កម្ពុជាមានការប្រើប្រាស់ទិន្នន័យដែលផ្តល់ដោយក្រុមហ៊ុន SGS ជាឯកសារយោងក្នុងការវាយតំលៃពន្ធគយ ។ កិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយ បានហាមយ៉ាងតឹងរឹងចំពោះការអនុវត្តន៍បែបនេះ ហើយកម្ពុជាគួរតែលុបចោលអោយបានមុនពេលចូលជា សមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

៨៧. តំណាងប្រតិភូប្រតិភូកម្ពុជាបានបញ្ជាក់ថា កម្ពុជាបានប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះ ដើម្បីគ្រាន់តែជាឯកសារយោងក្នុងការ គណនាតំលៃប្រតិវេទន៍គយតែប៉ុណ្ណោះ។ ប្រព័ន្ធទិន្នន័យនេះនឹងមិនត្រូវប្រើដើម្បីបង្កើតការវាយតំលៃលើការធ្វើពាណិជ្ជកម្មជាក់ស្តែងទេ ប៉ុន្តែគ្រាន់តែជាឯកសារយោង ដើម្បីជាហេតុផលនៃការវាយតំលៃពន្ធគយ និងសំរាប់គោលបំណងនៃការវាយតំលៃលើលក្ខណៈសម្បត្តិអ្នកនាំចូលអោយស្របតាមកិច្ចព្រមព្រៀង។ តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ក្រៅពីផលិតផលដែលបានចុះក្នុងតារាងទី ៦ ដែលកម្ពុជាបានប្រើសំរាប់វាយតំលៃពន្ធគយជាអប្បបរមា. កម្ពុជានឹងមិនប្រើប្រាស់បញ្ជីនេះ ដើម្បីកំណត់ការវាយតំលៃលើការធ្វើពាណិជ្ជកម្មជាក់ស្តែងទេ។

៨៨. ចំពោះបញ្ហាតំលាភាពនៃការអនុវត្តន៍ច្បាប់តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា មាត្រា៩៣ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាតំរូវអោយច្បាប់ទាំងអស់ត្រូវបោះពុម្ពផ្សាយនៅក្នុងសារពត៌មានផ្លូវការ(រាជកិច្ច) ហើយផ្សព្វផ្សាយជូនប្រជាពលរដ្ឋមុនពេលចាប់ផ្តើមអនុវត្ត ។ អត្ថបទច្បាប់ដែលទាក់ទងនឹងបញ្ហាពន្ធគយត្រូវបោះពុម្ពនៅក្នុងសារពត៌មានផ្លូវការសំរាប់សាធារណជនទូទៅដោយផ្អែកលើមូលដ្ឋានមិនមានការរើសអើង និងតំលាភាព។ លើសពីនេះទៀត. ទីចាត់ការគយ និងរដ្ឋាករជារឿយៗបានផ្តល់ច្បាប់ និងបទបញ្ញត្តិផ្សេងៗដល់អ្នកនាំចូលធំៗចំនួនពី ៣០ ទៅ៥០ក្រុមហ៊ុន ដើម្បីធ្វើអោយពួកគេយល់ពីការវិវឌ្ឍន៍នៃច្បាប់ថ្មីៗ ។ លោករំពឹងថាច្បាប់ថ្មីស្តីពីពន្ធគយ

នឹងទទួលបានការពុម្ពផ្សាយដ៏ទូលំទូលាយតាមរយៈសិក្ខាសាលាការប្រកាសផ្សាយ និងប្រភពពត៌មានដទៃទៀត ដូចជាគេហទំព័ររបស់ទីចាត់ការគយ ។

៨៩. តំណាងប្រតិភូកម្ពុជា បានថ្លែងអំណរគុណដល់សមាជិកក្រុមងារទាំងអស់ចំពោះការផ្តល់ជំនួយបច្ចេកទេសក្នុងវិស័យនេះ ព្រមទាំងចំពោះការទទួលស្គាល់លើតំរូវការអោយមានជំនួយបច្ចេកទេសច្រើនបន្ថែមទៀត ។ ជាការបញ្ជាក់កម្ពុជាបានស្នើរសុំអោយមានដំណាក់កាលអន្តរកាល ដើម្បីដកចេញជាបណ្តើរៗនូវការវាយតំលៃពន្ធគយអប្បបរមា និងការកែទំរង់ខាងរដ្ឋបាលគយដូចមានចែងក្នុងតារាង៦. ព្រមទាំងការអនុវត្តន៍អោយបានពេញលេញនូវរបៀបវាយតំលៃពន្ធគយ ដែលបានចែងក្នុងមាត្រា២១ នៃពង្រាងច្បាប់ស្តីពីពន្ធគយ ។ ប្រការចែងនានា ដែលមានចែងក្នុងកិច្ចព្រមព្រៀងការវាយតំលៃពន្ធគយ ដែលទាក់ទងនឹងតំលាភាព. ការសំងាត់. សិទ្ធិប្តឹងតវ៉ា. ភាពជឿជាក់នៃការបញ្ចេញទំនិញ. និងការអធិប្បាយខ្លីៗ ដែលទាក់ទងទៅនឹងបញ្ហាទាំងនេះនឹងត្រូវអនុវត្តនៅពេលដែលកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

៩០. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ការអនុវត្តន៍ពេញលេញ នឹងចាប់ផ្តើមពីថ្ងៃទី១ ខែមករា ឆ្នាំ ២០០៩។ ក្រុមការងារបានកត់ត្រានូវការសន្យាទាំងអស់នេះ។ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំអោយក្រុមការងារផ្តល់រយៈអន្តរកាលគិតពីថ្ងៃចូលជាសមាជិកចំនួន៥ឆ្នាំ គឺរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៩. ក្នុងការអនុវត្តន៍ប្រការចែងមួយចំនួន នៃកិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ ដើម្បីអោយកម្ពុជាទទួលបាន និងប្រើប្រាស់ជំនួយឧបត្ថម្ភ ដើម្បីធានាអោយបាននូវការអនុវត្តន៍កិច្ចព្រមព្រៀងនោះអោយបានពេញលេញ។ ក្នុងកំឡុងពេលអន្តរកាលនេះ ទំនិញនាំចូលដែលមានចុះក្នុងតារាងទី ៧ កម្ពុជានឹងមិនត្រូវតំរូវអោយអនុវត្តតាមមាត្រា ៧:២ (ច) ដែលអនុញ្ញាតិអោយអនុវត្តការវាយតំលៃពន្ធគយអប្បបរមាចំពោះការនាំចូល។ ប្រសិនបើរយៈពេលអន្តរកាលនេះត្រូវបានផ្តល់អោយនោះការអនុញ្ញាតិអោយកម្ពុជាមិនអនុវត្តតាមប្រការចែងនានានៃកិច្ចព្រមព្រៀងនេះត្រូវស្ថិតក្រោមការរិតត្បិតយ៉ាងតឹងរឹង ហើយអនុញ្ញាតិចំពោះតែការអនុវត្តន៍វិធានការនេះតែប៉ុណ្ណោះ។ ចំពោះប្រការចែងផ្សេងៗទៀត នៃកិច្ចព្រមព្រៀងនឹងត្រូវអនុវត្តដោយពេញលេញចំពោះការនាំចូលទំនិញ រួមទាំងទំនិញដែលអនុញ្ញាតិដោយរយៈពេលអន្តរកាលផង។

៩១. ក្នុងកំឡុងពេលនេះកម្ពុជានឹងធានាថា បទបញ្ញត្តិពេលបច្ចុប្បន្នរបស់ខ្លួនដែលត្រូវអនុវត្តក្នុងកំឡុងពេលអន្តរកាលដែលទាក់ទងការវាយតំលៃពន្ធគយ នឹងត្រូវអនុវត្តដោយឈរលើមូលដ្ឋានមិនមានការរើសអើងចំពោះការនាំចូលទាំងអស់ ។ ជាពិសេសចំពោះការអនុវត្តន៍ជាក់ស្តែង នៃវិធីសាស្រ្តវាយតំលៃលើការនាំចូលរថយន្តដែលត្រូវផ្អែកលើប្រទេសជាប្រភពដើមនឹងត្រូវលុបចោលចាប់ពីពេលចូលជាសមាជិក ហើយកម្ពុជានឹងអនុវត្តពន្ធគយតែមួយលើទំនិញដែលមានប្រភពដើមនៅក្នុងប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោកលើមូលដ្ឋានស្មើភាព ។ ការកែប្រែច្បាប់ បទបញ្ញត្តិ និងការអនុវត្តជាក់ស្តែងក្នុងដំណាក់កាលអន្តរកាលនឹងមិនធ្វើអោយ

កំរិតនៃភាពស្របគ្នាទៅនឹងកិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយធ្លាក់ចុះទាបជាងកំរិត ដែលមានស្រាប់នៅថ្ងៃចូលជាសមាជិក ។ កម្ពុជានឹងចូលរួមក្នុងកិច្ចការរបស់គណៈកម្មាធិការ ស្តីពីការវាយតំលៃពន្ធគយ ។ លោកបានបន្ថែមទៀតថា កម្ពុជានឹងស្វែងរកជំនួយបច្ចេកទេសតាម ដែលអាចធ្វើទៅបានដើម្បីធានាលើសមត្ថភាពរបស់ខ្លួនក្នុងការអនុវត្តកិច្ចព្រមព្រៀងដល់ផុតរយៈពេលអន្តរកាលដែលបានទទួល ។

៩២. ជាការឆ្លើយតបទៅនឹងសំណើរបស់ប្រទេសជាសមាជិក ដែលសុំអោយមានការពន្យល់អោយបានច្បាស់លាស់នោះតំណាងប្រតិភូកម្ពុជាបានបង្ហាញនូវផែនការសកម្មភាពមួយបញ្ជាក់ពីជំហាន ដែលនៅសេសសល់ដើម្បីនឹងសំរេចបានគោលដៅនិងកាលវិភាគសំរាប់ជំហាននិមួយៗ ( តារាង៧) ។

**តារាង៧ : ផែនការសកម្មភាពសំរាប់អនុវត្តកិច្ចព្រមព្រៀងស្តីអំពីការ វាយតំលៃពន្ធគយ**

| សកម្មភាពការងារ | កាលបរិច្ឆេទ |
|---|---|
| ក្រុមការងារពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីគយ | មុនពេលចូលជាសមាជិក |
| បង្កើតក្រុមការងារសំរាប់អនុវត្តគំរោងវាយតំលៃពន្ធគយរបស់អង្គការពាណិជ្ជកម្មពិភពលោកនិងរៀបចំកម្មវិធីការងារថ្នាក់នាយកដ្ឋាន ដើម្បីអនុវត្តផែនការវាយតំលៃពន្ធគយក្នុងដំណាក់កាលអន្តរកាល | មុនខែធ្នូ ឆ្នាំ២០០៣ |
| ក្នុងករណីបន្តយន្តការ PSI កិច្ចព្រមព្រៀងថ្មីត្រូវតែស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយរបស់អង្គការពាណិជ្ជកម្មពិភពលោក | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ |
| រដ្ឋសភាពិនិត្យ និងអនុម័តច្បាប់ស្តីពីវិធានវាយតំលៃពន្ធគយដែលស្របជាមួយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក | មុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤ |
| ការវាយតំលៃលើការធ្វើចរាចរទំនិញអនុវត្តចំពោះ<br>១. ការនាំចូលជាដុំកំភួនធ្វើឡើងដោយក្រុមហ៊ុនពហុជាតិនិងក្រុមហ៊ុនកម្ពុជា ដែលរកស៊ីត្រឹមត្រូវតាមការវាយតំលៃរបស់នាយកដ្ឋានគយនិងរដ្ឋាករ ហើយត្រូវបានចាត់ទុកថាជាអ្នកនាំចូល ដែលមានអត្រាគ្រោះថ្នាក់ទាប ។<br>២. ការនាំចូលដោយក្រុមហ៊ុនក្រៅពីក្រុមហ៊ុនធំៗ ដូចជាក្រុមហ៊ុនពហុជាតិ និង ក្រុមហ៊ុនកម្ពុជា ដែលនាំចូលទំនិញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នាទៅនឹងទំនិញដែលនាំចូលដោយក្រុមហ៊ុនធំៗផ្អែកលើរបាយការណ៍វាយតំលៃរបស់គយ ។ | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ |

| | |
|---|---|
| ៣. ការនាំចូលធ្វើឡើងដោយក្រុមហ៊ុនវិនិយោគនិង អ្នកនាំចូលផ្សេងៗទៀត ដែលបានទទួលសិទ្ធិរួចពន្ធលើការនាំចូល (ដូចជា អង្គការក្រៅរដ្ឋាភិបាល បេសសកម្មក្រៅប្រទេសជាដើម)។ | |
| ការបណ្តុះបណ្តាលបច្ចេកទេស និងការរៀបចំការិយាល័យបច្ចេកទេសវាយតំលៃពន្ធគយ<br>- ណែនាំអោយប្រើកម្មវិធីត្រួតពិនិត្យទំនិញក្រោយពេលទំនិញត្រូវបានបញ្ចេញពីដែនគយ<br>- ណែនាំអោយប្រើប្រាស់កម្មវិធីវាយតំលៃពន្ធគយស្វ័យប្រវត្តិ | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ |
| ការវាយតំលៃលើការធ្វើចរាចរទំនិញអនុវត្តចំពោះ<br>៤. ការនាំចូលដោយក្រុមអ្នកនាំចូលដែលមានអត្រាគ្រោះថ្នាក់ទាប មានផលប៉ះពាល់តិចតួចចំពោះចំណូលថវិកាជាតិ<br>៥. ការនាំចូលនូវមុខទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នាដោយអ្នកនាំចូលដទៃទៀត | មុនថ្ងៃទី០១ ខែ មករា ឆ្នាំ២០០៧ |
| ការវាយតំលៃលើការធ្វើចរាចរទំនិញអនុវត្តចំពោះ<br>៦. ការនាំចូលនូវទំនិញដែលមានតំលៃទាបនិងមានអត្រាពន្ធនាំចូលទាបផ្សេងៗទៀត។ | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨ |
| ការវាយតំលៃលើការធ្វើចរាចរទំនិញអនុវត្តចំពោះ<br>៧. ការនាំចូលទំនិញគ្រប់ប្រភេទរួមមានទំនិញដែលជាប់អត្រានាំចូលខ្ពស់ និងជាទំនិញវនេយិតភាព | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ |
| អនុវត្តយ៉ាងពេញលេញ នូវកិច្ចព្រមព្រៀងស្តីអំពីការអនុវត្តន៏តាម មាត្រា ៧ នៃកិច្ចព្រមព្រៀង GATT-1994 | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ |

៩៣. តំណាងប្រតិភូកម្ពុជាបានថ្លែងថា បទបញ្ញត្តិស្តីពីការវាយតំលៃពន្ធគយលើការនាំចូលសំរាប់គោលបំណងយកពន្ធ និងអាករផ្សេងៗទៀត ដែលបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយ នឹងត្រូវអនុម័តនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤។ កម្ពុជានឹងអនុវត្តជាបណ្តើរៗ នូវកិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយតាមកម្មវិធីការងារនៅក្នុងតារាង ៧ ហើយទទួលស្គាល់ថា ៖ ក្នុងកំឡុងពេលនេះទំហំនៃការអនុវត្តន៏ប្រការចែងនានានៃកិច្ចព្រមព្រៀង ដូចដែលបានចែងក្នុង កថាខ័ណ្ឌ៨៩, ៩០ និង៩១ នឹងត្រូវអនុវត្តដោយភាគីកម្ពុជា។

ការអនុវត្តន៍ពេញលេញនូវកិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយ នឹងចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ ។

## វិធានប្រភពដើម

៩៤. ដោយកត់សំគាល់លើសេចក្តីថ្លែងការណ៍ដំបូងរបស់តំណាងប្រតិភូកម្ពុជាដែលថា កម្ពុជាមិនទាន់បានបង្កើតអោយមានច្បាប់ស្តីពីវិធានប្រភពដើមទំនិញនៅឡើយ ប៉ុន្តែកម្ពុជាមានបំណងដាក់អោយប្រើវិធានប្រភពដើមអនុគ្រោះ ដែលជាការតំរូវនៃបេក្ខភាពក្នុងអាស៊ានរបស់ខ្លួន ។ ប្រទេសជាសមាជិកមួយបានស្នើសុំអោយមានការប្តេជ្ញាចិត្តមួយដែលថា នៅពេលចូលជាសមាជិកកម្ពុជានឹងអនុវត្តច្បាប់ និងបញ្ញត្តិស្តីពីវិធានប្រភពដើមទំនិញរបស់ខ្លួនអោយស្របតាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីវិធានប្រភពដើម ។ សមាជិកនេះក៏បាន ស្នើរសុំអោយមានការបញ្ជាក់ផងដែរថា ច្បាប់របស់កម្ពុជានឹងដាក់បញ្ចូល កិច្ចតំរូវទាំងអស់ នៃមាត្រា ៣(ជ) និងឧបសម្ព័ន្ធ ២ កថាខ័ណ្ឌ ៣(ឃ) ដូចជាវិធានប្រភពដើមអនុគ្រោះ និងមិនអនុគ្រោះតាមលំដាប់លំដោយ ។ អាជ្ញាធរគយនឹងផ្តល់តាមការស្នើរសុំដល់អ្នកនាំចូលឬអ្នកផ្សេងៗទៀត នូវហេតុផលផ្សេងៗនៃការវាយតំលៃប្រភពដើមនៃការនាំចូល និងកំណត់លក្ខខ័ណ្ឌដែលត្រូវផ្តល់អោយហើយសំណើផ្សេងៗសំរាប់ការវាយតំលៃទាំងនោះនឹងត្រូវទទួលស្គាល់មុនពេល ដែលពាណិជ្ជកម្មខាងទំនិញដែលជាប់ពាក់ព័ន្ធត្រូវបានចាប់ផ្តើម ។

៩៥. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ចំពោះការធ្វើពាណិជ្ជកម្ម ដែលមិនទទួលការអនុគ្រោះ, អ្នកនាំចូលត្រូវបានតំរូវអោយបង្ហាញអំពីប្រភពដើមរបស់ផលិតផលនៅក្នុងសេចក្តីប្រកាសនាំចូល ។ សេចក្តីត្រូវការនេះធ្វើឡើងក្នុងគោលបំណងធ្វើស្ថិតិតែប៉ុណ្ណោះ ។ លោកបានបន្ថែមទៀតថា កម្ពុជានឹងពិចារណាលើប្រការចែងនានា នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីវិធានប្រភពដើមនៅពេលដែលបញ្ញត្តិច្បាប់ក្នុងវិស័យនេះត្រូវរៀបចំធ្វើ ។ ប្រការចែងស្តីពីការគ្រប់គ្រងវិធានប្រភពដើមនឹងត្រូវបញ្ចូលក្នុងច្បាប់ថ្មីស្តីពីពន្ធគយ ដែលសង្ឃឹមថា កម្ពុជានឹងអនុវត្តនៅក្នុងឆ្នាំ២០០៤។ ក្រសួងពាណិជ្ជកម្មទទួលខុសត្រូវចំពោះការចេញវិញ្ញាបនប័ត្រប្រភពដើមរបស់ទំនិញ ។

៩៦. តំណាងប្រតិភូកម្ពុជាបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាមានបំណងអនុវត្តអោយស្របទៅនឹងប្រការចែងនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីវិធានប្រភពដើមក្នុងការអនុវត្តន៏វិធានប្រភពដើមទាក់ទងទៅនឹងការទទួលបានការអនុគ្រោះនិងមិនទទួលបានការអនុគ្រោះក្នុងការធ្វើអោយពាណិជ្ជកម្មបន្ទាប់ពីច្បាប់គយថ្មី និង បញ្ញត្តិនានាសំរាប់ការអនុវត្តន៏ច្បាប់ត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០៥។ ជាពិសេសសេចក្តីតំរូវនៃមាត្រា ៣(ឆ) និងឧបសម្ព័ន្ធ ២ កថាខ័ណ្ឌ ៣(ឃ) នៃកិច្ចព្រមព្រៀងនេះ ដែលតំរូវអោយមានការវាយតំលៃលើប្រភពដើមទំនិញក្នុងករណីមានសំណើរពីអ្នកនាំចូល ព្រមទាំងកំណត់លក្ខខ័ណ្ឌដែលត្រូវបំពេញនោះត្រូវតែដាក់បញ្ចូលទៅក្នុងច្បាប់គយថ្មីរបស់កម្ពុជាចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានប្រកាសអោយប្រើ

ឬក៏ដាក់អោយមាននៅក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលក្នុងករណីចាំបាច់អោយបានមុនថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៤។ ក្រុមការងារបានកត់ត្រាលើកាសន្យានេះ។

**<u>ទំរង់បែបបទគយផ្សេងៗទៀត</u>**

៩៧. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា កម្ពុជាមិនត្រូវការឯកសារនាំចូលជាផ្លូវការ ដែលចេញដោយមន្ត្រីការទូត ឬ ស្ថាប័នដទៃទៀតនៅប្រទេសនាំចេញទេ។ លោកបានបន្ថែមទៀតថា ទីចាត់ការគយ និង រដ្ឋាករពិនិត្យលើនិតិវិធីនៃការបញ្ចេញទំនិញដោយបង្កើតអោយមានភាពងាយស្រួលនិងទំនើបភាវូបនីយកម្ម និងការអនុវត្តន៍ការវាយតំលៃលើលក្ខណៈសម្បត្តិនៃអ្នកនាំចូល។ អនុក្រឹត្យលេខ ៦៤ ដែលបានប្រកាសអោយប្រើនៅពាក់កណ្តាល ឆ្នាំ២០០១ បានដាក់ចេញនូវវិធានការនានាក្នុងការដាក់ភ្នាក់ងាររបស់រដ្ឋាភិបាលនៅតាមច្រកទ្វារព្រំដែន។ ទីចាត់ការគយ និងរដ្ឋាករ និងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហារណ៍ និងបង្ក្រាបការក្លែងបន្លំ (ក្រសួងពាណិជ្ជកម្ម) គឺជាភ្នាក់ងារមានសមត្ថកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការបញ្ចេញទំនិញពីដែនគយ ហើយភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀតចូលរួមក្នុងគណៈកម្មាធិការចំរុះដោយមានការទទួលខុសត្រូវច្បាស់លាស់នៅគ្រប់ច្រកទ្វារព្រំដែនទាំងអស់។ តំណាងប្រតិភូកម្ពុជាបានបង្ហាញនូវការជឿជាក់ថា ដំណើរការបញ្ចេញទំនិញពីដែនគយដោយស្វ័យប្រវត្តិនឹងផ្តល់នូវប្រសិទ្ធិភាពថែមទៀត ហើយច្បាប់ស្តីពីពន្ធគយថ្មីនឹងផ្តល់មូលដ្ឋានច្បាប់សំរាប់គំនិតផ្តួចផ្តើមនេះ។

៩៨. ទាក់ទងទៅនឹងការខិតខំប្រឹងប្រែងប្រឆាំងអំពើរត់ពន្ធ - បញ្ហាមួយ ដែលលើកឡើងដោយសមាជិកមួយចំនួនដែលបារម្ភអំពីការប្រកួតប្រជែងពីទំនិញរត់ពន្ធ ដែលធ្វើអោយប៉ះពាល់ដល់ការបើកទីផ្សារសំរាប់ទំនិញចម្មតា តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា បទបញ្ជារបស់រដ្ឋាភិបាលលេខ០២ ចេញដោយគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០១ បានដាក់ចេញនូវគំនិតផ្តួចផ្តើមក្នុងការប្រឆាំង នឹងអំពើរត់ពន្ធ។ បទបញ្ជារបស់រដ្ឋាភិបាលនេះបានណែនាំមន្ត្រីយោធា នគរបាល និងអាជ្ញាធរមូលដ្ឋានអោយសហការណ៍ និងជួយជ្រោមជ្រែង ដល់ទីចាត់ការគយ និងរដ្ឋាករក្នុងប្រតិបត្តិការទប់ស្កាត់អំពើរត់ពន្ធ។ គណៈកម្មាការអន្តរក្រសួងមួយត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដើម្បីរៀបចំផែនការ សំរបសំរួល និងត្រួតពិនិត្យគំនិតផ្តួចផ្តើមនេះ ។ នៅក្នុងពេលដំណាលគ្នានេះវិធានការមួយចំនួនត្រូវបានអនុវត្តដើម្បីពង្រឹងសមត្ថភាពមន្ត្រីទីចាត់ការគយ និងរដ្ឋាករ ហើយបង្កើនសុក្រិត្យភាពនៃការងារ។ គំនិតផ្តួចផ្តើមនៃការប្រឆាំងនឹងអំពើរត់ពន្ធបានផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដ៏សំបើមដល់មន្ត្រីគយ ដែលបានចូលរួមក្នុងប្រតិបត្តិការប្រឆាំងអំពើរត់ពន្ធបានជោគជ័យ។ កម្ពុជាកំពុងតែស្វែងរកជំនួយបច្ចេកទេស ដើម្បីបំពាក់អោយក្រុមប្រតិបត្តិករនោះនូវឧបករណ៍ និង មធ្យោបាយសមស្រប។

៩៩. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ដើម្បីដោះស្រាយបញ្ហាវត់ពន្ធ និងបញ្ហាបែបបទរដ្ឋបាលរបស់គយ រដ្ឋាភិបាលកំពុងបង្កើតអោយមានយន្តការដោះស្រាយជំលោះនៅក្រោមទីចាត់ការគយ និង រដ្ឋាករ ដែលជាសេវាកម្មរបស់ភ្នាក់ងារគយកម្ពុជាទទួលដោះស្រាយនូវបណ្តឹងតវ៉ានានាពីពាណិជ្ជករនិង រដ្ឋាភិបាលនានាលើការធានានូវការអនុវត្តន៏របស់ភ្នាក់ងារគយ ។ យន្តការនេះមានចែងនៅក្នុងច្បាប់គយថ្មី ហើយនឹងបង្កើតអោយបានមុនថ្ងៃទី០១ ខែ មករា ឆ្នាំ២០០៥ ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ ។

## <u>ការត្រួតពិនិត្យទំនិញមុនពេលផ្ទុក</u>

១០០. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា រដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចសន្យាមួយជាមួយក្រុមហ៊ុនត្រួតពិនិត្យទំនិញមុនពេលផ្ទុក (PSI) នៅឆ្នាំ១៩៩៥ ។ កិច្ចសន្យាថ្មីបានចូលជាធរមាននៅ ខែតុលា ឆ្នាំ ២០០០ ។ កិច្ចសន្យានេះមានសុពលភាពរយៈពេល២ឆ្នាំ និងអាចពន្យារបាន ១ឆ្នាំទៀតអាចនឹងមានសុពលភាពរហូតដល់ខែ តុលា ឆ្នាំ២០០៣ ។ ប្រព័ន្ធត្រួតពិនិត្យនេះបានដាក់អោយប្រើដោយអនុលោមតាមប្រកាសលេខ៥៩៩ SHV.PRK ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០០ ស្តីពី "ការអនុវត្តន៏សេវាកម្មត្រួតពិនិត្យមុនពេលផ្ទុក" ។ ប្រការចែងនានានៃកិច្ចសន្យានេះបានបញ្ជាក់អំពីការផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដល់ទីចាត់ការគយ និងរដ្ឋាករ ដើម្បីបង្កើតអោយមានអ្នកជំនាញ និងអ្នកបច្ចេកទេសអាចអោយការត្រួតពិនិត្យទំនិញមុនពេលផ្ទុកបញ្ចប់កិច្ចសន្យាក្នុងរយៈពេលយ៉ាងយូរ៣ឆ្នាំ ។

១០១. កិច្ចសន្យាត្រួតពិនិត្យទំនិញមុនពេលផ្ទុកបច្ចុប្បន្ននេះអនុវត្ត ចំពោះតែការបញ្ជូនទំនិញដែលមានតំលៃ ៤,០០០ដុល្លាអាមេរិក ឬលើសពីនេះ (FOB) ។ ទំនិញដែលមានតំលៃតិចជាង ៤,០០០ដុល្លាអាមេរិក ត្រូវកំណត់ដោយទីចាត់ការគយ និងរដ្ឋាករកម្ពុជា (ចំណុចត្រួតពិនិត្យគយដាច់ស្រយាលខ្លះត្រូវបានអនុញ្ញាតិអោយធ្វើការកំណត់លើការនាំចូលដែលមានតំលៃត្រឹម១,២០០ដុល្លាអាមេរិក) ។ ទំនិញដែលលើកលែងពីការត្រួតពិនិត្យទំនិញមុនពេលផ្ទុករួមមានត្បូងថ្មមានតំលៃ និងលោហៈមានតំលៃ វត្ថុសិល្បៈ គ្រឿងផ្ទុះ អាវុធយុទ្ធភ័ណ្ឌ គ្រឿងសព្វាវុធ និងគ្រឿងចំបាំង សត្វពាហនៈមានជីវិត សារពត៌មាន ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ និងរបស់របរផ្ទាល់ខ្លួន កញ្ចប់ប្រៃសណីយ៍ ឬវត្ថុគំរូពាណិជ្ជកម្ម វត្ថុអនុស្សាវរីយ៍ពីរដ្ឋាភិបាលបរទេស ឬអង្គការអន្តរជាតិចំពោះការងារមូលនិធិ អង្គការមនុស្សធម៌ វត្ថុអនុស្សាវរីយ៍ និងគ្រឿងផ្គត់ផ្គង់ចំពោះបេសកកម្មកុងស៊ុល-ស្ថានទូត និងបណ្តាភ្នាក់ងារដែលទាក់ទងទៅនឹងអង្គការសហប្រជាជាតិ ដែលនាំចូលមកសំរាប់បំពេញតំរូវការផ្ទាល់ខ្លួន ទំនិញដែលនាំចូលសំរាប់ការប្រើប្រាស់របស់រដ្ឋាភិបាលនៅក្រោមការបញ្ជាទិញរបស់រដ្ឋាភិបាល កំទេចដែក បារី និងទំនិញដែលអនុញ្ញាតិអោយនាំចូលបណ្តោះអាសន្ន (វត្ថុធាតុដើមបំរើអោយផលិតកម្មនាំចេញ) ។

១០២. ក្រុមហ៊ុនត្រួតពិនិត្យទំនិញមុនពេលផ្ទុក (PSI) បានផ្ទៀងផ្ទាត់ ពត៌មានដែលត្រូវប្រើដោយមន្ត្រី គយដូចជា បរិមាណ គុណភាព តំលៃ ប្រភេទពន្ធនាំចូល និងពន្ធផ្សេងៗទៀតដែលត្រូវបង់ ។ ការវាយតំលៃលើទំនិញនាំចូល នឹងផ្អែកលើគោលការណ៍ទីផ្សារសេរីរហូតដល់ការចូលជាធរមាននៃច្បាប់គយថ្មី។ បន្ទាប់ពីនោះមកក្រុមហ៊ុនត្រួត ពិនិត្យទំនិញមុនពេលផ្ទុក នឹងផ្តល់យោបល់លើការវាយតំលៃទំនិញនាំចូលដោយផ្អែកលើនីតិវិធីដែលស្របគ្នា ទៅនឹងតំរូវការរបស់កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ។ ថ្លៃដែលត្រូវបង់សំរាប់សេវាត្រួតពិនិត្យ ទំនិញមុនពេលផ្ទុកគឺ ០.៨ ភាគរយ នៃតំលៃ FOB របស់ទំនិញដែលត្រូវត្រួតពិនិត្យ លើកលែងតែផលិតផលប្រេង (០.៣០ដុល្លាអាមេរិក ក្នុង១តោន) ។ អ្នកនាំចូលដែលមិនបានដាក់ទំនិញរបស់ខ្លួនអោយមានការត្រួតពិនិត្យទំនិញ មុនពេលផ្ទុក ហើយទំនិញនោះតំរូវអោយមានការត្រួតពិនិត្យជាចាំបាច់ដោយមន្ត្រីគយនៅចំណុចត្រួតពិនិត្យ តាមព្រំដែននោះនឹងត្រូវផាកពិន័យ ៧ភាគរយ លើតំលៃ CIF នៃទំនិញនាំចូលទាំងអស់។ ក្រុមការងារដោះស្រាយ វិវាទមួយត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយការប្តឹងតវ៉ាដែលកើតឡើងពីការអនុវត្តន៍ការត្រួតពិនិត្យទំនិញ មុនពេលផ្ទុកនេះ។ លោកបានកត់សំគាល់ថា ចាប់តាំងពីក្រុមការងារដោះស្រាយវិវាទមានប្រតិបត្តិការតាំងពី ដើមឆ្នាំ ២០០១ មក មិនទាន់ដែលមានអ្នកនាំចូលណានាំយកករណីជំលោះជាផ្លូវការមកអោយក្រុមការងារជួយ ដោះស្រាយទេ។ អ្នកនាំចូលហាក់ដូចជាចង់លើកបញ្ហារបស់គេជាមួយនឹងទីចាត់ការគយ និងរដ្ឋាករ ឬ ក្រុមហ៊ុន ត្រួតពិនិត្យទំនិញ មុនពេលផ្ទុកដែលតាមរយៈនោះបញ្ហាត្រូវលើកបន្តទៅក្រុមការងារដើម្បីដោះស្រាយ។ ផែនការ ជាច្រើន ត្រូវអនុវត្តដើម្បីលើកទឹកចិត្តអ្នកនាំចូលអាចប្តឹងតវ៉ាតាមផ្លូវច្បាប់ពីករណីផ្សេងៗមកក្រុមការងារ ។ លោកបានបន្ថែមទៀតថា មាត្រា ២៤ នៃពង្រាងច្បាប់ស្តីពីគយផ្តល់សិទ្ធិប្តឹងតវ៉ាដល់អ្នកនាំចូលប្តឹងទៅនឹង សេចក្តីសំរេចរបស់មន្ត្រីគយ ជាដំបូងត្រូវប្តឹងទៅទីចាត់ការគយ និងរដ្ឋាករ បន្ទាប់មកប្តឹងទៅគណៈកម្មាធិការ ពន្ធគយ ហើយជាចុងក្រោយប្តឹងទៅតុលាការ ។ គណៈកម្មាធិការមួយត្រូវបានបង្កើតឡើង ជាពិសេសសំរាប់ ដោះស្រាយការប្តឹងតវ៉ានានា ក្នុងករណីដែលអ្នកនាំចូលមិនយល់ព្រមតាមការវាយតំលៃរបស់ក្រុមហ៊ុនត្រួតពិនិត្យ ទំនិញមុនពេលផ្ទុកចំពោះប្រភេទពន្ធដែលទំនិញត្រូវជាប់ពន្ធ ឬការវាយតំលៃចំពោះទំនិញរបស់ខ្លួន ។ នៅក្រោម ច្បាប់គយថ្មី គណៈកម្មាធិការពន្ធគយមានកាតព្វកិច្ចក្នុងការសំរេចលើការប្តឹងតវ៉ានានាពីសំណាក់អ្នកនាំចូលចំពោះ សេចក្តីសំរេចរបស់គយ។

១០៣. ប្រទេសសមាជិកខ្លះបានចាត់ទុកថា តំលៃសេវាត្រួតពិនិត្យ ចំនួន០.៨ភាគរយ នៃថ្លៃទំនិញត្រូវត្រួតពិនិត្យ ជាការបានបំពានដល់មាត្រា ៨ នៃកិច្ចព្រមព្រៀង GATT ដែលការយកថ្លៃឈ្នួលបែបនេះមិនសម និងមិន ត្រូវទាក់ទងនឹងថ្លៃដើមប៉ាន់ស្មាននៃសេវាកម្មដែលបានផ្តល់ដោយក្រុមហ៊ុនត្រួតពិនិត្យ។ តំណាងប្រតិភូកម្ពុជា បានឆ្លើយតបថា នៅពេលដែលកិច្ចសន្យាសព្វថ្ងៃនេះផុតសុពលភាពកិច្ចសន្យាថ្មី នឹងចែងពីលក្ខខ័ណ្ឌអោយស្រប ទៅនឹងកិច្ចព្រមព្រៀង GATT មាត្រា ៨ ហើយតំរូវអោយការបង់ថ្លៃត្រួតពិនិត្យមុនពេលផ្ទុកត្រូវតែប្រហាក់ ប្រហែល នឹងថ្លៃសេវាកម្មដែលបានផ្តល់អោយមិនមែនផ្អែកលើតំលៃ នៃទំនិញដែលត្រូវត្រួតពិនិត្យនោះទេ។ កិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រីបានប្រកាសឡើងវិញពីសេចក្តីសំរេចនោះ ហើយបានចូលជាធរមាន នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០០២។

១០៤. ជាការបន្ថែម សមាជិកមួយរូបបានលើកឡើងថា ការពិន័យ ៧ភាគរយលើទំនិញមិនបានត្រួតពិនិត្យគឺបំពានលើកិច្ចព្រមព្រៀង GATT មាត្រា ៨ កថាខ័ណ្ឌ ៣ ។ តំណាងប្រតិភូកម្ពុជាមានទស្សនៈថា មាត្រា ៨ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ អនុវត្តចំពោះតែ "ការពិន័យលើកំហុសតូចតាចលើច្បាប់គយ ឬនិតិវិធីដែលតំរូវអោយមានតែប៉ុណ្ណោះ។ នៅពេលដែលអ្នកនាំចូលខកខានមិនអនុវត្តតាមច្បាប់នៃការត្រួតពិនិត្យទំនិញមុនពេលផ្ទុកត្រូវបានចាត់ទុកថាជាបទល្មើសធំដុំ ដែលបំពានលើប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការត្រួតពិនិត្យទំនិញមុនពេលផ្ទុកនៃផលិតផលដែលបាននាំចូល ។ លោកបានសង្កត់ធ្ងន់ថា ការផាកពិន័យបានធ្វើអោយការគេចពន្ធថយចុះ ហើយបានការពារចំណូលរបស់រដ្ឋាភិបាលព្រមទាំងការពារការប្រកួតប្រជែងរបស់អ្នកនាំចូលត្រឹមត្រូវទៀតផង។ ទោះបីជាមានការពន្យល់ដូចនេះ ក៏ដោយក៏សមាជិកមួយនៅតែប្រកាន់ថា ការពិន័យយ៉ាងដូច្នេះមិនសមស្រប ហើយចាត់ទុកថារបាំងមិនមែនពន្ធគយចំពោះការនាំចូល ហើយគួរតែត្រូវបានធ្វើវិសោធនកម្មដើម្បីបន្ថយភាពស្មុគស្មាញ និងបំពេញតំរូវការរបស់កិច្ចព្រមព្រៀង GATT មាត្រា ៨ និង មាត្រា ១១ ។

១០៥. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ចាប់ពីថ្ងៃចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក រដ្ឋាភិបាលកម្ពុជានឹងទទួលខុសត្រូវទាំងស្រុងលើប្រតិបត្តិការនៃក្រុមហ៊ុនត្រួតពិនិត្យទំនិញមុនពេលផ្ទុកដោយធានាថាបំពេញបានតាមតំរូវការនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដែលរួមមានការកំណត់ថ្លៃឈ្នួលអោយស្របតាមមាត្រា ៨ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងតំរូវការអោយមានតំលាភាពនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសក្នុងមាត្រា ១០ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ព្រមទាំងកិច្ចសន្យាដែលមានចែងនៃកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍ មាត្រា ៨ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យទំនិញមុនពេលផ្ទុក។ លោកបានបញ្ជាក់បន្តទៀតថា ប្រព័ន្ធត្រួតពិនិត្យទំនិញមុនពេលផ្ទុករបស់កម្ពុជានឹងអនុវត្តជាបណ្តោះអាសន្នប៉ុណ្ណោះរហូតដល់ពេលដែលទីចាត់ការគយ និងរដ្ឋាករមានលទ្ធភាពអនុវត្តមុខងារទាំងអស់នេះបាន ដែលសព្វថ្ងៃការងារនេះត្រូវប្រតិបត្តិដោយក្រុមហ៊ុនផ្តល់សេវាត្រួតពិនិត្យទំនិញមុនពេលផ្ទុក។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## <u>ការទប់ស្កាត់ការលក់បង្ខូចថ្លៃ, វិធានការតបត វិធានការការពារសុវត្ថិភាព</u>

១០៦. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាមិនទាន់បានបង្កើតច្បាប់ស្តីពីការការពារការធ្វើពាណិជ្ជកម្មណាមួយនៅឡើយទេ។ យោងតាមរបៀបវារៈបង្កើតច្បាប់របស់កម្ពុជា ច្បាប់ស្តីពីការទប់ស្កាត់ការលក់បង្ខូចថ្លៃ និងវិធានការតបត និងវិធានការការពារសុវត្ថិភាពនឹងមិនសង្ឃឹមថាអាចត្រូវបានអនុម័តទេរហូតដល់ពាក់កណ្តាលឆ្នាំ២០០៤។ លោកបានបន្ថែមទៀតថា កម្ពុជានឹងអនុវត្តវិធានការការពារសុវត្ថិភាព វិធានការទប់ស្កាត់ការលក់បង្ខូចថ្លៃ និងវិធានការតបតអោយស្របទៅនឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដែលរួមទាំងការអនុវត្តន៍និតិវិធីនានា ក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

១០៧. ដោយកោតសរសើរចំពោះសេចក្តីអះអាងនេះសមាជិកខ្លះ បានស្នើអោយកម្ពុជាធ្វើការសន្យាមិនអនុវត្តនូវវិធានការទប់ស្កាត់ការលក់បង្ខូចថ្លៃ វិធានការតបត និងវិធានការការពារសុវត្ថិភាពដោយមិនបានអនុវត្តច្បាប់ត្រឹមត្រូវជាមុន ហើយត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅអង្គការពាណិជ្ជកម្មពិភពលោកពីបទបញ្ញត្តិដែលគ្របដណ្តប់លើវិធានការទាំងអស់នេះដោយស្របតាមកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍មាត្រា VI របស់កិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ លើវិធានការឧបត្ថម្ភធន និងវិធានការតបត ព្រមទាំងការការពារសុវត្ថិភាព។ សមាជិកទាំងអស់នេះបានស្នើសុំអោយកម្ពុជាបញ្ជូនពង្រាងច្បាប់ និង បញ្ញត្តិនានា (ប្រសិនបើមាន) ទៅក្រុមការងារដើម្បីពិនិត្យមើលឡើងវិញ។

១០៨. តំណាងប្រតិភូកម្ពុជាបានថ្លែងថា កម្ពុជានឹងមិនអនុវត្តវិធានការទប់ស្កាត់ការលក់បង្ខូចថ្លៃ, វិធានការតបត ឬវិធានការការពារសុវត្ថិភាពណាមួយទេ រហូតដល់វិធានការត្រូវបានជូនដំណឹងនិងអនុវត្តតាមច្បាប់ដែលស្របទៅនឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីការអនុវត្តន៍មាត្រា ៦ ស្តីអំពីការ ឧបត្ថម្ភធន វិធានការតបត និងការការពារសុវត្ថិភាព ។ កម្ពុជាធានាថា ការបង្កើតច្បាប់ ឬបញ្ញត្តិនានាទាក់ទង នឹងវិធានការទប់ស្កាត់ការលក់បង្ខូចថ្លៃ វិធានការតបត និងវិធានការការពារសុវត្ថិភាព នឹងស្របទៅតាមប្រការចែងនានានៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដោយរួមទាំងមាត្រា ៦ ១៤ និងកិច្ចព្រមព្រៀង GATT-1994 នឹងកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍មាត្រា ៦ កិច្ចព្រមព្រៀងស្តីពីវិធានឧបត្ថម្ភធននិងវិធានតបត និងកិច្ចព្រមព្រៀងស្តីពីការការពារសុវត្ថិភាព ។ បន្ទាប់ពីច្បាប់បែបនេះត្រូវបានអនុវត្តន៍កម្ពុជានឹងអនុវត្តន៍ផងដែរនូវវិធានការលក់បង្ខូចថ្លៃ វិធានតបត និងវិធានការការពារសុវត្ថិភាពឱ្យស្របនឹងខប្បញ្ញត្តិរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលមានការពាក់ព័ន្ធ ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## ២. បទបញ្ញត្តិនៃការនាំចេញ

### ការផ្តល់នូវតារាងពន្ធគយ, តំលៃឈ្នួលនិងតំលៃសេវាកម្ម, ការអនុវត្តន៍ ពន្ធផ្ទៃក្នុងលើការនាំចេញ

១០៩. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាបានយកពន្ធនាំចេញលើវត្ថុធាតុដើម និងផលិតផលមិនទាន់កែច្នៃមួយចំនួន ដើម្បីលើកទឹកចិត្តដល់ផលិតកម្មក្នុងស្រុក លើកទឹកចិត្តដល់ការនាំចេញផលិតផលសំរេច និងដើម្បីការពារសុខភាពប្រជាជន ។ ផលិតផលដែលជាប់ពន្ធនាំចេញត្រូវបានពណ៌នាក្នុងតារាង ៨។ ឆ្លើយតបទៅនឹងសំណើរបស់សមាជិកមួយចំនួន ដែលស្នើរសុំអោយកម្ពុជាលុបចោលពន្ធនាំចេញទាំងអស់នៅពេលដែលខ្លួនចូលជាសមាជិក តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ពន្ធនាំចេញត្រូវបានអនុញ្ញាតិអោយយកនៅក្រោមច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលស្របទៅនឹងនៃមាត្រា ១ និងកិច្ចព្រមព្រៀង GATT ។ ពន្ធនាំចេញរបស់កម្ពុជាត្រូវដាក់អោយអនុវត្តលើមូលដ្ឋានគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលការ អនុគ្រោះ (MFN) ដូច្នេះការយកពន្ធលើការនាំចេញក៏ត្រូវបានអនុវត្ត ដូចគ្នាដែរចំពោះការនាំចេញទៅប្រទេសជាសមាជិកអាស៊ាន។ ពន្ធនាំចេញមានចំនួនប្រហែល ២ភាគរយ នៃចំណូលពន្ធគយទាំងអស់ដែលបានប្រមូលដោយទីចាត់ការគយ និងរដ្ឋាករក្នុងឆ្នាំ២០០០។

១១០. ប្រទេសជាសមាជិកមួយបានកត់សំគាល់ថា មាត្រា ២៤ នៃកិច្ចព្រមព្រៀង GATT-1994 បានចែងថា ការយកពន្ធរវាងបណ្តាប្រទេសក្នុងកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីត្រូវតែលុបចោលទាំងពន្ធលើទំនិញនាំចូល និងពន្ធលើទំនិញនាំចេញ។ នៅក្រោមកាលៈទេសៈ បែបនេះកម្ពុជាត្រូវបញ្ជាក់ពីហេតុផលនៃការលើកលែងពន្ធបែបនេះ ហើយកម្ពុជានឹងធ្វើយ៉ាងដូច្នេះ ដើម្បីអោយវិធានការនេះស្របជាមួយប្រការចែងនានារបស់អង្គការពាណិជ្ជកម្មពិភពលោក ។ តំណាងប្រតិភូ កម្ពុជាបានកត់សំគាល់ឃើញថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ត្រូវបានជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោកនៅក្រោមប្រការចែងស្តីពីការលើកលែង។

១១១. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ការចុះបញ្ជីសំរាប់ការនាំចេញ ក៏ដូចគ្នានឹងការចុះបញ្ជីសំរាប់ការនាំចូលដែរ. ហើយតំលៃឈ្នួល ១៥.០០០រៀល ត្រូវបានអនុវត្តលើប្រតិវេទនាំចេញ/នាំចូលនិមួយៗ ដែលជាថ្លៃបោះពុម្ពប្រតិវេទគយ និងការចំណាយពេលវេលារបស់មន្ត្រីគយក្នុងដំណើរការនៃការពិនិត្យលើប្រតិវេទនេះ។ ការត្រួតពិនិត្យទំនិញមុនពេលផ្ទុកផលិតផលដែលត្រូវនាំចេញមុនពេលផ្ទុកត្រូវធ្វើឡើងដោយនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញទីហរណ៍ អាហារណ៍ និងបង្ក្រាបការក្លែងបន្លំ ដែលជាអង្គភាពមួយត្រូវស្ថិតនៅក្រោមឱវាទរបស់ក្រសួងពាណិជ្ជកម្ម។ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញទីហរណ៍ អាហារណ៍ និង បង្ក្រាបការក្លែងបន្លំពិនិត្យរាល់ទំនិញនាំចេញដោយគ្មានការលើកលែង។

<u>**ការរិតត្បិតចំពោះការនាំចេញ**</u>

១១២. សមាជិកខ្លះបានកត់សំគាល់ថា កម្ពុជារិតត្បិតចំពោះការនាំចេញផលិតផលមួយចំនួន។ កម្ពុជាត្រូវបានរំលឹកថែមទៀតថា ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកមួយអាចអនុវត្តការដាក់កំរិតលើការនាំចេញបានតែនៅក្រោមលក្ខខ័ណ្ឌកំណត់យ៉ាងតឹងរឹងប៉ុណ្ណោះ ហើយការអនុវត្តន៍របស់កម្ពុជាពុំបានបំពេញនូវលក្ខខ័ណ្ឌទាំងនោះទេ ។ ជាក់ស្តែងលក្ខខ័ណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណនាំចេញចំពោះផលិតផលអង្ករ និង ឈើមូលបង្ហាញច្បាស់ពីការរំលោភលើមាត្រា ១១ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ដែលលក្ខខ័ណ្ឌទាំងនេះត្រូវបានអនុវត្តចំពោះហេតុផលសេដ្ឋកិច្ចជាជាងហេតុផលអភិរក្ស។ កម្ពុជាត្រូវបានស្នើសុំអោយពន្យល់ពីលក្ខខ័ណ្ឌដូចគ្នា ដែលបានអនុវត្តចំពោះផលិតកម្មក្នុងស្រុក និងបង្ហាញថា តើកម្ពុជាធ្វើយ៉ាងដូចម្តេចដើម្បីដាក់ជំនួសវិធានការបច្ចុប្បន្នអោយស្របនឹងកិច្ចតំរូវរបស់អង្គការពាណិជ្ជកម្មពិភពលោក?

១១៣. តំណាងប្រតិភូកម្ពុជាបានឆ្លើយតបថា ជាទូទៅកម្ពុជាមិនបានរិតត្បិតលើការនាំចេញទេ លើកលែងតែផលិតផលអង្ករ ឈើមូល ឈើមិនទាន់កែច្នៃ និងផលិតផលព្រៃឈើផ្សេងៗ វត្ថុបុរាណដែលមានអាយុលើសពី១០០ឆ្នាំ ថ្នាំញៀន និងថ្នាំពុល អាវុធយុទ្ធភ័ណ្ឌ គ្រឿងរំសេវផ្ទុះ ព្រមទាំងរថយន្តនិងគ្រឿងបរិក្ខាយោធា (សូមពិនិត្យមើលតារាង៩)។ លោកបានបន្ថែមទៀតថា ការដាក់កំរិតលើការនាំចេញអង្ករត្រូវបានដកចេញកាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០១ តាមប្រកាស លេខ 2290/MoC/M2001 របស់ក្រសួងពាណិជ្ជកម្ម។ ទោះជា

យ៉ាងណាក៏ដោយ ប្រសិនបើចាំបាច់រដ្ឋាភិបាលកម្ពុជាសូមរក្សាសិទ្ធិដើម្បីដាក់អោយប្រើប្រាស់ឡើងវិញអំពីវិធានការដាក់កំហិតនានាលើការនាំចេញនាពេលអនាគត ដើម្បីការពារ ឬសម្រាលការខ្វះខាតស្បៀង ដូចដែលបានចែងនៅក្នុងមាត្រា ១១:២(ក) នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤។

១១៤. ចំពោះការរិតត្បិតផលិតផលឈើរដ្ឋាភិបាលកម្ពុជាបានចេញប្រកាសស្តីពីវិធានការគ្រប់គ្រង ដើម្បីលុបបំបាត់ភាពអាណាធិបតេយ្យព្រៃឈើលេខ ០១ PROK នៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៩ និងអនុក្រឹត្យមួយស្តីពីការគ្រប់គ្រងព្រៃឈើសម្បទានលេខ ០៥ ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០០០ ។ ផ្អែកលើអំណាចដែលផ្តល់អោយតាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន រដ្ឋាភិបាលកម្ពុជាបានព្យួរមិនអោយក្រុមហ៊ុនព្រៃសម្បទានបន្តកាប់ឈើមូល។ រដ្ឋាភិបាលនឹងមិនអនុញ្ញាតិអោយក្រុមហ៊ុនទាំងនេះបន្តកាប់ឈើមូលទៀតទេ រហូតដល់ក្រុមហ៊ុនទាំងនេះដាក់ជូនរដ្ឋាភិបាលពិនិត្យនូវផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការវាយតំលៃអំពីផលប៉ះពាល់ចំពោះសង្គម និងបរិស្ថាន។ ផែនការ និងការវាយតំលៃទាំងនេះនឹងត្រូវពិនិត្យដោយរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងសាធារណៈជន ជាពិសេសសហគមក្នុងតំបន់ដែលមានផលប៉ះពាល់ពីការកាប់ព្រៃឈើ ព្រមទាំងជំនាញការអន្តរជាតិ។ ការវាយតំលៃលើផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការវាយតំលៃផលប៉ះពាល់សង្គម និងបរិស្ថាន បច្ចុប្បន្ននេះត្រូវបានអនុវត្ត ។ រដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ការអនុញ្ញាតិអោយក្រុមហ៊ុនណាមួយធ្វើអាជីវកម្ម លើផលិតផលព្រៃឈើទេចាប់តាំងពីថ្ងៃទី ១ខែមករា ឆ្នាំ ២០០២មក។ ការនាំចេញឈើមូល និងឈើអារត្រូវបានហាមឃាត់ ហើយសេចក្តីសំរេចរបស់រដ្ឋាភិបាល លេខ១៧ ចុះថ្ងៃ ទី២៩ ខែមេសា ឆ្នាំ១៩៩៧ បានដាក់ចេញនូវបញ្ជីផលិតផលឈើដែលមានសិទ្ធិនាំចេញ ព្រមទាំងលក្ខខ័ណ្ឌលំអិតរួមទាំងកាតព្វកិច្ចរបស់អ្នកនាំចេញដើម្បីទទួលបាននូវសម្បទានពិសេសក្នុងការធ្វើអាជីវកម្មលើធនធានព្រៃឈើពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទដែលអាចទទួលកូតានាំចេញដែលកំណត់ដោយរដ្ឋាភិបាល ព្រមទាំងអាជ្ញាប័ណ្ណនាំចេញមិនស្វ័យប្រវត្តិពីក្រសួងពាណិជ្ជកម្ម។ សេចក្តីសំរេចក៏បានកំណត់អំពីចំណុចច្រកទ្វារព្រំដែន ដែលអនុញ្ញាតិអោយការនាំចេញផលិតផលព្រៃឈើមានលក្ខណៈស្របច្បាប់ ។ តាមទស្សនៈរបស់គាត់អាជ្ញាប័ណ្ណនាំចេញផលិតផលឈើត្រូវបានអនុវត្តស្របទៅនឹងការរិតត្បិតទៀត នៃផលិតកម្មក្នុងស្រុកសំដៅការពារព្រៃឈើ ឬប្រភពធនធាន ធម្មជាតិដូចបានចែងក្នុងប្រការ ២០ (ឆ) នៃកិច្ចព្រមព្រៀង GATT-1994 ។

១១៥. តំណាងប្រតិភូកម្ពុជាបានថ្លែងថា ចាប់តាំងពីពេលចូលជាសមាជិកកម្ពុជានឹងធានាថាខ្លួនត្រូវអនុវត្តច្បាប់ និងបទបញ្ញត្តិរបស់ខ្លួន ដែលគ្រប់គ្រងលើវិធានការនាំចេញធ្វើអោយស្របតាមប្រការចែងរបស់កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដែលរួមមានមាត្រា ១ និង ១១ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបត ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

**ឧបត្ថម្ភធនសំរាប់ការនាំចេញ**

១១៦. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាមិនទាន់បានកំណត់ពីគោលនយោបាយ ឬ វិធានការទាក់ទងនឹងការផ្តល់ហិរញ្ញវត្ថុសំរាប់នាំចេញ ឬការជួយជ្រោមជ្រែងលើការនាំចេញនៅឡើយទេ។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ក្រសួងពាណិជ្ជកម្មបានចេញសេចក្តីប្រកាសលេខ ៣៨៣ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់នាយកដ្ឋានជំរុញការនាំចេញ ដោយយោងតាមអនុក្រឹត្យរបស់រដ្ឋាភិបាលលេខ ៥៤ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧។ នាយកដ្ឋាននោះមានតួនាទីដឹកនាំរាល់សកម្មភាពជំរុញការនាំចេញ ដូចជាការជួយជ្រោមជ្រែងវិស័យឯកជនក្នុងការប្រមូលពត៌មានស្តីពីទីផ្សារបរទេស. កំណត់ពីសក្តានុពលនៃឳកាសនាំចេញ និងចូលរួមក្នុងការដឹកនាំពិព័រណ៍ពាណិជ្ជកម្ម។ ចំពោះការលើកទឹកចិត្តសំរាប់ការនាំចេញ លោកបានកត់សំគាល់ថា មាត្រា ១៤ នៃច្បាប់វិនិយោគទុនចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤ បានចែងពីការលើកលែងពន្ធនាំចូល ១០០ភាគរយ លើសំភារៈ សំណង់ មធ្យោបាយផលិតកម្ម. សំភារៈបរិក្ខារ ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់ ដែលប្រើប្រាស់ក្នុងគំរោងវិនិយោគផលិតដើម្បីនាំចេញដែលយ៉ាងតិច៨០ភាគរយនៃផលិតកម្មនោះសំរាប់នាំចេញ"។ ដោយផ្អែកលើគោលការណ៍ជាមូលដ្ឋានគំរោងទាំងអស់ដែលទទួលបានការឯកភាពសិទ្ធិពីការលើកលែងពន្ធនេះ។

១១៧. សមាជិកមួយចំនួនបានកត់សំគាល់ថា ការលើកទឹកចិត្តដែលមានចែងក្នុងច្បាប់ស្តីពីវិនិយោគទុនគឺអាស្រ័យលើលទ្ធភាពនៃការនាំចេញ។ មាត្រា៣ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបតបានហាមឃាត់ការឧបត្ថម្ភធនបែបនេះ ហើយសមាជិកទាំងនេះបានសាកសួរជាបន្តបន្ទាប់អោយកម្ពុជាបង្ហាញថា តើកម្ពុជាធ្វើបែបណាដើម្បីលុបបំបាត់ការឧបត្ថម្ភធនលើការនាំចេញដែលហាមឃាត់បែបនោះពីពាណិជ្ជកម្មរបស់ខ្លួន? នៅក្នុងទស្សនៈរបស់សមាជិកទាំងនោះ សំណើណាមួយ ក៏ដោយដែលស្នើរសុំអោយមានអន្តរកាលសំរាប់កម្ពុជាគួរភ្ជាប់ជាមួយនឹងការសន្យាក្បោះក្បាយក្នុងការលុបបំបាត់ការអនុវត្តន៍ដែលមិនស្របទៅនឹងគោលការណ៍អង្គការពាណិជ្ជកម្មពិភពលោក។ ប្រទេសជាសមាជិកទាំងនោះបានរំលឹកកម្ពុជាថា ទោះបីជាប្រទេសក្រីក្រមានសិទ្ធិប្រើប្រាស់ការឧបត្ថម្ភធនបែបនេះក៏ដោយក៏វិធានការទាំងនោះនៅតែអាចត្រូវបានគេប្តឹងតវ៉ាតាមកិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបត ដែលបណ្តាលអោយប៉ះពាល់ដល់លទ្ធភាពនៃការព្យាករណ៍ និង តំលាភាពដែលអ្នកវិនិយោគទុននិងអ្នកប្រើប្រាស់ត្រូវការ។

១១៨. តំណាងប្រតិភូកម្ពុជាបានចាត់ទុកការលើកលែងពន្ធនាំចូលចំពោះសំភារៈផលិតកម្មនៃគំរោង ដែលមានទិសដៅនាំចេញគឺដូចគ្នា ទៅនឹងការលើកលែងដែលបានចែងនៅក្នុងមាត្រា ១ (កំណត់សំគាល់ ទី១) និងកថាខ័ណ្ឌ (ជ) នៃឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបត។ លោកបានទទួលស្គាល់ថាគោលការណ៍កាត់ពន្ធទុកនឹងជាវិធីសាស្ត្រដ៏ប្រសើរមួយសំរាប់ដោះស្រាយបញ្ហានេះ ប៉ុន្តែបច្ចុប្បន្នកម្ពុជានៅខ្វះខាតធនធានរដ្ឋបាល ដើម្បីអនុវត្តគោលការណ៍នេះអោយបានត្រឹមត្រូវ។ លោកបានចាត់ទុកថាបណ្តាប្រទេស

ក្រីក្រទាំងនោះក្នុងករណីណាក៏ដោយមិនត្រូវបានអនុញ្ញាតិអោយអនុវត្តមាត្រា ៣.១(ក) ដោយអាស្រ័យលើមាត្រា ២៧.២ នៃកិច្ចព្រមព្រៀង ស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបត។

១១៩. សមាជិកខ្លះបានចាត់ទុកប្រព័ន្ធដែលមិនយកកំរៃលើការនាំចូល ឬការមិនយកពន្ធលើការនាំចូលចំពោះផលិតផលមួយចំនួន ដែលនាំចូលដោយវិនិយោគិនខ្លះបានធ្វើអោយស្មុកស្មាញកាន់តែខ្លាំងបាត់បង់តំលាភាព និងធ្វើអោយច្បាប់ងាយនឹងត្រូវបានបំពាន ហើយបានជំរុញកម្ពុជាអោយអនុវត្តគោលការណ៍កាត់ពន្ធទុកមុនអោយស្របតាមកិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបត។ ការអាក់ខានមិនបានអនុវត្តគោលការណ៍កាត់ពន្ធទុកមុនធ្វើការសងប្រាក់ពន្ធលើទំនិញនាំចេញមានក៏រិត។ កម្មវិធីអនុវត្តបច្ចុប្បន្នគួរត្រូវធ្វើសេចក្តីជូនដំណឹងក្នុងលក្ខណៈជាការឧបត្ថម្ភធនព្រោះកម្មវិធីនេះមិនមែនជាគោលការណ៍កាត់ពន្ធទុក ដែលច្បាប់អនុញ្ញាតិទេ។

១២០. តំណាងប្រតិភូកម្ពុជាបញ្ជាក់ថា កម្មវិធីឧបត្ថម្ភធននានា ដែលបានផ្តល់ដោយរដ្ឋាភិបាលកម្ពុជា និងត្រូវបានរៀបចំឡើងវិញ បន្ទាប់ពីបានចូលជាសមាជិករួចមកអោយស្របតាមកិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបត រួមទាំងមាត្រា ២៧ ហើយរាល់ពតិមានសំខាន់ៗ ស្តីពីនយោបាយឧបត្ថម្ភធនសំរាប់នាំចេញ និងកម្មវិធីដទៃទៀតដែលអាចជំរាបជូនបាន នឹងត្រូវបានជំរាបអោយគណៈកម្មាធិការលើវិធានការឧបត្ថម្ភធន និងវិធានការតបតបានដឹងដោយយោងតាមមាត្រា២៥ នៃកិច្ចព្រមព្រៀងនេះនៅពេលដែលពិធីសារនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជាចូលជាធរមាន។ លោកបានបញ្ជាក់ផងដែរថា ប្រសិនបើចាំបាច់កម្ពុជានឹងលុបចោលប្រព័ន្ធមិនយកកំរៃនាំចូល និងការលើកលែងពន្ធលើទំនិញនាំចូលមួយចំនួនដែលនាំចូលដោយវិនិយោគិនខ្លះ ឬបង្កើតប្រព័ន្ធកាត់ពន្ធទុកមុនអោយស្របតាមប្រការដែលមានចែងក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក តាមរយៈវិសោធនកម្មច្បាប់វិនិយោគទុននៅដំណាច់ឆ្នាំ ២០១៣។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## ៣. គោលនយោបាយផ្ទៃក្នុង ដែលជះឥទ្ធិពលដល់ការធ្វើ ពាណិជ្ជកម្មក្រៅប្រទេស ផ្នែកទំនិញ

### <u>គោលនយោបាយឧស្សាហកម្ម, រួមទាំងឧបត្ថម្ភធន</u>

១២១. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា គោលបំណងនៃគោលនយោបាយឧស្សាហកម្មរបស់កម្ពុជាគឺសំដៅជំរុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយបង្កើនការបើកទីផ្សារអន្តរជាតិនិងពង្រឹងមូលដ្ឋានឧស្សាហកម្ម។ ការខិតខំប្រឹងប្រែងបានផ្តោតជាសំខាន់លើការស្ថាបនាឧស្សាហកម្មធុនស្រាល និងការអភិវឌ្ឍន៍ផលិតកម្មផ្នែកកសិកម្ម និងសហគ្រាសផលិតម្ហូបអាហារ ដើម្បីធ្វើអោយមាននិរន្តរ៍ភាពនៃវិស័យកសិកម្ម។ វិធានការជាច្រើនត្រូវបានអនុវត្ត ដើម្បីធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសំរាប់ការដឹកជញ្ជូន និងទូរគមនាគមន៍

លើកទឹកចិត្តផ្នែកឯកជននិងលើកទឹកចិត្តវិនិយោគទុនផ្ទាល់ពីបរទេស តាមរយៈការអនុម័តក្របខ័ណ្ឌច្បាប់ត្រឹមត្រូវ និងការធ្វើឯកជនភាវូបនីយកម្ម នៃសហគ្រាសរដ្ឋ និងជំរុញការអភិវឌ្ឍន៍តំបន់ឧស្សាហកម្ម។ ការចាប់អារម្មណ៍ជាពិសេស គឺការបណ្តុះបណ្តាលកម្មកររោងចក្រទាំងអស់។ ការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលប្រេងឥន្ធនៈ និងវិទ្យាស្ថានបណ្តុះបណ្តាលរ៉ែ និងភូគព្ភសាស្ត្រត្រូវបានយកមកពិចារណា។ ក្រសួងដែលទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍គោលនយោបាយឧស្សាហកម្មរបស់កម្ពុជាគឺ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ លោកបានបញ្ជាក់ថា កម្ពុជាមិនបានផ្តល់ការឧបត្ថម្ភធនណាមួយក្នុងក្របខ័ណ្ឌនៃគោលនយោបាយឧស្សាហកម្មរបស់ខ្លួនទេ។

១២២. តំណាងប្រតិភូកម្ពុជាបានថ្លែងថា រាល់កម្មវិធីឧបត្ថម្ភធននានា ត្រូវគ្រប់គ្រងដោយស្របទៅនឹងកិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងវិធានការតបត ហើយកម្មវិធីនេះនឹងត្រូវជូនដំណឹងទៅគណៈកម្មាធិការវិធានការឧបត្ថម្ភធន និងវិធានការតបតនៅពេលកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម, វិធានការអនាម័យ និងភូតគាមអនាម័យ

### ក) ស្តង់ដារ និងវិញ្ញាបនប័ត្រ

១២៣. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ប្រព័ន្ធស្តង់ដាររបស់កម្ពុជាស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍។ គាត់បានជំរាបក្រុមការងារថា កម្ពុជាត្រូវការជំនួយបច្ចេកទេស ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធស្តង់ដាររបស់ខ្លួន។ បញ្ជីតំរូវការ និងការអនុវត្តន៍របាំងបច្ចេកទេស (TBT) របស់ព្រះរាជាណាចក្រកម្ពុជាបានផ្តល់នៅក្នុងឯកសារ WT/ACC/ KHM/8 ។ ប្រព័ន្ធស្តង់ដារបច្ចុប្បន្នជាប្រព័ន្ធស្ម័គ្រចិត្ត ប៉ុន្តែស្តង់ដារជាកាតព្វកិច្ចបានអនុវត្តចំពោះផលិតផលខ្លះដែលចាំបាច់ចំពោះការការពារសន្តិសុខជាតិ ទប់ស្កាត់ការក្លែងបន្លំ ឬការពារជីវិត ឬសុខភាពមនុស្ស សត្វ និងរុក្ខជាតិ។

១២៤. សមាជិកខ្លះបានរំលឹកកម្ពុជាថា កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មមិនបានតំរូវអោយកម្ពុជាបង្កើតស្តង់ដារ បទបញ្ញត្តិបច្ចេកទេស ឬនីតិវិធីវាយតំលៃផលិតផលទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រការចែងនានា នៃកិច្ចព្រមព្រៀងនេះបានអនុវត្តនៅពេលដែលវិធានការនេះត្រូវបង្កើតឡើង និងចូលជាធរមាន។ កិច្ចព្រមព្រៀងនេះបានបង្កើតឡើងនូវវិធានជាមូលដ្ឋាន និងនិតិវិធីនៃការបង្កើតការអនុម័ត និងការអនុវត្តន៍ស្តង់ដារតាមគោលការណ៍ស្ម័គ្រចិត្ត បទបញ្ញត្តិបច្ចេកទេស និងនីតិវិធីដែលបានប្រើ ដើម្បីកំណត់ថាតើផលិតផលមួយមានគុណភាពតាមស្តង់ដារកំណត់ដែរឬទេ? ករណីនេះជាកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការបង្កើតវិធីសាស្ត្រ

សំរបសំរួលដើម្បីបង្កើតអនុម័ត និងអនុវត្តស្តង់ដារ បទបញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតំលៃដើម្បីធានាថា រាល់ក្រសួង ភ្នាក់ងារ និងក្រុមហ៊ុនឯកជនទាំងអស់ចូលរួមក្នុងសកម្មភាពទាំងនេះ ហើយត្រូវបានជំរាបអោយដឹងពីកាតព្វកិច្ច និងគោរពតាមដំណើរការដែលកំពុងប្រព្រឹត្តិទៅ ។ ផលប្រយោជន៍ណាមួយចំពោះសមាជិកទាំងអស់ ដោយរួមទាំងការប្រើស្តង់ដារអន្តរជាតិ អនុសាសន៍ ឬការណែនាំក្នុងការបកស្រាយអំពីស្តង់ដារ បទបញ្ញត្តិបច្ចេកទេស ឬវិញ្ញាបនប័ត្រនៅកម្ពុជា ការធ្វើអោយស៊ីគ្នារវាងស្តង់ដារជាតិ និងស្តង់ដារអន្តរជាតិ យន្តការបោះពុម្ពផ្សព្វផ្សាយពង្រាងច្បាប់ និងស្តង់ដារសំរាប់សាធារណៈជនផ្តល់មតិមុនការចូលជាធរមាន នៃច្បាប់នោះ. ការបង្កើតការិយាល័យផ្តល់ពត៌មានអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដំណើរការត្រួតពិនិត្យទំនិញនាំចូលទល់នឹងទំនិញផលិតក្នុងស្រុក ការទទួលស្គាល់ភាពស្មើគ្នានៃបទបញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតំលៃគុណភាពទំនិញរបស់ប្រទេសដទៃទៀត និងការទទួលស្គាល់ភាពស្របតាមនៃនីតិវិធីវាយតំលៃគុណភាពទំនិញ ដែលបានអនុវត្តដោយមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់នៅតាមបណ្តាប្រទេសផលិត និងដោយមានការចូលរួមរបស់កម្ពុជាក្នុងកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលទាក់ទងនឹងស្តង់ដារ ឬកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមក ។

១២៥. តំណាងប្រតិភូកម្ពុជាបានឆ្លើយតបថា ការិយាល័យស្តង់ដារនៃនាយកដ្ឋានបច្ចេកទេសនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទទួលខុសត្រូវលើកិច្ចការបច្ចុប្បន្នដែលទាក់ទងទៅនឹងស្តង់ដារ និងការផ្តល់វិញ្ញាបនប័ត្រ ។ អនុក្រឹត្យស្តីពីស្តង់ដារឧស្សាហកម្មលេខ 42/ANK/BK ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០០១ បានបង្កើតច្បាប់ និងនីតិវិធីជាមូលដ្ឋាន សំរាប់ការអនុម័តស្តង់ដារថ្មីៗ បទបញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតំលៃស្តង់ដាររបស់ផលិតផល ។ លោកបានជឿថា អនុក្រឹត្យស្តីពីមាត្រសាស្ត្រនឹងត្រូវអនុម័តក្នុងឆ្នាំ ២០០៣ នេះ ។ ច្បាប់ថ្មីមួយ ស្តីពីស្តង់ដារឧស្សាហកម្មកម្ពុជា គឺស្ថិតនៅក្នុងការរៀបចំ និងត្រៀមប្រកាសអោយប្រើនៅត្រីមាសទី១ ឆ្នាំ២០០៤ ។ អនុក្រឹត្យ និងបទបញ្ញត្តិផ្សេងៗទៀត នឹងត្រូវដាក់អោយប្រើដើម្បីអនុវត្តច្បាប់ថ្មីនេះ ។ ច្បាប់នេះត្រូវបានដាក់ជូនក្រុមការងារដើម្បីពិនិត្យរួចហើយ ។

១២៦. ច្បាប់ថ្មីនេះបានកំណត់អោយបង្កើតនាយកដ្ឋានស្តង់ដារ ឧស្សាហកម្មកម្ពុជា (ISC) ចំណុះអោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ គាត់បានបន្ថែមថា នាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជាបានបង្កើតឡើងកាលពីឆ្នាំ ២០០២ តាមអនុក្រឹត្យលេខ ១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ នាយកដ្ឋានស្តង់ដារ ឧស្សាហកម្មកម្ពុជាមានតួនាទីជាការិយាល័យផ្តល់ពត៌មានអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដែលទទួលខុសត្រូវក្នុងការធ្វើសេចក្តីជូនដំណឹងទៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកនៅក្រោមកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម ។ នាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា នឹងបោះពុម្ពព្រឹត្តិប័ត្រសារពិមានជាប្រចាំអំពីបទបញ្ញត្តិបច្ចេកទេសដែលបានស្នើរឡើង និងនិតិវិធីវាយតំលៃគុណភាពផលិតផល ។ រយៈពេលសំរាប់ការផ្តល់យោបល់ជាសាធារណៈលើពង្រាងស្តង់ដារ នឹងត្រូវបានពន្យារពេលរហូតដល់៦០ថ្ងៃ ៣០ថ្ងៃ ចំពោះស្តង់ដារដែលបាន

ធ្វើវិសោធនកម្ម និង ៤៥ថ្ងៃចំពោះស្តង់ដារថ្មី ដែលបានបញ្ជាក់ច្បាស់នៅក្នុងច្បាប់បច្ចុប្បន្ន។ ពង្រាងច្បាប់ស្តង់ដារថ្មីកំពុងត្រូវបានរៀបចំ។

១២៧. កម្ពុជាបានចូលជាសមាជិកនៃអង្គការស្តង់ដារអន្តរជាតិ (ISO) តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៥ និងបានផ្តល់សច្ចាប័នក្របខ័ណ្ឌកិច្ចព្រមព្រៀងអាស៊ានស្តីពីកិច្ចការទទួលស្គាល់ទៅវិញទៅមក។ ទំនិញនាំចូលក៏មានការត្រួតពិនិត្យដូចគ្នានឹងទំនិញដែលផលិតក្នុងស្រុកដែរ ហើយកម្ពុជានឹងផ្តល់ការអនុវត្តន៍ដូចគ្នានេះដល់ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ ដូចគ្នាទៅនឹងបណ្តាប្រទេសជាសមាជិកអាស៊ានដែរ។ កម្ពុជាបានទទួលស្គាល់វិញ្ញាបនប័ត្របញ្ជាក់គុណភាពពីអង្គការ នៃប្រទេសទីបីក្នុងករណីអង្គការទាំងនេះបានទទួលសិទ្ធិជាផ្លូវការពីអង្គការទទួលស្គាល់គុណភាពក្នុងតំបន់ និងអន្តរជាតិ ឬមានការ ចុះហត្ថលេខាទទួលស្គាល់ទៅវិញទៅមក។ ក្នុងករណីផលិតផលឱសថ ការពិសោធន៍នៅក្នុងប្រទេសកម្ពុជាត្រូវធ្វើជាចាំបាច់មុនការចុះបញ្ជីដើម្បីពិនិត្យមើលគុណភាពនៃទំនិញគំរូ។

១២៨. ការងារដែលត្រូវបំពេញផែនការសកម្មភាព និងជំនួយបច្ចេកទេសដែលត្រូវការពីឆ្នាំ ១៩៩៩ ដល់ ឆ្នាំ ២០០៦ មានចែងយ៉ាងល្អិតល្អន់នៅក្នុងផែនការសកម្មភាពរបស់កម្ពុជាសំរាប់ការអនុវត្តន៍កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មមានក្នុងឯកសារ WT/ACC/KHM/14 ហើយផែនការសកម្មភាពនេះ ក៏ត្រូវបានកែប្រែបន្តបន្ទាប់នៅក្នុងឯកសារ WT/ACC/KHM/Rev.1 ។ ផែនការសកម្មភាពនេះត្រូវបានសង្ខេបនៅក្នុងតារាង១០។ ដោយពិនិត្យផែនការសកម្មភាពរបស់កម្ពុជាសមាជិកខ្លះបានចោទសួរថា កម្ពុជាត្រូវការរយៈពេល ២ឆ្នាំទៀតដើម្បីកែសំរួលបទបញ្ញត្តិបច្ចេកទេស. ស្តង់ដាររបស់ខ្លួន ដើម្បីអនុវត្តន៍អោយបានត្រឹមត្រូវដូចដែលបានចែងនៅក្នុងមាត្រា ២.៣ នៃកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដែលតំរូវអោយមានភាពសមរម្យ និងប្រសិទ្ធភាពនៃស្តង់ដារចំពោះផលិតផលមួយចំនួន និងបទបញ្ញត្តិបច្ចេកទេសមួយចំនួនដែលត្រូវតែពិនិត្យឡើងវិញជារឿយៗ។ កម្ពុជាគួរចាប់ផ្តើមជាបន្ទាន់ ដើម្បីបំពេញនូវតំរូវការតំលាភាពនៃកិច្ចព្រមព្រៀង ។ កម្ពុជាត្រូវបានជំរុញអោយជូនដំណឹងអំពីបទបញ្ញត្តិ ដែលបានស្នើរឡើងដល់សមាជិកអង្គការពាណិជ្ជកម្មពិភពលោកមុនពេលអនុម័ត និងពិចារណាយ៉ាងយកចិត្តទុកដាក់លើការសុំយោបល់ផ្នែកបច្ចេកទេសពីសមាជិកនានា ចំពោះបទបញ្ញត្តិខាងលើមុននឹងធ្វើការអនុម័ត។ ដោយកត់សំគាល់លើសំណើរបស់កម្ពុជាចំពោះជំនួយបច្ចេកទេស សមាជិកខ្លះបានសង្កត់ធ្ងន់ថា កម្ពុជាមិនគួរស្នើរសុំអោយមានការអនុវត្តន៍កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មដោយភ្ជាប់លក្ខខ័ណ្ឌនៃការផ្តល់ជំនួយបច្ចេកទេសនៅពេលអនាគតទេ។

១២៩. រដ្ឋាភិបាលកម្ពុជាបានស្នើរសុំអោយក្រុមការងារផ្តល់រយៈពេលអន្តរកាលចាប់ពីថ្ងៃបានចូលជាសមាជិករហូតដល់ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ សំរាប់ការអនុវត្តន៍កិច្ចព្រមព្រៀង របស់អង្គការពាណិជ្ជកម្មពិភពលោក

ស្តីអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដែលការធ្វើបែបនេះអនុញ្ញាតិអោយកម្ពុជាប្រើប្រាស់ជំនួយបច្ចេកទេស ដើម្បីអនុវត្តអោយបានពេញលេញនូវកាតព្វកិច្ចរបស់កិច្ចព្រមព្រៀង ។ ក្នុងរយៈពេលអន្តរកាលនេះ វិធានការនានា ដែលកំពុងប្រើប្រាស់ត្រូវអនុវត្តលើគោលការណ៍ស្មើភាពចំពោះការនាំចូលពីគ្រប់ប្រទេសជាសមាជិកទាំងអស់ ។ វិធានការនានាដែលកំពុងអនុវត្ត ដែលមិនផ្ទុយទៅនឹងកិច្ចព្រមព្រៀងស្តីអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម នឹងមិនទទួលបានរយៈពេលអន្តរកាលទេ ហើយកម្ពុជាធានាថា ការធ្វើវិសោធនកម្មលើច្បាប់ ឬបទបញ្ញត្តិ ឬការអនុវត្តន៍ណាមួយក្នុងរយៈពេលអន្តរកាលនេះ នឹងមិនបន្ថយកំរិតនៃភាពស្របគ្នាទៅនឹងប្រការចែងនានា របស់កិច្ចព្រមព្រៀងជាងពេលដែលកម្ពុជា បានចូលជាសមាជិកនោះទេ ។ ស្តង់ដារ បទបញ្ញត្តិបច្ចេកទេស និងនិតិវិធីវាយតំលៃគុណភាពទំនិញ ដែលអនុម័តក្នុងរយៈពេលអន្តរកាលត្រូវតែបង្កើតឡើងអោយស្របតាម ប្រការចែងនានានៃកិច្ចព្រមព្រៀង ។ កម្ពុជានឹងចូលរួមយ៉ាងពេញលេញក្នុងគណៈកម្មាធិការរបាំងបច្ចេកទេស ចំពោះពាណិជ្ជកម្ម ។ គាត់បានបន្ថែមថា កម្ពុជានឹងស្វែងរកជំនួយបច្ចេកទេសគ្រប់បែបយ៉ាងដែលមាន ដើម្បីធានា អោយសមត្ថភាពរបស់កម្ពុជាអាចអនុវត្តកិច្ចព្រមព្រៀងបានបន្ទាប់ពីរយៈពេលអន្តរកាលចប់សព្វគ្រប់ ។

១៣០. ឆ្លើយតបទៅនឹងសំណើរបស់បណ្តាប្រទេសសមាជិកនានាអំពីភាពច្បាស់លាស់ថែមទៀត តំណាងប្រតិភូ កម្ពុជាបានបង្ហាញផែនការសកម្មភាពដែលបានចែងយ៉ាងក្បោះក្បាយអំពីសកម្មភាពនានា ដែលត្រូវអនុវត្តដើម្បី សំរេចបាននូវគោលដៅនេះព្រមទាំងការវិភាគសំរាប់ការអនុវត្តន៍ផងដែរ ( សូមពិនិត្យមើល តារាង១០) ។

**តារាង១០ : ផែនការសកម្មភាពសំរាប់អនុវត្តកិច្ចព្រមព្រៀងស្តីអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម**

| **សកម្មភាព** | **កាលបរិច្ឆេទ** |
|---|---|
| - ការអនុម័តអនុក្រឹត្យស្តីពីស្តង់ដារឧស្សាហកម្មលេខ 42/ANK/BK<br>- ការអនុម័តអនុក្រឹត្យស្តីអំពីមាត្រសាស្ត្រ<br>- ការអនុវត្តន៍ការកែតំរូវសេចក្តីជូនដំណឹងស្តីពីការចុះបញ្ជី នៃផលិតផល ឧស្សាហកម្ម | ១៩៩៩-២០០២ |
| - ចាត់តាំងនាយដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជាជាអាជ្ញាធរទទួលខុស ត្រូវក្នុងការជូនដំណឹង និងផ្សព្វផ្សាយពត៌មានដែលតំរូវដោយកិច្ច ព្រមព្រៀងស្តីពីរបាំង បច្ចេកទេសចំពោះពាណិជ្ជកម្ម ។<br>- បង្កើតការិយាល័យផ្តល់ពត៌មាន នៅក្នុងនាយកដ្ឋានស្តង់ដារឧស្សាហកម្ម កម្ពុជា<br>នាយដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>លេខ៤៥ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា<br>ទូរសារ : ៨៥៥-២៣ ២១៦ ០៨១<br>អ៊ីម៉ែល: discinfor@camnet.com.kh | ២០០៣ |

| | |
|---|---|
| - បង្កើតបណ្ណាល័យ សំរាប់របាំងបច្ចេកទេស ចំពោះពាណិជ្ជកម្មនៅនាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា<br>- បំពាក់ឧបករណ៍ មន្ទីរពិសោធន៍នៅនាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា<br>- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីទទួលខុសត្រូវ ស្តង់ដារសំខាន់ៗ ក្នុងវិស័យស្តង់ដារ ការគ្រប់គ្រង វិធីសាស្ត្រ និងនិតិវិធីសំរាប់ការជ្រើសរើសគំរូផលិតផល ត្រួតពិនិត្យ និងសំរាប់មន្ត្រីអធិការកិច្ច និងមន្ត្រីទទួលខុសត្រូវការធ្វើតេស្ត និងផ្តល់ វិញ្ញាបនប័ត្រ និងអាជ្ញាប័ណ្ណ។ | ២០០៣ |
| - ក្រុមការងារពិនិត្យច្បាប់ និងបទបញ្ញត្តិនានា | មុនការចូលសមាជិក |
| - ដាក់ជូនអង្គការពាណិជ្ជកម្មពិភពលោក ពិនិត្យនូវសេចក្តីប្រកាសពីការអនុវត្តន៍ កិច្ចព្រមព្រៀង | នៅពេលចូលជា សមាជិក |
| - ដាក់អោយប្រើច្បាប់ស្តីពីស្តង់ដារឧស្សាហកម្ម និងការអនុម័តអនុក្រឹត្យ និងបទបញ្ញត្តិនានាសំរាប់អនុវត្ត<br>- ធ្វើអោយស្របតាមទំលាប់នៃការអនុវត្តន៍ដ៏ប្រសើរ<br>- បង្កើតបទបញ្ញត្តិបច្ចេកទេស និងនិតិវិធីវាយតំលៃគុណភាពទំនិញសំរាប់ការអនុវត្តន៍កិច្ចព្រមព្រៀងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (មានចែងក្នុង ឯកសារ WT/ACC/KHM/14/Rev.1) | មុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤ |
| - បោះពុម្ពព្រឹត្តិប័ត្រស្តង់ដារដោយទៀងទាត់ដោយនាយដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា អំពីសកម្មភាពពាក់ព័ន្ធទៅនឹង បទដ្ឋានបច្ចេកទេស ស្តង់ដារ និងនិតិវិធីវាយតំលៃគុណភាពទំនិញ | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ |
| - បណ្តុះបណ្តាលមន្ត្រីស្តង់ដារអំពីពាណិជ្ជកម្មអន្តរជាតិ និងការអនុវត្តន៍របាំង បច្ចេកទេសចំពោះពាណិជ្ជកម្ម<br>- ពិនិត្យ និងកែតំរូវបទដ្ឋានបច្ចេកទេស និងនិតិវិធីអោយស្របតាមការរកឃើញ ថ្មីៗនៃវិទ្យាសាស្ត្រ | ២០០៥-២០០៦ |
| - អនុវត្តឱ្យបានពេញលេញកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម | មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ |

១៣១. តំណាងប្រតិភូកម្ពុជាបញ្ជាក់ថា កម្ពុជានឹងអនុវត្តកិច្ចព្រមព្រៀងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មជាបណ្តើរៗទៅតាមផែនការសកម្មភាពនៅក្នុងតារាង១០ ហើយយល់ឃើញថា ក្នុងរយៈពេលនេះទំហំនៃការអនុវត្តន៍ទិដ្ឋភាពផ្សេងៗទៀត នៃកិច្ចព្រមព្រៀងដូចមានចែងក្នុងកថាខ័ណ្ឌ១២៩ នឹងត្រូវបានអនុវត្តដោយកម្ពុជាផងដែរ។ ការអនុវត្តន៍កិច្ចព្រមព្រៀងនេះដោយពេញលេញនឹងចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ ដោយមិនស្នើសុំអោយមានរយៈពេលអន្តរកាលបន្ថែមទៀតទេ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## ២). វិធានការអនាម័យ និងវិធានការភូតគាមអនាម័យ

១៣២. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា វិធានការអនាម័យ និងភូតគាមអនាម័យ ដែលកំពុងអនុវត្តនៅកម្ពុជា ផ្អែកលើមូលដ្ឋាន នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពនៃផលិតផល និង សេវាកម្ម ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ អនុក្រឹត្យស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៨ អនុក្រឹត្យស្តីពីភូតគាមអនាម័យ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៨៣ និង អនុក្រឹត្យស្តីពីស្តង់ដារ និងការគ្រប់គ្រងបរិក្ខាកសិកម្មចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨។ ចំពោះការងារបន្តដើម្បីធានាដល់ការអនុវត្តន៍ ដើម្បីអោយបានស្របតាមកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍វិធានការអនាម័យ និងភូតគាមអនាម័យ (SPS Agreement) ដែលទាក់ទងដល់ការរៀបចំឡើងវិញនូវអនុក្រឹត្យឆ្នាំ១៩៨៣ និង១៩៨៨ ក៏ដូចជាការរៀបចំអនុក្រឹត្យនិងបទបញ្ជាថ្មីៗ ដែលទាក់ទងដល់អនាម័យចំណីអាហារ ការបិតផ្លាកសញ្ញា និងលក្ខខ័ណ្ឌសុវត្ថិភាព ដូចមានចែងក្នុងតារាងអនាម័យ និងភូតគាមអនាម័យនៃឯកសារ WT/ACC/KHM/9 និងផែនការសកម្មភាពសំរាប់អនុវត្តកិច្ចព្រមព្រៀងស្តីអំពីអនាម័យ និង ភូតគាមអនាម័យដែលមានចែងក្នុងឯកសារ WT/ACC/KHM/15 ហើយឯកសារនោះបានកែសំរួលជាបន្តនៅក្នុងឯកសារ WT/ACC/KHM/15/Rev.1 ។

១៣៣. គាត់បានបញ្ជាក់ថា ក្នុងចំណោមសកម្មភាពនានា ដែលបានអនុវត្តពីឆ្នាំ២០០១ និង២០០២ កម្ពុជាបានបង្កើតឡើងនូវគណៈកម្មាធិការជាតិកូដិច (Codex) និងក្រុមការងារបច្ចេកទេស ដែលជួបប្រជុំជាទៀងទាត់ ហើយការិយាល័យ Codex ត្រូវបានបង្កើតឡើងនៅគ្រប់ក្រសួងពាក់ព័ន្ធទាំងអស់ ដើម្បីផ្តល់នូវយោបល់ព្រមទាំងចូលរួមយ៉ាងសកម្ម ក្នុងការធ្វើអោយគណៈកម្មាធិការមានដំណើរការល្អ។ មន្ទីរពិសោធន៍សំរាប់វិភាគសារជាតិគីមី និងអាហារជីវសាស្ត្រ នៅនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនិហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ ត្រូវបានពង្រឹងស្ថានីយ៍ចត្តាឡីស័ក្តសំរាប់រុក្ខជាតិ និងសត្វត្រូវបានបង្កើតឡើង ហើយកម្មវិធីត្រួតពិនិត្យជំងឺសត្វ និងរុក្ខជាតិត្រូវបានតាក់តែងឡើងក្នុងផ្នែកមួយចំនួនស្តីពីការតាមដានត្រួតពិនិត្យជំងឺសត្វ រុក្ខជាតិ និងជំងឺប៉េស្ត មន្ត្រីទទួលបន្ទុកការងារនេះត្រូវបានទទួលការបណ្តុះបណ្តាលអំពីការវិភាគពីភាពគ្រោះថ្នាក់ ហើយកម្ពុជាបានអនុវត្តកម្មវិធីបណ្តុះបណ្តាលក្នុងវិស័យចត្តាឡីស័ក្តរុក្ខជាតិ និងសត្វ. ការវិភាគ រោគវិនិច្ឆ័យ និងការធ្វើតេស្តផលិតផលនិងការការពារជំងឺរុក្ខជាតិ និងសត្វ។ សេចក្តីព្រាងអនុក្រឹត្យលើទី ១ ស្តីពីអនាម័យអាហាររួម ទាំងតំរូវការនៃការរក្សាទុក ព្រមទាំងតំរូវការនៃអាហារជីវសាស្ត្រត្រូវបានធ្វើចប់សព្វគ្រប់។

១៣៤. លោកបានបន្ថែមទៀតថា គណៈកម្មាធិការ Codex ជាតិ នៃក្រសួងពាណិជ្ជកម្ម នឹងដើរតួជាការិយាល័យផ្តល់ពត៌មានស្តីពីអនាម័យ និងភូតគាមអនាម័យរបស់កម្ពុជា។ ឧបមាថា ជំនួយបច្ចេកទេស នឹងត្រូវបានផ្តល់អោយលោកជឿថាការិយាល័យផ្តល់ពត៌មានអាចដំណើរការនៅឆ្នាំ២០០៣។ តំលាភាព ជាមូលដ្ឋាននៃប្រការចែងក្នុងកិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យត្រូវបានបញ្ចូលក្នុងអនុក្រឹត្យស្តីពីចត្តាឡីស័ក្តរុក្ខជាតិ និងសត្វតំរូវអោយមានការផ្សព្វផ្សាយនូវវិធានការ ដែលបានស្នើរឡើងនៅដំណាក់កាលដំបូង និងនីតិវិធីផ្តល់

ពត៌មានដល់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយអនុញ្ញាតិអោយមានរយៈពេលសមស្របសំរាប់ការផ្តល់យោបល់របស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក និង យោបល់របស់សាធារណជន និងបង្កើតបាននូវដំណើរការមិនធ្វើអោយមានការទទួលយក នូវការផ្តល់យោបល់ទាំងដោយគ្មានការរើសអើង។ អនុក្រឹត្យស្តីពីចត្តាឡីស័ក្តរុក្ខជាតិ និងអនុក្រឹត្យស្តីពីការត្រួតពិនិត្យអនាម័យលើសត្វ និងផលិតផលសត្វបានអនុម័តដោយគណៈរដ្ឋមន្ត្រីនាថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៣។ ក្របខ័ណ្ឌនៃការអនុម័តស្តង់ដារ គោលការណ៍ណែនាំ និងអនុសាសន៍ដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិដូចជាៈ (គណៈកម្មាធិការកូដិចអាលីម៉ង់តារីស ការិយាល័យអេពីហ្សូទិចអន្តរជាតិ និងបណ្តាអង្គការ ដែលកំពុងដំណើរការនៅក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញាការពារភូតគាមអន្តរជាតិក្នុងតំបន់ និងអន្តរជាតិ) នឹងត្រូវបញ្ចូលទៅក្នុងច្បាប់ស្តីពីស្តង់ដារឧស្សាហកម្មនៃកម្ពុជា ដែលបានគ្រោងនឹងប្រកាសអោយប្រើប្រាស់នៅត្រីមាសទី១ ឆ្នាំ២០០៣។ បទបញ្ញត្តិផ្សេងៗទៀតដែលរៀបចំក្នុងឆ្នាំ ២០០៣ រួមមានសេចក្តីព្រាងអនុក្រឹត្យស្តីពីស្តង់ដារសុវត្ថិភាពម្ហូបអាហារ និងគ្រឿងបន្ថែម (ដូចជាជាតិផ្អែម ពណ៌ រសជាតិ ការរក្សាទុក និងគ្រឿងប្រឆាំងនឹងជាតិអុកស៊ីតកម្ម) បែបបទនៃការត្រួតពិនិត្យម្ហូបអាហារ ស្តង់ដារសុវត្ថិភាពអាហារអំពីបរិស្ថាន និងការចំលងមេរោគ ស្តង់ដារសុវត្ថិភាពម្ហូបអាហារនៃគីមីកសិកម្ម (ជីងី) សេចក្តីព្រាងច្បាប់ស្តីពីតំរូវការសុវត្ថិភាពផ្លែឈើស្រស់ និងផ្លែឈើកែច្នៃ សេចក្តីព្រាងច្បាប់ស្តីពីតំរូវការសុវត្ថិភាពសំរាប់គ្រាប់ធញ្ញជាតិ សេចក្តីព្រាងការណែនាំអំពីការធានាគុណភាពអាហារសមុទ្រ និងពង្រាង និតិវិធីចុះបញ្ជី និងអនុវត្តការចុះបញ្ជីផលិតផលគ្រឿងសំអាង។

១៣៥. ដោយកត់សំគាល់លើការហាមប្រាមជាបណ្តោះអាសន្នការនាំចូលសាច់, ផលិតផលសាច់ និងផលិតផលដែលមានជាតិទឹកដោះគោពីប្រទេសមួយចំនួនរបស់សហគមន៍អឺរ៉ុប សមាជិកមួយបានចាប់អារម្មណ៍ថា មន្ត្រីគយនៅក្នុងប្រទេសកម្ពុជាបកស្រាយអំពីការហាមឃាត់នោះដោយបញ្ចូលប្រទេសដទៃទៀត ហើយបានសាកសួរថា តើកម្ពុជានឹងធានាបានការមិនរើសអើងចំពោះការអនុវត្តន៍របបអនាម័យ និងភូតគាមអនាម័យរបស់ខ្លួនយ៉ាងដូចម្តេច?

១៣៦. តំណាងប្រតិភូកម្ពុជាបានឆ្លើយតបថា ការហាមឃាត់បណ្តោះអាសន្នត្រូវបានអនុវត្តសំដៅរារាំងជំងឺរាត្បាតដែលបណ្តាលអោយមានគ្រោះថ្នាក់ខ្លាំងដល់សុខភាពមនុស្ស និងសត្វ។ ការហាមឃាត់ត្រូវបានដាក់អោយប្រើដោយសារពត៌មានដែលទទួលបានពីអង្គការ Codex Allimentarius អំពីគ្រោះថ្នាក់ជាដុំកំភួន នៃជំងឺ BSE នៅក្នុងសាច់, ផលិតផលសាច់ និងផលិតផលពីទឹកដោះសត្វ ដែលមានប្រភពពីប្រទេសនៅក្នុងសហគមន៍អឺរ៉ុបមួយចំនួន។ ការហាមឃាត់ការនាំចូលជាបណ្តោះអាសន្ននេះ បានចាប់ផ្តើមធ្វើកាលពីខែមិនា ឆ្នាំ២០០១ តាមប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០៨៩ ហើយការហាមឃាត់នេះត្រូវបានដកចេញកាល ពីខែកញ្ញា ឆ្នាំ២០០១។

១៣៧. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ការសំរេចអោយបាននូវការអនុវត្តន៍អោយស្របទាំងស្រុងទៅតាមកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យគឺជាដំណើរការដ៏ស្មុគ្រស្មាញមួយ ដោយហេតុ

នោះហើយ ទើបកម្ពុជាស្នើរសុំអោយមានរយៈពេលអន្តរកាលក្នុងកំឡុងពេលដែលតំរូវការទាំងអស់អនុវត្តដោយបន្តបន្ទាប់តាមផែនការសកម្មភាពដូចដែលបានសង្ខេបនៅក្នុងតារាង១១ ។ លោកបានសង្កត់ធ្ងន់ថា ល្បឿនក្នុងការអនុវត្តន៏កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យរបស់កម្ពុជាត្រូវពឹងផ្អែកលើលទ្ធភាពជំនួយបច្ចេកទេសពីបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ដែលអាចផ្តល់លទ្ធភាពអោយកម្ពុជាបង្កើតបាននូវបទបញ្ញត្តិថ្មីៗ អោយស្របតាមប្រការចែងរបស់អង្គការពាណិជ្ជកម្មពិភពលោក ហើយធានាដល់ការអនុវត្តន៏ប្រកបដោយប្រសិទ្ធភាព ជាពិសេសតាមរយៈការបណ្តុះបណ្តាល ។

១៣៨. សមាជិកខ្លះបានថ្លែងថា គេបានចាត់ទុកការអនុវត្តន៏កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យជាកត្តាដ៏សំខាន់មួយក្នុងការចូលជាសមាជិករបស់កម្ពុជា។ តាមរយៈការពិនិត្យមើលផែនការសកម្មភាពរបស់កម្ពុជាសមាជិកទាំងនេះនៅស្ទាក់ស្ទើរក្នុងការផ្តល់រយៈពេលបណ្តោះអាសន្នចំនួន៥ឆ្នាំ ដោយគ្មានសេចក្តីណែនាំច្បាស់លាស់ក្នុងការអនុវត្តន៏ ឬសេចក្តីពន្យល់ដើម្បីអាចទទួលបាននូវរយៈពេលអន្តរកាលទេ។ គេសង្កេតឃើញថាកម្ពុជាគួរកំណត់អាទិភាពក្នុងការបង្កើតការិយាល័យផ្តល់ពត៌មានអំពីវិធានការអនាម័យ និងភូតគាមអនាម័យ។ រាល់វិធានការអនាម័យ និងភូតគាមអនាម័យដែលអនុវត្តដោយកម្ពុជាត្រូវជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោក ហើយកម្ពុជាត្រូវរៀបចំខ្លួន ដើម្បីពិគ្រោះយោបល់ជាមួយសមាជិកអង្គការពាណិជ្ជកម្មពិភពលោកក្នុងករណីមានការស្នើរសុំប្រសិនបើវិធានការទាំងនេះជះឥទ្ធិពលមិនល្អដល់ការនាំចេញរបស់ពួកគេ។ រយៈពេល២ឆ្នាំដែលត្រូវការសំរាប់"ការកែតំរូវបទបញ្ញត្តិបច្ចេកទេសស្តង់ដារ ។ ល ។" ត្រូវស្ថិតនៅក្នុងការពិចារណា។ កម្ពុជាត្រូវជំរុញអោយពិចារណាលើការទទួលយកស្តង់ដារអន្តរជាតិក្នុងករណីដែលស្តង់ដារនេះបំពេញតំរូវការរបស់កម្ពុជា ហើយកម្ពុជាក៏គួរពិចារណា លើការប្រើប្រាស់ស្តង់ដារអង្គការពាណិជ្ជកម្មពិភពលោក ដែលបង្កើតឡើងដោយរដ្ឋាភិបាលដទៃទៀតដែរ ។

១៣៩. ជាការឆ្លើយតប តំណាងប្រតិភូកម្ពុជាបានយោងទៅលើផែនការសកម្មភាពសំរាប់ការអនុវត្តន៏នៃកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ ដែលមានជូនភ្ជាប់ក្នុងឯកសារ WT/ACC/KHM/15/ Rev.1, ដែលក្នុងទស្សនៈរបស់គាត់រួមមានគំរោង និងសេចក្តីពិស្តារដ៏ជាក់លាក់ ដែលទាក់ទងនឹងការអនុវត្តន៏។ តាមទស្សនៈនេះការអនុវត្តន៏តាមទាំងស្រុងចំពោះកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យអាចសំរេចបាននៅ ឆ្នាំ២០០៧/២០០៨ ។ កម្ពុជានឹងប្រើប្រាស់ស្តង់ដារអន្តរជាតិ និងស្តង់ដារដែលរៀបចំដោយរដ្ឋាភិបាលដទៃទៀតក្នុងករណីសមស្រប។ លោកបានកត់សំគាល់ថា រដ្ឋសភានិងព្រឹទ្ធសភាបានផ្តល់សច្ចាប័នលើពិធីសារទី៨ ស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានលើការសំរបសំរួល នៃទំនិញឆ្លងកាត់។

១៤០. ផ្អែកលើពត៌មានដែលបានទទួល ស្តីពីការរីកចំរើនរបស់កម្ពុជា និងផែនការត្រូវបន្តធ្វើដូចដែលមានចែងក្នុងឯកសារ WT/ACC/KHM/15/Rev.1 សមាជិកទាំងអស់បានស្នើថា កម្ពុជាគួរតែអាចរៀបចំបង្កើត

អោយមាននូវច្បាប់ នីតិវិធី និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសំរាប់ការអនុវត្តន៍ វិធានការអនាម័យ និងភូតគាមអនាម័យចំពោះការនាំចូលអោយបានស្របតាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកអោយបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ ព្រមទាំងត្រៀមខ្លួនដើម្បីអនុវត្តអោយបានពេញលេញ នូវប្រការចែងនៃកិច្ចព្រមព្រៀងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ និងស្នើសុំអោយមានការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការទទួលយកពេលវេលានៃការអនុវត្តន៍ដោយផ្អែកលើមូលដ្ឋាននេះ ។

១៤១. តំណាងប្រតិភូកម្ពុជាបានស្នើសុំអោយក្រុមការងារផ្តល់រយៈពេលអន្តរកាលចាប់ពីថ្ងៃកម្ពុជាបានចូលជាសមាជិករហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨ ក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីអនាម័យ និងភូតគាមអនាម័យ ដើម្បីអនុញ្ញាតិអោយកម្ពុជាអាចទទួលបាននិងប្រើប្រាស់ជំនួយបច្ចេកទេសសំដៅអនុវត្តអោយបានពេញលេញនូវកាតព្វកិច្ចរបស់កិច្ចព្រមព្រៀង ។ ក្នុងរយៈពេលនេះ វិធានការនានាដែលកំពុងអនុវត្តត្រូវអនុវត្តដោយស្មើភាពទាំងប្រព្រឹត្តិកម្មជាតិ និងគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលការអនុគ្រោះចំពោះការនាំចូលពីគ្រប់ប្រភព។ ចំពោះវិធានការដែលមានបច្ចុប្បន្ន ហើយស្របរួចទៅហើយទៅនឹងប្រការចែងនានានៃកិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យ នឹងមិនត្រូវអនុលោមតាមរយៈពេលអន្តរកាលទេ ហើយកម្ពុជាធានាថា ការធ្វើវិសោធនកម្មលើបទបញ្ញត្តិ និងការអនុវត្តនក្នុងរយៈពេលអន្តរកាលនឹងមិនបណ្តាលអោយថយចុះនូវកំរិតនៃភាពស្របគ្នាទៅនឹងកិច្ចព្រមព្រៀងជាងនៅពេលចូលជាសមាជិកទេ។ បទបញ្ញត្តិបច្ចេកទេសនិងវិធានការដទៃទៀត ដែលអនុម័តអោយប្រើនៅក្នុងរយៈពេលនេះនឹងត្រូវរៀបចំឡើងអោយស្របទៅនឹងប្រការចែងនានា នៃកិច្ចព្រមព្រៀង ។ ការបង្កើតនូវការិយាល័យផ្តល់ពត៌មាន ការផ្តល់ពត៌មានអំពីវិធានការអនាម័យ និងភូតគាមអនាម័យរបស់កម្ពុជាទៅគណៈកម្មាធិការគឺជាអាទិភាពមួយ។ គាត់បន្ថែមថាកម្ពុជានឹង ស្វែងរកជំនួយបច្ចេកទេសដែលអាចរកបាន ដើម្បីធានាថា កម្ពុជានឹងមានសមត្ថភាពក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យបានពេញលេញនៅពេលដែលរយៈពេលអន្តរកាលត្រូវផុតរលត់។ កម្ពុជានឹងចូលរួម ដោយពេញលេញក្នុងគណៈកម្មាធិការស្តីអំពីវិធានការអនាម័យ និងភូតគាមអនាម័យ។ ក្នុងការឆ្លើយតបទៅនឹងសំណូមពររបស់ប្រតិភូ នៃបណ្តាប្រទេសជាសមាជិកអំពីភាពជាក់ស្តែងថែមទៀត តំណាងប្រតិភូកម្ពុជាបានបង្ហាញផែនការសកម្មភាព ដែលចែងយ៉ាងច្បាស់លាស់អំពីជំហានទីមួយដែលត្រូវធ្វើ ដើម្បីសំរេចបាននូវគោលដៅនៃដំណាក់កាលនីមួយៗ (តារាង១១) ។

**តារាង១១ : ផែនការសកម្មភាពសំរាប់អនុវត្តកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ**

| សកម្មភាព | កាលបរិច្ឆេទ |
|---|---|
| ការដាក់អោយប្រើបទបញ្ញត្តិជាមូលដ្ឋាន និងក្របខ័ណ្ឌសំរាប់ដំណើរការដើម្បីអនុវត្តមាត្រា ២-៨ នៃកិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យ<br>- អនុក្រឹត្យស្តីអំពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលពីសត្វ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៨ ( លេខ 14 AR. NOR. KRAR) ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣<br>- អនុក្រឹត្យស្តីអំពីចត្តាឡីស័ករុក្ខជាតិ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៨៣ ( លេខ 98. AR. NOR KRO) ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០០៣<br>- អនុក្រឹត្យស្តីអំពីស្តង់ដារ និងការគ្រប់គ្រងបរិក្ខារកសិកម្ម ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ១៩៩៨ ( លេខ 69 ARNOR KRA/BARKAR)<br>- ច្បាប់ស្តីអំពីការគ្រប់គ្រងសុវត្ថិភាព និងគុណភាពរបស់ផលិតផល និងសេវាចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២000 ។<br>- អនុក្រឹត្យលេខ៥ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរៈក្រសួងសំរាប់សំរបសំរួល និងត្រួតពិនិត្យសុវត្ថិភាព និង គុណភាពទំនិញ និងសេវា ។<br>- ច្បាប់ស្តីពីការគ្រប់គ្រងសុវត្ថិភាព និងគុណភាពផលិតផល និងសេវា ដែលបានប្រកាសអោយប្រើតាមរយៈរាជក្រមលេខ... NS/RKM/0600/001 ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២000 ។<br>- អនុក្រឹត្យលេខ ២៨ ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ Codex និងលេខាធិការដ្ឋាន Codex ។<br>- ប្រកាសលេខ 357/MOC ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសំរាប់គណៈកម្មាធិការ Codex ជាតិ ។ | បានធ្វើរួចសព្វគ្រប់ |

| | |
|---|---|
| ការដាក់អោយប្រើបទបញ្ញត្តិបន្ថែមទៀត សំរាប់អនុវត្តកិច្ចព្រមព្រៀង អនាម័យ និងភូតគាមអនាម័យ : កម្មវិធីដូចជា សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីអនាម័យចំណីអាហាររួមទាំងការរក្សាទុក និងលក្ខណ:គំរូនៃមីក្រូជីវសាស្ត្រតាមឯកសារ WT/ACC/KHM/15/Rev.1 | ២០០៣ |
| បង្កើតការិយាល័យផ្ដល់ពត៌មានអំពីអនាម័យ និងភូតគាមអនាម័យ. | |
| ការបណ្ដុះបណ្ដាលអ្នកជំនាញ និងការទិញសំភារ:ចាំបាច់ ( សេចក្ដីសំរេចរបស់ទីស្ដីការគណ:រដ្ឋមន្ត្រី កំណត់បង្ហាញលេខ ១០៩៣ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០២) :<br>គណ:កម្មាធិការជាតិ Codex<br>នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនិហរណ៍ អាហារណ៍ និង បង្ក្រាបការក្លែងបន្លំ ក្រសួងពាណិជ្ជកម្ម ( ជាលេខាធិការដ្ឋាន)<br>Fax: ៨៥៥ ២៣ ៤២៦ ១៦៦<br>Email: camcontrol@camnet.com.kh | |
| បង្កើតបណ្ណាល័យ Codex | |
| អនុវត្តកម្មវិធីបណ្ដុះបណ្ដាលបច្ចេកទេសជាក់ស្ដែងមួយចំនួនអំពីអនាម័យ និង ភូតគាមអនាម័យតាមឯកសារ WT/ACC/SPEC/KHM/15/Rev.1 | |
| ធ្វើសេចក្ដីព្រាងច្បាប់ និងអនុក្រឹត្យបន្ថែមទៀត ដើម្បីអនុវត្តកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ និងសំរាប់ការអនុវត្តវិធានការអនាម័យ និង ភូតគាមអនាម័យចាំបាច់មួយចំនួនតាមឯកសារ WT/ACC/SPEC/KHM/15/Rev.1 | |
| សមត្ថភាពដ៏ពេញលេញ នៃការធ្វើតេស្តចំណីអាហារ : មីក្រូជីវសាស្ត្រ និងវិភាគ គឺមីម្លូបអាហារឈានទៅរកការទទួលស្គាល់ទៅវិញទៅមកនៅក្នុងតំបន់ | |
| បណ្ដុះបណ្ដាលធនធានមនុស្សរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហារណ៍ និងបង្ក្រាបការក្លែងបន្លំ. ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ | |

| | |
|---|---|
| និងនេសាទ និងក្រសួងសុខាភិបាលអំពីការអនុវត្តន៍បទបញ្ញត្តិខាងលើ ។ | |
| ក្រុមការងារពិនិត្យច្បាប់ និងបទបញ្ញត្តិ | មុនពេលចូល ជាសមាជិក |
| ធ្វើសេចក្តីព្រាងច្បាប់បន្ថែមទៀតស្តីអំពីសុវត្ថិភាពចំណីអាហារ និងការណែនាំអំពីការផ្តល់វិញ្ញាបនប័ត្រចំពោះម្ហូបអាហារ (សំរាប់ការនាំចេញ) តាមឯកសារ WT/ACC/SPEC/KHM/15/Rev.1<br>បណ្តុះបណ្តាលធនធានមនុស្សរបស់នាយដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍អាហារណ៍ និងបង្ក្រាបការក្លែងបន្លំ គណៈកម្មាធិការជាតិ Codex និងក្រុមការងារបច្ចេកទេសអំពីការអនុវត្តន៍បទបញ្ញត្តិខាងលើ ។<br>បន្ថែមឯកសារថ្មីៗទៅក្នុងបណ្ណាល័យ Codex | ២០០៤-២០០៥ |
| កែតំរូវបទបញ្ញត្តិបច្ចេកទេសស្តង់ដារ និងនិតិវិធីអោយស្របតាមការរកឃើញថ្មីៗនៃវិទ្យាសាស្ត្រ<br>ខិតខំធ្វើយ៉ាងណាសំរេចអោយបាននូវការទទួលស្គាល់ជាផ្លូវការចំពោះការត្រួតពិនិត្យគុណភាព និងមន្ទីរពិសោធន៍ ។<br>បណ្តុះបណ្តាលធនធានមនុស្សរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរណ៍អាហារណ៍ និងបង្ក្រាបការក្លែងបន្លំ. គណៈកម្មាធិការជាតិ Codex និងក្រុមការងារបច្ចេកទេសអំពីការអនុវត្តន៍បទបញ្ញត្តិខាងលើ ។<br>បន្ថែមឯកសារថ្មីៗ ទៅក្នុងបណ្ណាល័យ Codex | ២០០៦-២០០៧ |
| អនុវត្តពេញលេញនូវកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីអំពីការអនុវត្តន៍វិធានការអនាម័យ និងភូតគាមអនាម័យ | ឱ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨ |

១៤២. តំណាងប្រតិភូកម្ពុជាបានអះអាងថា កម្ពុជានឹងអនុវត្តជាបណ្តើរៗនូវប្រការចែង នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យទៅតាមកាលវិភាគ ដែលបានផ្តល់នៅក្នុងផែនការសកម្មភាពសំរាប់ការអនុវត្តន៍នៅក្នុងតារាង ១១ ហើយធានាអនុវត្តអោយបានពេញលេញតាមកិច្ចព្រមព្រៀងនេះ នៅមុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៨ ហើយយល់ថា ក្នុងរយៈពេលនេះ ទំហំនៃការអនុវត្តន៍ផ្នែកផ្សេងៗទៀតនៃកិច្ចព្រមព្រៀងដូចដែលបានចែងក្នុងកថាខ័ណ្ឌ១៤១ នឹងត្រូវបានអនុវត្តដោយកម្ពុជា។ គាត់បានបន្ថែមទៀតថា កម្ពុជាត្រូវពិគ្រោះជាមួយប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ប្រសិនបើការស្នើរសុំក្នុងករណីដែលវិធានការណាមួយ ដែលអនុវត្តក្នុងរយៈពេលអន្តរកាលត្រូវបានចាត់ទុកថាប៉ះពាល់ផលប្រយោជន៍ខាងពាណិជ្ជកម្មរបស់ប្រទេសជាសមាជិកក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## <u>វិធានការវិនិយោគដែលទាក់ទងនឹងពាណិជ្ជកម្ម (TRIMs)</u>

១៤៣. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ជំពូក ៥ នៃច្បាប់វិនិយោគទុនចុះថ្ងៃទី ៤ ខែសីហា ឆ្នាំ១៩៩៤ និងជំពូក ៧ នៃអនុក្រឹត្យរបស់រដ្ឋាភិបាលលេខ 88 ANKR.BK ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគទុន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ដែលរួមមានប្រការចែងនានាទាក់ទងនឹងការធ្វើពាណិជ្ជកម្ម ដែលរួមមានការលើកទឹកចិត្តចំពោះការធ្វើវិនិយោគសំរាប់នាំចេញ រួមទាំងការលើកលែងពន្ធគយ និងពន្ធដារទាំងស្រុង ឬមួយផ្នែកការលើកលែងពន្ធលើផលចំណេញរបស់ក្រុមហ៊ុន អាស្រ័យលើលក្ខណៈសន្ធត់របស់គំរោងវិនិយោគ និងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះគំរោងនោះ, និងការលើកលែងពន្ធលើការបែងចែកប្រាក់ចំណេញថ្វីបើត្រូវផ្ទេរទៅបរទេស ឬត្រូវបែងចែកនៅក្នុងប្រទេសកម្ពុជាក៏ដោយ (មាត្រា ១២ ១៣ និង ១៤:១-៣ នៃច្បាប់វិនិយោគទុន)។ ការធ្វើវិនិយោគទុនបែបនេះអាចត្រូវលើកលែងពន្ធនាំចេញ និង ទទួលបានច្បាប់ពិសេសសំរាប់ការចូលមកធ្វើការនៃជនបរទេស។ ជាពិសេសមាត្រា១៤:៤(ក) និង(ខ) បានលើកលែងមិនយកពន្ធគយ ១០០ភាគរយលើការនាំចូលសំភារៈសំណង់ មធ្យោបាយផលិតកម្ម ផលិតផលពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់ដែលប្រើនៅក្នុងគំរោងវិនិយោគទុនមានទិសដៅនាំចេញផលិតផលរបស់ខ្លួនយ៉ាងតិច៨០ភាគរយ ឬជាក្រុមហ៊ុនវិនិយោគ ដែលមានទីតាំងនៅក្នុងតំបន់កែច្នៃនាំចេញ (SPZ) ដែលស្ថិតនៅក្នុងបញ្ជីអភិវឌ្ឍន៍ជាអាទិភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ មាត្រា ១៤:៤(គ) (ឃ) (ង) បានផ្តល់ការលើកទឹកចិត្តដូចគ្នានេះចំពោះការធ្វើវិនិយោគលើវិស័យឧស្សាហកម្មទេសចរណ៍ ឧស្សាហកម្មប្រើកំលាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ, កសិឧស្សាហកម្ម ឬហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្មថាមពលសំរាប់រយៈពេលនៃការកសាងសហគ្រាសរោងចក្រ អគារ និងឆ្នាំដំបូងនៃដំណើរការអាជីវកម្មផលិតកម្ម។ តាមទស្សនៈរបស់លោក វិធានការផ្តល់ការលើកទឹកចិត្តបែបនេះស្របនឹងកិច្ចព្រមព្រៀង ស្តីពីវិធានការវិនិយោគដែលទាក់ទងនឹងពាណិជ្ជកម្ម ហើយនឹងត្រូវបានរក្សាក្នុងករណីគ្មានការជំទាស់ នឹងប្រការចែង នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និង ពិធីសារនៃការចូលជាសមាជិករបស់កម្ពុជា ហើយជាសេចក្តីត្រូវការចាំបាច់សំរាប់ការអភិវឌ្ឍន៍របស់កម្ពុជា ។ ទោះបីជាមានការធ្វើវិសោធនកម្មថ្មីលើច្បាប់វិនិយោគទុនក្នុងមាត្រា ១៤ ស្តីពីការលើកទឹកចិត្តមិនសំដៅនៅលើផលិតផល

សំរាប់នាំចេញក៏រិតអប្បបរមា 80% នេះទេ ។ ម្យ៉ាងទៀតការអនុវត្តអនុក្រិត្យ ដែលនឹងត្រូវបានព្រៀងទុកនឹងធានាស្របទាំងស្រុងជាមួយនឹងប្រការចែងក្នុងពាណិជ្ជកម្មពិភពលោកស្តីពីវិធានការវិនិយោគដែលទាក់ទងទៅនឹងពាណិជ្ជកម្ម ។

១៤៤. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជានឹងមិនរក្សាទុកវិធានការណាមួយ ដែលមិនស្របជាមួយកិច្ចព្រមព្រៀង ស្តីអំពីវិធានការវិនិយោគដែលទាក់ទងនឹងពាណិជ្ជកម្ម TRIMs ហើយកម្ពុជានឹងអនុវត្តកិច្ចព្រមព្រៀងនេះចាប់តាំងពីថ្ងៃចូលជាសមាជិកដោយស្នើសុំអោយមានរយៈពេលអន្តរកាលឡើយ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

<u>**សហគ្រាសពាណិជ្ជកម្មរដ្ឋ**</u>

១៤៥. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ក្រុមហ៊ុនរដ្ឋចំនួន៧ ធ្វើសកម្មភាពពាណិជ្ជកម្មលើការនាំចូលនិងការនាំចេញផលិតផលមួយចំនួនដូចជា អង្ករ ជ័រកៅស៊ូ ជីរ ផលិតផលនេសាទ ផលិតផលឱសថ និងបរិក្ខាកសិកម្ម។ សហគ្រាសទាំងនេះបានដំណើរការដូចគ្នា និងដោយស្មើភាពជាមួយក្រុមហ៊ុនពាណិជ្ជកម្មឯកជន. ហើយមិនមានសិទ្ធិពិសេសណាមួយត្រូវផ្តល់អោយសហគ្រាសរដ្ឋទាំងនោះទេ។ អាស្រ័យហេតុនេះ លោកជឿថាគ្មានសហគ្រាសរដ្ឋរបស់កម្ពុជាណាមួយស្ថិតក្រោមការហាមឃាត់នៃមាត្រា ១៧ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ទេ ការយល់ឃើញអំពីការបកស្រាយមាត្រា ១៧ នៃ GATT ឆ្នាំ ១៩៩៤. ឬបញ្ជីក្រៅផ្លូវការនៃសហគ្រាសពាណិជ្ជកម្មរដ្ឋមានក្នុងឯកសារ G/STR/4 ។

១៤៦. ដោយមានការសាកសួរពត៌មានអោយកាន់តែច្បាស់អំពីសកម្មភាពពាណិជ្ជកម្ម និងការទំនាក់ទំនងជាមួយរដ្ឋាភិបាលរបស់សហគ្រាសទាំងអស់ តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ក្រុមហ៊ុន គ្រីនត្រេដ (GTC), ដែលបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧២ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨. ទទួលខុសត្រូវក្នុងការធ្វើស្តុកអង្ករបំរុងតាមរយៈការទិញ និងលក់តាមតំលៃទីផ្សារ។ ទោះបីជាក្រុមហ៊ុនគ្រីនត្រេដ ត្រូវធ្វើពាណិជ្ជកម្មលើគ្រឿងបរិភោគ និងទំនិញផ្សេងទៀតតាមជំរើសរបស់ខ្លួនដោយសេរីក៏ដោយ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែងក្រុមហ៊ុនគ្រីនត្រេដបានធ្វើពាណិជ្ជកម្មតែទៅលើអង្ករមួយមុខប៉ុណ្ណោះ។ ក្រៅពីការផ្តល់ទុនដំបូងចំនួន៣០ពាន់លានរៀល ដែលបានយល់ព្រមដោយរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៨ ក្រុមហ៊ុនគ្រីនត្រេដមិនបានទទួលការផ្តល់ទុនពីមូលនិធិសាធារណៈទេ។ រៀងរាល់ឆ្នាំ ក្រុមហ៊ុនគ្រីនត្រេដ បានបង្វិលប្រាក់១ភាគរយនៃចំណូលដុលរបស់ខ្លួនឬ២០ភាគរយ នៃចំណេញសុទ្ធរបស់ខ្លួន (មួយណាដែលខ្ពស់ជាង) ទៅអោយរដ្ឋាភិបាលជាប្រាក់បង្វិលលើចំណូលពីការបណ្តាក់ទុន។ ក្រុមហ៊ុនត្រូវការសាច់ប្រាក់សំរាប់ទុនបង្វិលសំរាប់ប្រតិបត្តិការដែលត្រូវបានផ្តល់តាមរយៈប្រព័ន្ធធនាគារតាមអត្រាការប្រាក់ធម្មតា។ ប្រសិនបើមានសំណូមពរនិងមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋាភិបាលនឹងចេញលិខិតធានាចំពោះកំចីនេះ។ ក្រុមហ៊ុនគ្រីនត្រេដត្រូវបានត្រួតពិនិត្យ

បច្ចេកទេសអាជីវកម្មពីក្រសួងពាណិជ្ជកម្ម និងការត្រួតពិនិត្យខាងហិរញ្ញវត្ថុពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មុនថ្ងៃ២៦ ខែកក្កដា ឆ្នាំ២០០១ ជាពេលដែលអាជ្ញាប័ណ្ណនាំចេញអង្ករត្រូវបានលុបចោល ក្រុមហ៊ុនគ្រឿនគ្រេដត្រូវផ្តល់តាមសំណូមពរនូវពត៌មានទីផ្សារដល់ក្រសួងពាណិជ្ជកម្មសំរាប់ការចេញអាជ្ញាប័ណ្ណនាំចេញអង្ករ។ ចាប់ពីពេលនោះមកក្រុមហ៊ុនគ្រឿនគ្រេដគ្មានតួនាទីជាអ្នកនាំអង្ករចេញរបស់កម្ពុជាទេ ដោយក្រុមហ៊ុនធ្វើពាណិជ្ជកម្មតែក្នុងការចែកចាយ ផលិតផលអង្ករក្នុងស្រុកតែប៉ុណ្ណោះ។

១៤៧. តាមរយៈអនុក្រឹត្យលេខ១២ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ ក្រុមហ៊ុនសំភារៈកសិកម្មគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលចំនួន៥រូបមកពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។ ក្រុមហ៊ុនធ្វើអាជីវកម្មលើការនាំចូល ទិញ និងលក់ផលិតផលកសិកម្ម (ដូចជាៈ ជីរ ថ្នាំសំលាប់សត្វល្អិត គ្រាប់ពូជ និងបរិក្ខាកសិកម្ម) ផ្តល់សេវាកម្ម និងស្តុក និងចែកចាយជីរគីមី និងវត្ថុធាតុដើមកសិកម្មក្រោមជំនួយពីបរទេស គ្រប់គ្រងទិន្នន័យស្ថិតិ និងចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងស្រាវជ្រាវ។ លោកបានសង្កត់ធ្ងន់ថា ក្រុមហ៊ុនផលិតផលកសិកម្មបានដំណើរការលើមូលដ្ឋានពាណិជ្ជកម្មដ៏តឹងរឹងមួយក្នុងការប្រកួតប្រជែងជាមួយផ្នែកឯកជន។ ការនាំចូលវត្ថុធាតុដើមកសិកម្ម ដោយក្រុមហ៊ុនសំភារៈកសិកម្មត្រូវរងការប្រកួតប្រជែងពីសហគ្រាសឯកជន។ ក្នុងឆ្នាំ២០០២ ក្រុមហ៊ុនបានដាក់អោយដេញថ្លៃពីអ្នកនាំចូលផ្នែកឯកជន ដើម្បីផ្គត់ផ្គង់ ជីរចំនួន ១៥,០០០តោន សំរាប់ឆ្នាំ២០០៣ ប៉ុន្តែគ្មានការផ្គត់ផ្គង់ទេ។ លោកបានបន្ថែមទៀតថា រដ្ឋាភិបាលកម្ពុជាមានបំណងក្នុងការបង្កើតគណៈកម្មាធិការមួយ ដែលនឹងត្រូវរៀបចំពង្រាងផែនការមួយ ដើម្បីធ្វើធ្វើការវិនិយោគឱ្យបានពេញលេញនូវកម្មសិទ្ធិរដ្ឋ នៃក្រុមហ៊ុនវត្ថុធាតុដើម សំភារៈកសិកម្មនៅឆ្នាំ ២០០៦ (សារាចររបស់គណៈរដ្ឋមន្ត្រីលេខ ២០១៨ ចុះថ្ងៃ ២៦ ខែ ធ្នូ ឆ្នាំ ២០០២ )។

១៤៨. ទាក់ទងនឹងកម្មសិទ្ធរបស់រដ្ឋ លើផ្នែកអាជីវកម្មផលិតផលកៅស៊ូ តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ចំការកៅស៊ូចំនួន៧កន្លែង (ជប់ ក្រែក មេមត់ ស្នួល ចំការអណ្តូង បឹងកេត និងពាម ជាំង) កំពុងត្រូវបានកែទំរង់អោយទៅជាសហគ្រាសសាធារណៈចំណុះក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ដោយយោងតាមច្បាប់ ស្តីពីសហគ្រាសសាធារណៈ និងតាមរយៈអនុក្រឹត្យដែលបានអនុម័តនៅថ្ងៃ ទី១៥ ខែមិនា ឆ្នាំ ១៩៩៩ ។ ទោះបីជាក្រុមហ៊ុននៅតែជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែអនុក្រឹត្យបានប្រគល់សិទ្ធិស្វ័យភាពទាំងស្រុងអោយទៅក្រុមប្រឹក្សានាយក នៃក្រុមហ៊ុនដែលផ្តល់សិទ្ធិក្នុងការប្រតិបត្តិការប្រចាំថ្ងៃទៅអោយអគ្គនាយកមួយរូប។ ការដឹកនាំប្រតិបត្តិការហិរញ្ញវត្ថុ និងការគ្រប់គ្រងសហគ្រាសមិនបានទទួលអភ័យឯកសិទ្ធិពីរាជរដ្ឋាភិបាលទេ។ នាពេលថ្មីៗនេះដំណើរការសាជីវកម្មកំពុងប្រព្រឹត្តិទៅ ដើម្បីត្រួតពិនិត្យក្រុមហ៊ុននិមួយៗ ដើម្បីកំណត់ថា តើក្រុមហ៊ុនណាមួយត្រូវបញ្ជប់លក់ទៅអោយផ្នែកឯកជន ឬ បង្វែរអោយទៅជាការរកស៊ីរួមទុនជាមួយក្រុមហ៊ុនឯកជន។ រដ្ឋាភិបាលកម្ពុជាមានបំណងចង់ដកចេញនូវកម្មសិទ្ធិ ឬភាគហ៊ុនពីក្រុមហ៊ុន

ទាំងអស់នេះនៅឆ្នាំ២០០៦ (តាមសារាចរណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ២០១៨ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០០២ ។ សហគ្រាសដែលជាកម្មសិទ្ធិរបស់រដ្ឋ គិតត្រឹមខែមិនា ឆ្នាំ ២០០៣ មានចុះក្នុងតារាង ១(ខ) ។

១៤៩. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ប្រសិនបើកម្ពុជាត្រូវអនុញ្ញាតិអោយដំណើរការសហគ្រាសពាណិជ្ជកម្មរដ្ឋណាមួយកម្ពុជានឹងធានាថានឹងគោរពតាមច្បាប់ និងបទបញ្ញត្តិទាំងអស់ដោយអនុលោមតាមតំរូវការមាត្រា ១៧ របស់កិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ដោយយល់អំពីការបកស្រាយ នៃមាត្រា ១៧ របស់កិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងមាត្រា ៨ របស់កិច្ចព្រមព្រៀងទូទៅ ស្តីអំពីសេវាកម្ម (GATS), រួមនឹងប្រការដែលតំរូវអោយអនុវត្តនៃ "ការពិនិត្យពិច័យក្នុងការធ្វើពាណិជ្ជកម្ម" ក្នុងការលក់និងទិញរបស់របរពីរដ្ឋ និងកិច្ចតំរូវនៃការជូនដំណឹង។ លោកបានបញ្ជាក់បន្តទៀតថា ដំណើរការរបស់សហគ្រាសដែលត្រូវរក្សាទុកជាកម្មសិទ្ធរបស់រដ្ឋរួមទាំងក្រុមហ៊ុនឡើនត្រេដផង ត្រូវបានអនុលោមតាមប្រការដែលមានចែងនៃកិច្ចព្រមព្រៀង GATT មាត្រា ១៧ និងមិនមានការផ្តល់សិទ្ធិពិសេសថ្មីៗទៀតទេ។ កម្ពុជានឹងអនុវត្តច្បាប់ និងបញ្ញត្តិរបស់ខ្លួន ក្នុងការគ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម របស់សហគ្រាសរដ្ឋទាំងនេះអោយបានស្របតាមប្រការចែងនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ។ ក្រុមការងារបានកត់ត្រាលើការសន្យាទាំងនេះ ។

## តំបន់ពាណិជ្ជកម្មសេរី, តំបន់សេដ្ឋកិច្ចពិសេស

១៥០. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា សព្វថ្ងៃមិនមានតំបន់ពាណិជ្ជកម្មសេរីនៅកម្ពុជាទេ។ រដ្ឋាភិបាលកម្ពុជាបានពិចារណាលើការបង្កើតតំបន់ឧស្សាហកម្ម រួមទាំងតំបន់កែច្នៃនាំចេញ។ អនុក្រឹត្យ លេខ៧៣ របស់រដ្ឋាភិបាលចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ និងអនុក្រឹត្យ លេខ០២ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ ១៩៩៦ កំណត់បង្កើតតំបន់ឧស្សាហកម្មនៅស្ទឹងហាវ ក្រុងព្រះសីហនុ ប៉ុន្តែគំរោងនេះនៅតែរង់ចាំការអនុវត្តន៍នៅឡើយ។ តំបន់ប៉ោយប៉ែត កោះកុង ប៉ៃលិន (នៅតាមព្រំដែនកម្ពុជា-ថៃ) និងតំបន់ ខ្លះទៀតនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាមកំពុងត្រូវបានចាត់ទុកថា ជាទីកន្លែងដែលមានសក្តានុពលសំរាប់បង្កើតតំបន់កែច្នៃនាំចេញ។ ដោយផ្អែកលើការវាយតំលៃនេះ សេចក្តីសំរេចក្នុងការបង្កើតតំបន់ឧស្សាហកម្មនៅក្នុងខេត្តកោះកុង ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ១០ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០០២។ ក្រៅពីនេះច្បាប់ស្តីពីវិនិយោគទុន និងអនុក្រឹត្យលេខ 88.ANKR.BK បានកំណត់អោយបង្កើតតំបន់ទាក់ទាញវិនិយោគពិសេសដូចមានចែងក្នុងកថាខ័ណ្ឌ ១៤៧ ខាងលើ។ សេចក្តីព្រាងច្បាប់ស្តីពីតំបន់ឧស្សាហកម្មត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីកាលពី ខែមិនា ឆ្នាំ២០០៣ ហើយបច្ចុប្បន្នកំពុងត្រូវបានពិនិត្យដោយសភាជាតិ។ ក្នុងរយៈពេលនៃការរង់ចាំការអនុម័តច្បាប់នេះតំបន់សេដ្ឋកិច្ចផ្សេងៗអាចត្រូវបានបង្កើតតាមរយៈអនុក្រឹត្យ។ លោកបានអះអាងថា សេចក្តីព្រាងច្បាប់គ្មានចែងអំពីសេចក្តីតំរូវក្នុងការនាំចេញ ឬការប្រើប្រាស់មធ្យោបាយក្នុងស្រុកទេ។

១៥១. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា តំបន់ពាណិជ្ជកម្មសេរីតំបន់សេដ្ឋកិច្ចពិសេស រួមទាំងតំបន់ទាក់ទាញវិនិយោគពិសេស ដែលបង្កើតឡើងក្រោមច្បាប់ស្តីពីវិនិយោគ នឹងត្រូវអនុលោមតាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចសន្យាធ្វើរបស់ខ្លួនដែលមានចែងនៅក្នុងពិធីសារនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយកម្ពុជាធានាក្នុងការអនុវត្តន៏កាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកនៅក្នុងតំបន់ទាំងនោះ។ ជាបន្ថែម ដោយផ្អែកលើពង្រាងច្បាប់ស្តីពីតំបន់ឧស្សាហកម្មទំនិញដែលផលិតនៅក្នុងតំបន់ទាំងនោះ ដោយមិនយកពន្ធលើការនាំចូលវត្ថុធាតុដើម នឹងត្រូវស្ថិតនៅក្រោមបែបបទគយធម្មតា នៅពេលដែលទំនិញទាំងនោះនាំចូលមកក្នុងតំបន់ផ្សេងៗទៀត ក្នុងប្រទេសកម្ពុជារួមទាំងការយកពន្ធនាំចូល និងអាករផ្សេងៗទៀត។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

**<u>លទ្ធកម្មរបស់រដ្ឋាភិបាល</u>**

១៥២. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៏ថា ប្រព័ន្ធលទ្ធកម្មសាធារណៈថ្មីមួយបានចាប់ផ្តើមអនុវត្តតាំងពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៥ (អនុក្រឹត្យលេខ៦០)។ លទ្ធកម្មត្រូវបានអនុវត្តតាមរយៈ (១) ការដេញថ្លៃជាអន្តរជាតិ (ICB) (២) ការដេញថ្លៃក្នុងស្រុក (DCB) (៣) ការទិញទំនិញជាអន្តរជាតិ (IS) (៤) ការស្ទាបស្ទង់ថ្លៃក្នុងស្រុក (DC) ឬ (៥) ការទិញផ្ទាល់ ឬទិញតាមកិច្ចសន្យាផ្ទាល់ (Dcon)។ កិច្ចសន្យាការដេញថ្លៃជាអន្តរជាតិ និងការដេញថ្លៃក្នុងស្រុកត្រូវផ្សព្វផ្សាយដោយចំហជាសាធារណៈ ដល់ក្រុមហ៊ុនដេញថ្លៃទាំងអស់ដែលមានចំណាប់អារម្មណ៍ ។ នីតិវិធីនៃការដេញថ្លៃក្នុងស្រុកត្រូវអនុវត្តលើគំរោងដែលមានតំលៃតិចជាង ២០០លានរៀល ចំពោះកិច្ចការស៊ីវិល និង១០០លានរៀលចំពោះទំនិញ។ នីតិវិធីដែលប្រើសំរាប់ធ្វើលទ្ធកម្មគំរោងដែលមានតំលៃច្រើនជាងនេះត្រូវអនុវត្តការដេញថ្លៃជាអន្តរជាតិ ដែលបទបញ្ញត្តិទាំងអស់បានអនុលោមតាមស្តង់ដារអន្តរជាតិ ។ និតិវិធីពាចុងក្រោយមិនតំរូវអោយដេញថ្លៃជាសាធារណៈទេ ប៉ុន្តែការចូលរួមរបស់បរទេសក៏មិនបានហាមឃាត់ដែរ។

១៥៣. ជាទូទៅ ការដេញថ្លៃដែលមានតំលៃទាបបំផុតត្រូវជ្រើសរើសនៅក្នុងនីតិវិធីដេញថ្លៃជាអន្តរជាតិ និងការដេញថ្លៃក្នុងស្រុក ប៉ុន្តែកត្តាដទៃទៀតដូចជាការដេញថ្លៃចប់សព្វគ្រប់ក្នុងកំឡុងពេលនៃការគោរពបាននូវបទដ្ឋានបច្ចេកទេសបទពិសោធន៏ និងធនធានហិរញ្ញវត្ថុរបស់អ្នកដេញថ្លៃ និងឯកសារចាំបាច់ក៏ត្រូវបានយកមកពិចារណាផងដែរ។ ការទិញទំនិញជាអន្តរជាតិ (IS) តំរូវអោយមានការស្រង់ថ្លៃពីក្រុមហ៊ុន ចំនួន៣ ពីប្រទេសយ៉ាងតិច២ផ្សេងគ្នា ។ លោកបានបន្ថែមទៀតថា ការអនុវត្តន៏ជាក់ស្តែងអាចមានការខុសគ្នាខ្លះពីនីតិវិធីលទ្ធកម្មដែលបានបង្កើតឡើង ហើយការលំអៀងទៅអ្នកដេញថ្លៃក្នុងស្រុកក៏អាចកើតមានក្នុងករណីនៃការទិញបន្ទាន់ កម្មសិទ្ធិនៃការធ្វើលទ្ធកម្ម ផលិតផលដែលមានតំលៃតិចតួច និងការផ្គត់ផ្គង់បរិក្ខាយោធា។

១៥៤. សមាជិកខ្លះបានកត់សំគាល់ថា គោលនយោបាយលទ្ធកម្មរបស់កម្ពុជាបានបើកចំហជាធម្មតា ហើយការធ្វើបែបនេះកម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីសមាជិកភាពក្នុងកិច្ចព្រមព្រៀង ស្តីពីការធ្វើលទ្ធកម្មឧបត្ថម្ភរបស់រដ្ឋាភិបាល ។ សមាជិកមួយបានស្នើរសុំអោយកម្ពុជាធានាលើតំលាភាព នៅក្នុងការអនុវត្តន៍ជាក់ស្តែងលើគោលនយោបាយលទ្ធកម្មរដ្ឋាភិបាលរបស់ខ្លួន និងអោយពិចារណាចំពោះការងារដែលត្រូវធ្វើនៅក្នុងក្រុមការងារអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីតំលាភាពក្នុងលទ្ធកម្មរបស់រាជរដ្ឋាភិបាល ។

១៥៥. តំណាងប្រតិភូកម្ពុជាបានឆ្លើយតបថា កម្ពុជាគ្មានបំណងចូលរួមក្នុងកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មរបស់រដ្ឋាភិបាលក្នុងពេលនេះទេ។ ទោះយ៉ាងណាក៏ដោយ លោកបានកត់សំគាល់លើយោបល់របស់សមាជិកទាំងអស់ ។

## ការធ្វើពាណិជ្ជកម្មក្នុងវិស័យអាកាសយានស៊ីវិល

១៥៦. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា អត្រាពន្ធបច្ចុប្បន្នលើយន្តហោះស៊ីវិល និងគ្រឿងបន្លាស់បានកំណត់យកពី០ភាគរយ ទៅ១៥ភាគរយ។ កម្ពុជាមិនបានយល់ព្រមលើការលើកលែងពន្ធចំពោះ បរិក្ខារគ្រឿងបន្លាស់ ឬការផ្គត់ផ្គង់បច្ចេកទេស ដែលត្រូវការសំរាប់អាកាសយានដ្ឋានដែលទាក់ទងជាមួយសេវាកម្មផ្លូវអាកាសទេ។

## ទំនិញឆ្លងកាត់

១៥៧. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាមិនមានបទបញ្ញត្តិជាក់លាក់ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មទំនិញឆ្លងកាត់ទេ។ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីពាណិជ្ជកម្មឆ្លងកាត់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៩៤ និងជាមួយសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៤។ យោងតាមកិច្ចព្រមព្រៀង ជាមួយប្រទេសវៀតណាមភាគីទាំងអស់ត្រូវបានអនុញ្ញាតិអោយដឹកទំនិញឆ្លងកាត់ទឹកដីនៃប្រទេសនិមួយៗ លើកលែងតែទំនិញដែលហាមឃាត់ដូចជា គ្រឿងញៀនស្រវឹង ទំនិញមានជាតិពុល ទំនិញមានជាតិវិទ្យុសកម្ម ភាពយន្ត និងរូបភាពអាសអាភាស និងសំភារៈផ្សេងៗទៀតដែលផ្ទុយនឹងសីលធម៌សាធារណៈ ក៏ ដូចជា សត្វព្រៃ និងរុក្ខជាតិដែលកំរ ។

១៥៨. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា កម្ពុជានឹងអនុវត្តច្បាប់ និងបទបញ្ញត្តិនានារបស់ខ្លួន ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មទំនិញឆ្លងកាត់អោយស្របតាមប្រការនានា នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកជាពិសេសមាត្រា ៥ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ ។

## គោលនយោបាយកសិកម្ម

### ក. ការនាំចូល: វិធានការនានានៅតាមព្រំដែន

១៥៩. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាមិនតំរូវអោយមានអាជ្ញាប័ណ្ណ ឬការដាក់កំរិតលើបរិមាណ ឬការហាមឃាត់លើការនាំចូលផលិតផលកសិកម្មទេ។ ពន្ធនាំចូលជាមធ្យមពីលើផលិតផលកសិកម្មគឺ ១៧ភាគរយ ។វិញ្ញាបនប័ត្រភូតគាមអនាម័យត្រូវតំរូវអោយមានចំពោះការនាំចូលផលិតផលកសិកម្ម។

### ខ. ការនាំចេញ

១៦០. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាមិនហាមឃាត់ ឬដាក់កំរិតលើការនាំចេញផលិតផលកសិកម្មទេលើកលែងតែថ្នាំញៀន។ ការនាំចេញសត្វពាហនៈឬជ្រូកពូជសុទ្ធត្រូវជាប់ពន្ធ១០ភាគរយ ដូចដែលមានចែងនៅក្នុងតារាង៨។ ការដាក់កំហិតលើការនាំចេញចំពោះអង្ករបានត្រូវលុបចេញកាល ពីខែកក្កដា ឆ្នាំ២០០១ ប៉ុន្តែកម្ពុជាសូមរក្សាសិទ្ធិរបស់ខ្លួនចំពោះការដាក់កំហិតលើការនាំចេញអង្ករជាបណ្តោះអាសន្ន ដើម្បីការពារឬជួយបន្ធូរដល់ភាពខ្វះខាតស្បៀងអាហារ ដូចដែលមានចែងនៅក្រោមមាត្រា ១១:២(ក) នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤។ លោកបានបញ្ជាក់ថា កម្ពុជាពុំបានផ្តល់ឥណទានចំពោះការនាំចេញ ការធានាឥណទាន ឬកម្មវិធីធានារ៉ាប់រងផ្សេងទៀតចំពោះការនាំចេញផលិតផលកសិកម្មទេ។

### គ. គោលនយោបាយផ្ទៃក្នុង: ការចំណាយថវិកា និងការបាត់បង់ចំណូលថវិកា ដែលបណ្តាលមកពីវិធានការគាំទ្រក្នុងស្រុកដែលកំពុងអនុវត្ត

១៦១. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ប្រជាជនកម្ពុជាភាគច្រើនរស់នៅតំបន់ជនបទ នឹងពឹងផ្អែកទៅលើកសិកម្ម ជាពិសេសការដាំដំណាំស្រូវ ។ គោលនយោបាយរបស់រដ្ឋាភិបាលបានតំរង់ទៅលើការបង្កើនទិន្នផលស្បៀង និងសន្តិសុខស្បៀង។ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានគ្រប់គ្រងការទុកដាក់ស្រូវពូជសំរាប់ផ្តល់ដល់ប្រជាកសិករនៅពេលដែលមានការគំរាមកំហែងដោយគ្រោះធម្មជាតិ។ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត-ក្រុង នៃក្រសួងធនធានទឹក និងឧតុនិយមក៏បានបែងចែកប្រេងឥន្ធនៈ ដោយគ្មានគិតកំរៃ ដល់កសិករដើម្បីបូមទឹកបញ្ចូលស្រែនៅពេលជួបគ្រោះរាំងស្ងួត។

១៦២. លោកបានផ្តល់ពត៌មាន ស្តីពីឧបត្ថម្ភធនក្នុងស្រុក និងឧបត្ថម្ភធននាំចេញក្នុងវិស័យកសិកម្ម ពីឆ្នាំ ១៩៩៨-២០០០ នៅក្នុងឯកសារ WT/ACC/SPEC/KHM/3 ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០១ និងការកែតំរូវលើកទី១ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០២ ព្រមទាំងសេចក្តីបន្ថែមនៅក្នុងឯកសារនោះផង (កំណត់សំគាល់បន្ថែម)។

ជាការបន្ថែមលើវិធានការ "ប្រអប់បៃតង" (Green box measures) ដែលរួមបញ្ចូលកម្មវិធីទាំងអស់ដូចបានពោលខាងលើក៏ដូចជាការលើកលែងពន្ធលើដីកសិកម្ម និងពន្ធលើប្រាក់ចំណូលរបស់កសិករ (ដែលចាត់ទុកថាជាការឧបត្ថម្ភក្រៅពីប្រាក់ចំណូល) តំណាងប្រតិភូកម្ពុជាបានកត់ត្រានៅក្នុងតារាង DS:៩ ថែងថា ជាទូទៅមានការលើកលែងអាករលើតំលៃបន្ថែម (VAT) លើផលិតផលវត្ថុធាតុដើមកសិកម្មអនុវត្តជាធម្មតាចំពោះកសិករទាំងអស់ ទោះបីជាការចំណាយថវិការបស់រដ្ឋាភិបាលមិនអាចកត់ត្រាបានដោយសារតែពុំមានទិន្នន័យស្ថិតិគ្រប់គ្រាន់ក៏ដោយ។ ការលើកលែងពន្ធលើដីធ្វើស្រែចំការ និងចំណូលរបស់កសិករ និងពន្ធលើផលរបរ ឬអាករលើតំលៃបន្ថែមលើផលិតផលដាំដុះផ្ទាល់ខ្លួននៅពេលចាប់ផ្តើមលក់ជាលើកដំបូង គឺជាកត្តាដ៏សំខាន់មួយនៃយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទរបស់កម្ពុជា ។ ចំពោះក្រុមហ៊ុនចំការដំណាំធំៗត្រូវជាប់អាករលើតំលៃបន្ថែម។

១៦៣. ឆ្លើយតបទៅនឹងសំណួរលើគោលនយោបាយស្តុកអង្ករបំរុងរបស់កម្ពុជា តំណាងប្រតិភូកម្ពុជាបានបន្ថែមទៀតថា គោលបំណងនៃការត្រៀមបំរុងអង្ករ គឺដើម្បីផ្តល់ការឧបត្ថម្ភស្បៀងដល់ជនរងគ្រោះ ដែលទទួលរងការបំផ្លិចបំផ្លាញដោយគ្រោះធម្មជាតិ ។ ក្នុងកំឡុងឆ្នាំ១៩៩៨-២០០០ រដ្ឋាភិបាលបានត្រៀមទុកមូលនិធិចំនួន ១,០០០លានរៀល ក្នុងមួយឆ្នាំទុកសំរាប់ការទិញអង្ករបំរុង ហើយការត្រៀមនេះបានកើនរហូតដល់ ១,៦៤០លានរៀល នៅឆ្នាំ២០០១ និង៣,២៨០លានរៀលនៅឆ្នាំ២០០២។ ការទិញអង្ករបំរុង (និងការលក់ទៅវិញ) ត្រូវបានអនុវត្តដោយក្រុមហ៊ុនគ្រីនត្រេដ ហើយបានជួយទប់ស្កាត់ការឡើងថ្លៃអង្ករទីផ្សារក្នុងស្រុក។ នៅពេលមានហេតុការបន្ទាន់ ដែលតំរូវអោយមានការបញ្ចេញអង្ករត្រៀមបំរុងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនឹងបញ្ជា និងបន្ថែមតំលៃបន្តិចបន្តួចទិញអង្ករលើថ្លៃដើមពីក្រុមហ៊ុនគ្រីនត្រេដ ។ ផ្ទុយមកវិញគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយផ្តល់អង្ករដល់ជនរងគ្រោះ ដោយសារមហន្តរាយធម្មជាតិដោយឥតគិតថ្លៃ។

១៦៤. តំណាងប្រតិភូកម្ពុជាយល់ព្រមថា នៅថ្ងៃដែលកម្ពុជាបានចូលជាសមាជិក កម្ពុជានឹងកំណត់កំរិត នៃការធ្វើឧបត្ថម្ភធន លើការនាំចេញផលិតផលកសិកម្មនៅកំរិតសូន្យនៅក្នុងកម្មវិធីសម្បទាន និងការសន្យារបស់ខ្លួនលើពាណិជ្ជកម្មទំនិញ និងមិនរក្សាទុក ឬអនុវត្តនយោបាយឧបត្ថម្ភធនលើការនាំចេញផលិតផលកសិកម្ម។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

**<u>របបវាយនភ័ណ្ឌ</u>**

១៦៥. តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ទំនិញវាយនភ័ណ្ឌ និងសំលៀកបំពាក់មិនត្រូវបានគ្រប់គ្រងដោយគោលនយោបាយពិសេសណាមួយទេនៅកម្ពុជា។ ទោះបីជាអត្រាពន្ធនាំចូលផលិតផលនេះមានកំរិតខ្ពស់ក៏ដោយ ដែលជាមធ្យមគឺ៣៤ភាគរយ លើសំលៀកបំពាក់ និង១៤ភាគរយលើសរសៃអំបោះ និងក្រណាត់សំពត់-ក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ភាគច្រើននៅកម្ពុជាតំរូវអោយចុះបញ្ជីក្រុមហ៊ុនវិនិយោគទុន ដែលផលិតសំរាប់នាំចេញ ដូច្នេះហើយនឹងទទួលបានការលើកលែងពីការបង់ពន្ធនាំចូល វត្ថុធាតុដើម និងទំនិញពាក់កណ្តាលសំរេច។

កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីអំពីការធ្វើពាណិជ្ជកម្ម កប្បាស រោមសត្វ អំបោះត្បាញដោយដៃ សរសៃធម្មជាតិ និងវាយនភ័ណ្ឌសរសៃសូត្រ និងផលិតផលវាយនភ័ណ្ឌនានា ជាមួយសហរដ្ឋអាមេរិក។ តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា កម្ពុជានឹងផ្តល់ជូនដល់សមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់នូវអត្រាពន្ធគយអនុគ្រោះលើផលិតផលនេះ ដូចដែលបានព្រមព្រៀងជាមួយសហរដ្ឋអាមេរិកដោយគោរពតាមគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលការអនុគ្រោះនៅពេលដែលកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ នៅក្រោមលក្ខខ័ណ្ឌ នៃកិច្ចព្រមព្រៀងទ្វេភាគី សហរដ្ឋអាមេរិកបានដាក់កំហិតលើបរិមាណនាំចេញផលិតផលសំលៀកបំពាក់ ១៣ប្រភេទ ពីប្រទេសកម្ពុជា។ ការនាំចេញនៃផលិតផលវាយនភ័ណ្ឌមួយចំនួនទៅកាន់ប្រទេសកាណាដា ក៏មានឧបសគ្គដោយកិច្ចព្រមព្រៀងទ្វេភាគីដែរ។ កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌរវាងសហគមន៍អឺរ៉ុប និងកម្ពុជាអនុញ្ញាតិអោយការនាំចេញផលិតផលវាយនភ័ណ្ឌមួយចំនួនពីកម្ពុជាទៅសហគមន៍អឺរ៉ុប ដោយមិនកំណត់បរិមាណនាំចេញ តែបានបង្កើតប្រព័ន្ធត្រួតពិនិត្យពីរដង លើទំនិញ ៩ ប្រភេទ ព្រមទាំងសហប្រតិបត្តិការរដ្ឋាភិបាល ដើម្បីបញ្ជាក់ប្រភពដើមនៃទំនិញផលិតនៅកម្ពុជា។

១៦៦. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ការដាក់កំហិតលើបរិមាណនាំចូលទំនិញវាយនភ័ណ្ឌ និងសំលៀកបំពាក់ដែលអនុវត្តដោយសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក លើទំនិញដែលមានប្រភពដើមមកពីប្រទេសកម្ពុជា ហើយចូលជាធរមាននៅមុនថ្ងៃដែលកម្ពុជាចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ត្រូវជូនដំណឹងទៅអង្គការត្រួតពិនិត្យវាយនភ័ណ្ឌ (TMB) ដោយអះអាងថាការដាក់កំហិតទាំងនេះអនុវត្តន៏ស្របទៅតាមមាត្រា២ នៃកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់។ ដូច្នេះចំពោះបំណងនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា ឃ្លាថា "ការអនុវត្តន៏មុនថ្ងៃចូលជាធរមាន នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក " ដែលមាននៅក្នុងមាត្រា ២.១ នៃកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌនិងសំលៀកបំពាក់ត្រូវមានន័យថា មុនពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា។ ដោយហេតុនេះការកើនឡើងនូវអត្រាកំណើនដែលមានចែងនៅក្នុងមាត្រា ២.១៣ និង២.១៤ នៃកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ត្រូវបានអនុវត្តស្របទៅនឹងកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ចាប់តាំងពីថ្ងៃចូលជាសមាជិករបស់កម្ពុជា ។ ក៏វិតជាមូលដ្ឋាន និងអត្រាកំនើននឹងត្រូវបានបញ្ចប់នៅពេលដែលកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់នឹងត្រូវផុតរលត់។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ។

## សិទ្ធិ កម្មសិទ្ធិបញ្ញាទាក់ទិននឹងពាណិជ្ជកម្ម

### ១-ទិដ្ឋភាពទូទៅ

### (ក) ការការពារកម្មសិទ្ធិឧស្សាហកម្ម

១៦៧. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា រដ្ឋាភិបាលរបស់លោក បានចាត់ទុកការការពារកម្មសិទ្ធិបញ្ញាមានសារៈសំខាន់ក្នុងការបង្កើតឱ្យមានការអភិវឌ្ឍន៏ផ្នែកសេដ្ឋកិច្ច ជំរុញការវិនិយោគរបស់បរទេស និងការផ្ទេរបច្ចេក

វិទ្យា ព្រមទាំងជួយសំរបសំរួលដល់ការធ្វើសមាហរណកម្មរបស់ប្រទេសកម្ពុជាទៅក្នុងសេដ្ឋកិច្ចពិភពលោក ។ ជាបឋម ការការពារកម្មសិទ្ធិបញ្ញារបស់ប្រទេសកម្ពុជាបានផ្អែកលើមាត្រាទី៤៧ និង ៤៨ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទ័ណ្ឌ និងនីតិវិធីព្រហ្មទ័ណ្ឌសំរាប់អនុវត្តបាននៅក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ និង ប្រកាសលេខ ៣៦៨ របស់ក្រសួងពាណិជ្ជកម្មស្តីពីនីតិវិធីរបស់នាយកដ្ឋាន កម្មសិទ្ធិបញ្ញា ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ ។

១៦៨. លោកបានបន្ថែមទៀតថា រដ្ឋាភិបាលរបស់លោកកំពុងតែរៀបចំសេចក្តីព្រាងច្បាប់ថ្មី ក្រោមជំនួយឧបត្ថម្ភពីជំនាញការបរទេស និង អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីធ្វើឱ្យច្បាប់របស់ប្រទេសកម្ពុជាសមស្របទៅនឹងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) រួមមានទាំងច្បាប់ ស្តីពីម៉ាកពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០២ ច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានប្រយោជន៍ និង គំនូសព្រាងឧស្សាហកម្ម ដែលប្រកាសឱ្យប្រើនៅថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៣ និងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលប្រកាសឱ្យប្រើនៅថ្ងៃទី០៣ ខែមិនា ឆ្នាំ ២០០៣ ។ ជាងនេះទៅទៀតច្បាប់ស្តីពីកំណត់សំគាល់លក្ខណៈភូមិសាស្ត្រ គំនូសបំព្រួញនៃសៀគ្វីប្រមូលផ្តុំ ការការពារពត៌មានសំងាត់ និង ការសំងាត់ពាណិជ្ជកម្ម និងច្បាប់ស្តីពីការការពារប្រភេទផ្សេងៗនៃរុក្ខជាតិកំពុងស្ថិតនៅក្នុងដំណាក់កាលរៀបចំ ហើយរំពឹងថា អាចនឹងបានប្រកាសឱ្យប្រើបាននៅឆ្នាំ២០០៤ ។ កម្ពុជាកំពុងតែព្រាងក្រម រដ្ឋប្បវេណីថ្មីមួយ ដោយកំណត់កាលបរិច្ឆេទដើម្បីអនុម័តនៅក្នុងឆ្នាំ ២០០៤ ដែលអាចជាបង្អែកមួយសំរាប់ការ ការពារកម្មសិទ្ធិបញ្ញាផងដែរ។ លោកបានអះអាងថា ក្រមរដ្ឋប្បវេណីថ្មីនេះនឹងមិនត្រួតគ្នាទៅលើបទបញ្ញត្តិទាំងឡាយ នៃច្បាប់កម្មសិទ្ធិបញ្ញាណាមួយនោះឡើយ ។

១៦៩. តំណាងរបស់ប្រទេសកម្ពុជា បានផ្តល់ពត៌មានលំអិតអំពីការអនុវត្តន៍កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ដែលមាននៅក្នុងឯកសារលេខ WT/ACC/KHM/7 និងសំណៅកែសំរួល ឡើងវិញរបស់ឯកសារនេះ ត្រង់ចំណុច១ និង២។ លោកក៏បានដាក់ជូនពិនិត្យផងដែរនូវផែនការការងារ ដែលមាននៅក្នុងឯកសារលេខ WT/ACC/KHM/16 និង ផែនការការងារដែលបានពិនិត្យកែសំរួលឡើងវិញ នៅក្នុងឯកសារ WT/ACC/KHM/16/Rev.1 ហើយបានអធិប្បាយអំពីការប្រឹងប្រែងនៃរដ្ឋាភិបាលរបស់លោក ដើម្បីធានាឱ្យទទួលបាននូវជំនួយបច្ចេកទេស ដែលទាក់ទងដល់ផែនការការងារនេះ។

### (ខ) អង្គភាពដែលទទួលខុសត្រូវក្នុងការបង្កើត និង អនុវត្តគោលនយោបាយកម្មសិទ្ធិបញ្ញា

១៧០. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មជាអ្នកទទួលខុសត្រូវក្នុងការបង្កើត និង អនុវត្តគោលនយោបាយស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែង

មិនស្មោះត្រង់។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលជាអ្នកទទួលបន្ទុក ផ្នែកប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និង គំនូសព្រាងឧស្សាហកម្ម, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអ្នកទទួលបន្ទុកផ្នែក សិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ហើយក្រសួងពត៌មានទទួលបន្ទុកផ្នែកគ្រប់គ្រងរួម នៃសិទ្ធិទូរផ្សាយ។

១៧១. នៅពេលត្រូវបានសួរថាតើ កម្ពុជាមានបំណងធ្វើឱ្យការរៀបចំផ្នែករដ្ឋបាលរបស់ខ្លួនកាន់តែសុក្រិត្យ ដោយបង្កើតអង្គភាពរួមមួយទទួលបន្ទុកគ្រប់គ្រងសិទ្ធិ ដែលជាកម្មវត្ថុនៃការផ្តល់ និងការចុះបញ្ជីដូចជា ប្រកាស នីយប័ត្រតក្កកម្ម ពាណិជ្ជសញ្ញា និងគំនូសព្រាងឧស្សាហកម្មឬទេ ។ តំណាងរបស់ប្រទេសកម្ពុជាបានឆ្លើយតបថា កម្ពុជាបានបង្កើតគណៈកម្មការធិការមួយ ដើម្បីគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា (ដូចជា ពាណិជ្ជសញ្ញា, ប្រកាសនីយប័ត្រតក្កកម្ម និង សិទ្ធិអ្នកនិពន្ធរួចហើយ ។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម គឺជាប្រធាននៃគណៈកម្មការ ធិការនេះ ដែលមានភារៈកិច្ចត្រូវសហការផ្នែកបច្ចេកទេសនិងនីតិវិធីរដ្ឋបាលជាមួយអង្គភាពដទៃទៀត ដែលមាន ការទទួលខុសត្រូវខាងកម្មសិទ្ធិបញ្ញា។ គណៈកម្មការធិការក៏សហការផងដែរ ក្នុងការទទួលជំនួយបច្ចេកទេសក្នុង ផ្នែកទាំងនេះ។ តំណាងរបស់ប្រទេសកម្ពុជាបានយល់ឃើញថា ការបង្កើតគណៈកម្មការធិការនេះគឺ ជាលទ្ធភាពនៃ ជំហានទី១ នៃការបង្កើតឡើងនូវអង្គភាពតែមួយ ដែលទទួលបន្ទុកគ្រប់គ្រងសិទ្ធិទាំងឡាយជាកម្មវត្ថុនៃការផ្តល់ និង ចុះបញ្ជីកម្មសិទ្ធិបញ្ញា។

## (ត) ការចូលរួមក្នុងកិច្ចព្រមព្រៀងកម្មសិទ្ធិបញ្ញាអន្តរជាតិ

១៧២. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា កម្ពុជាបានក្លាយជាសមាជិក នៃអង្គការកម្មសិទ្ធិបញ្ញា ពិភពលោក ចាប់តាំងពីឆ្នាំ ១៩៩៥ និង អនុសញ្ញាទីក្រុងប៉ារីស សំរាប់ការការពារកម្មសិទ្ធិឧស្សាហកម្ម ចាប់តាំងពីឆ្នាំ ១៩៩៨ មកម្លេះ ។ កម្ពុជាមានផែនការ ចូលរួមក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WTC) និងសន្ធិសញ្ញាស្តីពី ហ្វូណូក្រាម និងការសំដែងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WPPT) ក្នុងឆ្នាំ ២០០៥ ព្រមទាំងចូលរួមក្នុងអនុសញ្ញាទីក្រុងប៊ែន បន្ទាប់ពីការអនុម័តច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និង សន្ធិសញ្ញាស្តីពីសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មនៅពេល ដែលច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូតដែលមានប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្មបានត្រូវបង្កើតឡើងរួច។ រដ្ឋាភិបាលរបស់កម្ពុជាកំពុងតែ ពិចារណាផងដែរ អំពីការចូលជាសមាជិកភាពក្នុងអនុសញ្ញាអន្តរជាតិ សំរាប់ការការពារប្រភេទផ្សេងៗនៃ រុក្ខជាតិថ្មី (UPOV) ហើយនឹងច្បាប់ថ្មីមួយទៀត កំពុងត្រូវបានព្រាងបញ្ចប់ ដោយមានជំនួយពីអង្គការ UPOV ។ ការផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវ ស្តីពីហ្វូណូក្រាម និងអនុសញ្ញាក្រុងប្រ៊ុយសែលស្តីពីផ្កាយរណប ក៏ត្រូវពឹងផ្អែកផងដែរ លើការបង្កើតច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ព្រមទាំងច្បាប់ពាក់ព័ន្ធ ផ្សេងទៀត ដែលកំពុងតែត្រូវបានរៀបចំនាពេលបច្ចុប្បន្ននេះ ។

១៧៣. កម្ពុជាបានចូលរួមក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា តាំងពីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ កម្ពុជាបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការការពារ និង កិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាជាមួយសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រថៃផងដែរ ។

**(ឃ) ការអនុវត្តគោលការណ៍ប្រព្រឹត្តិកម្មជាតិ និង ប្រព្រឹត្តកម្មប្រជាជាតិដែលបានទទួលការអនុគ្រោះបំផុតចំពោះជនបរទេស**

១៧៤. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា ប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តកម្មប្រជាជាតិ ដែលបានទទួលការអនុគ្រោះបំផុតត្រូវបានផ្តល់ជូនទៅជនបរទេសទាំងអស់ក្រោមច្បាប់កម្មសិទ្ធិបញ្ញា ដែលមានជាធរមាន ហើយសេចក្តីព្រាងច្បាប់ផ្សេងទៀត ក៏នៅបន្តដាក់បញ្ចូលគោលការណ៍ដូចគ្នានេះផងដែរ ។

**(ង) កំរៃនិងពន្ធផ្សេងៗ**

១៧៥. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា កំរៃសំរាប់ដំណើរការចុះបញ្ជីពាណិជ្ជសញ្ញាមានតំលៃស្មើនឹង ៥០ដុល្លាសហរដ្ឋអាមេរិក ចំពោះការចុះបញ្ជីវិញ្ញាប័នប័ត្រមួយ, ៥០ដុល្លាអាមេរិក សំរាប់ការបោះផ្សាយក្នុងមួយចំណាត់ថ្នាក់ និង០៥ដុល្លាអាមេរិកទៀត សំរាប់ថ្លៃសេវាកម្មក្នុងមួយចំណាត់ថ្នាក់។ កំរៃទាំងនេះត្រូវអនុលោមតាមការពិនិត្យសើរើឡើងវិញដោយក្រសួងពាណិជ្ជកម្ម ដោយត្រូវពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តាមរយៈប្រកាសរួមមួយ របស់ក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។ កំរៃទាក់ទងនឹង ប្រកាសនីយប័ត្រតក្កកម្ម និងសិទ្ធិអ្នកនិពន្ធ កំពុងស្ថិតនៅក្នុងការពិនិត្យសំរេច។

**២. បទដ្ឋានជាខ្លឹមសារនៃការការពារ រួមមានទាំងនីតិវិធី សំរាប់ការទទួលយក និង ការរក្សាការពារកម្មសិទ្ធិបញ្ញា**

**(ក) ការការពារសិទ្ធិអ្នកនិពន្ធ**

១៧៦. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា ច្បាប់ថ្មីមួយស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងខែមិនា ឆ្នាំ២០០២ ហើយបានត្រូវផ្តល់សច្ចាប័ន ដោយសភាជាតិ និងព្រឹទ្ធសភា នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៣។ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែលនេះត្រូវបានប្រកាសឱ្យប្រើ នៅថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០៣ ។ ក្នុងសម័យអន្តរកាលការការពារសិទ្ធិអ្នកនិពន្ធត្រូវបានគ្រប់គ្រង ដោយមាត្រា ៤៨ នៃបទបញ្ញត្តិ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទ័ណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ។

១៧៧. ច្បាប់បានផ្តល់ការការពារសិទ្ធិអ្នកនិពន្ធ ចំពោះស្នាដៃអក្សរសាស្ត្រ ឯកសារសិល្បៈ និងឯកសារវិទ្យាសាស្ត្រ (ស្នាដៃដែលបានថ្លែងក្នុងសន្និសីទ បញ្ញត្តិច្បាប់ជាផ្លូវការ អត្ថបទតុលាការ និងអត្ថបទរដ្ឋបាល សង្កត់ធ្ងន់ថា ធម្មទេសនា ។ ល ។) ស្នាដៃនាដកម្ម និងស្នាដៃនាដកម្មតូរ្យតន្ត្រី ស្នាដៃរបាំសម័យ និង ការសំដែងកាយវិការ ការតែងបទភ្លេង ដោយមាន ឬគ្មានទំនុកច្រៀង ស្នាដៃសោតទស្សន៍ដោយមានឬគ្មានសំលេងនិងរូបថត ទាំងឡាយ ដែលដកស្រង់ពីស្នាដៃទាំងនេះ ស្នាដៃគំនូរ ស្នាដៃជាផ្ទាំងគំនូរផាត់ពណ៌ ស្នាដៃស្ថាបត្យកម្ម ផ្ទាំងចម្លាក់ ស្នាដៃចម្លាក់ និង ស្នាដៃសិលាលេខ ស្នាដៃក្រាភិច និងស្នាដៃឋានលេខា ស្នាដៃរូបថត និងស្នាដៃទាំងឡាយដែល ផលិតដោយបច្ចេកទេសដែលស្រដៀងគ្នាទៅនឹងការថតរូប ស្នាដៃ សិល្បៈអនុវត្ត រូបភាពពន្យល់ ផែនទីប្លង់ គំនូសវាស និងស្នាដៃស្តែងចេញជារូប ដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ស្ថាបត្យកម្ម និងវិទ្យាសាស្ត្រនានា កម្មវិធីកុំព្យូទ័រ និងស្នាដៃដែលបែកចេញពីស្នាដៃ ដើមដូចជា ការបកប្រែ ការយកលំនាំតាមការបំប្លែងរូបពីស្នាដៃ ដើមដែលមានស្រាប់មួយ ឬ ច្រើន។

១៧៨. ការការពារត្រូវបានផ្តល់ជូនក្នុងរយៈពេលមួយជីវិតអ្នកនិពន្ធ បូកនឹង៥០ឆ្នាំ បន្ទាប់ពីមរណៈភាពរបស់ គាត់។ សិទ្ធិនៅតែមានសុពលភាព សំរាប់រយៈពេល ៥០ឆ្នាំ ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា នៃឆ្នាំប្រក្រតីទិន ដែលមានបន្ទាប់ពីកាលបរិច្ឆេទ នៃការតាក់តែងជាស្នាដៃ ការសំដែងដោយបើកចំហជាលើកដំបូង ឬការ ចាក់ផ្សាយជាលើកដំបូង។ ចំពោះស្នាដៃដែលមានស្រាប់ពីមុនមក ហើយមិនទាន់បានក្លាយជាសម្បត្តិសាធារណៈ, ស្មារតីនៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល បានគោរពតាមសមស្របទៅនឹងប្រការទាំងឡាយ ពីមាត្រា ១ រហូតដល់មាត្រា ២១ នៃអនុសញ្ញាទីក្រុងប៊ែន រួមទាំងមាត្រា ១៨ ផង។ ជំពូកទី៥ (មាត្រា ៣០ និង៣១ និង ជំពូកទី៦ (មាត្រា ៦៧) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិន ស្មោះត្រង់ក៏បានគ្របដណ្តប់រយៈពេលការពារ និង ផ្សារភ្ជាប់ទៅនឹងសន្ធិសញ្ញាអន្តរជាតិទាំងឡាយផងដែរ។ ក្នុងការឆ្លើយតប ទៅនឹងសំនួរជាច់ដោយឡែកមួយ តំណាងរបស់ប្រទេសកម្ពុជាបានបន្ថែមថា ច្បាប់បានរួមបញ្ចូល បញ្ញត្តិទាំងឡាយស្តីពីការពង្រឹងការអនុវត្តច្បាប់ ដោយអនុញ្ញាតឱ្យមានការបំផ្លាញទំនិញទាំងអស់ ដែលរំលោភ បំពានសិទ្ធិកម្មសិទ្ធិបញ្ញា (មាត្រា ៥៨ -៦៦)។

១៧៩. តំណាងប្រតិភូកម្ពុជាក៏បានបន្ថែមថា ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលបានផ្តល់ការ ការពារការចងក្រងទិន្នន័យ (មាត្រា៧ និងមាត្រា២១), ការការពារកម្មវិធីកុំព្យូទ័រ ដូចជាស្នាដៃអក្សរសាស្ត្រ ការពារសិទ្ធិជួលចំពោះ កម្មវិធីកុំព្យូទ័រ និងសិទ្ធិផ្តាច់មុខនៃអ្នកផ្សព្វផ្សាយក្នុងការអនុញ្ញាតឱ្យផ្សព្វផ្សាយឡើងវិញ តាមរលកធាតុ អាកាស (មាត្រា៤៧ និង៤៨)។

## (ខ) ពាណិជ្ជសញ្ញា រួមទាំងសេវាសញ្ញា

១៨០. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា ច្បាប់ថ្មីស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ បានត្រូវប្រកាសឱ្យប្រើនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ។ អនុក្រឹត្យ និងបទបញ្ជាទាំងឡាយសំរាប់អនុវត្តច្បាប់ម៉ាក ត្រូវរំពឹងថា នឹងទទួលបានការអនុម័តក្នុង ឆ្នាំ២០០៣ ។ តាមច្បាប់នេះការដាក់ពាក្យសុំចុះបញ្ជីម៉ាកមួយ ត្រូវដាក់ជូនមកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។ ការប្រើប្រាស់ជាក់ស្តែង នៃម៉ាកមួយមិនមែនជាល័ក្ខខ័ណ្ឌសំរាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីនោះទេ ។ សិទ្ធិអាទិភាពត្រូវបានផ្តល់ជូនទៅឱ្យបុគ្គលណា ដែលបានដាក់ពាក្យសុំចុះបញ្ជីម៉ាក ប្រកបដោយសុពលភាពត្រឹមត្រូវតាមច្បាប់មុនគេ ឬដែលបានទាមទារសិទ្ធិអាទិភាពមុនគេបំផុត ចំពោះម៉ាកមួយ ។ សិទ្ធិអាទិភាពចំពោះម៉ាកមួយ ដែលបានដាក់ពាក្យសុំរួចជាស្រេចក្នុងប្រទេសជាសមាជិកផ្សេងណាមួយទៀតនៃអនុសញ្ញាទីក្រុងប៉ារីស ឬ អង្គការពាណិជ្ជកម្មពិភពលោកអាចត្រូវបានផ្តល់ជូនដោយឈរលើមូលដ្ឋាន នៃកាលបរិច្ឆេទដាក់ពាក្យសុំមុនគេចំពោះអ្នកដាក់ពាក្យសុំដូចគ្នា ឬចំពោះអ្នកស្នងមរតករបស់គាត់អោយតែការដាក់ពាក្យក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើឡើងក្នុងរយៈពេល៦ខែ បន្ទាប់ពីការដាក់ពាក្យសុំដំបូង ។ ពាណិជ្ជសញ្ញា មួយត្រូវបានការពារក្នុងរយៈពេល១០ឆ្នាំ ហើយអាចត្រូវបានចុះបញ្ជីសារឡើងវិញ ដោយគ្មានកំណត់សំរាប់រយៈពេល ១០ឆ្នាំ ជាបន្តបន្ទាប់។ ការខកខានមិនបានប្រើប្រាស់ម៉ាក ដែលបានចុះបញ្ជីរួចលើសពី ៥ឆ្នាំ ដោយមិនមានហេតុផលត្រឹមត្រូវអាចនាំទៅរកមោឃភាពនៃការការពារ ។ សិទ្ធិពាណិជ្ជសញ្ញាអាចប្តូរ ឬ ផ្តល់អាជ្ញាប័ណ្ណបាន ហើយម្ចាស់សិទ្ធិមានសិទ្ធិផ្តាច់មុខ ក្នុងការស្នើសុំអោយអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយករណីរំលោភបំពាននានា។ ការប្រើប្រាស់ពាណិជ្ជសញ្ញាមួយដោយម្ចាស់អាជ្ញាប័ណ្ណ (ប៉ុន្តែមិនមែនការផ្តល់អាជ្ញាប័ណ្ណទាំងស្រុងចំពោះសិទ្ធិទេ) ត្រូវបានចាត់ទុកថា ជាសកម្មភាពមួយ នៃការប្រើប្រាស់។

១៨១. ការការពារត្រូវបានផ្តល់ឱ្យបានចំពោះម៉ាកមួយ ដែលគ្មានលក្ខណៈសម្បត្តិទាំងឡាយដាច់ដោយឡែកឱ្យតែម៉ាកនោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ហើយទទួលបាននូវកិត្តិយសដ៏ល្បីល្បាញក្នុងប្រទេសកម្ពុជា ។ លោកបានអះអាងថា ម៉ាកល្បីត្រូវបានការពារដោយយោងតាមមាត្រា៦ស្ទួន នៃអនុសញ្ញាទីក្រុងប៉ារីស និង មាត្រា ១៦ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (តាមមាត្រា៤ (ង) និង (ច)និង មាត្រា១៤ (ច) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ កម្ពុជាបានធ្វើប្រតិបត្តិការជាច្រើនរួចមកហើយ ដើម្បីពង្រឹងការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញាទាក់ទងនឹងម៉ាកល្បី ហើយលោកបានអះអាងផងដែរអំពីការប្តេជ្ញារបស់កម្ពុជាក្នុងការផ្សារភ្ជាប់ និង ពង្រឹងអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា និង ច្បាប់កម្មសិទ្ធិបញ្ញារបស់ខ្លួន ដែលទាក់ទងទៅនឹងម៉ាកល្បីប្រកបដោយលក្ខណៈស្មោះត្រង់ និង មានតម្លាភាពក្នុងពេលអនាគត។ ច្បាប់នេះ ក៏បានរួមបញ្ចូលនូវបទប្បញ្ញត្តិ ទាំងឡាយដែលទាក់ទងដល់ការប្រកួតប្រជែងមិនស្មោះត្រង់រួមទាំងការបង្ហាញ ឬ ការសង្ស័យទាំងឡាយ ដែលហាក់បីដូចជានាំឱ្យមានការភ័ន្តច្រឡំចំពោះសាធារណៈជន ។ គ្មានច្បាប់ដាច់ដោយឡែកណាមួយស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ ត្រូវបានរំពឹងទុកថានឹងរៀបចំសំរាប់ពេលបច្ចុប្បន្ននេះ។

## (ត) កំណាត់សំគាល់លក្ខណៈភូមិសាស្ត្រ រួមទាំងបញ្ជាក់ឈ្មោះប្រភពដើមនៃទំនិញ

១៨២. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា កម្ពុជាមិនបានផ្តល់ការការពារចំពោះកំណត់សំគាល់លក្ខណៈភូមិសាស្ត្រទេ នាពេលបច្ចុប្បន្ននេះ។ លោករំពឹងថា នឹងមានការរៀបចំច្បាប់ថ្មីមួយ ដែលគ្របដណ្តប់លើប្រធានបទនេះ និង រួមបញ្ចូលការការពារ បន្ថែមចំពោះកំណត់សំគាល់លក្ខណៈភូមិសាស្ត្រសំរាប់ស្រា និង ភេសជ្ជៈស្រវឹង ដែលនឹងត្រូវប្រកាសឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០០៤ ។

## (ឃ) គំនូសព្រាងឧស្សាហកម្ម

១៨៣. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា គំនូសព្រាងឧស្សាហកម្មត្រូវបានការពារដោយផ្អែកតាមច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្ម ដែលប្រកាសអោយប្រើនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ។ មានតែគំនូសព្រាងឧស្សាហកម្មថ្មីដូចជាគំនូសព្រាង ដែលមិនទាន់ត្រូវបានបើកចំហដល់សាធារណជន តាមរយៈការបោះផ្សាយ ឬការប្រើប្រាស់មុនកាលបរិច្ឆេទអាទិភាពទេ ទើបអាចចុះបញ្ជីបានតាមច្បាប់ថ្មីនេះ ។ ការការពារមិនត្រូវផ្តល់ជូនចំពោះ ផ្នែកនានានៃគំនូសព្រាងមួយ ដែលតំរូវយ៉ាងសំខាន់តាមរយៈការពិចារណាផ្នែកបច្ចេកទេសទេ ។ គំនូសព្រាងឧស្សាហកម្ម ដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ មិនអាចចុះបញ្ជីបានទេ ។ ពាក្យស្នើរសុំចុះបញ្ជីត្រូវដាក់មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយកាលបរិច្ឆេទអាទិភាពជាកាលបរិច្ឆេទដាក់ពាក្យ ឬការទាមទារសិទ្ធលើកដំបូង ។ ពាក្យស្នើរសុំត្រូវបោះផ្សាយ ដើម្បីផ្តល់ឱកាសអោយមានការប្តឹងជំទាស់នឹងការចុះបញ្ជី ។ ការការពារបានផ្តល់ឱ្យរយៈពេល ៥ ឆ្នាំ ហើយអាចបន្ត សាឡើងវិញបានពីរដង គំនូសព្រាងឧស្សាហកម្មអាចត្រូវបានផ្ទេរ ឬផ្តល់អាជ្ញាប័ណ្ណបាន ។ ម្ចាស់កម្មសិទ្ធិមានសិទ្ធិផ្តាច់មុខ ដើម្បីស្នើរសុំអោយអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការប្រឆាំងទល់នឹងការរំលោភបំពាន និងអាចទាមទារសំណងបាន ។

១៨៤. សមាជិកម្នាក់បានអញ្ជើញកម្ពុជាអោយបញ្ជាក់ថា តើច្បាប់កម្ពុជាស្របតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រា ២៦.១ របស់កិច្ចព្រមព្រៀង TRIPS ដែលពាក់ព័ន្ធទៅនឹងសិទ្ធិនៃម្ចាស់គំនូសព្រាងឧស្សាហកម្ម ដើម្បីរារាំងការនាំចូលនូវផលិតផល ដែលប្រើឬមានរូបរាងដូចគំនូសព្រាងដែលបានការពារឬទេ ។ តំណាងប្រតិភូប្រទេសកម្ពុជាបានឆ្លើយថា ច្បាប់កម្ពុជាបានធានាឱ្យម្ចាស់សិទ្ធិមានសិទ្ធិហាមឃាត់ភាគីទីបីពី "ការធ្វើអាជីវកម្ម" នូវគំនូសព្រាងឧស្សាហកម្ម ដែលបានចុះបញ្ជីរួចហើយ ដូចជាតាមរយៈ ការផលិត ការលក់ ឬការនាំចូលផលិតផលទាំងឡាយដែលមានប្រើគំនូសព្រាងឧស្សាហកម្ម (មាត្រា ៤២.១ នៃសេចក្តីព្រាងច្បាប់) ។

## ( ង ) ប្រកាសនីយប័ត្រតក្កកម្ម

១៨៥. តំណាងប្រទេសកម្ពុជាបានថ្លែងថា ច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និង គំនូសព្រាងឧស្សាហកម្ម ត្រូវបានប្រកាសឱ្យប្រើ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ។ ការរៀបចំបទបញ្ញា អនុវត្តច្បាប់នេះត្រូវចាប់ផ្តើមធ្វើក្នុងត្រីមាសទី១ នៃឆ្នាំ២០០៣។ ច្បាប់នេះអាចការពារប្រកាសនីយប័ត្រតក្កកម្ម ចំពោះតក្កកម្ម ដែលពាក់ព័ន្ធនឹងជំហានច្នៃប្រឌិតហើយអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ។ ប្រកាសនីយ ប័ត្រតក្កកម្ម មិនអាចចេញជូនចំពោះរបកគំហើញ ទ្រឹស្តីវិទ្យាសាស្ត្រ និង វិធីសាស្ត្រ គណិតវិទ្យា ប្រព័ន្ធវិធាន និងវិធីសាស្ត្រទាំងឡាយសំរាប់ធ្វើជំនួញ ការសំដែងនូវសកម្មភាពកម្មសិទ្ធិបញ្ញា ឬ ការលេងល្បែងផ្សេងៗ និងកម្មវិធីកុំព្យូទ័រ វិធីសាស្ត្រវិនិច្ឆ័យរោគ វិធីសាស្ត្រព្យាបាលរោគ និង វះកាត់សំរាប់ការព្យាបាលមនុស្ស និងសត្វ តក្កកម្មដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ និង វិធីសាស្ត្រជីវសាស្ត្រសំរាប់ការបង្កាត់ពូជដំណាំ និងសត្វ ក្រៅពីវិធីសាស្ត្រមីក្រូជីវសាស្ត្រ ក៏ដូចជាផលិតផល ដែលបានមកពីវិធីសាស្ត្រទាំងនេះ ។ ឆ្លើយតបនឹង សំនួរដ៏ជាក់លាក់ ដែលពាក់ព័ន្ធទៅនឹងការមិនរាប់បញ្ចូលនូវការការពារទាំងនេះលោកបានបន្ថែមថា វិធាន ទាំងឡាយដែលត្រូវបានប្រើប្រាស់ក្នុងកម្មវិធីកុំព្យូទ័រមិនមែនជាកម្មវិធីនោះទេ ព្រោះមិនមានលក្ខណៈគ្រប់គ្រាន់ សំរាប់ការការពារជាប្រកាសនីយប័ត្រតក្កកម្ម ហើយដែលប្រព័ន្ធ ឬវិធីសាស្ត្រសំរាប់ធ្វើជំនួញទាំងនោះអាចនឹង មិនមានលក្ខណៈគ្រប់គ្រាន់សំរាប់ការការពារជាប្រកាសនីយប័ត្រតក្កកម្ម ដោយសារតែប្រព័ន្ធ ឬ វិធីសាស្ត្រ ទាំងនោះខ្វះការអនុវត្តខាងឧស្សាហកម្ម ។ ភាពខុសប្លែកគ្នាទាំងនេះ នឹងត្រូវបានបញ្ជាក់ច្បាស់ក្នុងបទបញ្ញា អនុវត្តច្បាប់នេះ។

១៨៦. ពាក្យស្នើរសុំចុះបញ្ជី ត្រូវដាក់មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយអាទិភាពត្រូវបានផ្តល់ជូន ជនណាដែលបានដាក់ពាក្យមុនដំបូងគេ ឬទាមទារសិទ្ធិអាទិភាព សំរាប់ប្រកាសនីយប័ត្រតក្កកម្ម ។ ពាក្យស្នើរ សុំប្រកាសនីយប័ត្រតក្កកម្មត្រូវអនុលោមតាមការពិនិត្យទាំងបែបបទ និងខ្លឹមសារ ។ ប្រកាសនីយប័ត្រតក្កកម្ម ត្រូវបានផ្តល់ជូននៅពេលផុតកំណត់នៃរយៈពេល១៨ខែគិតចាប់តាំងពីកាលបរិច្ឆេទអាទិភាព ហើយការការពារបាន ផ្តល់ឱ្យសំរាប់រយៈពេល២០ឆ្នាំ ចាប់ពីថ្ងៃដាក់ពាក្យសុំ ។ ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មមានសិទ្ធិផ្តាច់មុខក្នុង ការផ្ទេរ ឬផ្តល់អាជ្ញាប័ណ្ណប្រកាសនីយប័ត្រតក្កកម្ម ហើយអាចស្នើសុំឱ្យភាគីទី៣ បញ្ឈប់ការរំលោភបំពាន ហើយអាចទាមទារសំណងបាន ។ បទប្បញ្ញត្តិទាំងឡាយស្តីពីការផ្តល់អាជ្ញាប័ណ្ណដោយបង្ខំមានចែងនៅក្នុង មាត្រា៤៧ ដល់ ៦២ នៃច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែល មានប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្ម ហើយអាចអនុវត្តបានក្រោយរយៈពេល៣ឆ្នាំជាបន្តបន្ទាប់ នៃការមិនប្រើប្រាស់ប្រកាសនីយប័ត្រតក្កកម្មមួយ ឬប្រសិនបើផលិតផលនៃប្រកាសនីយប័ត្រតក្កកម្ម ដែលបានការពាររួចហើយមិនត្រូវបានផ្តល់អោយដាក់លក់ក្នុង បរិមាណគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ទីផ្សារកម្ពុជាដោយគ្មានហេតុផលសមស្របប៉ុន្តែសំរាប់តែការប្រើប្រាស់ភាគច្រើន ចំពោះការផ្គត់ផ្គង់ទីផ្សារក្នុងស្រុកប៉ុណ្ណោះ ។

១៨៧. ចំពោះការលើកឡើងទាក់ទងដល់សកម្មភាពប្រឆាំងទល់នឹងផលិតផលឱសថក្លែងក្លាយ លោកបានធ្វើការកត់សំគាល់ថា ម្ចាស់សិទ្ធិអាចប្រើប្រាស់បទប្បញ្ញត្តិទាំងឡាយនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងផលិតផលឱសថ ដើម្បីការពារសិទ្ធិស្របច្បាប់របស់គេ ។ ដោយយល់ដឹងអំពីភាពខុសប្លែកគ្នាអំពីផលិតផលក្លែងក្លាយនិង ផលិតផលត្រឹមត្រូវដែលប្រើឈ្មោះផ្សេង លោកបានកត់សំគាល់ថា ក្នុងករណីនាំចូលឱសថក្លែងក្លាយ ម្ចាស់សិទ្ធិអាចស្វែងរកការការពារសិទ្ធិរបស់ខ្លួនបានតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម ឬបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងផលិតផលឱសថ ។ មាត្រា ១២ របស់ច្បាប់នេះអនុញ្ញាតឱ្យមាន ការផ្តន្ទាទោសឧក្រិដ្ឋនិងការផាកពិន័យពី២០លានរៀលរហូតដល់ ៥០លានរៀល និងដាក់គុកពី ០៥ឆ្នាំ ដល់១០ឆ្នាំ ចំពោះការដឹងអំពីការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ឬ ការលក់ថ្នាំញៀនណាកូទិក ឬ ផលិតផលឱសថ ដែលក្លែងក្លាយផលិតផលដែលមានគុណភាពទាបជាងស្តង់ដារ ឬ ផលិតផលហួសកាលកំណត់ប្រើប្រាស់ ហើយមានផលប៉ះពាល់អវិជ្ជមានដល់សុខភាពមនុស្ស។

## ( ទ) __ការការពារប្រភេទផ្សេងៗនៃរុក្ខជាតិ__

១៨៨. តំណាងប្រទេសកម្ពុជាបានថ្លែងថា ប្រភេទផ្សេងៗនៃរុក្ខជាតិ មិនត្រូវបានរាប់បញ្ចូលនៅក្នុងច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្មម៉ូដែលមានអត្ថប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្មទេ។ ដូច្នេះកម្ពុជាមិនបានផ្តល់ការការពារប្រភេទផ្សេងៗនៃរុក្ខជាតិនាពេលបច្ចុប្បន្ននេះទេ ប៉ុន្តែសេចក្តីព្រាងច្បាប់មួយស្តីពីការការពារប្រភេទផ្សេងៗនៃរុក្ខជាតិកំពុងតែត្រូវបានរៀបចំឡើងដោយមានជំនួយពីអង្គការ UPOV ។ បច្ចុប្បន្នសេចក្តីព្រាងច្បាប់នេះត្រូវរំពឹងថានឹង ប្រកាសឱ្យប្រើក្នុងឆ្នាំ ២០០៥ ។

## ( ឆ) __គំនូសព្រាងនៃសៀគ្វីប្រមូលផ្តុំ__

១៨៩. សមាជិកម្នាក់បានកត់សំគាល់ថា ច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្មរបស់ប្រទេសកម្ពុជាមិនបានបង្ហាញឱ្យឃើញបទប្បញ្ញត្តិណាមួយសំរាប់ការការពារគំនូសព្រាងដូចដែលតំរូវដោយមាត្រា៣៥ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) និងបានស្វែងរកចំលើយបញ្ជាក់ថាតើ បទប្បញ្ញត្តិទាំងនេះមាន ឬត្រូវបានចែងនៅក្នុងច្បាប់ដោយឡែកណាមួយឬទេ ។

១៩០. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា ប្រធានបទដែលបានលើកឡើងនេះត្រូវការពារតាមរយៈច្បាប់ថ្មីមួយស្តីពីគំនូសព្រាងនៃសៀគ្វីប្រមូលផ្តុំ។ បច្ចុប្បន្ននេះកម្ពុជាកំពុងស្វែងរកជំនួយបច្ចេកទេសដើម្បីជួយរៀបចំច្បាប់នេះ ។

**( ជ) លក្ខខណ្ឌតម្រូវស្ដីពីព័ត៌មានសំងាត់ ដែលរួមមានការសំងាត់ពាណិជ្ជកម្មនិងទិន្នន័យសាកល្បង**

១៩១. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា មាត្រា១២៨ នៃច្បាប់ស្ដីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្មបានផ្ដល់ការការពារចំពោះទិន្នន័យសំងាត់។ ជាបន្ថែមពីលើនេះ ប្រទេសកម្ពុជានឹងរៀបចំ ហើយអនុម័តច្បាប់ដោយឡែកមួយស្ដីពីការការពារព័ត៌មានសំងាត់ និងការសំងាត់ពាណិជ្ជកម្ម ។ ច្បាប់នេះគ្រោងអនុម័តដោយសភាជាតិក្នុង ឆ្នាំ២០០៤ ហើយប្រកាសឱ្យប្រើក្នុងឆ្នាំ ២០០៥ ។

**៣- វិធានការត្រួតពិនិត្យការរំលោភបំពានកម្មសិទ្ធិបញ្ញា**

១៩២. តំណាងប្រទេសកម្ពុជាបានថ្លែងថា វិធានការបច្ចុប្បន្នដែលត្រួតពិនិត្យការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញាមានមូលដ្ឋានផ្អែកលើបទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា សម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ និងប្រកាសលេខ៣៦៨ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីវិធានការដែលត្រួតពិនិត្យការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា ។ លើសពីនេះទៀត ច្បាប់ថ្មីទាំងឡាយដូចជា ច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងច្បាប់ស្ដីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្មរួមមាន បទប្បញ្ញត្តិស្ដីពីការមិនអនុវត្តតាមកាតព្វកិច្ចទាំងឡាយដូចជា ការខកខានមិនបានបង់កំរៃសំរាប់ថែរក្សា ឬ ខកខានមិនបានប្រើប្រាស់ពាណិជ្ជសញ្ញា ឬប្រកាសនីយប័ត្រតក្កកម្ម ដែលបានចុះបញ្ជីរួច ក្នុងរយៈពេលកំណត់ដោយច្បាប់ ដែលប្រការនេះអាចនាំឱ្យឈានទៅដល់ការធ្វើមោឃៈភាព នូវការការពារ ឬ ការផ្ដល់អាជ្ញាប័ណ្ណដល់ភាគីទី៣ ឬ អង្គភាពរដ្ឋបាលណាមួយក្នុងគោលបំណងផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ។

**៤- ការពង្រឹងការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា**

**( ក) កាតព្វកិច្ចទូទៅ**

១៩៣. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា សេចក្ដីព្រាងច្បាប់ទាំងឡាយរបស់ប្រទេសកម្ពុជាស្ដីពី សិទ្ធិកម្មសិទ្ធិបញ្ញា នឹងគោរពតាមទាំងស្រុងទៅនឹងបទប្បញ្ញត្តិទាំងអស់ នៃមាត្រា ៤១ របស់កិច្ចព្រមព្រៀងស្ដីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងសិទ្ធិកម្មសិទ្ធបញ្ញា (TRIPS) ស្ដីពីភាពដែលអាចមាននៃនីតិវិធីពង្រឹងការអនុវត្តន៍តាមបញ្ញត្តិច្បាប់ ក្នុងស្រុកវត្តមាននៃនីតិវិធីស្មោះត្រង់និងស្មើភាពព្រមទាំងឱកាសសំរាប់ភាគីទាំងអស់ទទួលបានចំណាត់ការនៃការពិនិត្យឡើងវិញ នៃសេចក្ដីសំរេចផ្នែករដ្ឋបាលជាចុងក្រោយ និង សេចក្ដីសំរេចជាបឋមរបស់តុលាការ ដែលធ្វើឡើងដោយអាជ្ញាធរតុលាការ ។

**(ខ) នីតិវិធីតុលាការរដ្ឋប្បវេណី និងការផ្តល់សំណង**

១៩៤. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថាបទប្បញ្ញត្តិស្តីពីដំណោះស្រាយ និងនីតិវិធីរដ្ឋប្បវេណីត្រូវបានបញ្ចូលទៅក្នុងសេចក្តីព្រាងក្រមរដ្ឋប្បវេណីសេចក្តីព្រាង ក្រមនីតិវិធីរដ្ឋប្បវេណីនិងច្បាប់ស្តីពីសិទ្ធិកម្មសិទ្ធិបញ្ញត្តិទាំងឡាយ បច្ចុប្បន្ននេះកំពុងតែត្រូវបានរៀបចំ ។ បទបញ្ជាសំរាប់ការអនុវត្តច្បាប់ និង ក្រមទាំងនេះកំពុងស្ថិតនៅក្រោមការពិចារណា។ ក្រមស្តីពីនីតិវិធីរដ្ឋប្បវេណីត្រូវបញ្ចូលនីតិវិធី ដែលទាក់ទងដល់ការអនុវតសាលក្រមរដ្ឋប្បវេណី និងវិធានបណ្តោះអាសន្នទាំងឡាយ ហើយច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាត្រូវមានចែងពីបទបញ្ញត្តិទាំងឡាយសំរាប់ដោះស្រាយ និងវិធានការបណ្តោះអាសន្នដទៃទៀត។ អាជ្ញាធរអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញារួមមានតុលាការ អាជ្ញាធរគយក៏ដូចជាអង្គភាពកាំកុងត្រូល ដែលជាអង្គភាពមួយស្ថិតក្រោមអំណាចរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងនគរបាលសេដ្ឋកិច្ចដែលអង្គភាពទាំងពីរនេះទទួលបន្ទុកបង្ក្រាបទាំងការក្លែងបន្លំ និងការត្រួតពិនិត្យទំនិញនាំចូល និងនាំចេញ ។ តាមច្បាប់ថ្មីតុលាការរួមមានតុលាការខេត្តក្រុង ត្រូវមានអំណាចដោះស្រាយរឿងក្តីរំលោភបំពានកម្មសិទ្ធិបញ្ញា និងវិវាទអំពីកំរៃសួយសារ និងប្រាក់ទំនុកចិត្ត ការរំលោភ និងការអនុវត្តសិទ្ធិអ្នកនិពន្ធ និងវិវាទទាក់ទងដល់ការផ្ទេរសិទ្ធិ និងការផ្តល់អាជ្ញាប័ណ្ណចំពោះសិទ្ធិ ។ ភាគីរងគ្រោះអាចស្វែងរកអធិបញ្ជាពីតុលាការ ដើម្បីបញ្ឈប់ការរំលោភបំពាន និងអាចទាមទារសំណងចំពោះការខូចខាតរបស់ខ្លួន ។ ចំនួននៃការខូចខាតត្រូវគណនា ដោយផ្អែកលើមូលដ្ឋាននៃករណីនិមួយៗ ។ សមាជិកមួយរូបបានថ្លែងនូវការចង់ដឹងអំពីកត្តាទាំងឡាយ ដែលបានប្រើប្រាស់ដោយតុលាការ ដើម្បីកំណត់ការខូចខាតក្នុងករណីអវត្តមានច្បាប់ជាក់លាក់ចំពោះបញ្ហានេះ។ តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា ការគណនាត្រូវផ្អែកលើមូលដ្ឋាននៃតំលៃរបស់អត្ថប្រយោជន៏ដែលត្រូវបាត់បង់ដោយសារការរំលោភបំពាន និងផ្អែកតាមរយៈពេលដែលសកម្មភាពរំលោភបំពាននេះបានប្រព្រឹត្តឡើង។ លោកបានបន្ថែមទៀតថា បញ្ហានេះបច្ចុប្បន្នកំពុងតែត្រូវបានពិភាក្សាក្នុងចំណោមចៅក្រមទាំងឡាយ និងអាជ្ញាធរ ដែលពាក់ព័ន្ធទោះជាយ៉ាងនេះក្តីការកំណត់អំពីរបៀបណែនាំការវាយតំលៃការខូចខាត និងការដាក់ចេញនូវវិធានការជាដំណោះស្រាយបច្ចុប្បន្ននេះពុំទាន់ត្រូវបានលើកយកមកពិចារណានៅឡើយ។ ក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណីត្រូវចែងពីអំណាចគតិយុត្តសេចក្តីសំរេចស្តីពីការផ្តល់សំណងចំពោះការខូចខាត និងវិធានការជាដំណោះស្រាយដទៃទៀត ទោះជាគ្មានបទប្បញ្ញត្តិលំអិតក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយលោកមានជំនឿ ថាច្បាប់កម្មសិទ្ធិបញ្ញារបស់ប្រទេសកម្ពុជាបច្ចុប្បន្ននេះ និងច្បាប់ក្នុងពេលអនាគត នឹងនៅតែស្របតាមល័ក្ខខ័ណ្ឌតម្រូវនៃមាត្រា ៤៨ របស់កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងសិទ្ធិកម្មសិទ្ធិបញ្ញាពាក់ពន្ធ័ នឹងការធ្វើសំណងរបស់ចុងចម្លើយ ។

១៩៥. តុលាការមានអំណាច ក្នុងការបង្គាប់ឱ្យផ្តល់ឯកសារ (មាត្រា ១៥២ នៃសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី) ហើយការខកខានមិនបានធ្វើតាមបញ្ជានេះ នឹងនាំឱ្យតុលាការចាត់ទុកថាការអះអាងរបស់ភាគីម្ខាងទៀតថាមានលក្ខណៈត្រឹមត្រូវ (មាត្រា១៥៣) និងចាប់បង្ខំឱ្យភាគីជំទាស់បង់ប្រាក់ពិន័យ (មាត្រា១៥៤)។

ពត៌មានសំងាត់ត្រូវបានការពារតាមមាត្រា៤២ នៃច្បាប់ស្តីពី ពាណិជ្ជសញ្ញា និងមាត្រា១២៨ នៃច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ។ បទប្បញ្ញត្តិទូទៅដែលយោងទៅដល់ច្បាប់ ដាច់ដោយឡែកត្រូវបានបញ្ចូលទៅក្នុងមាត្រា ១១៥.១ នៃសេចក្តីព្រាងក្រមនៃនីតិវិធីរដ្ឋប្បវេណី។

១៩៦. សមាជិកមួយបានលើកឡើងការព្រួយបារម្ភ ចំពោះកិច្ចខំប្រឹងប្រែងរបស់កម្ពុជាក្នុងការធានាគោរពតាមមាត្រា៤៨ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងសិទ្ធិកម្មសិទ្ធិបញ្ញា (TRIPS) ពាក់ព័ន្ធនឹងការធ្វើសំណងរបស់ចុងចោទដែលរួមមានទាំងកំរៃសមស្របរបស់មេធាវីផង។ ក្នុងការឆ្លើយតប ទៅនឹងសំនួរនេះ តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា សេចក្តីព្រាងច្បាប់មិនបានផ្តល់អោយមន្ត្រីរដ្ឋបាល និងមន្ត្រីតុលាការនូវអំណាចបញ្ជាឱ្យជនរំលោភបំពានផ្តល់អោយអ្នកកាន់កាប់សិទ្ធិនូវពត៌មានស្តីពីភាគីទី៣ ដែលពាក់ព័ន្ធក្នុងផលិតកម្ម និងការចែកចាយទំនិញរំលោភបំពានកម្មសិទ្ធិបញ្ញា ដូចមានចែងក្នុងមាត្រា៤៧ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) លើកលែងតែចៅក្រមស៊ើបអង្កេត (រួមទាំងអាជ្ញាធរគយ និងអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត) ទើបអាចស្នើរសុំអោយជនរំលោភបំពានដាក់ជូនពត៌មានទាំងនេះទៅអោយតុលាការក្នុងករណីអនុវត្តនីតិវិធីព្រហ្មទណ្ឌ ហើយបញ្ហានេះត្រូវបានលើកឡើងក្នុងមាត្រា ៤២ (កថាខ័ណ្ឌទី២) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ លោកបានអះអាងទៀតថា សេចក្តីសំរេចលើករណីអង្គសេចក្តីក្នុងដំណាក់កាលជំរះក្តីរបស់តុលាការត្រូវបានផ្តល់ជូន ជាលាយល័ក្ខអក្សរ នឹងត្រូវផ្សាយចំពោះសាធារណជនតាមរយៈការចុះក្នុងសារពត៌មាន ហើយលោកបានបន្ថែមថា រដ្ឋាភិបាលរបស់លោកកំពុងតែពិចារណាផងដែរ នូវការបោះផ្សាយពីសេចក្តីសំរេចរបស់តុលាការក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម។

## (ខ) វិធានការបណ្តោះអាសន្ន

១៩៧. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា តុលាការនិងអាជ្ញាធរ ដែលទទួលខុសត្រូវផ្នែករដ្ឋបាលក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាមានអំណាចក្នុងការបញ្ជារជាបន្ទាន់ប្រកបដោយប្រសិទ្ធភាពអោយចេញវិធានការបណ្តោះអាសន្នដោយផ្អែកលើភ័ស្តុតាងជាក់ស្តែង ដើម្បីរារាំងការរំលោភបំពាន និងដើម្បីរក្សាទុកភ័ស្តុតាងដែលពាក់ព័ន្ធ ។ យោងតាមមាត្រា ៣០. (ក) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ការមានភ័ស្តុតាងដំបូងចំពោះមុខ គឺនៅពេលដែលមានហេតុផលសមស្របដើម្បីជឿបានថាការរំលោភបំពានកំពុងតែកើតឡើង ។ វិធានការបណ្តោះអាសន្នទាំងឡាយដែលអាចអនុវត្តទៅបានរួមមានការឃាត់ទុកនូវភ័ស្តុតាងជាសំភារៈ និងឧបករណ៍ទាំងឡាយ ការស្រាវជ្រាវរក សំភារៈ និង ឧបករណ៍ដែលលាក់ទុក ដីការបង្គាប់ឱ្យបញ្ឈប់ការរំលោភបំពាន, ការរឹបអូសទំនិញរំលោភបំពាន និងការរឹបអូសយកជាបណ្តោះអាសន្ននូវទំនិញ ក្នុងបំណងធានាសំណងឱ្យបានត្រឹមត្រូវ ។

## (ឃ) ដំណោះស្រាយ និងនីតិវិធីរដ្ឋបាល

១៩៨. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា តាមបទប្បញ្ញត្តិថ្មី អាជ្ញាធរមានសមត្ថកិច្ចអាចអនុវត្តវិធានការ និងតាមផ្លូវរដ្ឋបាល ដែលជាវិធានការរបស់ផ្នែកត្រួតពិនិត្យទីផ្សាររបស់ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ទីចាត់ការគយ និង រដ្ឋាករព្រមទាំងនគរបាលសេដ្ឋកិច្ច ។វិធានការរដ្ឋបាលនឹងសំណង រួមមានការព្រមាន ការពិន័យជាប្រាក់រហូតទៅដល់ ២០លានរៀល (ប្រហែលជា ៦០០០ ដុល្លាអាមេរិក) ការរឹបអូសសម្ភារៈជាភ័ស្តុតាង និងឧបករណ៍ផ្សេងៗ, ការបំផ្លាញទំនិញដែលរំលោភបំពាន និងផ្តល់សំណងចំពោះការខូចខាត ។ យោងតាមច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងពង្រាងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែលអាជ្ញាធរមានសមត្ថកិច្ចមានអំណាចចេញអធិបញ្ជាបង្គាប់ឱ្យភាគីមួយបញ្ឈប់ការរំលោភបំពាន និងព្យួរទុកការធ្វើបែបបទគយ ដូចមានចែងនៅក្នុងមាត្រា ៤៤.១ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ប៉ុន្តែមិនមានអំណាចដើម្បីបញ្ជាឱ្យជនរំលោភបំពានផ្តល់ឱ្យអ្នកកាន់កាប់សិទ្ធិនូវពត៌មានស្តីពីភាគីទី៣ ដែលពាក់ព័ន្ធក្នុងផលិតកម្ម និងការចែកចាយទំនិញរំលោភបំពាននោះ ។ ទោះជាយ៉ាងនេះក្តី អ្នកកាន់កាប់សិទ្ធិអាចទទួលពត៌មាននេះដោយខ្លួនគេផ្ទាល់ ។ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (មាត្រា ៤៦) និងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល (មាត្រា ៥៩) បានហាមឃាត់ការនាំចេញបន្តនូវទំនិញក្លែងក្លាយ ឬទំនិញរំលោភសិទ្ធិអ្នកនិពន្ធ ហើយបានប្រគល់អោយអាជ្ញាធរគយ និងអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត នូវអំណាចបំផ្លាញចោលទំនិញ រំលោភបំពានតាមសេចក្តីសំរេចរបស់តុលាការ។ ទំនិញរំលោភបំពានមិនអាចត្រូវបានកំទេចចោលទេ កាលណាគ្មានបញ្ជាពីតុលាការ។

## (ង) វិធានការពិសេសតាមព្រំដែន

១៩៩. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា សេចក្តីព្រាងច្បាប់គយ មិនបានបញ្ចូលបទប្បញ្ញត្តិទាំងឡាយ ស្តីពីវិធានការព្រំដែនដូចបានតំរូវដោយមាត្រា៥១ ដល់៦០ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) នោះទេ ។វិធានការចាំបាច់តាមព្រំដែន មានបញ្ចូលទៅក្នុងច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (មាត្រា ៣៥ ដល់ ៤៧) ។ លើសពីនេះទៅទៀត ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល (មាត្រា៦៣) ត្រូវបានបញ្ចូលដោយយោងដល់វិធានការតាមព្រំដែនទាំងអស់ដែលមានចែងនៅក្នុងច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (មាត្រា ៣៥ ដល់៤៧) រួចស្រេចហើយ។ លោកបានពិនិត្យឃើញថា មិនចាំបាច់ដាក់បញ្ចូលវិធានការទាំងនេះទៅក្នុងច្បាប់គយថ្មីទេ ដោយពង្រាងច្បាប់ (មាត្រា៨) បានតំរូវជាពិសេសអោយអាជ្ញាធរគយអនុវត្តច្បាប់ទាំងអស់របស់កម្ពុជា ហើយបញ្ញត្តិនេះនឹងត្រូវគាំទ្របន្ថែមដោយអនុក្រឹត្យមួយដែលកំពុងត្រូវបានរៀបចំដោយទីចាត់ការគយ និងរដ្ឋាករក្រោមកិច្ចសហការជាមួយក្រសួងទាំងឡាយ ដែលទទួលបន្ទុកការការពារសិទ្ធិកម្មសិទ្ធិបញ្ញា។

២០០. ច្បាប់របស់ប្រទេសកម្ពុជា បានចែងពីមានការរឹបអូសនិងការបំផ្លាញចោលនូវទំនិញដែលរំលោភបំពានភ័ស្តុតាង ច្បាប់ចំលង និងឧបករណ៍ដែលប្រើប្រាស់ក្នុងការផលិតទំនិញរំលោភបំពាន ព្រមទាំងហាមឃាត់មិនអោយមានការនាំចេញបន្ត នូវទំនិញដែលមានពាណិជ្ជសញ្ញាក្លែងក្លាយ ឬការប្រើប្រាស់នីតិវិធីផ្សេងទៀតរបស់គយ។ តាមច្បាប់ថ្មី អាជ្ញាធរគយត្រូវបានអនុញ្ញាតឱ្យជូនដំណឹងដល់ម្ចាស់សិទ្ធិ អំពីការនាំចូល ឬការនាំចេញទំនិញរំលោភបំពានដែលអាចកើតមានឡើង។ ម្ចាស់សិទ្ធិអាចស្នើរសុំឱ្យអាជ្ញាធរគយ ព្យួរទុកបែបបទគយនូវទំនិញដែលគេសង្ស័យ។ ពាក្យស្នើសុំ រួមមានការពិពណ៌នាលំអិត ពីទំនិញនោះ។ អាជ្ញាធរគយត្រូវបានតំរូវឱ្យធ្វើការជូនដំណឹងទៅម្ចាស់សិទ្ធិអំពីវិធានការដែលបានអនុវត្តរួចហើយ និងត្រូវលុបចោលវិធានការទាំងនោះវិញ ប្រសិនបើគ្មានចំណាត់ការប្តឹងផ្តល់ត្រូវបានផ្តួចផ្តើមធ្វើឡើងក្នុងរយៈពេល ១០ ថ្ងៃ ។ ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលកើតចេញពីការស្នើរសុំ ដែលមិនបានបង្ហាញភ័ស្តុតាងច្បាស់លាស់។ ក្នុងករណីដែលមានភ័ស្តុតាងជាក់ស្តែង អាជ្ញាធរគយអាចព្យួរទុកនូវការធ្វើបែបបទគយ នៃទំនិញជាប់សង្ស័យតាមការផ្តួចផ្តើមផ្ទាល់របស់គយ ហើយត្រូវបញ្ជូនព័ត៌មានជាបន្ទាន់ទៅឱ្យម្ចាស់សិទ្ធិ ពីទីកន្លែង និងកាលបរិច្ឆេទនៃការព្យួរទុកនេះ ។

## (ខ) នីតិវិធីព្រហ្មទណ្ឌ

២០១. តំណាងរបស់ប្រទេសកម្ពុជាបានថ្លែងថា ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញាអាចនាំឱ្យមានបណ្តឹងព្រហ្មទណ្ឌដោយយោងទៅតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (មាត្រា៦៣ ដល់៦៨) ច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូសព្រាង ឧស្សាហកម្ម (មាត្រា១៣២ និង ១៣៣) និងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល (មាត្រា៦៤ និង ៦៥)។ ករណីរំលោភ ព្រហ្មទណ្ឌត្រូវផ្តន្ទាទោសពិន័យជាប្រាក់រហូតទៅដល់ ២៥លានរៀល (ប្រហែល ៦០០០ ដុល្លាអាមេរិក) ឬ ផ្តន្ទាទោសដោយជាក់ពន្ធនាគារ ក្នុងចន្លោះពី ០១ខែ រហូតដល់ ០៦ខែ ។ ការផ្តន្ទាទោស ជាអតិបរិមាគឺត្រូវទ្វេដង ចំពោះបទល្មើសលើកទីពីរ ដែលប្រព្រឹត្តក្នុងរយៈពេល៥ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការសំរេចអោយជាប់ទោសលើកទី១។ បទបញ្ញាទាំងឡាយសំរាប់អនុវត្តច្បាប់ត្រូវបញ្ជាក់នូវកាលៈទេសៈសំរាប់ ដាក់ទោសព្រហ្មទណ្ឌ ។ ករណីនៃការលក់ ការចែកចាយ និងការនាំចូលឱសថក្លែងក្លាយត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ ត្រង់មាត្រាដែលចែងពីការផ្តន្ទាទោសក៏រិតព្រហ្មទណ្ឌ និងដើម្បីការពារសិទ្ធិរបស់ម្ចាស់សិទ្ធិ ។

២០២. តំណាងរបស់ប្រទេសកម្ពុជាបានអះអាងថា ក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) កម្ពុជាត្រូវបន្តធ្វើដោយអនុលោមតាមផែនការសកម្មភាព ដែលបានពិនិត្យកែសំរួលសារឡើងវិញ ហើយមានចែងនៅក្នុងឯកសារ WT/ACC/KHM/16/Rev.1 និងបានសង្ខេបក្នុង

តារាងលេខ ១២ ។ សមាជិកមួយបានជំរុញឱ្យបង្កើនល្បឿនការងាររៀបចំ សេចក្តីព្រាងក្រមនីតិវិធី រដ្ឋប្បវេណីថ្មី ដែលគាំទ្រដល់ពង្រឹងការអនុវត្តច្បាប់ដទៃទៀត ហើយតំណាងប្រទេសកម្ពុជាបានថ្លែងថា សេចក្តីព្រាងក្រមនីតិវិធី រដ្ឋប្បវេណីបានបញ្ចប់រួចហើយ ហើយនឹងត្រូវដាក់ជូនទៅឱ្យគណៈរដ្ឋមន្ត្រីពិនិត្យក្នុងពេលឆាប់ៗមុខខាងនេះ ។

២០៣. ដោយពិនិត្យហើយឡើងវិញ នូវផែនការសកម្មភាពរបស់កម្ពុជាក្នុងការអនុវត្តតាមល័ក្ខខ័ណ្ឌតំរូវ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) សមាជិកមួយបានស្វែងយល់អំពី ផែនការជាក់ស្តែងមួយដែលលាតត្រដាងនូវវិធានការទាំងឡាយដែលកម្ពុជា ត្រូវចំណាយពេលវេលាបន្ថែមទៀត ដើម្បីធ្វើអោយរបបកម្មសិទ្ធិបញ្ញារបស់ខ្លួនស្របទៅតាមបទប្បញ្ញត្តិទាំងឡាយ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាព ពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) អោយបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។ ផែនការនេះ ត្រូវបង្កើតឡើងនូវការយោគយល់គ្នាមួយរវាងកម្ពុជា និង អង្គប្រជុំក្រុមការងារ ថាតើកម្ពុជាត្រូវប្រើប្រាស់ រយៈពេលអន្តរកាលហើយបង្កើតគំនូសព្រាងផែនការជំនួយបច្ចេកទេសមួយយ៉ាងដូចម្តេច ដើម្បីអោយមាន លទ្ធភាពស្របទៅតាមក្របខ័ណ្ឌរយៈពេលមួយដែលបានកំណត់។ កម្ពុជាគួរត្រូវផ្តល់នូវការធានាជាក់លាក់មួយ ផងដែរចំពោះការអនុវត្តនូវវិធានការទាំងឡាយរបស់ខ្លួន ដែលគ្របដណ្តប់ដោយវិសាលភាពនៃកិច្ចព្រមព្រៀង ស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ក្នុងរយៈពេល អន្តរកាលណាមួយ ដែលអនុមត័ដោយ អង្គប្រជុំក្រុមការងារ ។វិធានការទាំងឡាយដែលស៊ីសង្វាក់ទៅនឹង កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទង នឹងកម្មសិទ្ធិបញ្ញា (TRIPS) ហើយដែលមានជាធរមាន មិនត្រូវអនុលោមតាមតំណាក់កាលអន្តរកាលទេ ហើយមាត្រា ៣. ៤ និង ៥ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ដែលចែងពីប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មនៃប្រជាជាតិ ដែលទទួលបានការអនុគ្រោះបំផុតត្រូវអនុវត្តចាប់ពី កាលបរិច្ឆេទចូលជាសមាជិករបស់ខ្លួន ។ លើសពីនេះទៀត កម្ពុជាមិនអនុញ្ញាតអោយមានផលិតកម្មទំនិញ ឬ ស្លាដៃ ដែលមិនសមស្របទៅនឹងខ្លឹមសារនៃបទប្បញ្ញត្តិទាំងឡាយរបស់កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ក្នុងអំឡុងពេលអន្តរកាលផងដែរ ។

២០៤. តំណាងរបស់ប្រទេសកម្ពុជា បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារចំពោះការគាំទ្រ និង ការផ្តល់ជំនួយបច្ចេកទេសរបស់ពួកគេ ។ ចំពោះហេតុផលដែលបានផ្តល់ពីខាងលើរដ្ឋាភិបាលកម្ពុជាស្នើរអោយអង្គ ប្រជុំក្រុមការងារផ្តល់នូវរយៈពេលអន្តរកាលមួយរហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ ដើម្បីទទួលបានជំនួយ បច្ចេកទេស និងបំពាក់នូវការគ្រប់គ្រងរដ្ឋបាល សំរាប់អនុវត្តអោយបានពេញលេញ នូវកាតព្វកិច្ចទាំងឡាយនៃកិច្ច ព្រមព្រៀងស្តីពី ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ។ តំណាងប្រទេសកម្ពុជាបានអះអាងថា រយៈពេលអន្តរកាលមួយគួរត្រូវបានគេផ្តល់អោយសំរាប់ការអនុវត្តកិច្ចព្រមព្រៀង របស់អង្គការពាណិជ្ជកម្ម ពិភពលោកស្តីពី ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ហើយរដ្ឋាភិបាលរបស់លោកកំពុងរៀបចំ

ដើម្បីអនុវត្តការសន្យាទាំងឡាយរបស់ខ្លួន ។ ក្នុងរយៈពេលអន្តរកាលតាមផែនការសកម្មភាព ដើម្បីអនុវត្តអោយបានពេញលេញនូវកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) កម្ពុជាត្រូវអនុវត្តឱ្យត្រឹមត្រូវតាមមាត្រាទី ៣, ៤ និង ៥ នៃកិច្ចព្រមព្រៀង ដែលបានផ្តល់អោយក្នុងចំណោមមាត្រាទាំងឡាយដូចជាមាត្រាស្តីពីប្រព្រឹត្តកម្មជាតិ និងប្រព្រឹត្តកម្មនៃប្រជាជាតិ ដែលបានទទួលការអនុគ្រោះបំផុត តាមច្បាប់ដែលកំពុងមានក្នុងពេលបច្ចុប្បន្ននេះ ។ ប្រទេសកម្ពុជាត្រូវធានាផងដែរ នូវការផ្លាស់ប្តូរណាមួយដែលបានធ្វើក្នុងច្បាប់និងបទបញ្ញត្តិរបស់ខ្លួន ព្រមទាំងការអនុវត្តក្នុងរយៈពេលនេះដែលមិនត្រូវផ្តល់ជាលទ្ធផលណាមួយដែលមានកំរិតស្រាលជាងភាពស៊ីសង្វាក់ទៅនឹងបទបញ្ញត្តិទាំងឡាយ នៃកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ដែលកើតមានឡើងចាប់ពីកាលបរិច្ឆេទនៃការចូលជាសមាជិករបស់កម្ពុជាទេ។ លើសពីនេះទៀត ប្រទេសកម្ពុជានឹងមិនផ្តល់ប្រកាសនីយប័ត្រតក្កកម្ម, ពាណិជ្ជសញ្ញា ឬសិទ្ធិនិពន្ធ ឬការអនុមត័ឱ្យធ្វើការឃោសនារកទីផ្សារសំរាប់ផលិតផលឱសថ ឬសារធាតុគីមីកសិកម្មដែលមិនស្របទៅនឹងបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) នោះទេ ។

២០៥. តំណាងរបស់ប្រទេសកម្ពុជា បានបន្តអះអាងទៀតថា រយៈពេលអន្តរកាលគួរតែត្រូវផ្តល់ឱ្យហើយរដ្ឋាភិបាលរបស់លោកនឹងធានាថា អត្រានៃការរំលោភបំពានកម្មសិទ្ធិបញ្ញាដែលមានស្រាប់ ក្នុងពេលបច្ចុប្បន្ននេះនឹងមិនកើនឡើងយ៉ាងខ្លាំងក្លាគួរកត់សំគាល់នោះទេហើយថា ការរំលោភបំពានណាមួយចំពោះកម្មសិទ្ធិបញ្ញានឹងត្រូវទប់ស្កាត់ជាបន្ទាន់ ដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងជំនួយពីអ្នកកាន់កាប់សិទ្ធិដែលរងគ្រោះនោះ ។ លោកបានបន្តអះអាងទៀតថា នៅក្នុងអំឡុងពេលអន្តរកាល កម្ពុជានឹងធ្វើការការពារប្រឆាំងទល់នឹងការប្រើប្រាស់ជា លក្ខណៈពាណិជ្ជកម្ម ដែលមិនស្មោះត្រង់នូវការសាកល្បងដែលមិនបើកចំហរ ឬទិន្នន័យផ្សេងទៀតដែលបានដាក់ជូនពិនិត្យភ្ជាប់ជាមួយពាក្យស្នើរសុំសំរាប់ការអនុម័តអោយធ្វើការឃោសនារកទីផ្សារឱសថ ឬផលិតផលគីមីកសិកម្ម ដែលបានប្រើប្រាស់រូបធាតុគីមីថ្មីតាមរយៈការមិនផ្តល់ឱ្យជនណាម្នាក់ក្រៅពីបុគ្គលដែលបានដាក់ជូនពិនិត្យនូវទិន្នន័យនេះ ដោយគ្មានការអនុញ្ញាតពីបុគ្គលនោះ ហើយអាចពឹងផ្អែកលើទិន្នន័យបែបនេះក្នុងការគាំទ្រពាក្យស្នើរសុំសំរាប់ការទទួលស្គាល់ផលិតផលក្នុងរយៈពេលយ៉ាងហោចណាស់ ០៥ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទ ដែលកម្ពុជាបានផ្តល់នូវការអនុម័តអោយធ្វើការឃោសនារកទីផ្សារដល់បុគ្គលណាម្នាក់ដែលបានផលិតទិន្នន័យនោះ ។ មុនពេលចេញការអនុម័តអោយធ្វើការឃោសនារកទីផ្សារចំពោះផលិតផលឱសថនិងផលិតផលគីមីកសិកម្មក្រសួងពាក់ព័ន្ធទាំងឡាយនៅក្នុងប្រទេសកម្ពុជា ត្រូវកំណត់អត្ថិភាព នៃប្រកាសសនីយប័ត្រតក្កកម្ម ដែលការពារផលិតផលមួយ ដែលពាក្យស្នើរសុំការអនុម័តឱ្យធ្វើការឃោសនាស្វែងរកទីផ្សារនោះត្រូវបានដាក់សុំដោយភាគីណាមួយក្រៅពីម្ចាស់ប្រកាសនីយប័ត្រតក្កកម្ម ហើយមិនត្រូវបានទទួលការអនុម័តឱ្យធ្វើការឃោសនាស្វែងរកទីផ្សារទេរហូតទាល់តែដល់កាលបរិច្ឆេទផុតកំណត់ នៃប្រកាសនីយប័ត្រតក្កកម្មនោះ ។ លោកបានបន្ថែមទៀតថា កម្ពុជាត្រូវស្វែងរកជំនួយបច្ចេកទេសដែលអាចរកបានទាំងអស់ ដើម្បីធានានូវ

សមត្ថភាពរបស់ប្រទេសកម្ពុជា ក្នុងការពង្រឹងការអនុវត្តឱ្យបានពេញលេញនូវរបបកម្មសិទ្ធិបញ្ញាស្របច្បាប់ ដែលសមស្របទៅនឹងកិច្ចព្រមព្រៀងស្តីពី ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) នៅពេលផុតកំណត់នៃរយៈពេលអន្តរកាល ហើយត្រូវធានាថា កម្ពុជានឹងផ្សព្វផ្សាយជាចំហនូវច្បាប់ទាំងអស់ ទាំងក្នុងទំរង់ជាសេចក្តីព្រាង ហើយនឹងប្រកាសឱ្យប្រើដើម្បីផ្ញើរជូនសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ឱ្យផ្តល់យោបល់ស្តីពី ភាពស្របគ្នាទៅនឹងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ដែលអាចទទួលបានរួចហើយ ។ ឆ្លើយតបនឹងសំណើរបស់គណៈប្រតិភូមួយចំនួនឱ្យកាន់តែច្បាស់លាស់ថែមទៀត តំណាងប្រទេសកម្ពុជាបានបង្ហាញនូវផែនការសកម្មភាពដែលដាក់ចេញយ៉ាងលំអិតនូវដំណាក់កាលទាំងឡាយដែលនៅសេសសល់ដើម្បីប្រកាន់យកសំដៅសំរេចឱ្យបាននូវគោលដៅនិងកាលវិភាគមួយសំរាប់ដំណាក់កាលនីមួយៗ ( សូមពិនិត្យមើល តារាងទី ១២) ។

**<u>តារាង១២</u> : ផែនការសកម្មភាពសំរាប់ការអនុវត្តកិច្ចព្រមព្រៀង ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS)**

| សកម្មភាពត្រូវអនុវត្ត | កាលបរិច្ឆេទត្រូវបញ្ចប់ |
|---|---|
| ការប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ។<br><br>ច្បាប់ស្តីពីការគ្រប់គ្រងឱសថ<br>សមាជិកភាពនៅក្នុង:<br>• អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ( តាំងពីឆ្នាំ ១៩៩៥)<br>• អនុសញ្ញាក្រុងប៉ារីស ( តាំងពីឆ្នាំ ១៩៩៨) | ឆ្នាំ ២០០២ ឬមុននេះ |
| ការប្រកាសឱ្យប្រើ:<br>• ច្បាប់ស្តីពីប្រកាសនីយបត្រ័តក្កកម្មនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣<br>• ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០៣<br><br>សមាជិកភាពនៅក្នុង:<br>• អនុសញ្ញាទីក្រុងប៊ែន<br>• អនុសញ្ញាទីក្រុងហ្សឺណែវ ស្តីពីហ្វូណូក្រាម<br>• អនុសញ្ញាទីក្រុងប្រ៊ុយសែល ស្តីពីផ្កាយរណប | ឆ្នាំ ២០០៣ |

| | |
|---|---|
| • សន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម<br>ការអនុវត្តអនុក្រឹត្យស្តីពីការអនុវត្តបទបញ្ជាទាំងឡាយនៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។<br>ការកសាងសមត្ថភាពសំរាប់មន្ត្រីជំនាញកម្មសិទ្ធិបញ្ញាសំខាន់ៗ នៅក្នុងវិស័យពាណិជ្ជសញ្ញា | |
| ពិនិត្យឡើងវិញចំពោះអត្ថបទពាក់ពន្ធ័ទាំងអស់ដោយក្រុមការងារ | មុនកាលបរិច្ឆេទ នៃការចូលជាសមាជិក |
| ការប្រកាសឱ្យប្រើ:<br>• ច្បាប់ស្តីពីកំណត់សំគាល់លក្ខណ:ភូមិសាស្ត្រ<br>• ក្រមរដ្ឋប្បវេណី<br>ការអនុវត្តអនុក្រឹត្យនិងបទបញ្ជាអនុវត្តទាំងឡាយ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូសព្រាង ឧស្សាហកម្ម ។<br>ការកសាងសមត្ថភាពសំរាប់មន្ត្រីជំនាញកម្មសិទ្ធិបញ្ញាសំខាន់ៗក្នុងវិស័យសិទ្ធិអ្នកនិពន្ធ ប្រកាសនីយបត្រតក្កកម្ម និងគំនូសព្រាងឧស្សាហកម្ម ។ | មិនអោយហួសទី០១ ខែមករាឆ្នាំ ២០០៥ |
| ការប្រកាសឱ្យប្រើ:<br>• ច្បាប់ស្តីពីគំនូសព្រាងសៀគ្វីប្រមូលផ្តុំ<br>• ច្បាប់ស្តីពីការការពារពត៌មានសំងាត់ និងការសំងាត់ពាណិជ្ជកម្ម<br>• ច្បាប់ស្តីពីការការពារប្រភេទរុក្ខជាតិ<br>• ក្រមនីតិវិធីរដ្ឋប្បវេណី<br>• ក្រមព្រហ្មទណ្ឌ<br>សមាជិកភាពនៅក្នុងអនុសញ្ញាអន្តរជាតិ សំរាប់ការការពារប្រភេទថ្មីៗរបស់រុក្ខជាតិ ។<br>ការអនុវត្តអនុក្រឹត្យ និងបទបញ្ញត្តិទាំងឡាយរបស់:<br>• ច្បាប់ស្តីពីកំណត់បង្ហាញលក្ខណ:ភូមិសាស្ត្រ<br>• ច្បាប់ស្តីពីការការពារពត៌មានសំងាត់ និងការសំងាត់ពាណិជ្ជកម្ម | មិនអោយហួសពីថ្ងៃទី ០១ មករា ឆ្នាំ ២០០៦ |

| | |
|---|---|
| ការកសាងសមត្ថភាពសំរាប់មន្ត្រីកម្មសិទ្ធិបញ្ញាសំខាន់ៗ ក្នុងផ្នែកស្តីពីកំណត់សំគាល់លក្ខណៈភូមិសាស្ត្រ និងការការពារពតិមានសំងាត់ និងការសំងាត់ពាណិជ្ជកម្ម ។ | |
| ការអនុវត្តអនុក្រឹត្យនិងបទបញ្ញាអនុវតផ្សេងៗសំរាប់:<br>• ច្បាប់ស្តីពីគំនូសព្រាងសៀគ្វីប្រមូលផ្តុំ<br>• ច្បាប់ស្តីពីការការពារប្រភេទរុក្ខជាតិ<br>ការកសាងសមត្ថភាពសំរាប់មន្ត្រីកម្មសិទ្ធិបញ្ញាសំខាន់ៗ នៅក្នុងវិស័យពាណិជ្ជសញ្ញា សិទ្ធិអ្នកនិពន្ធ ប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមាន អត្ថប្រយោជន៍ និងគំនូសព្រាងឧស្សាហកម្ម កំណត់សំគាល់លក្ខណៈភូមិសាស្ត្រ ការការពារពតិមានសំងាត់ និងការសំងាត់ពាណិជ្ជកម្ម គំនូសព្រាង សៀគ្វីប្រមូលផ្តុំ និងការការពារប្រភេទរុក្ខជាតិ ។<br>ការបង្កើតឡើងនូវបទប្បញ្ញត្តិច្បាប់ចាំបាច់បន្ថែមទៀត និងបទបញ្ញាទាំងឡាយដែលចែងពីមូលដ្ឋានគតិយុត្តសំរាប់យន្តការអនុវត្តកម្មសិទ្ធិបញ្ញា ។ | មិនអោយហួសពីថ្ងៃទី ០១ មករា ឆ្នាំ ២០០៧ |
| ការអនុវត្តពេញលេញនូវកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា | មិនអោយហួសពីថ្ងៃទី ០១ មករា ឆ្នាំ ២០០៧ |

២០៦. តំណាងរបស់ប្រទេសកម្ពុជាបានអះអាងថា កម្ពុជានឹងអនុវត្តកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា មិនអោយហួសថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ ដោយអនុលោមតាមផែនការសកម្មភាពនៅក្នុងតារាងទី១២ដោយយល់ថានៅក្នុងអំឡុងពេលនេះការការពារកម្មសិទ្ធិបញ្ញា ដែលមានចែងក្នុងកថាខ័ណ្ឌទី ២០៤ និង២០៥ និងត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជា ។ អង្គប្រជុំក្រុមការងារបានកត់ត្រានូវការសន្យានេះ ។

## គោលនយោបាយដែលជះឥទ្ធិពលលើពាណិជ្ជកម្មផ្នែកសេវាកម្ម

២០៧. តំណាងរបស់ប្រទេសកម្ពុជាបានអះអាងថា ឧស្សាហកម្មសេវាកម្ម ដែលគ្របដណ្តប់លើសលប់ដោយផ្នែកឯកជនស្រូមយកប្រមាណប្រហែល ៤០% នៃផលទុនសរុបក្នុងស្រុកក្នុងឆ្នាំ១៩៩៩ ផ្នែកនេះមានការកើនឡើងប្រហែល ៦% ក្នុងមួយឆ្នាំក្នុងរវាងចន្លោះពីឆ្នាំ១៩៩៥-១៩៩៩។ ក្របខ័ណ្ឌច្បាប់សំរាប់ផ្នែកនេះនៅមានភាពទន់ខ្សោយមិនទាន់អភិវឌ្ឍន៍នៅឡើយ ហើយផ្នែកសេវាកម្មមួយចំនួននៅពុំទាន់បានគ្រប់គ្រងដោយច្បាប់ទេ។ ពតិមានអំពីចំណាត់ថ្នាក់តាមផ្នែកសេវាកម្ម ត្រូវបានផ្តល់ឱ្យនៅក្នុងឯកសារលេខ WT/ACC/KHM/2, ឧបសម្ព័ន្ធ ៧ក ។

២០៨. លោកបានបន្ថែមទៀតថា ច្បាប់របស់កម្ពុជា ជាទូទៅមានសង្គតភាពទៅតាមគោលការណ៍ និងបទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មផ្នែកសេវាកម្ម (GATS)។ សិទ្ធិកម្មសិទ្ធិរបស់ជនបរទេសខាងផ្នែកសារពតិមានត្រូវបានកំណត់ត្រឹម២០% នៃចំនួនសារពតិមានសរុបជាភាសាខ្មែរ។ ក្រុមហ៊ុនទាំងឡាយដែលមានម្ចាស់កម្មសិទ្ធិជាជនបរទេសពុំអាចម្ចាស់សិទ្ធិកម្មសិទ្ធិលើដីធ្លីបានទេ ។ ចំនួនជនបរទេសដែលត្រូវជួលមកបំរើការងារក្នុងគ្រឹះស្ថានណាមួយ ឬផ្នែកសេវាកម្មទាំងឡាយត្រូវបានកំណត់ត្រឹម១០% នៃកំលាំងពលកម្មសរុប ហើយអនុញ្ញាតឱ្យបានចំពោះតែបុគ្គលជាជនដែលតាំងទីលំនៅក្នុងប្រទេសកម្ពុជា ។ ក្រសួងការងារអាចអនុញ្ញាតឱ្យបង្កើនភាគរយចំពោះចំនួនជនបរទេស ដែលត្រូវជួលមកបំពេញការងារនៅពេលដែលជំនាញជាក់លាក់ណាមួយពុំអាចរកបាននៅក្នុងទីផ្សារក្នុងស្រុក ។ យោងតាមច្បាប់ស្តីពីគណៈមេធាវីរបស់កម្ពុជាដែលបានអនុម័តនៅថ្ងៃ ទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ មេធាវីបរទេសពុំអាចធ្វើជាតំណាងអោយអតិថិជននិងធ្វើសកម្មភាពទាំងឡាយ ដើម្បីទាក់ទាញអតិថិជន ឬបោះផ្សាយការផ្សព្វផ្សាយពាណិជ្ជកម្មបានឡើយ។ ទោះជាយ៉ាងនេះក្តី មេធាវីទាំងនោះត្រូវបានអនុញ្ញាតឱ្យធ្វើការនៅក្នុងសមាគមពាណិជ្ជកម្មជាមួយនឹងមេធាវីសញ្ជាតិកម្ពុជា។ លក្ខខ័ណ្ឌសមាគមពាណិជ្ជកម្មនេះនឹងពុំត្រូវបានយកមកអនុវត្តទេ នៅពេលណាដែលសេវាកម្មផ្នែកច្បាប់ត្រូវបានផ្តល់ឱ្យនៅក្នុងវិស័យច្បាប់អន្តរជាតិ និងច្បាប់បរទេស។

២០៩. នៅឆ្នាំ១៩៨៩ កម្ពុជាបានដាក់អោយប្រើនូវប្រព័ន្ធធនាគារដែលមានពីរថ្នាក់ គឺធនាគារថ្នាក់កណ្តាល និងធនាគារពាណិជ្ជកម្មជំនួសអោយប្រព័ន្ធធនាគារតែមួយថ្នាក់ដែលមានពីមុន។ ចាប់តាំងពីឆ្នាំ ១៩៩១មកធនាគារបរទេសត្រូវបានអនុញ្ញាតិអោយរកស៊ីនៅកម្ពុជា។ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុប្រកាសឱ្យប្រើនៅឆ្នាំ ១៩៩៩ គ្រប់គ្រងលើកិច្ចប្រតិបត្តិការហិរញ្ញវត្ថុគ្រប់ប្រភេទ លើកលែងតែសេវាកម្មធានារ៉ាប់រង។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ នៅកម្ពុជាមានធនាគារពាណិជ្ជកម្មចំនួន១៣ ដែលក្នុងនោះធនាគារពាណិជ្ជកម្មមួយជាធនាគាររបស់រដ្ឋ ៩ផ្សេងទៀត ជាធនាគារឯកជន ហើយ៣ទៀតជាធនាគារបរទេស (២ជាសាខា)។ វិស័យធនាគារនៅកម្ពុជាមាន ធនាគារឯកទេស៤ ដែលអនុញ្ញាតិអោយធ្វើសកម្មភាពអោយខ្ចីប្រាក់សំដៅផ្តល់ឥណទានជនបទ និងគាំទ្រសហគ្រាសធុនតូច និងធុនមធ្យម។ ធនាគារអភិវឌ្ឍន៍ជនបទ បានទទួលមូលនិធិពីប្រទេសផ្តល់ជំនួយ គឺជាស្ថាប័នផ្តល់ឥណទានមួយក្នុងចំណោមស្ថាប័នខាងលើ។ ជាងនេះទៅទៀតស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនធំ (ចំនួនប្រហែល ៩០) កំពុងរកស៊ីនៅកម្ពុជា។ ស្ថាប័នទាំងនេះជាអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការទាក់ទងទៅនឹងសកម្មភាពមនុស្សធម៌ និងផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយភាពក្រីក្រស្របជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញកាលពីឆ្នាំ២០០០។ ស្ថាប័នមីក្រូហិរញ្ញវត្ថុផ្តល់ប្រាក់ឥណទាន និងជំរុញសញ្ច័យធនជាពិសេសក្នុងចំណោមសមាជិករបស់ខ្លួន ។ គាត់បានបន្ថែមថាធនាគារពាណិជ្ជកម្មគឺជាធនាគារដែលមានសកម្មភាពជាងគេនៅកម្ពុជា។ ស្ថាប័នផ្សេងៗទៀត មានសកម្មភាពតិចតួច ហើយមានស្ថេរភាពទៅបានក៏អាស្រ័យដោយធនាគារពាណិជ្ជកម្មមិនបានផ្តល់សេវាកម្មដូចគ្នានេះនៅកម្ពុជា ។ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានចែងអំពីសិទ្ធិ និងកាតព្វកិច្ចស្មើភាពគ្នារវាងធនាគារ

ក្នុងស្រុក និងធនាគារជាកម្មសិទ្ធិរបស់ជនបរទេស ។ បញ្ជីច្បាប់ និងបទបញ្ញានានា ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មលើវិស័យធនាគារ មានផ្តល់ជូនក្នុងឯកសារ WT/ACC/KHM/2 ឧបសម្ព័ន្ធ២ ផ្នែកទី៥។

២១០. វិស័យធានារ៉ាប់រង ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីអំពីការបង្កើតឧស្សាហកម្មធានារ៉ាប់រងចុះថ្ងៃ ទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩២ អនុក្រឹត្យស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០ អនុក្រឹត្យស្តីពីការត្រួតពិនិត្យសកម្មភាពធានារ៉ាប់រង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩២ និងសេចក្តីជូនដំណឹងរបស់រដ្ឋាភិបាលចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២។ ច្បាប់ស្តីពីការធានារ៉ាប់រងថ្មី ត្រូវបានប្រកាសអោយប្រើក្នុងឆ្នាំ ២០០០ និងអនុក្រឹត្យស្តីពីការធានារ៉ាប់រងសំរាប់អនុវត្តច្បាប់ស្តីពីធានារ៉ាប់រងត្រូវបានអនុម័តក្នុង ឆ្នាំ២០០១។ ច្បាប់ និងអនុក្រឹត្យបង្កើតក្របខ័ណ្ឌទូទៅសំរាប់បង្កើតក្រុមហ៊ុនធានារ៉ាប់រងរួមទាំងលក្ខខ័ណ្ឌតំរូវឱ្យមានដើមទុនអប្បបរមា និងកំរិតសាធនភាព ។ ក្រុមហ៊ុនធានារ៉ាប់រងឯកជន ជាច្រើនរួមទាំងក្រុមហ៊ុនធានារ៉ាប់រងបរទេសផងបានប្រកួតប្រជែងក្នុងទីផ្សារធានារ៉ាប់រងក្រៅពីធានារ៉ាប់រងជីវិតនៅកម្ពុជា។ ក្រុមហ៊ុន Caminco ជាក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋបានធ្វើអាជីវកម្មលើមូលដ្ឋានស្មើភាព និងប្រកួតប្រជែងជាមួយក្រុមហ៊ុនធានារ៉ាប់រងដទៃទៀតនៅលើទីផ្សារ ។ ក្រុមហ៊ុនធានារ៉ាប់រង ដែលបានទទួលអាជ្ញាប័ណ្ណទាំងអស់អាចផ្តល់សេវាកម្មធានារ៉ាប់រងគ្រប់ប្រភេទដូចជាការលក់បន្តជាដើម។ ទោះបីយ៉ាងណាក៏ដោយ ផ្អែកលើអនុក្រឹត្យស្តីពីការលក់ធានារ៉ាប់រងបន្ត ។ ទោះជាយ៉ាងណាក៏ដោយយោងតាមអនុក្រឹត្យធានារ៉ាប់រងក្រុមហ៊ុនធានារ៉ាប់រងទាំងអស់តំរូវអោយលក់បន្តនូវការធានារបស់ខ្លួនចំនួន២០ភាគរយនៅក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀតកិច្ចសន្យាធានារ៉ាប់រងទាំងអស់ ដែលមានតំលៃសរុប ៥០០,០០០ដុល្លាអាមេរិក ត្រូវតែលក់បន្តនៅក្នុងប្រទេសជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយក៏បាន ។ ក្រុមហ៊ុនធានារ៉ាប់រងមានសេរីភាព ក្នុងការជ្រើសរើសនូវក្រុមហ៊ុនណាមួយដែលខ្លួនចង់លក់បន្តការធានារបស់ខ្លួន។

២១១. រដ្ឋាភិបាលធ្វើសកម្មភាព ផ្តាច់មុខក្នុងការផ្តល់សេវាកម្មប្រៃសណីយ៍ក្នុងការដឹកជញ្ជូនសំបុត្រស្នាមដែលមានទំងន់តិចជាង៥០០ក្រាម ការផ្សាយពាណិជ្ជកម្ម (ត្រូវផុតសុពលភាពក្នុងឆ្នាំ២០០៣) ការដឹកជញ្ជូនផ្លូវដែក ការផ្គត់ផ្គង់ចរន្តអគ្គិសនី និងទឹកស្អាត។ រដ្ឋាភិបាលផ្តល់ឥណទានអនុគ្រោះដល់ក្រុមហ៊ុនអគ្គិសនីកម្ពុជា និងរដ្ឋាករទឹក។ អ្នកផ្តល់សេវាផ្តាច់មុខប្រព្រឹត្តិទៅតែលើការចែកចាយលក់ដុំ។ តំណាងប្រតិភូកម្ពុជាមានប្រសាសន៍ថា អាជ្ញាធរកម្ពុជាអនុវត្តតាមមាត្រា ៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មលើវិស័យសេវាកម្ម ដើម្បីធានាថា អ្នកផ្តល់សេវាកម្មផ្តាច់មុខ មិនរំលោភលើសិទ្ធិ លើសពីសិទ្ធិផ្តាច់មុខដែលខ្លួនមាន។

២១២. ក្នុងវិស័យទូរគមនាគមន៍ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជាទទួលខុសត្រូវក្នុងអាជីវកម្ម ផ្តល់សេវាកម្មទូរគមនាគមន៍នៅកម្ពុជា សំរបសំរួលនិងផ្តល់អាជ្ញាប័ណ្ណសំរាប់អាជីវកម្ម។ ក្នុងទសវត្សន៍ទី៩០ ទីផ្សារទូរគមនាគមន៍នៅកម្ពុជាបានបើកទូលាយជាបណ្តើរៗ អនុញ្ញាតិអោយជនបរទេសផ្តល់

សេវាកម្មក្នុងទ្រង់ទ្រាយជាការរកស៊ីចំរុះភាគហ៊ុន ក្នុងការផ្តល់សេវាកម្មទូរគមនាគមន៍អន្តរជាតិនិងអ៊ីនធើណិត វិទ្យុនិងទូរស័ព្ទចល័ត។ យោងតាមច្បាប់ថ្មីដែលកំពុងរៀបចំ កម្ពុជាមានផែនការក្នុងការបង្កើតអង្គភាពធ្វើគោលនយោបាយឯករាជ្យ ដែលអាចផ្តល់តម្លាភាពកាន់តែច្រើនថែមទៀត ក្នុងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម។ ច្បាប់ថ្មីនេះអាចនឹងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យក្នុងឆ្នាំ ២០០៤ ។ គេត្រូវការពេលវេលាបន្ថែមទៀត សំរាប់អនុម័ត និងអនុវត្តន៍ច្បាប់នេះ ។

២១៣. ទាក់ទងនឹងការបង្កើតការិយាល័យផ្តល់ពត៌មានដូចមានចែងក្នុងមាត្រា ៣:៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មលើវិស័យសេវាកម្ម តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា ពត៌មានអំពីការធ្វើពាណិជ្ជកម្មលើវិស័យសេវាកម្មអាចទទួលបានពីនាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម។

**តម្លាភាព**

**ការផ្សព្វផ្សាយពត៌មានអំពីពាណិជ្ជកម្ម**

២១៤. ទាក់ទងទៅនឹងលក្ខខ័ណ្ឌតំរូវអោយមានតម្លាភាពដែលមានចែងនៅក្នុងមាត្រា ១០ នៃកិច្ចព្រមព្រៀង GATT មាត្រា ៣ នៃកិច្ចព្រមព្រៀងទូទៅ ស្តីពីការធ្វើពាណិជ្ជកម្មលើវិស័យសេវាកម្ម និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកផ្សេងៗទៀត។ តំណាងប្រតិភូកម្ពុជាបានមានប្រសាសន៍ថា មាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាបានតំរូវអោយច្បាប់ដែលបានអនុម័តទាំងអស់ត្រូវបោះពុម្ពផ្សាយនៅក្នុងរាជកិច្ច ដើម្បីផ្សព្វផ្សាយអោយសាធារណៈជនបានដឹងមុនពេលច្បាប់ និងបទបញ្ជាទាំងនោះចូលជាធរមាន ។ យោងតាមមាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញ ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ត្រូវបានបោះពុម្ពផ្សាយក្នុងរាជកិច្ចជា ភាសាខ្មែរ ហើយចូលជាធរមានរយៈពេល១០ថ្ងៃ នៅទីក្រុងភ្នំពេញ និង ២០ថ្ងៃនៅទូទាំងប្រទេស បន្ទាប់ពីច្បាប់ និងបទបញ្ជាតាំងនោះត្រូវបានបោះពុម្ពផ្សាយ ។ សេចក្តីសំរេចអំពីការអនុវត្តផ្សេងដែលចេញដោយក្រសួងស្ថាប័នផ្សេងៗ របស់រដ្ឋក៏ត្រូវបានបោះពុម្ពផ្សាយនៅក្នុងរាជកិច្ចដែរ ហើយកម្ពុជាត្រូវធានាថា បទបញ្ញត្តិទាំងអស់របស់ខ្លួនត្រូវតែស្របទៅតាមប្រការចែង នៃកិច្ចព្រមព្រៀង GATT មាត្រា ១០.១ ។ កាលបរិច្ឆេទនៃការចូលជាធរមាន មានចែងនៅក្នុងច្បាប់នីមួយៗ ។ ចំពោះការបង្កើតការិយាល័យផ្តល់ពត៌មានដែលមានចែងក្នុងមាត្រា ៣ នៃកិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មលើវិស័យសេវាកម្ម គាត់បានអះអាងថា កម្ពុជាបានបង្កើតអោយមានការិយាល័យផ្តល់ពត៌មានដែលស្របទៅនឹងល័ក្ខខ័ណ្ឌតំរូវនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក នៃកិច្ចព្រមព្រៀងទូទៅ ស្តីពីកាធ្វើពាណិច្ចកម្មលើវិស័យសេវាកម្ម និងកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យ ។

២១៥. តំណាងនៃប្រទេសជាសមាជិកមួយបានបញ្ជាក់ថា រាជកិច្ចអាចរកបានតែតាមរយៈការដាក់បញ្ជាទិញតែប៉ុណ្ណោះ ហើយក្រុមហ៊ុនឯកជនភាគច្រើនហាក់បីដូចជាមិនបានដឹងអំពីរាជកិច្ចនោះទេ។ ទោះបីជាច្បាប់

ទាំងអស់ត្រូវបានបោះពុម្ពផ្សាយនៅក្នុងរាជកិច្ច ប៉ុន្តែបទបញ្ញត្តិថ្មីៗមួយចំនួនហាក់ដូចជាមិនបានបោះផ្សាយ ។ តំណាងនៃប្រទេសជាសមាជិករូបនោះបានស្នើរថា កម្ពុជាគួរពិចារណាក្នុងការផ្សព្វផ្សាយខ្លឹមសាររាជកិច្ចតាមរយៈអ៊ីនធើណែត ដើម្បីលើកកំពស់លទ្ធភាពនៃការស្វែងយល់ច្បាប់ និងបទបញ្ញត្តិនានា ហើយស្វាគមន៍ចំពោះការអនុវត្តន៍ជាក់ស្តែងនានា ក្នុងការកែលំអឡើងចំពោះការផ្សព្វផ្សាយច្បាប់ និង បទបញ្ញត្តិនានាតាមរយៈរាជកិច្ច។ តំណាងប្រទេសជាសមាជិកមួយរូបក៏បានសួរបន្ថែមទៀតថា តាមមាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញច្បាប់ ឬ បទបញ្ញត្តិផ្សេងៗទៀត តំរូវអោយមានការផ្សព្វផ្សាយមុនពេលចូលជាធរមាន តើមានតំរូវអោយធ្វើការផ្សព្វផ្សាយដូចគ្នាដែរឬទេ ចំពោះសេចក្តីសំរេចរបស់តុលាការ និងសេចក្តីណែនាំរដ្ឋបាលផ្សេងៗ ដែលទាក់ទងនឹងការអនុវត្តជាទូទៅ ដើម្បីអោយរដ្ឋាភិបាល នៃប្រទេសនានា និង ពាណិជ្ជករបានដឹង? ដូចដែលមាត្រា ១០ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មតំរូវអោយមានដែរឬទេ។ តើកម្ពុជាបានធ្វើអ្វីខ្លះហើយក្នុងការអនុវត្តន៍វិធានការស្តីពីតម្លាភាពដែលតំរូវអោយធ្វើដោយកិច្ចព្រមព្រៀងអង្គការពាណិជ្ជពិភពលោកមួយចំនួន ។

២១៦. ជាការឆ្លើយតប តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថាកម្ពុជាមានបំណងផ្តល់នូវពេលវេលាសមស្រប ដូចជារយៈពេលមិនតិចជាង៣០ថ្ងៃ ជូនដល់ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់អនុសាសន៍លើវិធានការនានា ដែលមានឥទ្ធិពលដល់ការធ្វើពាណិជ្ជកម្មលើទំនិញ លើសេវាកម្ម ឬកម្មសិទ្ធបញ្ញាមុនពេលវិធានការទាំងនេះត្រូវបានអនុម័ត លើកលែងតែបទបញ្ញត្តិ និងវិធានការដែលប៉ះពាល់ដល់សន្តិសុខជាតិ ឬការផ្សព្វផ្សាយអាចជាឧបសគ្គដល់ការអនុវត្តន៍ច្បាប់ ។ ការផ្សព្វផ្សាយនូវបទបញ្ញត្តិ និងវិធានការបែបនេះ មានដាក់បញ្ចូលផងដែរនូវកាលបរិច្ឆេទនៃការចូលជាធរមានព្រមទាំងភ្ជាប់ជូននូវបញ្ជីទំនិញ ឬ សេវាកម្មដែលអាចមានផលប៉ះពាល់លើការអនុវត្តន៍វិធានការទាំងនោះ ដែលបញ្ជាក់អោយកាន់តែច្បាស់តាមរយៈប្រភេទពន្ធគយ និង លេខកូដទំនិញ ។ គាត់បានបន្ថែមថា កម្ពុជានឹងដាក់ក្នុងអ៊ីនធើណែតរបស់រដ្ឋាភិបាលនូវខ្លឹមសារនៃរាជកិច្ច ច្បាស់លាស់ ច្បាប់ចាស់ និង ច្បាប់ថ្មី ។

២១៧. តំណាងប្រតិភូកម្ពុជាបានបញ្ជាក់ថា ចាប់ពីថ្ងៃចូលជាសមាជិកច្បាប់បទបញ្ញត្តិ ក្រិត្យសេចក្តីសំរេចរបស់តុលាការ និងសេចក្តីណែនាំរដ្ឋបាលផ្សេងៗ សំរាប់អនុវត្តជាទូទៅចំពោះការធ្វើពាណិជ្ជកម្មនឹងត្រូវធ្វើការបោះពុម្ពផ្សាយតាមរបៀបដែលស្របជាមួយលក្ខខ័ណ្ឌតំរូវរបស់កិច្ចព្រមព្រៀងអង្គការពាណិជកម្មពិភពលោក ។ ដូច្នេះគ្មានច្បាប់ ឬ បទបញ្ញត្តិណាមួយ ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិអាចចូលជាធរមាននៅ មុនពេលច្បាប់ ឬបទបញ្ញត្តិនោះត្រូវបានបោះពុម្ពផ្សាយនៅក្នុងរាជកិច្ចទេ។ គាត់បានបញ្ជាក់បន្ថែមថា ច្បាប់ទាំងអស់ដែលធ្វើវិសោធនកម្ម ដើម្បីអោយស្របទៅនឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក មានចែងអំពីបញ្ញត្តិដែលតំរូវអោយមានការផ្សព្វផ្សាយបែបនេះ ។ ក្រឹត្យអនុក្រឹត្យ និងប្រកាស ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិ នឹងត្រូវបោះពុម្ពផ្សាយនៅក្នុងរាជកិច្ច។ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ដែលមានបច្ចុប្បន្ន ឬដូចមានក្នុងបញ្ជីដែលភ្ជាប់ជូន ដែលគ្រោងនឹងធ្វើការអនុវត្តក្នុងពេលអនាគតដ៏ឆាប់ខាងមុខនេះ នឹងអនុវត្តតាម

មាត្រា ១០ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ ព្រមទាំងលក្ខខ័ណ្ឌតំរូវ នៃតម្លាភាពផ្សេងៗទៀត ដែលមានចែងក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដែលតំរូវអោយមានការជូនដំណឹង និងការបោះពុម្ពផ្សាយ។ គាត់បានបញ្ជាក់ទៀតថា ត្រឹមថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៤ កម្ពុជានឹងបង្កើតនូវវែបសាយសំរាប់ផ្សព្វផ្សាយខ្លឹមសាររាជក្រឹត្យព្រមទាំងបញ្ចូលពត៌មានថ្មីជាទៀងទាត់ ហើយអាចអោយសមាជិកនានារបស់អង្គការពាណិជ្ជកម្មពិភពលោក ក្រុមហ៊ុនឯកជន និងបុគ្គលនានា អាចស្រាវជ្រាវបាននូវច្បាប់ បទបញ្ញត្តិ និងវិធានការផ្សេងៗ ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្ម លើទំនិញ លើសេវាកម្ម និងកម្មសិទ្ធិបញ្ញា។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ ។

## ការធ្វើសេចក្តីជូនដំណឹង

២១៨. តំណាងប្រតិភូកម្ពុជាបាននិយាយថា យ៉ាងហោចណាស់រយៈពេល១២ខែ បន្ទាប់ពីពិធីសារនៃការចូលជាសមាជិកចូលជាធរមាន កម្ពុជានឹងធ្វើសេចក្តីជូនដំណឹងអំពីចំណុចសំខាន់ៗ ដែលកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកបានតំរូវ ។ ច្បាប់ណាមួយដែលអនុម័តដោយកម្ពុជាក្នុងពេលក្រោយមក ហើយដែលប៉ះពាល់ដល់ការអនុវត្តន៍នូវកិច្ចព្រមព្រៀងផ្នែកណាមួយរបស់អង្គការពាណិជ្ជកម្មពិភពលោកនឹងត្រូវបានជូនដំណឹងអំពីភាពស្របគ្នានៃលក្ខខ័ណ្ឌតំរូវរបស់កិច្ចព្រមព្រៀងនោះដែរ។

## កិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្ម

២១៩. តំណាងប្រតិភូកម្ពុជាបាននិយាយថា ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ និងការបោះឆ្នោតសាកលនាឆ្នាំ១៩៩៣ អនុញ្ញាតិអោយកម្ពុជាបានចូលរួមជាថ្មីជាមួយសហគមន៍អន្តរជាតិ និងចូលរួមនៅក្នុងវេទិការតំបន់ និងពិភពលោក។ ដូច្នេះបច្ចុប្បន្នកម្ពុជាបានក្លាយជាសមាជិកស្ថាប័នមួយចំនួនដូចជា ធនាគារអន្តរជាតិសំរាប់ការស្តារនិងអភិវឌ្ឍន៍មូនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី សមាគមអភិវឌ្ឍន៍អន្តរជាតិ ភ្នាក់ងារធានារ៉ាប់រងពហុភាគី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សន្និសីទសហប្រជាជាតិស្តីពីការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងអង្គការកសិកម្ម និងស្បៀងអាហារ មូនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍន៍កសិកម្ម អង្គការអាកាសចរស៊ីវិលអន្តរជាតិ អង្គការកម្មសិទ្ធបញ្ញាពិភពលោក អង្គការស្តង់ដារអន្តរជាតិ អង្គការសុខភាពពិភពលោក អង្គការដឹកជញ្ជូនតាមផ្លូវសមុទ្រអន្តរជាតិ សហព័ន្ធទូរគមនាគមន៍អន្តរជាតិ អង្គការវប្បធម៌ វិទ្យាសាស្ត្រ អប់រំសហប្រជាជាតិ អង្គការទេសចរណ៍ពិភពលោក គណៈកម្មការសង្គម និងសេដ្ឋកិច្ចសំរាប់អាស៊ី និងប៉ាស៊ីហ្វិក និងសន្ធិសញ្ញាទីក្រុងប៉ារីស សំរាប់ការការពារសិទ្ធិកម្មសិទ្ធិឧស្សាហកម្ម។

២២០. ចាប់តាំងពីឆ្នាំ១៩៩៣ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងលើអនុស្សារណៈនៃការយោគយល់ចំនួន២៤ លើវិស័យសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មអន្តរជាតិ ការជំរុញនិងការពារវិនិយោគ និងការការពារកម្មសិទ្ធិបញ្ញា ជាមួយប្រទេសចំនួន១៣ ដែលរួមមាន ចិន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ឡាវ វៀតណាម ថៃ សហព័ន្ធរុស្ស៊ី សហរដ្ឋអាមេរិក ហ្វីលីពីន និងសហគមន៍អឺរ៉ុប ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី មិនបានដាក់បញ្ចូលលក្ខខ័ណ្ឌអនុគ្រោះពាណិជ្ជកម្មទេ ប៉ុន្តែមានការសន្យាផ្តល់គោលការណ៍ស្មើភាព នៃប្រជាជាតិទទួលការអនុគ្រោះបំផុតក្នុងលក្ខណៈជាទូទៅ (ពត៌មានលំអិតផ្តល់ជូនក្នុងឯកសារ WT/ACC/KHM/2, ទំព័រ ៩១-៩៣) ។ លើសពីនេះទៀត កម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ស្តីពីការធ្វើសហប្រតិបត្តិការលើការការពារកម្មសិទ្ធិបញ្ញា ជាមួយប្រទេសថៃឡង់ដ៏ កិច្ចព្រមព្រៀងស្តីអំពីការលើកទឹកចិត្តការធ្វើវិនិយោគទុន ជាមួយសហរដ្ឋអាមេរិក កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការផ្នែក វប្បធមិ និងវិទ្យាសាស្រ្ត ជាមួយសហព័ន្ធរុស្ស៊ី កិច្ចព្រមព្រៀងសហប្រតិបត្តិការលើផ្នែកបច្ចេកទេស វិទ្យាសាស្រ្ត និងសេដ្ឋកិច្ច ជាមួយប្រទេសម៉ាឡេស៊ី ព្រមទាំងកិច្ចព្រមព្រៀងទំនិញឆ្លងកាត់ ជាមួយប្រទេសឡាវ និងវៀតណាម ។

២២១. កម្ពុជាបានចូលជាសមាជិកសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ នាថ្ងៃទី៣0 ខែមេសា ឆ្នាំ១៩៩៩ ដែលសំដៅដល់ការចូលរួមជាស្វ័យប្រវត្តិក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន។ រួមជាមួយសមាជិកដទៃទៀតរបស់អាស៊ាន កម្ពុជាបានទទួលយកនូវកិច្ចព្រមព្រៀងស្តីអំពី កម្មវិធីនៃការអនុគ្រោះពន្ធគយរួមមួយ សំរាប់តំបន់ពាណិជ្ជកម្មសេរីរបស់អាស៊ាន ដែលពន្ធគយសំរាប់អនុវត្តចំពោះផលិតផលរបស់អាស៊ាន នឹងត្រូវកាត់បន្ថយពី 0-៥ ភាគរយ ក្នុងកំលុងពេល១0ឆ្នាំ ចាប់ពីថ្ងៃទី0១ ខែមករា ឆ្នាំ២000 ។ បញ្ជីទំនិញដាក់បញ្ចូល (Inclusion List), បញ្ជីទំនិញលើកលែងបណ្តោះអាសន្ន (Temporary Exclusion List), បញ្ជីទំនិញរសើបភាព (Sensitive List) និងបញ្ជីទំនិញលើកលែង (General Exception List) របស់កម្ពុជា ត្រូវបានយល់ព្រមដោយកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៣១ និងកិច្ចប្រជុំក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្ម សេរីអាស៊ាន (AFTA) លើកទី១៣ ក្នុងខែតុលា ឆ្នាំ១៩៩៩ ។ នៅឯជំនួបកំពូលក្រៅផ្លូវការលើកទី៣ នាខែវិច្ឆិកា ឆ្នាំ១៩៩៩ កម្ពុជាបានយល់ព្រមលុបបំបាត់ពន្ធគយលើផលិតផលសំខាន់ៗទាំងអស់របស់អាស៊ាន នៅឆ្នាំ២០១៥ ។ បន្ថែមពីលើពន្ធគយក្របខណ្ឌអាស៊ាន ក៏បានបញ្ចូលវិស័យខ្លះទៀតដូចជា វិស័យគយ សហប្រតិបត្តិការណ៍លើវិស័យឧស្សាហកម្ម សហប្រតិបត្តិការលើការការពារកម្មសិទ្ធិបញ្ញា សេវាកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច ការជំរុញ និងការការពារវិនិយោគ សហប្រតិបត្តិការខាងថាមពល ការសំរបសំរួល ទំនិញឆ្លងកាត់ ការទទួលស្គាល់ទៅវិញទៅមក ។ ល ។

២២២. តំណាងប្រតិភូកម្ពុជាបានអះអាងថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន គឺជាតំបន់ពាណិជ្ជកម្ម សេរីតែមួយ ដែលកម្ពុជាជាសមាជិក ហើយកម្ពុជាមិនផ្តល់ការអនុគ្រោះពាណិជ្ជកម្មទៅអោយដៃគូពាណិជ្ជកម្មណាមួយ ដែលស្ថិតនៅក្រៅអាស៊ានឡើយ ។ ដោយមានការស្នើសុំអោយផ្តល់នូវ ឯកសារអំពីតំបន់ពាណិជ្ជកម្មសេរី តំណាងប្រតិភូកម្ពុជាបាននិយាយថា ឯកសារនានានៃតំបន់ពាណិជ្ជកម្មសេរីអាស៊ានអាចនឹងផ្តល់ជូនក្រុមការងារបាន បើសិនជាសមាជិកណាមួយមិនទាន់យល់ច្បាស់ពីកិច្ចព្រមព្រៀងនោះ។ ទិន្នន័យស្ថិតិ ដែលពាក់ព័ន្ធទៅនឹងការអនុគ្រោះពាណិជ្ជកម្មរបស់កម្ពុជា មិនទាន់មាននៅឡើយទេ ។

២២៣. តំណាងប្រតិភូកម្ពុជាបានអះអាងថា កម្ពុជានឹងពិនិត្យមើលរាល់បទប្បញ្ញត្តិទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលរួមទាំងបញ្ញត្តិនៃមាត្រា ២៤ របស់កិច្ចព្រមព្រៀង GATT-1994 និង មាត្រា ៥ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្មហើយធានាថា បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ទាំងនោះនឹងត្រូវបានជូនដំណឹង ពិគ្រោះយោបល់លើទិដ្ឋភាពនានា ដែលពាក់ព័ន្ធទៅនឹងតំបន់ពាណិជ្ជកម្មសេរី និងតំបន់គយរួមដែលកម្ពុជាជាសមាជិកមួយហើយចាប់អនុវត្តពីពេលដែលកម្ពុជាសុំចូលជាសមាជិក ។ គាត់បានអះអាងថា រយៈពេល១២ខែបន្ទាប់ពីកម្ពុជាបានចូលជាសមាជិកកម្ពុជានឹងធ្វើសេចក្តីជូនដំណឹង និងផ្ញើជូនក្រុមប្រឹក្សាពាណិជ្ជកម្មផ្នែកទំនិញ នូវឯកសារថតចំលងនៃកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងស្តីពីពន្ធគយរួម ដើម្បីអោយក្រុមប្រឹក្សានេះបញ្ជូនឯកសារនោះទៅគណៈកម្មការដែលទទួលខុសត្រូវចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់សំរាប់ធ្វើការពិនិត្យឡើងវិញ។ ក្រុមការងារបានកត់ត្រាលើការសន្យានេះ ។

## សេចក្តីសន្និដ្ឋាន

២២៤. ក្រុមការងារបានកត់ត្រាលើការពន្យល់ និងសេចក្តីថ្លែងការរបស់កម្ពុជាអំពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួន ដូចបានបញ្ជាក់ក្នុងសេចក្តីរាយការណ៍នេះ។ ក្រុមការងារបានកត់ត្រាលើកិច្ចសន្យារបស់កម្ពុជាលើបញ្ហាជាក់ស្តែងមួយចំនួន, ដូចដែលបានកត់ត្រាក្នុងកថាខ័ណ្ឌ២៥, ២៧, ៣៦, ៥០, ៥៥, ៥៩, ៦២, ៧១, ៧៧, ៨២, ៩៣, ៩៦, ៩៩, ១០៥, ១០៨, ១១៥, ១២០, ១២២, ១៣១, ១៤២, ១៤៤, ១៤៩, ១៥១, ១៥៨, ១៦៤, ១៦៦, ២០៦, ២១៧ និង២២៣ នៃសេចក្តីរាយការណ៍នេះ។ ក្រុមការងារបានកត់សំគាល់ថា ការសន្យាធ្វើនេះត្រូវបានចែងនៅក្នុងកថាខ័ណ្ឌ២ នៃពិធីសារនៃការចូលជាសមាជិករបស់កម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។

២២៥. ដោយបានធ្វើការត្រួតពិនិត្យ លើរបបពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា និងដោយយោងលើសេចក្តីពន្យល់ការសន្យាធ្វើ និងសម្បទាននានាដែលបានផ្តល់ដោយតំណាងប្រតិភូកម្ពុជា ក្រុមការងារបានសំរេចអោយកម្ពុជាចូលរួមក្នុងកិច្ចព្រមព្រៀង Marrakesh ដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោកតាមមាត្រា ១២ ។ ដោយផ្អែកលើគោលបំណងនេះ ក្រុមការងារបានរៀបចំធ្វើពង្រាង សេចក្តីសំរេច និងពិធីសារនៃការចូលជាសមាជិក ដែលបានភ្ជាប់ជូនជាមួយរបាយការណ៍នេះ ហើយកត់ត្រានូវកម្មវិធីបន្ថយពន្ធរបស់កម្ពុជាលើការធ្វើពាណិជ្ជកម្មលើទំនិញ (ឯកសារ WT/ACC/KHM/21/Add.1) និងកម្មវិធីសន្យាបើកទីផ្សារលើវិស័យសេវាកម្ម (ឯកសារ WT/ACC/KHM/21/Add.2) ដែលជាឧបសម្ព័ន្ធ នៃពង្រាងពិធីសារ។ ឯកសារទាំងអស់នេះ នឹងត្រូវស្នើរសុំការអនុម័តពីសន្និសីទថ្នាក់រដ្ឋមន្ត្រីនៅពេលអនុម័តរបាយការណ៍។ នៅពេលដែលសេចក្តីសំរេចត្រូវបានអនុម័ត ពិធីសារនៃការចូលជាសមាជិក នឹងបើកផ្លូវអោយកម្ពុជាទទួលយក ឬក្លាយជាសមាជិកពេញលេញក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីពិធីសារនេះត្រូវបានធ្វើសច្ចាប័នដោយរដ្ឋសភាកម្ពុជា។ ដូច្នេះក្រុមការងារបានយល់ព្រមថា ខ្លួនបានបំពេញការងារទាក់ទងនឹងការចរចាចូលជាសមាជិក នៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក នៃព្រះរាជាណាចក្រកម្ពុជាបាន ចប់សព្វគ្រប់ហើយ។

# ឧបសម្ព័ន្ធ I

## ច្បាប់, បទបញ្ញត្តិ និងពត៌មានផ្សេងៗ ដែលផ្តល់ជូនក្រុមការងារដោយព្រះរាជាណាចក្រកម្ពុជា

១. ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ របស់ព្រះរាជាណាចក្រកម្ពុជា (២០០១-២០១០)

២. ច្បាប់សារពើពន្ធ ថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៧

៣. ព្រះរាជក្រមស្តីពីច្បាប់ ស្តីពីការប្តូរប្រាក់លេខ CS/RKM/0897/03 ចុះខែសីហា ឆ្នាំ១៩៩៧

៤. ព្រះរាជក្រមស្តីពីច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជាលេខ 0196/27 ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦

៥. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីដំណើរការគណនេយ្យ សំរាប់ការទិញដូររូបិយ័វត្ថុបរទេសលេខ NBC/B700/50 ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០

៦. ពង្រាងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ចុះខែកញ្ញា ឆ្នាំ២០០២

៧. ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤

៨. សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ ថ្ងៃទី២៩ ខែមិនា ឆ្នាំ២០០២

៩. អនុក្រឹត្យ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជាលេខ 88/ANK/BK ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧

១០. អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥

១១. អនុក្រឹត្យស្តីពីវិសោធនកម្មលើអនុក្រឹត្យលេខ 51/ANK/BK ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ 048/ANK/BK ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩

១២. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមប្រឹក្សាវិនិយោគកម្ពុជា និងនាយកដ្ឋានច្បាប់ និងនិតិវិធីវិនិយោគ "ឯកសារតំរូវអោយមានសំរាប់ការដាក់ពាក្យសុំ ការលុបសហគ្រាសវិនិយោគពីបញ្ជីវិនិយោគរបស់ក្រុមប្រឹក្សាវិនិយោគកម្ពុជា" "ឯកសារតំរូវអោយមានសំរាប់ការដាក់ពាក្យសុំរបស់សហគ្រាសវិនិយោគសំរាប់ការផ្ទេរភាគហ៊ុន និងតំកល់អនុស្សារណៈថ្មីរបស់ក្រុមហ៊ុន" "ឯកសារដែលតំរូវអោយមាន ដើម្បីដាក់ពាក្យសុំផ្លាស់ប្តូរឈ្មោះរបស់សហគ្រាសវិនិយោគ" "ឯកសារដែលតំរូវអោយមាន ដើម្បីដាក់ពាក្យសុំផ្លាស់ប្តូរទីតាំង របស់សហគ្រាសវិនិយោគ" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៨

១៣. សេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីកាតព្វកិច្ចផ្តល់ពត៌មាន លើសកម្មភាពនៃការនាំចូល និងនាំចេញ របស់សហគ្រាសវិនិយោគលេខ 1538/99 CDC ចុះថ្ងៃទី ០១ខែកក្កដា ឆ្នាំ១៩៩៩

១៤. អនុក្រឹត្យស្តីពីវិធានការរឹតបណ្តឹងវិស័យវិនិយោគមួយចំនួនលេខ 80/ANK/BK ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៩

១៥. សេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីតំរូវការចំពោះក្រុមហ៊ុនបរទេសដែលបង្ហាញភស្តុតាងថាជាជនស្លូតត្រង់ សំរាប់បំពេញបែបបទដាក់ពាក្យសុំគំរោងវិនិយោគ លេខ 2736/99 CDC ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩

១៦. សារាចរណែនាំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការរៀបចំ និងការប្រើប្រាស់ការលើកទឹកចិត្ត ក្រុមប្រឹក្សាអភិវឌ្ឍន៍/ក្រុមប្រឹក្សាវិនិយោគកម្ពុជា ចំពោះសហគ្រាសវិនិយោគលេខ 165/00 CDC ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០

១៧. សេចក្តីព្រាងច្បាប់ស្តីពីភាពមិនអាចសងបំណុលបាន

១៨. សេចក្តីកែតំរូវ សេចក្តីព្រាងច្បាប់ស្តីពីភាពមិនអាចសងបំណុលបាន ចុះខែកក្កដា ឆ្នាំ២០០២

១៩. សេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការទូទាត់បំណុលពន្ធដែលជំពាក់ដោយសហគ្រាសវិនិយោគ ក្នុងព្រះរាជាណាចក្រកម្ពុជាលេខ 538/00 CDC ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០

២០. សារាចរណែនាំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីនិតិវិធីសំរាប់សហគ្រាសវិនិយោគដែលគ្មានសកម្មភាពលេខ 748/00 CDC ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០០០

២១. សេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីសហគ្រាសវិនិយោគលេខ 822/00 CDC ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០០

២២. ច្បាប់ភូមិបាល ( បកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ )

២៣. សេចក្តីព្រាងច្បាប់ ស្តីពីការជួលទ្រព្យសម្បត្តិផ្ទាល់ខ្លួន

២៤. សេចក្តីពន្យល់ចំពោះច្បាប់នៃកិច្ចសន្យាពាណិជ្ជកម្ម ចុះខែមេសា ឆ្នាំ២០០១

២៥. ច្បាប់ស្តីពីសភាពាណិជ្ជកម្ម ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៥

២៦. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការគ្រប់គ្រងការធ្វើពាណិជ្ជកម្មត្បូង និងលោហៈធាតុមានតំលៃលេខ NBC/999/100 ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩

២៧. អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មការជាតិអចិន្ត្រៃយ៍ សំរាប់សំរបសំរួលការធ្វើឯកជនភាវូបនីយ៍កម្ម និងការជំរុញការដាំដុះកៅស៊ូ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៤

២៨. អនុក្រឹត្យ ស្តីពីកិច្ចសន្យាសាងសង់, ធ្វើអាជីវកម្ម និងផ្ទេរ BOT No.11/ANK/BK ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ១៩៩៨

២៩. សេចក្តីព្រាងច្បាប់រដ្ឋប្បវេណី

៣០. សេចក្តីព្រាងច្បាប់រដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០២

៣១. សេចក្តីព្រាងច្បាប់ស្តីពីនិតិវិធីរដ្ឋប្បវេណីរបស់កម្ពុជា

៣២. ច្បាប់ស្តីពីសមាគមមេធាវី ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥

៣៣. ច្បាប់ស្តីពី និតិវិធីព្រហ្មទ័ណ្ឌ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣

៣៤. សេចក្តីសំរេចស្តីពី បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងច្បាប់ព្រហ្មទ័ណ្ឌ និងច្បាប់តុលាការនិង និតិវិធី ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងអំឡុងពេលអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២

៣៥. ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៥

៣៦. ព្រះរាជក្រមស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មមាត្រា១០, ១១, ១៤, ១៦, ១៧, ២១, ២២, ២៥, ២៦, ២៨, ២៩, ៣០, ៣១, ៣២, ៣៣, ៣៤, ៣៥, ៣៦, ៣៧, ៣៨, ៤០, ៤២, និង មាត្រា៤៤ នៃជំពូក២, មាត្រា៥៤, ៥៧ និង ៥៨ នៃជំពូក៤ និង មាត្រា៥៩ និង៦០ នៃជំពូក៥ លេខ NS/RKM/1199/12 ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

៣៧. ប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីសកម្មភាពពាណិជ្ជកម្ម របស់ក្រុមហ៊ុនពាណិជ្ជកម្មលេខ 017/PRK/MoC ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២000

៣៨. សេចក្តីព្រាងច្បាប់ស្តីពីគយ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២

៣៩. សៀវភៅពន្ធគយរបស់កម្ពុជា ឆ្នាំ២០០១

៤០. ប្រកាសរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការលើកទឹកចិត្តការអនុគ្រោះពន្ធគយសំរាប់ទ្រទ្រង់ ឧស្សាហកម្មក្នុងស្រុកនិងការផ្តល់សិទ្ធិសំរាប់ផ្ទេរភាគហ៊ុនលេខ 2895/99/CDC ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៩

៤១. ច្បាប់ស្តីពីការគ្រប់គ្រងផលិតផលឱសថ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩៦

៤២. ប្រកាសស្តីពីការអនុវត្តន៍សេវាត្រួតពិនិត្យទំនិញមុនពេលផ្ទុក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២000

៤៣. ប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីការចេញវិញ្ញាបនបត្រ័ប្រភពដើម វិក័យបត្រ័ពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់លេខ 1437/MoC/PRK ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ១៩៩៩

៤៤. ប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីការកែតំរូវបំពេញបន្ថែម និងការចេញវិញ្ញាបនប័ត្រ ប្រភពដើម វិក័យប័ត្រពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចេញ សំរាប់ការនាំចេញសំលៀកបំពាក់ លេខ 3414/MoC ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៩

៤៥. ព្រះរាជក្រមលើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថភាពផលិតផល និងសេវាកម្មលេខ NS/RKM/0600/001 ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២000

៤៦. អនុក្រឹត្យស្តីពីស្តង់ដារ និងការគ្រប់គ្រងសំភារៈកសិកម្មលេខ 69/ANK/BK ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨

៤៧. សេចក្តីព្រាងអនុក្រឹត្យស្តីពីចត្តាឡីស័ក្តរុក្ខជាតិ

៤៨. សេចក្តីព្រាងអនុក្រឹត្យស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលពីសត្វ ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០០២

៤៩. អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទានលេខ05/ANK/BK ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០០

៥០. ច្បាប់ព្រៃឈើ ខែសីហា ឆ្នាំ២០០២

៥១. សេចក្តីសំរេច ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ការការពារសកម្មភាពនេសាទខុសច្បាប់លើដែនសមុទ្រកម្ពុជាលេខ 18/SSR/RGC ចុះថ្ងៃ០៣ ខែមេសា ឆ្នាំ២០០០

៥២. សេចក្តីព្រាងច្បាប់ជលផល

៥៣. សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត

៥៤. សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងច្បាប់គ្រប់គ្រងអនាម័យ

៥៥. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រភពធនធានទឹក

៥៦. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិពាក់ព័ន្ធ

៥៧. ការកែតំរូវឡើងវិញ នៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិពាក់ព័ន្ធ ចុះខែឧសភា ឆ្នាំ២០០២

៥៨. សេចក្តីព្រាងច្បាប់ស្តីពីប្រកាសនីយ៍ប័ត្រតក្កកម្ម

៥៩. ច្បាប់ស្តីពីប្រកាសនីយ៍ប័ត្រតក្កកម្ម ដែលមានអត្ថប្រយោជន៍ និងគំនូសឧស្សាហកម្ម ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០០១

៦០. សេចក្តីសំរេចស្តីពីការបង្កើតការិយាល័យផ្តល់ពត៌មានសំរាប់ (១). ការងារសេវាកម្ម, (២). ការងារអនាម័យ និងភូតគាមអនាម័យ, (៣). របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម, និង(៤). ភាពធ្វើអោយស្របគ្នា នៃច្បាប់ជាមួយនឹងកិច្ចព្រមព្រៀង អង្គការពាណិជ្ជកម្មពិភពលោក ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០២

៦១. ច្បាប់ស្តីពីគណនេយ្យសារជីវកម្ម មុខជំនាញគណនេយ្យ និងការផែកបញ្ជីគណនេយ្យ

៦២. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការផ្តល់អាជ្ញាប័ណ្ណធនាគារដែលធ្វើអាជីវកម្ម ក្រោមច្បាប់ក្នុងស្រុក Thor.796-153 Bis Pra.kar ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៦

៦៣. ព្រះរាជក្រមស្តីពីច្បាប់ ស្តីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុលេខ NS/RKM/1199/13 ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ១៩៩៩

៦៤. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពី រចនាសម្ព័ន្ធ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា និងតួនាទីកាតព្វកិច្ចរបស់ការិយាល័យតំណាងលេខ B8/99/140 ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩

៦៥. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពី ការផ្តល់អាជ្ញាប័ណ្ណរបស់ធនាគារឯកទេសឥណទានជនបទលេខ NBC/B700/05 ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០០

៦៦. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារលេខ NBC/B700/04 ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២000

៦៧. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុលេខ NBC/ B700/06 ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២000

៦៨. ប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ស្តីពីការទូទាត់បំណុលរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុលេខ NBC/B700-08 ចុះថ្ងៃ០៩ ខែកុម្ភៈ ឆាំ២000

៦៩. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីដើមទុនអប្បបរិមា របស់ធនាគារលេខ NBC/B700/39 ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២000

៧០. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីសន្ទស្សន៍សាធនភាពរបស់ធនាគារលេខ NBC/B700/46 ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២000

៧១. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការគណនាដើមទុនរបស់ធនាគារលេខ NBC/B700/47 ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២000

៧២. ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីចំណាត់ថ្នាក់ និងល័ក្ខខ័ណ្ឌនៃបំណុលដែលមិនអាចសងបាន និងបំណុលសង្ស័យដែលរួមទាំងការប្រាក់ព្យួរទុក លេខ NBC/B700/51 ចុះថ្ងៃ១៧ ខែកុម្ភៈ ឆ្នាំ២000

៧៣. ប្រកាសរបស់ធនាគារជាតិកម្ពុជា ស្តីពីការត្រួតពិនិត្យការរីកចំរើនហួសហេតុរបស់ធនាគារ លេខ NBC/B700/52 ចុះថ្ងៃ១៧ ខែកុម្ភៈ ឆ្នាំ២000

៧៤. ច្បាប់ស្តីពីការធនារ៉ាប់រងលេខ NS/RKM/0700/02 ចុះថ្ងៃ២០ ខែមិថុនា ឆ្នាំ២000

៧៥. សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការធនារ៉ាប់រង ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២00២

៧៦. សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៏

៧៧. សេចក្តីព្រាងច្បាប់ស្តីពីទេសចរណ៏

៧៨. ការកែតំរូវឡើងវិញ លើសេចក្តីព្រាងច្បាប់ទេសចរណ៏ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២00២

៧៩. ច្បាប់ស្តីពីសញ្ជាតិ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៦

៨០. ច្បាប់ស្តីពីអន្តោរប្រវេសន្តន៏ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤

៨១. ច្បាប់ការងារ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧

៨២. ច្បាប់សារពតិមាន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥

៨៣. សេចក្តីព្រាងច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានាអាជីវកម្មធានារ៉ាប់រង

៨៤. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិធ្វើចរាចរ

៨៥. ព្រះរាជក្រឹត្យស្តីពីច្បាប់នៃការបង្ក្រាបល្បែងស៊ីសងលេខ NS/R.Decr/0196/28 ចុះថ្ងៃ២៦ ខែមករា ឆ្នាំ១៩៩៦

**ឧបសម្ព័ន្ធ II**

## កម្មវិធីអនុម័តច្បាប់ ដើម្បីអោយស្របជាមួយកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| **ឆ្នាំ 2001** | | | |
| ១. ផ្តល់សច្ចាប័នលើសន្ធិសញ្ញា ICSID | ទូទៅ | អនុម័តដោយគណៈរដ្ឋមន្ត្រី និងសភាជាតិ | ២០០១ |
| ២. ផ្តល់សច្ចាប័នលើសន្ធិសញ្ញាក្រុងញ៉ូវយ៉ក (ការទទួលយកសេចក្តីសំរេចរបស់អាជ្ញាកណ្តាលបរទេស) | ទូទៅ | អនុម័តដោយគណៈរដ្ឋមន្ត្រី និងសភាជាតិ | ២០០១ |
| ៣. ច្បាប់ភូមិបាល | ទូទៅ | អនុម័តដោយគណៈរដ្ឋមន្ត្រី និងសភាជាតិ | ខែ កញ្ញា ឆ្នាំ ២០០១ |
| ៤. ព្រះរាជកិច្ចស្តីពីសហករណ៍ | ទូទៅ | អនុម័តដោយគណៈរដ្ឋមន្ត្រី ខែតុលា ឆ្នាំ២០០១ | គ្មានការអនុម័តពីសភាទេ |
| ៥. ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា និងការប្រកួតប្រជែងមិនស្មោះត្រង់ | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជសញ្ញា | អនុម័តដោយគណៈរដ្ឋមន្ត្រីខែ តុលា ឆ្នាំ២០០១ រង់ចាំការអនុម័តពីសភាជាតិ | ខែ ធ្នូ ឆ្នាំ ២០០១ |
| **ឆ្នាំ 2002** | | | |
| ៦. អនុក្រឹត្យស្តីពីការបង្កើតការិយាល័យ ផ្តល់ពត៌មាន (១) សេវាកម្ម (២) អនាម័យ និងភូតគាមអនាម័យ (៣) របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម | កិច្ចព្រមព្រៀងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម អនាម័យ និងភូតគាមអនាម័យ | អនុម័តដោយគណៈរដ្ឋមន្ត្រី ប្រហែលក្នុងខែ មិថុនា ឆ្នាំ ២០០២ | គ្មានការអនុម័តពី សភាជាតិទេ |
| ៧. ច្បាប់ព្រៃឈើ | ទូទៅ | អនុម័តដោយសភាជាតិ ខែ សីហា ឆ្នាំ ២០០២ | ខែ សីហា ឆ្នាំ ២០០២ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| ៨. ច្បាប់ស្តីពីសេវាប្រៃសណីយ៍ | កិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មផ្នែកសេវាកម្ម GATS | អនុម័តដោយគណៈរដ្ឋមន្ត្រី និងបញ្ជូនទៅសភា ខែ ធ្នូ ឆ្នាំ ២០០១ | ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ |
| ៩. ច្បាប់ស្តីអំពីប្រកាសនីប័ត្រតក្កកម្ម ដែលមានប្រយោជន៍ និងគំនូសឧស្សាហកម្ម | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | អនុម័តដោយសភាជាតិ ខែវិច្ឆិកា ឆ្នាំ ២០០២ | ខែ ធ្នូ ឆ្នាំ ២០០២ |
| ១០. ច្បាប់ស្តីអំពី គណនេយ្យ | ទូទៅ | អនុម័តដោយសភាជាតិ | ខែ វិច្ឆិកា ឆ្នាំ ២០០២ |
| **ឆ្នាំ 2003** | | | |
| ១១. ច្បាប់ ស្តីអំពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិពាក់ព័ន្ធ | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | អនុម័តដោយសភាជាតិ ខែ មករា ឆ្នាំ ២០០៣ | ខែ កុម្ភៈ ឆ្នាំ ២០០៣ |
| ១២. វិសោធនកម្មច្បាប់វិនិយោគ | ទូទៅ | អនុម័តដោយសភាជាតិ ខែ កុម្ភៈ ឆ្នាំ ២០០៣ | ខែ កុម្ភៈ ឆ្នាំ ២០០៣ |
| ១៣. អនុក្រឹត្យស្តីពីចត្តាឡីស័ក្តសត្វ | កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ | អនុម័តដោយគណៈរដ្ឋមន្ត្រីខែ កុម្ភៈ ឆ្នាំ ២០០៣ | គ្មានការអនុម័តពី សភាជាតិទេ |
| ១៤. អនុក្រឹត្យស្តីពីចត្តាឡីស័ករុក្ខជាតិ | កិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ | អនុម័តដោយគណៈរដ្ឋមន្ត្រីខែ កុម្ភៈ ឆ្នាំ ២០០៣ | គ្មានការអនុម័តពី សភាជាតិទេ |
| ១៥. ច្បាប់ ស្តីអំពីសហគ្រាសពាណិជ្ជកម្ម | ទូទៅ | អនុម័តដោយគណៈរដ្ឋមន្ត្រី ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០២ និងដោយសភាជាតិ ខែ មិថុនា ឆ្នាំ ២០០២ | វិច្ឆិកា ឆ្នាំ ២០០២ |
| ១៦. ច្បាប់ស្តីពីការកំសាន្ត និងទេសចរណ៍ | កិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មផ្នែកសេវាកម្ម GATS | បញ្ជូនទៅគណៈរដ្ឋមន្ត្រីខែ មិនា ឆ្នាំ ២០០៣ និងទៅសភាជាតិ ខែ មេសា ឆ្នាំ ២០០៣ | វិច្ឆិកា ឆ្នាំ ២០០៣ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| ១៧. ច្បាប់ស្តីពីការទូទាត់ ក្នុងពាណិជ្ជកម្ម | ទូទៅ | បញ្ជូនទៅគណៈរដ្ឋមន្ត្រីខែ មិនា ឆ្នាំ ២០០៣ និងទៅសភាជាតិខែ មេសា ឆ្នាំ ២០០៣ | ខែ ធ្នូ ឆ្នាំ ២០០៣ |
| ១៨. ច្បាប់គយ | ការវាយតំលៃពន្ធគយ និងវិធានប្រភពដើម GATT 1994 | បញ្ជូនទៅគណៈរដ្ឋមន្ត្រីខែ ធ្នូ ឆ្នាំ ២០០២ និងទៅសភាជាតិខែ មករា ឆ្នាំ ២០០៣ | ខែ ធ្នូ ឆ្នាំ ២០០៣ |
| ១៩. ច្បាប់ស្តីពីសិទ្ធិធ្វើចរាចរ | ទូទៅ | សេចក្តីព្រាងច្បាប់នេះបានធ្វើចប់សព្វគ្រប់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន បញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងឆ្នាំ ២០០១ និងទៅសភាជាតិ ខែ មករា ឆ្នាំ ២០០៣ | ខែ ធ្នូ ឆ្នាំ ២០០៣ |
| ២០. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងធនធានទឹក និងឧតុនិយម បញ្ជូនទៅ គណៈរដ្ឋមន្ត្រី ខែមេសា ឆ្នាំ ២០០៣ និងទៅសភាជាតិ ខែឧសភា ឆ្នាំ ២០០៣ | ខែ ធ្នូ ឆ្នាំ ២០០៣ |
| ២១. ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បញ្ជូនទៅ គណៈរដ្ឋមន្ត្រី ខែមិនា ឆ្នាំ ២០០៣ និងទៅសភាជាតិ ខែមេសា ឆ្នាំ ២០០៣ | ខែ ធ្នូ ឆ្នាំ ២០០៣ |
| **ឆ្នាំ 2004** | | | |
| ២២. ច្បាប់ស្តីអំពីតំបន់កែច្នៃនាំចេញ | GATT 1994 | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បញ្ជូនទៅ គណៈរដ្ឋមន្ត្រី ខែមិនា ឆ្នាំ ២០០៣ និងទៅសភាជាតិ ខែ កញ្ញា ឆ្នាំ ២០០៣ | ខែ មករា ឆ្នាំ ២០០៤ |
| ២៣. ច្បាប់ស្តីពីអាជ្ញាកណ្តាលពាណិជ្ជកម្ម | ទូទៅ | បញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងខែ កុម្ភៈ ឆ្នាំ ២០០៣ និងសភាជាតិក្នុង ខែ មិនា ឆ្នាំ ២០០៣ | ខែ មករា ឆ្នាំ ២០០៤ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| ២៤. ច្បាប់ស្តីពីអាកាសចរស៊ីវិល | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។ បញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងខែ មិថុនា ឆ្នាំ ២០០២ និងបញ្ជូនទៅសភាជាតិក្នុង ខែ ធ្នូ ឆ្នាំ ២០០៣ | ខែ មករា ឆ្នាំ ២០០៤ |
| ២៥. ច្បាប់ស្តីពីការក្ស័យធន | ទូទៅ | បញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងខែ មិនា ឆ្នាំ ២០០៣ និងបញ្ជូនទៅសភាក្នុងខែមេសា ឆ្នាំ ២០០៣ | ខែ មករា ឆ្នាំ ២០០៤ |
| ២៦. ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា | ទូទៅ | បញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងខែ តុលាឆ្នាំ ២០០៣ និងបញ្ជូនទៅសភាក្នុងខែ ធ្នូ ឆ្នាំ ២០០៣ | ខែ កុម្ភៈ ឆ្នាំ ២០០៤ |
| ២៧. ច្បាប់ស្តីពីកិច្ចសន្យា ពាណិជ្ជកម្ម | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងពាណិជ្ជកម្ម។ បញ្ជូនទៅ គណៈរដ្ឋមន្ត្រីក្នុងខែវិច្ឆិកា ឆ្នាំ ២០០៣ និងទៅសភាជាតិឆ្នាំ ២០០៤ | ខែ កុម្ភៈ ឆ្នាំ ២០០៤ |
| ២៨. ច្បាប់ស្តីពីការជួលផ្នែកពាណិជ្ជកម្ម | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងពាណិជ្ជកម្ម។ បញ្ជូនទៅគណៈរដ្ឋមន្ត្រីក្នុងខែវិច្ឆិកា ឆ្នាំ ២០០៣ និងទៅសភាជាតិឆ្នាំ ២០០៤ | ខែ មិថុនា ឆ្នាំ ២០០៤ |
| ២៩. ច្បាប់ស្តីពីទូរគមនាគមន៍ | កិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មផ្នែកសេវាកម្ម GATS | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ បញ្ជូនទៅគណៈរដ្ឋមន្ត្រីខែតុលា ឆ្នាំ ២០០៣ និងទៅសភាជាតិ ក្នុងខែ ធ្នូ ឆ្នាំ ២០០៣ | ខែ មិថុនា ឆ្នាំ ២០០៤ |
| ៣០. ច្បាប់ស្តីពី ជលផល | អនាម័យ និងភូតគាមអនាម័យ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រីខែ ធ្នូ ឆ្នាំ ២០០៣ និងទៅសភាជាតិ នៅខែ មេសា ឆ្នាំ ២០០៤ | ខែ មិថុនា ឆ្នាំ ២០០៤ |
| ៣១. ច្បាប់ស្តីពីគំនូសឧស្សាហកម្ម និងការការពារ | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ កញ្ញា ឆ្នាំ ២០០៣ និងទៅសភាជាតិខែ កុម្ភៈ ឆ្នាំ ២០០៤ | ខែ កក្កដា ឆ្នាំ ២០០៤ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| ៣២. ច្បាប់ស្តីពីការការពារ*ពូជរុក្ខជាតិ* (ការពារទម្រង់រោងចក្រផ្សេងៗ) | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ មិនា ឆ្នាំ ២០០៣ និងទៅសភាជាតិខែ កញ្ញា ឆ្នាំ ២០០៤ | ខែ កញ្ញា ឆ្នាំ ២០០៤ |
| ៣៣. ច្បាប់ស្តីពីវិធានការសុវត្ថិភាព | វិធានការសុវត្ថិភាព | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បី រៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ។ បញ្ជូនទៅ គណៈរដ្ឋមន្ត្រី ខែ កញ្ញា ឆ្នាំ ២០០៣ និងទៅសភាជាតិខែ មេសា ឆ្នាំ ២០០៤ | ខែ តុលា ឆ្នាំ ២០០៤ |
| ៣៤. ច្បាប់ស្តីពីការប្រឆាំងការបង្ខូចថ្លៃ និង វិធានតបត | ការលក់បង្ខូចថ្លៃ ឧបត្ថម្ភកធន និងវិធានតបត | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បី រៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ។ បញ្ជូនទៅ គណៈរដ្ឋមន្ត្រី ខែ កញ្ញា ឆ្នាំ ២០០៣ និងទៅសភាជាតិខែ មករា ឆ្នាំ ២០០៤ | ខែ តុលា ឆ្នាំ ២០០៤ |
| ៣៥. ច្បាប់ស្តីពីការចង្អុលបង្ហាញទីតាំងភូមិសាស្ត្រ ដែលទាក់ទងដល់ឈ្មោះជាប្រភេទរបស់ ទំនិញ | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បី រៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ មេសា ឆ្នាំ ២០០៤ និងទៅសភាជាតិខែ មិថុនា ឆ្នាំ ២០០៤ | ខែ ធ្នូ ឆ្នាំ ២០០៤ |
| ៣៦. ច្បាប់ស្តីពីការការពារពត៌មានសម្ងាត់ | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បី រៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ។ បញ្ជូនទៅ គណៈរដ្ឋ មន្ត្រី ខែ តុលា ឆ្នាំ ២០០៣ និងទៅសភាជាតិ ខែ មីនា ឆ្នាំ ២០០៤ | ខែ វិច្ឆិកា ឆ្នាំ ២០០៤ |
| ៣៧. ច្បាប់ស្តីពីវិធានប្រភពដើម | វិធានប្រភពដើម | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បី រៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ។ បញ្ជូនទៅ គណៈរដ្ឋមន្ត្រី ខែ មិថុនា ឆ្នាំ ២០០៤ និងទៅសភាជាតិ ខែ សីហា ឆ្នាំ ២០០៤ | ខែ ធ្នូ ឆ្នាំ ២០០៤ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| ៣៨. ច្បាប់ស្តីពីការបង្កើតតុលាការពាណិជ្ជកម្ម | ទូទៅ | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌ ដើម្បីរៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ ធ្នូ ឆ្នាំ ២០០៣ និងទៅសភាជាតិ ខែ កុម្ភៈ ឆ្នាំ ២០០៤ | ខែ ធ្នូ ឆ្នាំ ២០០៤ |
| ៣៩. ច្បាប់ស្តីពីនិតិវិធីរដ្ឋប្បវេណី | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែមិថុនា ឆ្នាំ ២០០៣ និងទៅសភាជាតិនៅ ខែធ្នូ ឆ្នាំ ២០០៣ | ខែ ធ្នូ ឆ្នាំ ២០០៤ |
| ៤០. ច្បាប់ស្តីពីរដ្ឋប្បវេណី | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែមិថុនា ឆ្នាំ ២០០៣ និងទៅសភាជាតិនៅ ខែធ្នូ ឆ្នាំ ២០០៣ | ខែ មិថុនា ឆ្នាំ ២០០៣ |
| ៤១. ច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែមិថុនា ឆ្នាំ ២០០៣ និងទៅសភាជាតិនៅ ខែ មិថុនា ឆ្នាំ ២០០៤ | ខែ ធ្នូ ឆ្នាំ ២០០៤ |
| ៤២. ច្បាប់ស្តីពីព្រហ្មទណ្ឌ | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែកញ្ញា ឆ្នាំ ២០០៣ និងទៅសភាជាតិនៅ ខែ មិនា ឆ្នាំ ២០០៤ | ខែ វិច្ឆិកា ឆ្នាំ ២០០៤ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| **ឆ្នាំ 2005** | | | |
| ៤៣. ច្បាប់ស្តីពីការពារគំនូសឧស្សាហកម្ម | TRIPS | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ មិថុនា ឆ្នាំ២០០៤ និងទៅសភាជាតិខែ សីហា ឆ្នាំ ២០០៤ | ខែ មករា ឆ្នាំ ២០០៥ |
| ៤៤. ច្បាប់ស្តីពីការការពាររុក្ខជាតិថ្មីៗ | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ កក្កដា ឆ្នាំ ២០០៤ និងទៅសភាជាតិខែ កញ្ញា ឆ្នាំ ២០០៤ | ខែ មករា ឆ្នាំ ២០០៥ |
| ៤៥. ច្បាប់ស្តីពីការដូលផ្លែកពាណិជ្ជកម្ម | TRIPS | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងពាណិជ្ជកម្ម ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែមិថុនា ឆ្នាំ ២០០៤ និងទៅសភាជាតិនៅ ខែ សីហា ឆ្នាំ ២០០៤ | ខែ មករា ឆ្នាំ ២០០៥ |
| ៤៦. ច្បាប់ស្តីពីការដឹកទំនិញតាមនាវា | កិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មផ្នែកសេវាកម្ម GATS | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងទៅសភាជាតិនៅ ខែ ធ្នូ ឆ្នាំ ២០០៤ | ខែ កុម្ភៈ ឆ្នាំ ២០០៥ |
| ៤៧. ច្បាប់ស្តីពីការការពារពត៌មានសម្ងាត់ | កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងទិដ្ឋភាពពាណិជ្ជ សញ្ញា TRIPS | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បីរៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ តុលា ឆ្នាំ ២០០៤ និងទៅសភាជាតិខែ វិច្ឆិកា ឆ្នាំ ២០០៤ | ខែ មិនា ឆ្នាំ ២០០៥ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| ៤៨. ច្បាប់ស្តីពីវិធានការលក់បង្ខូចថ្លៃ និងវិធានតបត | ការលក់បង្ខូចថ្លៃ ការឧបត្ថម្ភធន និងវិធានតបត | ជំនួយបច្ចេកទេសត្រូវបានស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បីរៀបចំធ្វើសេចក្តីព្រាងច្បាប់នេះ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ កញ្ញា ឆ្នាំ ២០០៤ និងទៅសភាជាតិខែ ធ្នូ ឆ្នាំ ២០០៤ | ខែ មិនា ឆ្នាំ ២០០៥ |
| ៤៩. ច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងពាណិជ្ជកម្ម ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ កញ្ញា ឆ្នាំ ២០០៤ និងទៅសភាជាតិនៅ ខែ វិច្ឆិកា ឆ្នាំ ២០០៤ | ខែ កុម្ភៈ ឆ្នាំ ២០០៥ |
| ៥០. ច្បាប់ព្រហ្មទណ្ឌ | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងទៅសភាជាតិនៅ ខែ ធ្នូ ឆ្នាំ ២០០៤ | ខែ មិនា ឆ្នាំ ២០០៥ |
| ៥១. ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងទៅសភាជាតិនៅ ខែ ធ្នូ ឆ្នាំ ២០០៤ | ខែ មេសា ឆ្នាំ ២០០៥ |
| ៥២. ច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងពាណិជ្ជកម្ម ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងទៅសភាជាតិនៅខែ ធ្នូ ឆ្នាំ២០០៤ | ខែ មិថុនា ឆ្នាំ ២០០៥ |
| ៥៣. ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ ធ្នូ ឆ្នាំ២០០៣ និងទៅសភាជាតិនៅ ខែមិនា ឆ្នាំ ២០០៤ | ខែ មិថុនា ឆ្នាំ ២០០៥ |
| ៥៤. ច្បាប់ស្តីពីរដ្ឋប្បវេណី | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងយុត្តិធម៌ ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រី ខែ តុលា ឆ្នាំ២០០៣ និងទៅសភាជាតិនៅខែ ធ្នូ ឆ្នាំ២០០៤ | ខែ មិថុនា ឆ្នាំ ២០០៥ |

| ច្បាប់ | កិច្ចព្រមព្រៀង | ស្ថានភាពនៃពង្រាងច្បាប់ | កាលបរិច្ឆេទអនុម័ត |
|---|---|---|---|
| ៥៥. ច្បាប់ស្តីពីវិធានសុវត្ថិភាព | វិធានសុវត្ថិភាព | ជំនួយបច្ចេកទេសស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បីរៀបចំធ្វើសេចក្តីព្រាងនេះ ។ បញ្ជូនទៅគណៈ រដ្ឋមន្ត្រី ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងបញ្ជូនទៅសភាជាតិនៅ ខែ ធ្នូ ឆ្នាំ ២០០៤ | ខែ កក្កដា ឆ្នាំ ២០០៥ |
| **ឆ្នាំ 2006** | | | |
| ៥៦. ច្បាប់ស្តីពីការប្រកួតប្រជែង | ទូទៅ | ជំនួយបច្ចេកទេសស្នើដោយក្រសួងពាណិជ្ជកម្ម ដើម្បីរៀបចំធ្វើសេចក្តីព្រាងនេះ ។ បញ្ជូនទៅគណៈ រដ្ឋមន្ត្រី ខែ តុលា ឆ្នាំ ២០០៥ និងទៅសភាជាតិនៅ ខែ ធ្នូ ឆ្នាំ ២០០៥ | ខែ មករា ឆ្នាំ ២០០៦ |
| ៥៧. ច្បាប់ស្តីពីផ្សារហ៊ុន និងការប្តូរប្រាក់ | ទូទៅ | ត្រូវបានធ្វើសេចក្តីព្រាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បញ្ជូនទៅគណៈរដ្ឋមន្ត្រីខែ មិថុនា ឆ្នាំ២០០៥ និងបញ្ជូនទៅសភាជាតិនៅខែ តុលា ឆ្នាំ២០០៥ | ខែ មករា ឆ្នាំ ២០០៦ |

## តារាង 1 (a) : ស្ថានភាពនៃកម្មវិធីឯកជនភាវូបនីយកម្មរបស់កម្ពុជា ( ក្នុងចុងខែ មេសា ឆ្នាំ ២០០០ )

| ក្រសួងស្ថាប័នគ្រប់គ្រង | សហគ្រាសត្រូវរក្សាទុក | | | | សហគ្រាសត្រូវធ្វើឯកជនភាវូបនីយកម្ម | | | | សហគ្រាសបានធ្វើឯកជនភាវូបនីយកម្មរួច | | | សហគ្រាសដែលក្លាយជាសហគ្រាសសាធារណៈ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មាន សកម្មភាព | បន្ថយ សកម្មភាព | មិន ដំណើរការ | សរុប | មាន សកម្មភាព | បន្ថយ សកម្មភាព | មិន ដំណើរការ | សរុប | សហគ្រាស ជួល | សហគ្រាស ចំរុះទុន | លក់អោយ ឯកជន | | |
| ធនាគារ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 1 |
| កសិកម្ម | 0 | 0 | 0 | 0 | 5 | 2 | 0 | 7 | 22 | 2 | 0 | 7 | 31 |
| ពាណិជ្ជកម្ម | 0 | 0 | 0 | 0 | 0 | 2 | 0 | 2 | 19 | 0 | 5 | 3 | 27 |
| វប្បធម៌ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 4 |
| សុខាភិបាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 1 | 1 | 4 |
| ឧស្សាហកម្ម | 0 | 0 | 0 | 0 | 0 | 3 | 0 | 3 | 50 | 0 | 4 | 0 | 54 |
| សាធារណៈការ និងដឹកជញ្ជូន | 4 | 1 | 0 | 5 | 0 | 4 | 0 | 4 | 15 | 0 | 2 | 0 | 17 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 1 | 0 | 0 | 3 |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 1 | 0 | 0 | 1 | 0 | 0 | 0 | 0 | 3 | 1 | 2 | 0 | 6 |
| បរិស្ថាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 3 |
| ការបរទេស | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 8 | 0 | 0 | 0 | 8 |
| ការពារជាតិ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | 0 | 6 |
| ពត៌មាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 4 |
| អប់រំ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 7 | 0 | 0 | 0 | 7 |
| ទេសចរណ៍ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 5 | 0 | 0 | 0 | 5 |
| រៀបចំដែនដីនគររូបនីយកម្ម និង សំណង់ | 2 | 0 | 0 | 2 | 0 | 0 | 0 | 0 | 5 | 0 | 0 | 0 | 5 |
| មហាផ្ទៃ | 0 | 0 | 0 | 8 | 0 | 0 | 0 | 0 | 1 | 0 | 2 | 0 | 3 |
| **សរុប** | 7 | 1 | 0 | 8 | 5 | 11 | 0 | 16 | 152 | 5 | 20 | 11 | 188 |

**តារាង ១(b): បញ្ជីសហគ្រាសដែលជាកម្មសិទ្ធិរដ្ឋ គិតត្រឹម ខែមិនា ឆ្នាំ២០០៣**

| ល.រ | ក្រសួងស្ថាប័ន | ឈ្មោះសហគ្រាស |
|---|---|---|
| I. | **សហគ្រាសរដ្ឋ** | |
| 1. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមហ៊ុនចំការកៅស៊ូជប់<br>ក្រុមហ៊ុនចំការកៅស៊ូក្រែក<br>ក្រុមហ៊ុនចំការកៅស៊ូមេមុត<br>ក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូង<br>ក្រុមហ៊ុនចំការកៅស៊ូស្នួល<br>ក្រុមហ៊ុនចំការកៅស៊ូពាមជាំង<br>ក្រុមហ៊ុនចំការកៅស៊ូបឹងកេត<br>ក្រុមហ៊ុនបរិក្ខាកសិកម្ម |
| 2. | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | កំពង់ផែក្រុងព្រះសីហនុ<br>កំពង់ផែភ្នំពេញ<br>ភ្នាក់ងារនាវាចរណ៍កម្ពុជា (កាំសាប)<br>មន្ទីរពិសោធន៍ផ្នែកសំណង់<br>រាជាយស្វ័យយានកម្ពុជា<br>កំពង់ចម្លងអ្នកលឿង<br>កំពង់ចម្លងព្រែកក្តាម |
| 3. | សាលាក្រុងភ្នំពេញ | រដ្ឋាករទឹកកម្ពុជា |
| 4. | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អគ្គិសនីកម្ពុជា (EDC) |
| 5. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ធនាគារអភិវឌ្ឍន៍ជនបទ |
| 6. | ក្រសួងពាណិជ្ជកម្ម | ក្រុមហ៊ុន ហ្គ្រីនត្រេដ |
| II. | **សហគ្រាសចំរុះរដ្ឋ (៥១% ជាភាគហ៊ុនរបស់រដ្ឋ)** | |
| | | ក្រុមហ៊ុនកាំមិងតែល Camintel<br>សហគ្រាសឱសថកម្ពុជា |

## តារាង១(c) សហគ្រាសដែលស្ថិតនៅក្នុងកម្មសិទ្ធិរបស់រដ្ឋ បន្ទាប់ពីបញ្ចប់នូវកម្មវិធីឯកជនភាវូបនីយ៍កម្ម

| លេខរៀង | ក្រសួង | សហគ្រាសដែលស្ថិតនូវជាកម្មសិទ្ធិរបស់រដ្ឋ |
|---|---|---|
| ១ | ក្រសួងពាណិជ្ជកម្ម | ក្រុមហ៊ុនហ្គ្រីនត្រេដ Green Trade |
| ២ | ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | អគ្គិសនីកម្ពុជា |
| ៣ | ទីស្ដីការគណៈរដ្ឋមន្ត្រី | រោងពុម្ពរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី |
| ៤ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ធនាគារអភិវឌ្ឍន៍ជនបទ |
| ៥ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | កំពង់ផែក្រុងព្រះសីហនុ កំពង់ផែភ្នំពេញ ភ្នាក់ងារ ដឹកជញ្ជូនកម្ពុជា មន្ទីរពិសោធន៍ សំណង់ ក្រុមហ៊ុន រាជាយស្វ័យយានកម្ពុជា កំពង់ចំលងអ្នកលឿង កំពង់ចំលងព្រែក តាមាក់ កំពង់ចំលងព្រែកក្ដាម |
| ៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ក្រុមហ៊ុនបរិក្ខាកសិកម្ម ការពិភាក្សានៅតែ បន្ត ថាតើសហគ្រាសកៅស៊ូរបស់រដ្ឋ ទាំង៧ គួរតែរក្សាទុកជាសហគ្រាសរបស់រដ្ឋ ដដែលបន្ទាប់ពីការធ្វើឯកជនភាវូបនីយ៍កម្ម ត្រូវបានបញ្ចប់ ឬយ៉ាងណា ។ |

## តារាង២ : ពន្ធផ្សេងទៀតកំណត់យកលើយានយន្ត និងគ្រឿងបន្លាស់យានយន្តក្នុងប្រទេសកម្ពុជា

| Heading | HS-Code | មុខទំនិញ | អត្រាពន្ធ |
|---|---|---|---|
| ៨៧.០២ | | រថយន្តសំរាប់ដឹកមនុស្សពី ១០នាក់ ឡើងទៅ រួមទាំង អ្នកបើកបរ | |
| | | ដែលមានម៉ាស៊ីន Piston ដែលមានចំហេះនិង កុងតាក់ខាងក្នុង ( ម៉ាស៊ីនម៉ាស៊ូត រឺពាក់កណ្តាលម៉ាស៊ូត | |
| | ៨៧០២.១០.១០ | ទំងន់សរុបដែលលើសពី ៦តោន ប៉ុន្តែទាបជាង ១៨តោន មិនទាន់ដំលើងរួចរាល់ | ១០ |
| | ៨៧០២.១០.២០ | ទំងន់សរុបដែលលើសពី ៦តោន ប៉ុន្តែទាបជាង ១៨តោន តំឡើងរួចរាល់ | ១០ |
| | ៨៧០២.១០.៩០ | ផ្សេងៗ | ១០ |
| | ៨៧.០២.៩០.00 | ផ្សេងៗ | ១០ |
| ៨៧.០៣ | | រថយន្តតូច និងរថយន្តផ្សេងទៀត ដែលធ្វើឡើងសំរាប់ដឹកជញ្ជូនមនុស្ស ( មិនរាប់បញ្ចូល Heading No. 87.02) រួមមានចំណតសំរាប់កន្ទុយសណ្តោងនិងរថយន្តប្រណាំង រថយន្តដទៃទៀតដែលមានម៉ាស៊ីន Piston រត់ទៅមក មានប៊ូហ្សីចំហេះ កុងតាក់ខាងក្នុង | |
| | | ដែលមានសមត្ថភាពស៊ីឡាំង មិនលើសពី ១000 cc | |
| | ៨៧០៣.២១.២០ | រថយន្តដទៃទៀតសំរាប់ដឹកមនុស្សមិនលើសពី ៨នាក់ រាប់ទាំង អ្នកបើកបរ | ១៥ |
| | ៨៧០៣.២១.៣០ | រថយន្តផ្សេងទៀតដែលដឹកមនុស្ស ៩នាក់ រាប់ទាំង អ្នកបើកបរ | ១៥ |
| | | ដែលមានសមត្ថភាពស៊ីឡាំង ចាប់ពី ១000 cc ប៉ុន្តែ មិនលើសពី ១៥00 cc | |
| | ៨៧០៣.២២.២០ | រថយន្តដទៃទៀតដែលដឹកមនុស្សមិនលើសពី ៨នាក់ រាប់ទាំងអ្នកបើកបរ | ១៥ |

| | | | |
|---|---|---|---|
| | ៨៧០៣.២២.៣០ | រថយន្តដទៃទៀតសំរាប់ដឹកមនុស្ស ៩នាក់រួមទាំងអ្នកបើកបរ | ៤៥ |
| | | ដែលសមត្ថភាពស៊ីឡាំងលើសពី ១៥០០ cc ប៉ុន្តែទាប ជាង ៣០០០ cc | |
| | | ផ្សេងៗ ដែលមានសមត្ថភាពស៊ីឡាំងលើសពី១៥០០cc តែមានហួសពី ២០០០ cc | |
| | ៨៧០៣.២៣.២១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំងអ្នកបើកបរ | ៤៥ |
| | ៨៧០៣.២៣.២២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់រួមទាំងអ្នកបើកបរ | ៤៥ |
| | | ផ្សេងៗ ដែលសមត្ថភាពស៊ីឡាំងលើសពី ២០០០ cc តែមិនហួសពី ៣០០០ cc | |
| | ៨៧០៣.២៣.៣១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់រួមទាំងអ្នកបើកបរ | ៤៥ |
| | ៨៧០៣.២៣.៣២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់រួមទាំងអ្នកបើកបរ | ៨០ |
| | | ដែលសមត្ថភាពស៊ីឡាំងលើសពី ៣០០០ cc | |
| | | ផ្សេងៗ ដែលសមត្ថភាពស៊ីឡាំងមិនលើសពី៤០០០ cc | |
| | ៨៧០៣.២៤.២១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំងអ្នកបើកបរ | ៨០ |
| | ៨៧០៣.២៤.២២ | សំរាប់យានយន្តដែលដឹកមនុស្ស៩នាក់ រួមទាំងអ្នកបើកបរ | ១១០ |
| | | ផ្សេងៗទៀត ដែលមានសមត្ថភាពស៊ីឡាំងលើសពី ៤០០០ cc | |
| | ៨៧០៣.២៤.៣១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំងអ្នកបើកបរ | ១១០ |
| | ៨៧០៣.២៤.៣២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់រួមទាំងអ្នកបើកបរ | ១១០ |

| | | | |
|---|---|---|---|
| | | រថយន្តផ្សេងទៀតដែលមានម៉ាស៊ីន Piston ចំហេះនិងកុងតាក់ខាងក្នុង( ម៉ាស៊ីនម៉ាស៊ូតនិងពាក់កណ្តាលម៉ាស៊ូត) | |
| | | ដែលមានសមត្ថភាព ស៊ីឡាំងមិនលើសពី ១៥០០ cc | |
| | | ផ្សេងៗដែលមានសមត្ថភាពស៊ីឡាំងមិនលើសពី១០០០cc | |
| | ៨៧០៣.៣១.២១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំងអ្នកបើកបរ | ១៥ |
| | ៨៧០៣.៣១.២២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់ រួមទាំងអ្នកបើកបរ | ១៥ |
| | | ផ្សេងៗ ដែលសមត្ថភាពស៊ីឡាំងលើសពី ១០០០សេសេ តែ មិនហួស ១៥០០សេសេ | |
| | ៨៧០៣.៣១.៣១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំង អ្នកបើកបរ | ៤៥ |
| | ៨៧០៣.៣១.៣២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់ រួមទាំងអ្នកបើកបរ | ៤៥ |
| | | ដែលមានសមត្ថភាពស៊ីឡាំងលើសពី ១៥០០សេសេ ប៉ុន្តែ មិនហួសពី ២៥០០សេសេ | |
| | | ផ្សេងៗ ដែលសមត្ថភាពស៊ីឡាំងលើសពី ១៥០០សេសេ ប៉ុន្តែមិនហួសពី ២០០០សេសេ | |
| | ៨៧០៣.៣២.២១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំងអ្នកបើកបរ | ៤៥ |
| | ៨៧០៣.៣២.២២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់ រួមទាំងអ្នកបើកបរ | ៤៥ |
| | | ផ្សេងៗ ដែលមានសមត្ថភាពស៊ីឡាំង ២០០០សេសេ ប៉ុន្តែ មិនលើស ពី ២៥០០សេសេ | |
| | ៨៧០៣.៣២.៣១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំង អ្នកបើកបរ | ៨០ |
| | ៨៧០៣.៣២.៣២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់ រួមទាំងអ្នកបើកបរ | ៨០ |

| | | | |
|---|---|---|---|
| | | ដែលសមត្ថភាពស៊ីឡាំងលើសពី ២៥០០សេសេ | |
| | | ផ្សេងៗ ដែលសមត្ថភាពស៊ីឡាំងលើសពី ២៥០០សេសេ ប៉ុន្តែ មិនលើសពី ៣០០០សេសេ | |
| | ៨៧០៣.៣៣.២១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំងអ្នកបើកបរ | ៨០ |
| | ៨៧០៣.៣៣.២២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់ រួមទាំងអ្នកបើកបរ | ៨០ |
| | | ផ្សេងៗ ដែលសមត្ថភាពស៊ីឡាំង លើសពី ៣០០០ cc | |
| | ៨៧០៣.៣៣.៣១ | សំរាប់យានយន្តដែលដឹកមនុស្សមិនលើសពី ៨នាក់ រួមទាំងអ្នកបើកបរ | ១១០ |
| | ៨៧០៣.៣៣.៣២ | សំរាប់យានយន្តដែលដឹកមនុស្ស ៩នាក់ រួមទាំងអ្នកបើកបរ | ១១០ |
| ៨៧.០៤ | | យានយន្តសំរាប់ដឹកទំនិញ<br>ផ្សេងៗ ដែលមានម៉ាស៊ីនចំហេះ Piston កុងតាក់ខាងក្នុង (ប្រើម៉ាស៊ូត រឺពាក់កណ្តាលម៉ាស៊ូត) | |
| | ៨៧០៤.២១.០០ | G.v.wដែលមិនលើសពី ៥ តោន | ១០ |
| | ៨៧០៤.២២.០០ | G.v.wដែលលើសពី ៥តោន ប៉ុន្តែមិនហួសពី ២០តោន | ១០ |
| | ៨៧០៤.២៣.០០ | G.v.wដែលលើសពី២០តោន | ១០ |
| | | ផ្សេងៗ ដែលមានម៉ាស៊ីនចំហេះ Piston កុងតាក់ | |
| | | ខាងក្នុង និងប៊ូហ្ស៊ី | |
| | ៨៧០៤.៣១.០០ | G.v.wដែលមិនលើសពី ៥តោន | ១០ |
| | ៨៧០៤.៣២.០០ | G.v.wដែលលើស ៥តោន | ១០ |
| | ៨៧០៤.៩០.០០ | ផ្សេងៗ | ១០ |
| ៨៧.០៦ | | តួភ្ជាប់ជាមួយម៉ាស៊ីនសំរាប់យានយន្តដែលមាន Heading Nos ៨៧.០១ ទៅ ៨៧.០៥ | |
| | ៨៧០៦.០០.១០ | សំរាប់យានយន្តដែលមាន Subheading No. 8702.10.10 ទំងន់សរុប ៦តោន ប៉ុន្តែមិនលើស ១៨តោន | ២៥ |

| | | | |
|---|---|---|---|
| | | សំរាប់យានយន្ត heading No.៨៧.០៣ | |
| | ៨៧០៦.០០.២១ | សំរាប់យានយន្តដែលមាន subheading No. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ២៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៦.០០.២២ | សំរាប់យានយន្តដែលមាន subheading No. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ២៥ |
| | ៨៧០៦.០០.២៣ | សំរាប់យានយន្តដែលមាន subheading No. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |
| | ៨៧០៦.០០.៩០ | ផ្សេងៗ | ២៥ |
| ៨៧.០៧ | | តួ (រួមមានដំបូល) សំរាប់យានយន្តដែលមាន Subheading Nos. ៨៧.០១ ទៅ ៨៧.០៥ សំរាប់យានយន្តដែលមាន heading No. ៨៧.០៣ | |
| | ៨៧០៧.១០.១០ | សំរាប់យានយន្តដែលមាន subheading No. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៧.១០.២០ | សំរាប់យានយន្តដែលមាន subheading No. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ៣០ |
| | ៨៧០៧.១០.៣០ | សំរាប់យានយន្តដែលមាន subheading No. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |

| | | | |
|---|---|---|---|
| | ៨៧០៧.៩០.០០ | ផ្សេងៗ | ២៥ |
| ៨៧.០៨ | | ផ្នែកនិងគ្រឿងបំលាស់យានយន្ត heading Nos. ៨៧.០១ ទៅ ៨៧.០៥ សន្ទះមុខ ក្រោយសំរាប់ការពារ និងផ្នែកផ្សេងៗទៀត ដែលចាក់ពុម្ពផ្លាស់ស្ទិក | |
| | ៨៧០៨.១០.១២ | សំរាប់យានយន្តដែលមាន heading Nos ៨៧០២ និង ៨៧០៤ លើកលែងតែ subheading ៨៧០៤.១០.០០ | ២៥ |
| | ៨៧០៨.១០.១៣ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៨.១០.១៤ | សំរាប់យានយន្តដែលមាន subheading No. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ២៥ |
| | ៨៧០៨.១០.១៥ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |
| | | ផ្សេងៗ | |
| | ៨៧០៨.១០.៩២ | សំរាប់យានយន្តដែលមាន subheading Nos ៨៧០២ និង ៨៧០៤ លើកលែងតែ subheading ៨៧០៤.១០.០០ | ២៥ |
| | ៨៧០៨.១០.៩៣ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |

| | | | |
|---|---|---|---|
| | ៨៧០៨.១០.៩៤ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ៣០ |
| | ៨៧០៨.១០.៩៥ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |
| | | ផ្នែកផ្សេងៗ និងគ្រឿងបំលាស់តួ រួមទាំងដំបូល ខ្សែក្រវ៉ាត់ការពារ | |
| | ៨៧០៨.២១.២០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០២ និង ៨៧០៤ លើកលែងតែ subheading Nos. ៨៧០៤.១០.០០ | ២៥ |
| | ៨៧០៨.២១.៣០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៨.២១.៤០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ២៥ |
| | ៨៧០៨.២១.៥០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |
| | | ផ្សេងៗ | |
| | | គ្រឿងសំរាប់ដំល៊ើង និងគុបតែងទ្វារ | |

| | | | |
|---|---|---|---|
| | ៨៧០៨.២៩.១២ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០២ និង ៨៧០៤ លើកលែងតែ subheading No. ៨៧០៤.១០.00 | ២៥ |
| | ៨៧០៨.២៩.១៣ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៨.២៩.១៤ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ២៥ |
| | ៨៧០៨.២៩.១៥ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |
| | | ផ្សេងៗ | |
| | ៨៧០៨.២៩.៩២ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០២ និង ៨៧០៤លើកលែងតែ subheading Nos. ៨៧០៤.១០.00 | ២៥ |
| | ៨៧០៨.២៩.៩៣ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៨.២៩.៩៤ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ២៥ |

| | | | |
|---|---|---|---|
| | ៨៧០៨.២៩.៩៥ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |
| | | ហ្វ្រាំង និងផ្នែកដទៃទៀត<br>ទ្រនាប់ហ្វ្រាំងដែលដាក់ជាប់មួយកន្លែង | |
| | ៨៧០៨.៣១.២០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០២ និង ៨៧០៤ លើកលែងតែ subheading Nos. ៨៧០៤.១០.00 | ២៥ |
| | ៨៧០៨.៣១.៣០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៨.៣១.៤០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣.៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ២៥ |
| | ៨៧០៨.៣១.៥០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.១០ ៨៧០៣.២២.១០ ៨៧០៣.២៣.១០ ៨៧០៣.២៤.១០ ៨៧០៣.៣១.១០ ៨៧០៣.៣២.១០ ៨៧០៣.៣៣.១០ | ២៥ |
| | | ផ្សេងៗ | |
| | ៨៧០៨.៣៩.២០ | សំរាប់យានយន្តដែលមាន heading Nos. ៨៧០២ និង ៨៧០៤លើកលែងតែ subheading Nos.៨៧០៤.១០.00 | ២៥ |
| | ៨៧០៨.៣៩.៣១ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២១.២០ ៨៧០៣.២១.៣០ ៨៧០៣.២២.២០ ៨៧០៣.២២.៣០ ៨៧០៣.២៣.២១ ៨៧០៣.២៣.២២ ៨៧០៣.៣១.២១ ៨៧០៣.៣១.២២ ៨៧០៣.៣១.៣១ ៨៧០៣.៣១.៣២ ៨៧០៣.៣២.២១ ៨៧០៣.៣២.២២ | ២៥ |
| | ៨៧០៨.៣៩.៤០ | សំរាប់យានយន្តដែលមាន subheading Nos. ៨៧០៣.២៣.៣១ ៨៧០៣.២៣.៣២ ៨៧០៣.២៤.២១ ៨៧០៣.២៤.២២ ៨៧០៣.២៤.៣១ ៨៧០៣.២៤.៣២ ៨៧០៣.៣២.៣១ ៨៧០៣. ៣២.៣២ ៨៧០៣.៣៣.២១ ៨៧០៣.៣៣.២២ ៨៧០៣.៣៣.៣១ ៨៧០៣.៣៣.៣២ | ២៥ |

| | | | |
|---|---|---|---|
